ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ផែនទីបង្ហាញផ្លូវ
ការអប់រំមធ្យមសិក្សាកម្ពុជា ឆ្នាំ
២០៣០



ខែឧសភា ឆ្នាំ២០២១

ផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សា ឆ្នាំ ២០៣០

ឧបត្ថម្ភការបោះពុម្ព ដោយ**ធនាគារអភិវឌ្ឍអាស៊ី**

ចក្ខុវិស័យ

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជា ឱ្យក្លាយទៅជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

អារម្ភកថា

កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័ស និងការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅកម្ពុជា នាំឱ្យមានការកើនឡើងនូវតម្រូវការកម្លាំងពលកម្មជំនាញ។ ទោះជាយ៉ាងណា ប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលបច្ចេកទេស នៅពុំទាន់អាចឆ្លើយតបនឹងការផ្លាស់ប្តូរសំខាន់ៗទាំងនេះ ហើយគម្លាតជំនាញក៏មានទំហំធំ។ ខណៈពេលដែលមានវឌ្ឍនភាពសម្រេចបានជាច្រើន លើការចូលរៀន និងគុណភាពនៅកម្រិតបឋមសិក្សា ក៏បញ្ហាប្រឈមនៅតែកើតមានបន្តនៅកម្រិតមធ្យមសិក្សា។ ទោះបី ការអប់រំមធ្យមសិក្សា សម្រេចបានវឌ្ឍនភាពក្នុងការលើកកម្ពស់ការចូលរៀន និងគុណភាពអប់រំ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ក៏បច្ចេកវិទ្យាមានការវិវត្តយ៉ាងឆាប់រហ័សផងដែរ ដែលទាមទារឱ្យមានការពន្លឿនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីឱ្យប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាឆ្លើយតបបានទៅនឹងបម្រែបម្រួលទាំងនេះ និងអាចធ្វើឱ្យគម្លាតជំនាញកាន់តែតូច។ តម្រូវការផលិតជំនាញកម្រិតខ្ពស់ឆ្លើយតបនឹងលក្ខខណ្ឌចាំបាច់នៃសេដ្ឋកិច្ចសកល និងភាពជឿនលឿននៃផ្នែកបច្ចេកវិទ្យា ក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ កម្ពុជាត្រូវខិតខំពង្រឹងបន្ថែមទៀត ក្នុងការកែលម្អប្រព័ន្ធអប់រំរបស់ខ្លួនឱ្យកាន់តែមានលទ្ធភាពឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាឆ្នាំ ២០៣០ ក្នុងឆ្នាំ ២០២០ និងដើមឆ្នាំ ២០២១ ដោយមានការចូលរួមសហការ និងការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយនឹងក្រសួង-ស្ថាប័ន ពាក់ព័ន្ធ គ្រឹះស្ថានសិក្សា ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល។ ផែនទីបង្ហាញផ្លូវនេះ បានបន្សីជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រដែលមានស្រាប់ដូចជា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០៣០-គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។ ឯកសារនេះ បង្ហាញពីសនិទានកម្ម និងគោលបំណង នៃការអប់រំកម្រិតមធ្យមសិក្សា បញ្ហាប្រឈមនិងភាពជោគជ័យនៅក្នុងប្រព័ន្ធបច្ចុប្បន្ន អាទិភាពចម្បងៗ ផលសម្រេចសំខាន់ៗ ផែនការសកម្មភាព ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងក្របខណ្ឌចំណាយរយៈពេលវែង។

ផែនទីបង្ហាញផ្លូវនេះបានកំណត់អាទិភាពសំខាន់ៗ៨ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអប់រំមធ្យមសិក្សា និងជំរុញឱ្យកម្ពុជាឆ្ពោះទៅសម្រេចចក្ខុវិស័យរយៈពេលវែង ក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ និងប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ ២០៥០ ផងដែរ ។ អាទិភាពសំខាន់ៗទាំង៨ រួមមាន ៖

១. បង្កើនការចូលរៀន និងគុណភាពនៃការអប់រំមធ្យមសិក្សាចំណេះទូទៅ រួមទាំងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
២. បន្តផ្តោតការយកចិត្តទុកដាក់ជាប្រព័ន្ធលើការលើកកម្ពស់ការដឹកនាំ និងគ្រប់គ្រងសាលាមធ្យមសិក្សា
៣. បន្សីកម្មវិធីសិក្សា ការបង្រៀន និងវង្វាយតម្លៃគ្រប់មុខវិជ្ជា ជាពិសេស វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ឱ្យស្របតាមគុណភាពអប់រំសម្រាប់សតវត្សទី ២១
៤. បញ្ចូលការអប់រំឌីជីថលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សា

៥. រៀបចំ និងអនុវត្តគោលនយោបាយគ្រូបង្រៀនដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់កម្រិតមធ្យមសិក្សា
៦. បន្តផ្តោតការយកចិត្តទុកដាក់ជាប្រព័ន្ធលើការលើកកម្ពស់ការអប់រំគ្រូមធ្យមសិក្សា
៧. ធ្វើពិពិធកម្ម និងពង្រឹងលទ្ធផលនៃការអប់រំបច្ចេកទេសមធ្យមសិក្សា ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និង និងទីផ្សារការងារក្នុងមូលដ្ឋាន
៨. បង្កើនសហការរវាងការអប់រំមធ្យមសិក្សា និងក្រោយមធ្យមសិក្សា និងការចូលរួមពីតួអង្គពាក់ព័ន្ធ។

ផែនការសកម្មភាពសម្រាប់អនុវត្តផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាឆ្នាំ២០៣០ បានរួមបញ្ចូលនូវ ផលសម្រេចសំខាន់ៗ លទ្ធផលរំពឹងទុក ដែលឆ្លើយតបតាមអាទិភាពនីមួយៗក្នុងចំណោមអាទិភាពទាំង ៨។ ការអនុវត្តផែនទីបង្ហាញផ្លូវនេះត្រូវធ្វើឡើងជាដំណាក់កាលៗ ដើម្បីបន្តអនុវត្តពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀតទៅតាមលទ្ធផលសម្រេចបាន តាមរយៈការពិនិត្យតាមដានវឌ្ឍនភាពល្អិតល្អន់ជាទៀងទាត់នៃការសម្រេចចំណុចដៅ ជាក់លាក់ក្នុងដំណាក់កាលនីមួយៗ (សូមមើលផ្នែកទី១២៖ ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ)។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណចំពោះមន្ត្រីរាជរដ្ឋាភិបាលទាំងអស់ក្រុមការងារធនាគារអភិវឌ្ឍន៍អាស៊ី ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល ដែលបានចូលរួមគាំទ្រ និងរួមចំណែកដល់ការរៀបចំផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាឆ្នាំ ២០៣០ ឱ្យសម្រេចបានជោគជ័យ ទោះបីជាមានបញ្ហាប្រឈមជាច្រើនដោយសារការរាតត្បាតជាសកលនៃមេរោគកូរ៉ូណា ឬជំងឺកូវីដ-១៩។ ក្រសួងអប់រំ យុវជន និងកីឡា បង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ក្នុងកិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាឆ្នាំ ២០៣០ ឱ្យបានជោគជ័យ និងសូមអំពាវនាវដល់ដៃគូពាក់ព័ន្ធទាំងអស់ រួមទាំងសិស្ស និស្សិត និងមាតាបិតាសិស្សជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពខ្ពស់បំផុត និងក្រមសីលធម៌ ដើម្បីអភិវឌ្ឍសង្គមពុទ្ធិនៅក្នុងប្រទេសកម្ពុជា។

ថ្ងៃ អង្គារ ៧ កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០២១
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

មាតិកា

អារម្ភកថា i
មាតិកា iii
អក្សរកាត់ v
បញ្ជីរូបភាព តារាង និងប្រអប់ viii

១. សេចក្តីផ្តើម 1

១-១. ចក្ខុវិស័យ បេសកកម្ម និងគោលដៅសម្រាប់ការអប់រំ 1
១-២. គោលដៅនៃអនុវិស័យអប់រំមធ្យមសិក្សា 1
១-៣. តួនាទីនៃការអប់រំនៅក្នុងសង្គម 4
១-៤. សារៈសំខាន់នៃផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សា 4
១-៥. គោលបំណងនៃការអប់រំកម្រិតមធ្យមសិក្សា 6
១-៦. ភាពបន្ទាន់សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា 8
១-៧. លទ្ធផលអំពីការវិនិយោគលើវិស័យអបរំ 14
១-៨. ទំនាក់ទំនងក្នុងអនុវិស័យមធ្យមសិក្សា 15
- ការអប់រំកុមារតូច 15
- ការអប់រំបឋមសិក្សា 16
- ការអប់រំក្រៅប្រព័ន្ធ 17
- ការអប់រំឧត្តមសិក្សា 17
- ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ 19

១-៩. តួនាទីរបស់វប្បធម៌នៅក្នុងការអប់រំ 19
១-១០ ឧទាហរណ៍ល្អដែលមាននៅក្នុងបរិបទវប្បធម៌ 21
១-១១. ឧបសគ្គសម្រាប់ការវិវឌ្ឍជាវិជ្ជមានក្នុងស្ថាប័ន 22

២. សាវតារនៃឯកសារផែនទីបង្ហាញផ្លូវ 23

៣. បញ្ហាប្រឈមនៅក្នុងអនុវិស័យមធ្យមសិក្សា 26

៣-១. ការយល់ឃើញរបស់សាធារណជនចំពោះវិស័យអប់រំ 26
៣-២. បញ្ហាគណនេយ្យភាពនៅកម្រិតផ្សេងៗ 27
៣-៣. ការឆ្លងភូមិសិក្សាពីកម្រិតបឋមសិក្សាទៅមធ្យមសិក្សា 28
៣-៤. គុណវិបត្តិនៃការឆាប់ចាកចេញពីសាលារៀន 29
៣-៥. ការចូលរួមដោយគ្មានសមធម៌រវាងក្មេងប្រុស និងក្មេងស្រីនៅគ្រប់កម្រិតសិក្សា 30
៣-៦. ចំណុចខ្វះខាតក្នុងការអប់រំ និងបណ្តុះបណ្តាលគ្រូបង្រៀន 31
៣-៧. ការពង្រាយគ្រូ – "បញ្ហាលើស និងកង្វះគ្រូ" 33
៣-៨. ការធ្វើវិក្រឹតការគ្រូបង្រៀន និងនាយកសាលា 34
៣-៩. លទ្ធផលសិក្សាមុខវិជ្ជាស្នែមនៅកម្រិតមធ្យមសិក្សា 35
៣-១០. ការគ្រប់គ្រងតាមសាលារៀន 36
៣-១១. វិទ្យាល័យធនធាន 37
៣-១២. ការយល់ដឹងរបស់ក្មេងជំទង់អំពីយេនឌ័រ និងផ្លូវភេទ 38
៣-១៣. បរិក្ខាទឹកស្អាត និងអនាម័យ និងសុខភាពសាធារណៈ 38
៣-១៤. ការអប់រំបច្ចេកទេសនៅមធ្យមសិក្សា 39
៣-១៥. ទំនាក់ទំនងផ្សារភ្ជាប់គ្នារវាងការអប់រំមធ្យមសិក្សា និងទីផ្សារការងារ 40
៣-១៦. លទ្ធភាពរបស់អ្នកសិក្សាក្នុងការទទួលបានការអប់រំឌីជីថល 41

៤. កត្តាសំខាន់ៗសម្រាប់ការពង្រឹងការអប់រំកម្រិតមធ្យមសិក្សា 42

៤-១. ការធ្វើឱ្យមានការផ្លាស់ប្តូរជាប្រព័ន្ធ 42
៤-២. ការអភិវឌ្ឍគន្លងអប់រំ បណ្តុះបណ្តាល និងអាជីពសម្រាប់សិស្ស 43
៤-៣. ការបង្កើនសមិទ្ធកម្មរបស់គ្រូ 46
៤-៤. ការពង្រឹងការពង្រាយគ្រូ 47
៤-៥. ការផ្តល់អាទិភាពដល់ការដឹកនាំ និងការគ្រប់គ្រងសាលារៀន 45
៤-៦. ធានាឱ្យសិស្សអាចឆ្លងភូមិសិក្សា និងទទួលបានជោគជ័យ 50
៤-៧. ការបញ្ចូលជំនាញសតវត្សរ៍ទី ២១ 50
៤-៨. ការពង្រីកអភិក្រមបែបនវានុវត្តន៍ 51
៤-៩. ការលើកកម្ពស់ការអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា 53
៤-១០. ការបង្កើនភាពជាដៃគូនៅថ្នាក់តំបន់ក្នុងផ្នែកមុខវិជ្ជាសិក្សា 55
៤-១១. ការលើកកម្ពស់ការអប់រំមធ្យមសិក្សាបច្ចេកទេស 55

៤-១២. ការពង្រីកបណ្តាញរវាងសាលារៀន និង ធុរកិច្ចនៅក្នុងមូលដ្ឋាន 57

៤-១៣. ការឆ្លើយតបចំពោះកំណើននៃការអប់រំនៅកម្រិតមធ្យមសិក្សា 58

៤-១៤. និម្មាបនកម្មសាលារៀនសម្រាប់សតវត្សរ៍ទី ២១ 60

៤-១៥. ការផ្តល់ហិរញ្ញប្បទានអប់រំ 60

៤-១៦. ពិភពលោក ក្រោយជំងឺកូវីដ-១៩ 63

៥. កត្តាខាងក្រៅដែលជះឥទ្ធិពលលើការសិក្សារបស់សិស្ស 66

៥-១. ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ 66

៥-២. កត្តាសង្គម-សេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុ 67

៥-៣. កត្តាសង្គមវប្បធម៌ 68

៦. អាទិភាពនៃអនុវិស័យអប់រំមធ្យមសិក្សា 69

៦-១. បង្កើនការចូលរៀន និងគុណភាពអប់រំមធ្យមសិក្សាចំណេះទូទៅ (រួមទាំងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស) 69

៦-២. បន្តផ្តោតការយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ ការដឹកនាំ និង គ្រប់គ្រងសាលារៀនមធ្យមសិក្សា 70

៦-៣. រៀបចំកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃឱ្យស្របតាមការអប់រំប្រកបដោយគុណភាពសម្រាប់សតវត្សរ៍ទី២១ 71

៦-៤. បញ្ចូលការអប់រំឌីជីថលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សា 72

៦-៥. អនុវត្តគោលនយោបាយគ្រូបង្រៀនដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងអនុវិស័យអប់រំមធ្យមសិក្សា 73

៦-៦. បន្តផ្តោតការយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ការអប់រំគ្រូមធ្យមសិក្សា 74

៦-៧. ធ្វើពិពិធកម្ម និងពង្រឹងលទ្ធផលនៃការអប់រំមធ្យមសិក្សាបច្ចេកទេសដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និងទីផ្សារការងារក្នុងមូលដ្ឋាន 75

៦-៨. បង្កើនការសហការសម្រាប់ការអប់រំនៅកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សា 75

7. ការផ្លាស់ប្តូរនៃអនុវិស័យការអប់រំមធ្យមសិក្សាឆ្ពោះទៅឆ្នាំ ២០៣០ 75

៨. ផលជះរយៈពេលវែងនៃការផ្លាស់ប្តូរអនុវិស័យការអប់រំមធ្យមសិក្សា 77

៩. អាទិភាព និងលទ្ធផលសំខាន់ៗនៅក្នុងផែនទីបង្ហាញផ្លូវ 80

១០. ផែនការសកម្មភាពសម្រាប់អនុវត្តផែនទីបង្ហាញផ្លូវ 85

១១. ក្របខណ្ឌចំណាយរយៈពេលវែង 106

១២. ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ 112

ឧបសម្ព័ន្ធទី ១៖ វិទ្យាល័យធនធានដែលមានស្រាប់ 114

ឧបសម្ព័ន្ធទី ២៖ វិទ្យាល័យធនធានដែលបានគ្រោងក្នុងផែនការ 115

ឧបសម្ព័ន្ធទី ៣៖ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងមុខរបរខេត្ត (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) 116

ឧបសម្ព័ន្ធទី ៤ ៖ ការចូលរៀននៅក្នុងសាលារៀនសាធារណៈ និងឯកជន 117

អក្សរកាត់

អក្សរកាត់	ភាសាអង់គ្លេស	ភាសាខ្មែរ
ADB	Asian Development Bank	ធនាគារអភិវឌ្ឍន៍អាស៊ី
ASEAN	Association of Southeast Asian Nations	សមាគមអាស៊ាន
BEEP	Basic Education Equivalency Program	កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន
CAMSEB	Cambodia Secondary Education Blueprint	ផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាកម្ពុជា
CDE	Centre for Digital Education	មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល
CPD	Continuous Professional Development	ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
CQF	Cambodian Qualifications Framework	ក្របខណ្ឌគុណវុឌ្ឍិកម្ពុជា
DEXA	Department of Examination Affairs	នាយកដ្ឋានកិច្ចការប្រឡង
DGSE	Department of General Secondary Education	នាយកដ្ឋានអប់រំមធ្យមសិក្សាចំណេះទូទៅ
DHE	Department of Higher Education	នាយកដ្ឋានឧត្តមសិក្សា
DIT	Department of Information Technology	នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
DCD	Department of Curriculum Development	នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
DoC	Department of Construction	នាយកដ្ឋានសំណង់
DoF	Department of Finance	នាយកដ្ឋានហិរញ្ញវត្ថុ
DoP	Department of Personnel	នាយកដ្ឋានបុគ្គលិក
DoPo	Department of Policy	នាយកដ្ឋានគោលនយោបាយ
DP	Development Partner	ដៃគូអភិវឌ្ឍ
ESL	early school leaving	ការឆាប់ចាកចេញពីសាលារៀន
ESP	Education Strategic Plan	ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
ETCP	Education, Training and Career Pathways	គន្លងអប់រំ បណ្តុះបណ្តាល និងអាជីព
EU	European Union	សហភាពអឺរ៉ុប
GDP	gross domestic product	ផលិតផលសរុបក្នុងស្រុក
GEIP	General Education Improvement Project	គម្រោងកែលម្អការអប់រំចំណេះទូទៅ
GER	gross enrollment rate	អត្រារួមនៃការសិក្សា
GPE	Global Partnership for Education	ភាពជាដៃគូសកលសម្រាប់ការអប់រំ
GPI	gender parity index	សន្ទស្សន៍យុត្តភាពយេនឌ័រ
GTHS	General and Technical High School	វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
HCI	human capital index	សន្ទស្សន៍មូលធនមនុស្ស
HEI	higher education institution	វិទ្យាស្ថានអប់រំជាន់ខ្ពស់
ICT	information and communication technology	ព័ត៌មាន និងបច្ចេកវិទ្យាសារគមនាគមន៍
ILO	International Labour Organization	អង្គការអន្តរជាតិខាងការងារ
IMF	International Monetary Fund	មូលនិធិរូបិយប័ណ្ណអន្តរជាតិ
INSET	In-Service Teacher Education and Training	វិក្រឹតការគ្រូ
KAPE	Kampuchean Action to Promote Education	អង្គការសកម្មភាពលើកកម្ពស់ការអប់រំនៅកម្ពុជា

អក្សរកាត់	ភាសាអង់គ្លេស	ភាសាខ្មែរ
LSS	lower secondary school	សាលាមធ្យមសិក្សាបឋមភូមិ
MEF	Ministry of Economy and Finance	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MOEYS	Ministry of Education, Youth and Sport	ក្រសួងអប់រំ យុវជន និងកីឡា
MoH	Ministry of Health	ក្រសួងសុខាភិបាល
MLVT	Ministry of Labour and Vocational Training	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
MSS	Minimum Service Standards	ស្តង់ដារសេវាអប្បបរមា
NFE	nonformal education	ការអប់រំក្រៅប្រព័ន្ធ
NGO	nongovernment organization	អង្គការមិនមែនរដ្ឋាភិបាល
NGPRC	New Generation Pedagogical Research Centre	មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី
NGS	New Generation School	សាលារៀនជំនាន់ថ្មី
NIE	National Institute of Education	វិទ្យាស្ថានជាតិអប់រំ
NLA	National Literacy Assessment	ការវាយតម្លៃថ្នាក់ជាតិនៃអត្រាអក្ខរភាព
OOS	out-of-school	ក្រៅសាលារៀន
PISA-D	Program for International Student Assessment for Development	កម្មវិធីអន្តរជាតិស្តីពី វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍
PRESET	Pre-Service Teacher Education and Training	ការបណ្តុះបណ្តាលគ្រូ
PTC	Provincial Training Center	សាលាគរុកោសល្យ និងវិក្រឹតការខេត្ត
RGC	Royal Government of Cambodia	រាជរដ្ឋាភិបាលកម្ពុជា
RTTC	Regional Teacher Training Center	មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
SBM	school-based management	ការគ្រប់គ្រងតាមសាលារៀន
SDG	Sustainable Development Goal	គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
SDPDS	School Director Performance and Development Standards	ស្តង់ដាអភិវឌ្ឍ និងសមិទ្ធកម្មរបស់នាយកសាលា
SEAMEO	Southeast Asian Ministers of Education Organization	អង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍
SEIP	Secondary Education Improvement Project	គម្រោងលើកកម្ពស់ការអប់រំនៅមធ្យមសិក្សា
SIDA	Swedish International Development Agency	ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ ស៊ុយអែត
SMC	School Management Committee	គណៈកម្មការគ្រប់គ្រងសាលារៀន
SRC	Secondary Resource Center	អគារធនធានមធ្យមសិក្សា
SRS	Secondary Resource School	សាលាមធ្យមសិក្សាធនធាន
STEM	Science, Technology, Engineering, and Mathematics	វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
TCPP	Teacher Career Pathways Policy	គោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន
TEC	Teacher Education College	វិទ្យាស្ថានគរុកោសល្យ
TEI	teacher education institution	គ្រឹះស្ថានអប់រំគ្រូ
TPDS	Teacher Performance and Development Standards	ស្តង់ដាអភិវឌ្ឍ និងសមិទ្ធកម្មរបស់គ្រូបង្រៀន

អក្សរកាត់	ភាសាអង់គ្លេស	ភាសាខ្មែរ
TTD	Teacher Training Department	នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
TTI	technical training institute	វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស
TVET	Technical and Vocational Education and Training	ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
UNESCO	United Nations Education, Science, and Cultural Organization	អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ
UNICEF	United Nations International Children's Fund	អង្គការសហប្រជាជាតិនៃមូលនិធិកុមារ
USESDP	Upper Secondary Education Sector Development Project	គម្រោងអភិវឌ្ឍសាលាមធ្យមសិក្សាទុតិយភូមិ
USS	upper secondary school	សាលាមធ្យមសិក្សាទុតិយភូមិ
VOD	Vocational Orientation Department	នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ
VTC	Vocational Training Center	មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
WASH	water, sanitation, and hygiene	ទឹកស្អាត និងអនាម័យ

បញ្ជីរូបភាព តារាង និងប្រអប់

រូបភាពទី ១៖	ការបន្តឡើងថ្នាក់របស់ក្រុមសិស្សក្នុងឆ្នាំសិក្សា ២០០៧-២០០៨ ដល់ឆ្នាំសិក្សា ២០១៨-២០១៩	8
រូបភាពទី២៖	អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ	9
រូបភាពទី ៣៖	សន្ទស្សន៍មូលធនមនុស្សសម្រាប់ប្រទេសនៅអាស៊ាន	10
រូបភាពទី ៤៖	ចំនួនឆ្នាំដែលកុមារកើតនៅថ្ងៃនេះ រំពឹងថាទៅរៀនក្នុងសាលារៀន និងចំនួនឆ្នាំទៅរៀនក្នុងសាលារៀនដែលត្រូវបានកែសម្រួលទៅតាមកម្រិតនៃការរៀនសូត្រ	10
រូបភាពទី ៥៖	ការអប់រំមធ្យមសិក្សា និងទំនាក់ទំនងរបស់វា	15
រូបភាពទី ៦៖	ភាគរយនៃមនុស្សអាយុចាប់ពី ២៥ឆ្នាំ ឡើងទៅ ដែលបញ្ចប់ការសិក្សា យ៉ាងហោចណាស់ត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ ឆ្នាំសិក្សា២០០៤-២០១៧	22
រូបភាពទី ៧៖	រចនាសម្ព័ន្ធរៀបចំផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០	25
រូបភាពទី ៨៖	កំណើននៃការអប់រំឯកជននៅកម្ពុជា ឆ្នាំសិក្សា២០០៩-២០១៩	26
រូបភាពទី ៩៖	អត្រានៃការធ្លាក់ចាកចេញពីសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ ឆ្នាំ២០១៣-២០១៩	30
រូបភាពទី ១០៖	អត្រានៃការធ្លាក់ចាកចេញពីសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០១៣-២០១៩	30
រូបភាពទី ១១៖	យុគភាពយេនឌ័រនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា (បែងចែកតាមខេត្ត) ឆ្នាំសិក្សា ២០១៩-២០២០	31
រូបភាពទី ១២៖	បង្ហាញពីក្របខណ្ឌគុណវុឌ្ឍិកម្ពុជា	45
រូបភាពទី ១៣ ៖	សមិទ្ធកម្មរបស់គ្រូ	47
រូបភាពទី ១៤៖	ជំនាញសតវត្សរ៍ទី ២១	50
រូបភាពទី ១៥៖	ការធ្វើចំណោល ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិពី ២០១៣ ដល់ ២០៣១	58
រូបភាពទី ១៦៖	ចំណោលសិស្សបញ្ចប់ការសិក្សាពីកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ២០១៣ ដល់ ២០៣១	59
រូបភាពទី ១៧៖	សាលារៀនមធ្យមសិក្សា ២០១៤-២០១៩	59
រូបភាពទី ១៨៖	ចំណាយសាធារណៈក្នុងវិស័យអប់រំ (គិតជា លានដុល្លារអាមេរិក)	61
រូបភាពទី ១៩៖	ការប៉ាន់ប្រមាណពីគម្លាតហិរញ្ញប្បទាន (គិតជាលានដុល្លារសហរដ្ឋអាមេរិក)	62

តារាងទី១ ៖	ទិដ្ឋភាពរួមទូទៅនៃប្រព័ន្ធអប់រំកម្ពុជា ឆ្នាំសិក្សា ២០១៩-២០២០	3
តារាងទី២៖	អនុក្ខរកម្មអំណាននៅក្នុងប្រទេសកម្ពុជា និងប្រទេសជិតខាងក្នុងតំបន់	11
តារាងទី៣៖	លទ្ធផលតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី ១១ (២០១៨)	12
តារាងទី៤៖	ការផ្តល់អាទិភាពដល់បញ្ហាអប់រំសំខាន់ៗ	25
តារាងទី៥៖	លទ្ធផលកន្លងមកសម្រាប់ថ្នាក់ទី ៣ ទី៦ និងទី៨ បែងចែកតាមឆ្នាំ	28
តារាងទី៦៖	លទ្ធផលរំពឹងទុករបស់អាទិភាពគន្លឹះទាំង៨	81
តារាងទី៧៖	អាទិភាពទី ១ "បង្កើនការចូលរៀន និងគុណភាពអប់រំមធ្យមសិក្សាចំណេះទូទៅ (រួមទាំងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស)"	85

តារាងទី ៨៖ អាទិភាពទី ២ "បន្តផ្ដោតការយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ការដឹកនាំ និងគ្រប់គ្រងសាលាមធ្យមសិក្សា" 89

តារាងទី៩៖ អាទិភាពទី ៣ "រៀបចំកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃ ឱ្យស្របតាមការអប់រំប្រកបដោយគុណភាពសម្រាប់សតវត្សរ៍ទី ២១" 92

តារាងទី១០៖ អាទិភាពទី ៤ "បញ្ចូលការអប់រំឌីជីថលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សា" 94

តារាងទី ១១៖ អាទិភាពទី ៥ "អនុវត្តគោលនយោបាយគ្រូបង្រៀន ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនៅអនុវិស័យអប់រំមធ្យមសិក្សា" 96

តារាងទី ១២៖ អាទិភាពទី ៦ "បន្តផ្ដោតការយកចិត្តទុកដាក់ជាប្រព័ន្ធលើការលើកកម្ពស់ការអប់រំគ្រូមធ្យមសិក្សា" 99

តារាងទី ១៣៖ អាទិភាពទី ៧ "ធ្វើពិពិធកម្ម និងពង្រឹងលទ្ធផលនៃការអប់រំមធ្យមសិក្សាបច្ចេកទេស ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និងទីផ្សារការងារក្នុងមូលដ្ឋាន" 102

តារាងទី ១៤៖ អាទិភាពទី ៨ "បង្កើនការសហការសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សា" 105

តារាងទី១៥ ៖ តម្រូវការធនធាន ដើម្បីបំពេញស្ដង់ដាសេវាអប្បបរមា/ចំណុចដៅ និងអនុវត្តសកម្មភាពផែនទីបង្ហាញផ្លូវ 108

តារាងទី១៦ ៖ តម្រូវការថវិកា ដើម្បីបំពេញស្ដង់ដាសេវាអប្បបរមា និងផ្ដល់ហិរញ្ញប្បទានដល់សកម្មភាព ផែនទីបង្ហាញផ្លូវ (គិតជាលានដុល្លារ) 109

ប្រអប់ទី១៖ ឱកាស និងបញ្ហាប្រឈមក្នុងការអប់រំឌីជីថល 65

ប្រអប់ទី២៖ ដំណាក់កាលនិមួយៗ នៃផែនទីបង្ហាញផ្លូវ អប់រំមធ្យមសិក្សាកម្ពុជា ២០៣០ 75

ប្រអប់ទី៣៖ តួនាទី និងទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធការអប់រំ 77

តារាង ក១.១៖ ទីតាំងវិទ្យាល័យធនធាន 114

តារាង ក២.១៖ ទីតាំងវិទ្យាល័យធនធានដែលបានគ្រោង 115

តារាង ក៣.១៖ ទីតាំងមជ្ឈមណ្ឌលមុខរបរ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមខេត្ត 116

តារាង ក៤.១ ៖ សិស្សចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សា២០០៩-២០១០ ដល់ ឆ្នាំសិក្សា២០១៨-២០១៩ 117

រូបភាព ក៤.២ ៖ មធ្យមសិក្សាទុតិយភូមិ 118

១. សេចក្តីផ្តើម

"គេត្រូវចងចាំថា គោលបំណងនៃការអប់រំ គឺពុំមែនជាការចាក់បំពេញខួរក្បាលសិស្សជាមួយនឹងអង្គហេតុនោះឡើយ តែជាការបង្រៀនឱ្យពួកគេចេះគិត"[1]។

១-១. ចក្ខុវិស័យ បេសកកម្ម និងគោលដៅសម្រាប់ការអប់រំ

ចក្ខុវិស័យ

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាង និងអភិវឌ្ឍធនធាន មនុស្សប្រកបដោយគុណភាព និងគុណធម៌ ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

បេសកកម្ម

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡាមានបេសកកម្ម ដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៅកម្ពុជា ឱ្យឆ្លើយតបចំពោះតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច វប្បធម៌នៃប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះស្ថានភាពនៅថ្នាក់តំបន់ព្រមទាំងសកលភាវូបនីយកម្ម និងបដិវត្តន៍ឧស្សាហកម្ម ៤.០។

១-២. គោលដៅនៃអនុវិស័យអប់រំមធ្យមសិក្សា

ការអប់រំកម្រិតមធ្យមសិក្សានឹងបណ្តុះស្មារតីមោទកភាពជាតិនិងមោទកភាពប្រជាពលរដ្ឋស្តង់ដាសីលធម៌និងគុណធម៌កម្រិតខ្ពស់ និងការជឿជាក់យ៉ាងមុតមាំលើការទទួលខុសត្រូវរបស់យុវជនចំពោះប្រទេសជាតិ ពលរដ្ឋ និងបរិស្ថានធម្មជាតិ។ សិស្សបញ្ចប់ការសិក្សាមធ្យមសិក្សានឹងមានកម្រិតស្តង់ដាអន្តរជាតិអាចប្រកួតប្រជែងក្នុងទីផ្សារការងារសកលលោក និងដើរតួនាទីជាកាតាលីករសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់កម្ពុជា។ ដើម្បីសម្រេចគោលដៅទាំងនេះ ការអប់រំកម្រិតមធ្យមសិក្សានៅកម្ពុជាមានគោលបំណង ៖

1. បំពាក់បំប៉នយុវជនកម្ពុជានូវចំណេះដឹង មុខវិជ្ជា ជំនាញ និងសមត្ថភាពសតវត្សទី២១ (យ៉ាងហោចណាស់ រួមបញ្ចូលភាសាបរទេសចំនួន១) និងគុណតម្លៃនៃភាពជាពលរដ្ឋល្អ និងក្រមសីលធម៌ ដើម្បីឱ្យពួកគេក្លាយជាពលរដ្ឋដែលមានផលិតភាពក្នុងសង្គម ខណៈដែលកម្ពុជាកំពុងប្រែក្លាយទៅរកសេដ្ឋកិច្ចផ្អែកតាមចំណេះដឹង។
2. ផ្តល់ឱកាសស្មើភាពគ្នាដល់យុវជនកម្ពុជាគ្រប់រូបក្នុងការទទួលបានការអប់រំកម្រិតមធ្យមសិក្សា ដោយមិនគិតពីយេនឌ័រ ស្ថានភាពសង្គម ភូមិសាស្រ្ត ជាតិពន្ធ ភាសា និងសាសនា ។
3. បើកទូលាយ និងពង្រីកគន្លងសម្រាប់ភាពរីកចម្រើននៃការអប់រំរបស់សិស្សកម្រិតមធ្យមសិក្សា ដើម្បីបន្តទៅឧត្តមសិក្សា ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ឬការងារដែលមានផលិតភាព។

ផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ ២០៣០ ត្រូវបានរៀបចំឡើង ផ្អែកលើឯកសារគោលនយោបាយធំៗ ចំនួនពីររបស់ក្រសួងអប់រំ យុវជន និងកីឡា គឺ*ផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ ២០៣០ ស្តីពីការអប់រំនៅកម្ពុជា និងផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣*។ ឯកសារទាំងពីរនេះសុទ្ធសឹងតែគូសបញ្ជាក់ពីសារៈសំខាន់នៃអនុវិស័យអប់រំមធ្យមសិក្សា ក្នុងក្របខណ្ឌនៃវិស័យអប់រំ និងនិយាយជារួម ក្រោមក្របខណ្ឌសង្គម-សេដ្ឋកិច្ចជាតិកម្ពុជាទាំងមូល។

[1] R.M. Hutchins. 1969. The Learning Society. New York: Praeger Publications.

ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្ដីពីការអប់រំនៅកម្ពុជា បានរំលេចគោលដៅចម្បង ៥ ដែលពាក់ព័ន្ធនឹងការអប់រំមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស និងឧត្តមសិក្សា៖

១. សិស្សកម្ពុជាគ្រប់រូបបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន រយៈពេល៩ឆ្នាំ (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ដោយឥតបង់ថ្លៃប្រកបដោយគុណភាពសមធម៌ បរិយាបន្ន និងទទួលបានបំណិនអាន សរសេរ លេខនព្វន្តចំណេះដឹងលើមុខវិជ្ជាផ្សេងៗបំណិនក្នុងការគិត និងភាពប៉ិនប្រសប់ក្នុងការងារដែលផ្ដល់លទ្ធភាពឱ្យពួកគេអភិវឌ្ឍសក្ដានុពលបានយ៉ាងពេញលេញ។

២. សិស្សគ្រប់រូបមានលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលផ្ដល់ជម្រើសក្នុងការអប់រំបច្ចេកទេសវិជ្ជាជីវៈដែលមានតម្លៃសមរម្យ និងប្រកបដោយគុណភាពឬការត្រៀមខ្លួនសម្រាប់ឧត្តមសិក្សា។ ពោលគឺ ពួកគេមានសមត្ថភាពឆ្លងទៅដំណាក់កាលទាំងពីរនេះ។

៣. សម្រេចបានស្តង់ដានៃការបង្រៀន និងការរៀនសូត្រដែលមានគុណភាពខ្ពស់ តាមរយៈការបង្កើនការអប់រំគ្រូបង្រៀននៅកម្រិតបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀន។

៤. ស្តង់ដានៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងល្អនៅគ្រប់កម្រិត ដែលលើកកម្ពស់ការបង្រៀន និងការរៀនកម្រិតខ្ពស់ លេចឡើងនៅគ្រប់សាលាមធ្យមសិក្សាទាំងអស់នៅទូទាំងប្រទេសកម្ពុជា។

៥. យុវជនកាន់តែច្រើនមានលទ្ធភាពកាន់តែប្រសើរ ក្នុងការទទួលបានកម្មវិធីបច្ចេកទេសវិជ្ជាជីវៈដែលមានគុណភាព និងពាក់ព័ន្ធ ដែលឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច និងតម្រូវការឧស្សាហកម្មក្នុងមូលដ្ឋាន។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ រំលេចគោលដៅសំខាន់ៗចំនួនបី សម្រាប់អនុវិស័យអប់រំមធ្យមសិក្សា៖

១ លើកកម្ពស់ការចូលរៀន និងរក្សាសិស្សឱ្យបានគង់វង្ស ប្រកបដោយសមធម៌ និងបរិយាបន្ន នៅមធ្យមសិក្សា

២ កែលម្អគុណភាពបង្រៀន និងរៀនស្របតាមជំនាញសតវត្សរ៍ទី ២១

៣ ពង្រឹងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងនៅមធ្យមសិក្សា។

ដូចបង្ហាញជូនខាងលើ ផែនទីបង្ហាញផ្លូវនេះរៀបចំឡើង ដោយផ្អែកតាមគោលនយោបាយសំខាន់ៗ ដែលមាននៅក្នុងឯកសារទាំងពីរ និងយោងតាមក្របខណ្ឌគុណវុឌ្ឍិកម្ពុជាផងដែរ ។

តារាងទី១ ៖ទិដ្ឋភាពរួមទូទៅនៃប្រព័ន្ធអប់រំកម្ពុជា ឆ្នាំសិក្សា ២០១៩-២០២០

សូចនាករ	ប្រភេទ	មត្តេយ្យសិក្សា	បឋមសិក្សា	មធ្យមសិក្សាបឋមភូមិ	មធ្យមសិក្សាទុតិយភូមិ
កម្រិត		-	ថ្នាក់ទី ១-៦	ថ្នាក់ទី ៧-៩	ថ្នាក់ទី ១០-១២
អាយុ		៣-៥ ឆ្នាំ	៦-១១	១២-១៤	១៥-១៧
អត្រារួមនៃការសិក្សា	សាលារៀនសាធារណៈ	២៣,៤%	១០៤% (ស្រី ១០៣,៨%)	៥៦,៦% (ស្រី ៦១,៦%)	២៨,៩% (ស្រី ៣២,៩%)
	សាលារៀនឯកជន	៤,២%	៧,១% (ស្រី ៧,៣%)	៣,៣% (ស្រី ៣,៥)	២៨,៩% (ស្រី ៣២,៩%)
អត្រាពិតនៃការសិក្សា	សាលារៀនសាធារណៈ	៣៩,៩%	៩១% (ស្រី ៩១,៤%)	៤៥,៧% (ស្រី ៥១,៧%)	២៣% (ស្រី ២៧,១%)
	សាលារៀនឯកជន	N/A	៦,៣% (ស្រី ៦,៥%)	២,៩% (ស្រី ៣,១%)	២,១% (ស្រី ២,២%)
ចំនួនសិស្ស	សាលារៀនសាធារណៈ	២៣៣ ១៣២* (ស្រី ១១៦ ០៩៦)	២ ០២៣ ៤៧៣ (ស្រី ៩៧០ ០៥៣)	៦១៨ ៩៦៨ (ស្រី ៣២៥ ៥០៤)	៣៣៤ ៧១២ (ស្រី ១៨៣ ៣៩៤)
	សាលារៀនឯកជន	៥៦ ០០៤ (ស្រី ២៧ ៨៣១)	១៣៧ ៦៣៧ (ស្រី ៦៧ ៩៩៤)	៣៦ ០៨៧ (ស្រី ១៨ ៥៤៦)	២៣ ៨៤១ (ស្រី ១២ ២០៩)
ចំនួនសាលារៀន	សាលារៀនសាធារណៈ	៤ ៤០៩	៧ ២៨២	១ ៧៥៧	៥៤៤
	សាលារៀនឯកជន	៥៩៤	៥៧៤	២៥៤	១៧១
ចំនួនគ្រូបង្រៀន	សាលារៀនសាធារណៈ	៥ ៤១៤ (ស្រី ៥ ១៤៥)	៤៤ ៩១៤ (ស្រី ២៥ ៩២២)	២៧ ៧៣៨ (ស្រី ១២ ៤៥១)	១៥ ១៥៩ (ស្រី ៥ ៥២៤)
	សាលារៀនឯកជន	៣ ១៨២ (ស្រី ២ ៦៦៨)	៦ ៥៧២ (ស្រី ៤ ៤៣១)	៥ ៣១៨ (ស្រី ១ ៨៤៣)	
ផលធៀបសិស្ស-គ្រូ	សាលារៀនសាធារណៈ	៤៣,១	៤៥,១	២២,៣	២២,១
	សាលារៀនឯកជន	១៧,៦	២០,៩	N/A	N/A
ផលធៀបសិស្ស-បន្ទប់រៀន	សាលារៀនសាធារណៈ	៣៤,៣	៤៤,៧	៥០,២	៤៩,៦
	សាលារៀនឯកជន	២១,៦	២៣,១	១៦.១	២៥.១
សន្ទស្សន៍យុគភាពយេនឌ័រ	-	N/A	០,៩៨	១,១៩	១,៣១

* មិនរួមបញ្ចូលសិស្សរៀននៅមត្តេយ្យសិក្សាសហគមន៍

ប្រភព៖ ស្ថិតិ និងសូចនាករអប់រំសាធារណៈ និងឯកជន ក្រសួងអប់រំ យុវជន និងកីឡា ២០១៩-២០២០

១-៣. តួនាទីនៃការអប់រំនៅក្នុងសង្គម

Upper secondary students involved in collaborative project -based learning *(Photo by Andrew Jones)*

ការអប់រំបំពេញតួនាទីដ៏សំខាន់ ក្នុងដំណើរផ្លូវឆ្ពោះទៅសម្រេចកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជាតិរបស់ប្រទេសទាំងអស់។ ដូចនេះអ្វីដែលកំពុងកើតឡើងនៅក្នុងថ្នាក់រៀនបច្ចុប្បន្ន គឺជាមូលដ្ឋានដ៏ប្រសើរបំផុតសម្រាប់ការព្យាករណ៍ដ៏ជាក់លាក់អំពីអនាគតរបស់ប្រទេសជាតិមួយ។ ក្នុងយុគសម័យសេដ្ឋកិច្ចសកលបច្ចុប្បន្ន ជោគជ័យរបស់ជាតិមួយពឹងអាស្រ័យយ៉ាងខ្លាំងលើចំណេះដឹង ជំនាញ និងសមត្ថភាពរបស់ ពលរដ្ឋរបស់ខ្លួន។ ចំណុចនេះ មិនមានអ្វីភ្ញាក់ផ្អើលទេ ដែលប្រជាជាតិមួយមានកម្រិតអប់រំកាន់តែខ្ពស់ គឺច្រើនតែមានសេដ្ឋកិច្ចរីកចម្រើនខ្លាំងក្លា។ ការអប់រំ ក៏មានសារៈសំខាន់សម្រាប់ការកសាងនិងឯកភាពជាតិ។ ការអប់រំផ្តល់ឱ្យបុគ្គលម្នាក់ៗនូវឱកាសដែលធ្វើឱ្យជីវិតរបស់ពួកគេកាន់តែប្រសើរក្លាយជាអ្នកសិក្សពេញមួយជីវិត និងជាសមាជិកដ៏ជោគជ័យរបស់សហគមន៍និងជាអ្នករួមចំណែកយ៉ាងសកម្មដល់ការអភិវឌ្ឍជាតិ។

ការកសាងបំណងប្រាថ្នារួមគ្នា សម្រាប់អនាគតកម្ពុជា និងការចែករំលែកបទពិសោធន៍ជាមួយគ្នា អាចប្រព្រឹត្តទៅបានតែតាមរយៈការប្រាស្រ័យទាក់ទង ស្វែងយល់ ទទួលស្គាល់ និងទទួលយកភាពខុសប្លែកគ្នាជាមួយនឹងបុគ្គលដែលមានសាវតារសង្គម សេដ្ឋកិច្ច សាសនា និងជនជាតិខុសៗគ្នា។ តាមរយៈការចែករំលែកបទពិសោធន៍ និងបំណងប្រាថ្នារួម គឺអាចបំផុសស្មារតីបង្កើតឱ្យមានអត្តសញ្ញាណរួម និងឯកភាពជាតិ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ប្រព័ន្ធអប់រំកម្ពុជា (ជាពិសេស អនុវិស័យមធ្យមសិក្សា) ទទួលបានការយកចិត្តទុកដាក់តាមដានពីសាធារណជនទូទៅកាន់តែខ្លាំង និងត្រូវបានយកមកជជែកពិភាក្សាច្រើនឡើងៗ។ ដោយហេតុថា មាតាបិតា អ្នកអាណាព្យាបាលសិស្សមានការរំពឹងទុកកាន់តែខ្ពស់អំពីលទ្ធផលនៃការអប់រំ និងនិយោជកតម្រូវឱ្យយុវជនកម្ពុជាមានសមត្ថភាពគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនានាក្នុងសតវត្សរ៍ទី២១ និងបដិវត្តន៍ឧស្សាហកម្ម ៤.០។ ភាពប្រទាក់ក្រឡា និងស្មុគស្មាញនៃប្រព័ន្ធអប់រំ ត្រូវការពេលវេលាច្រើនសម្រាប់ការកែទម្រង់លើមូលដ្ឋានសំខាន់ៗក្នុងវិស័យអប់រំ។ ក្នុងដំណាក់កាលនេះ ចាំបាច់ត្រូវផ្តល់អាទិភាព និងរូតរះអនុវត្តជាបន្ទាន់នូវសកម្មភាព ដែលប្រកបដោយមហិច្ឆតា ដើម្បីសម្រេចបានសមិទ្ធផលអប់រំទៅតាមការចង់បានក្នុងពេលអនាគត។

១-៤. សារៈសំខាន់នៃផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សា

ផែនទីបង្ហាញផ្លូវជាចក្ខុវិស័យយុទ្ធសាស្ត្របង្ហាញពីយុទ្ធសាស្ត្រលទ្ធផលរំពឹងទុកនិងសកម្មភាពដែលនឹងរួមចំណែកកែលម្អការអប់រំកម្រិតមធ្យមសិក្សា និងទំនាក់ទំនងជាមួយនឹងអនុវិស័យដទៃទៀត ក៏ដូចជា វិស័យរដ្ឋ និងឯកជននានា។

ក្នុងរយៈពេលពីរទសវត្សកន្លងមក ក្រសួងអប់រំ យុវជន និងកីឡាបានទទួលជោគជ័យជាមួយនឹងនវានុវត្តន៍ជាច្រើន ដូចជា ការបង្កើតនូវគោលវិធីសាលាកុមារមេត្រី កម្រងសាលាបឋមសិក្សា ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក ការអប់រំពហុភាសា(ភាសាដើម និងភាសាខ្មែរ) ការរៀនមុខវិជ្ជាភាសាខ្មែរតាមអនឡាញ សាលារៀនជំនាន់ថ្មី គោលវិធីគ្រប់គ្រងតាម

សាលារៀនមានប្រសិទ្ធភាព បំណិនសតវត្សរ៍ទី២១ បណ្ណាល័យ និងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ តាមរយៈការណែនាំ និងការផ្តល់ប្រឹក្សាគរុកោសល្យជាដើម ។ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំសាលារៀនប្រកបដោយគុណភាព ក្រោមការគាំទ្រពីគម្រោងគាំទ្រវិស័យអប់រំនៅកម្ពុជា(២០០៥-២០០៩)[2] ហើយក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ ព្រមទាំងអង្គការសង្គមស៊ីវិលជាដៃគូ សុទ្ធតែបានរួមចំណែកដល់ការអភិវឌ្ឍនវានុវត្តន៍ទាំងនេះ។

ដោយឡែកពីការសម្រេចបានខាងលើ ក្នុងមួយទសវត្សចុងក្រោយនេះ ចំណុចខ្លាំង និងចំណុចត្រូវកែលម្អសម្រាប់អនុវិស័យអប់រំមធ្យមសិក្សា ក៏ត្រូវបានសិក្សាចងក្រងក្នុងឯកសារវិភាគស្ថានភាព ឯកសារផែនការ និងគម្រោងនានាដែលទទួលបានថវិកាគាំទ្រពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ដែលសំដៅគាំទ្រដល់ការអប់រំកម្រិតមធ្យមសិក្សា។ ដើម្បីបន្តអភិវឌ្ឍលើជោគជ័យដែលសម្រេចបានកន្លងមក និងឆ្លើយតបចំពោះឧបសគ្គដែលរារាំង ការបន្តធ្វើឱ្យប្រសើរឡើងដល់អនុវិស័យអប់រំមធ្យមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បានផ្តួចផ្តើមរៀបចំផែនទីបង្ហាញផ្លូវ ដែលជាចក្ខុវិស័យយុទ្ធសាស្ត្រសម្រាប់អនុវិស័យអប់រំមធ្យមសិក្សានៅកម្ពុជា ពីឆ្នាំ២០២១ ដល់ ២០៣០ ។

យុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុកមួយចំនួននៅក្នុងផែនទីបង្ហាញផ្លូវ គឺជាការដកស្រង់ចេញពីបទពិសោធន៍ និងសមិទ្ធិផលដ៏លេចធ្លោដែលកំពុងអនុវត្តនៅតាមសាលារៀន និងស្រុកមួយចំនួន។ ឧទាហរណ៍ទាំងនេះបានបង្ហាញឱ្យឃើញពីឧត្តមភាពដែលមានស្រាប់ហើយនៅក្នុងប្រព័ន្ធអប់រំ ដែលនឹងក្លាយជាឱកាសសម្រាប់ភាគីពាក់ព័ន្ធនានារៀនសូត្រដកពិសោធន៍។ ដូចនេះ ផែនទីបង្ហាញផ្លូវនេះមិនត្រឹមតែរំលេចឱ្យឃើញពីបញ្ហានិងចំណុចខ្វះខាតប៉ុណ្ណោះទេ ថែមទាំងបានស្វែងយល់ និងបង្ហាញពីឧត្តមានុវត្តន៍ ព្រមទាំងជោគជ័យដែលមានរួចជាស្រេចក្នុងប្រព័ន្ធអប់រំនាពេលបច្ចុប្បន្ន ដើម្បីអនុវត្តជាបន្តទៀត។

គោលដៅនៃកំណែទម្រង់
គឺបង្កើនគុណភាពនៃលទ្ធផលសិក្សារបស់សិស្ស

ការផ្លាស់ប្តូរគោលនយោបាយដោយផ្អែកលើភាពជោគជ័យដែលមានស្រាប់ និងការដោះស្រាយបញ្ហាប្រឈមនានា ត្រូវរៀបចំឡើងដោយផ្អែកលើគោលការណ៍កែលម្អគុណភាពអប់រំកម្រិតមធ្យមសិក្សា។ ក្នុងន័យនេះ កិច្ចខិតខំប្រឹងប្រែងកែទម្រង់នានា ត្រូវផ្តោតជាសំខាន់លើការបង្កើនលទ្ធផលសិក្សារបស់សិស្ស។ តើការផ្លាស់ប្តូរគោលនយោបាយ និងរចនាសម្ព័ន្ធក្នុងប្រព័ន្ធអប់រំ មានឥទ្ធិពលអ្វីខ្លះលើលទ្ធផលនៃការអប់រំ? តើអ្នករៀបចំគោលនយោបាយអាចធ្វើអ្វីខ្លះ ដើម្បីឱ្យសាលារៀនជួយគាំទ្រដល់ការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អបំផុត? បញ្ហាចោទទាំងនេះ គឺចំណុចគន្លឹះដ៏សំខាន់នៅក្នុងផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សា។ ផែនទីបង្ហាញផ្លូវក៏បង្ហាញពីការតម្រូវឱ្យមានផែនការសកម្មភាពដែលមានលក្ខណៈជាយុទ្ធសាស្ត្រ មានសង្គតិភាព និងសម្របសម្រួលគ្នាបានល្អ ដោយឈរលើជោគជ័យនៃគំនិតផ្តួចផ្តើមថ្មីៗ និង អន្តរាគមន៍នានាដែលអនុវិស័យអប់រំមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិកំពុងអនុវត្តនាបច្ចុប្បន្ន និងគួបផ្សំជាមួយនឹងការដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗទៀត ដើម្បីឱ្យការបង្រៀន និងរៀនមានលក្ខណៈកាន់តែល្អប្រសើរ។ ជាការពិត ប្រព័ន្ធដែលមានលក្ខណៈស្មុគស្មាញនិងទំហំធំ ដូចជាប្រព័ន្ធអប់រំ គឺត្រូវការពេលច្រើនឆ្នាំដើម្បីឱ្យបានឃើញផលប៉ះពាល់ពីការ អនុវត្តគោលនយោបាយ។ ក្រសួងមិនទាន់ពង្រីកវិសាលភាពរបស់គម្រោងផ្សេងៗ ដែលអនុវត្តបានជោគជ័យកន្លងមក នៅទូទាំងប្រទេសនៅឡើយដោយសារធនធានមនុស្ស និងថវិកាមានកម្រិត។ ដូចនេះ ក្រសួងត្រូវដាក់ចេញគោលនយោបាយថ្នាក់ជាតិកម្រិតណា និងដូចម្តេចដើម្បីធានាបាននូវភាពស័ក្តិសិទ្ធ ប្រសិទ្ធភាព និរន្តរភាព ភាពពាក់ព័ន្ធ និងអាចអនុវត្តបានចំពោះតួអង្គពាក់ព័ន្ធ ទាំងអស់ទាំងនៅថ្នាក់ជាតិ រាជធានី ខេត្ត ស្រុក និងសាលារៀន។ ផែនទីបង្ហាញផ្លូវ បង្ហាញពីសកម្មភាពប្រកបដោយមហិច្ឆតាខ្ពស់ដែលក្រសួងអប់រំយុវជននិងកីឡាត្រូវអនុវត្តជាបន្ទាន់ ដើម្បីឱ្យសម្រេចបានលទ្ធផលពេញលេញត្រឹមឆ្នាំ២០៣០។

[2] World Education Inc. 2009. External Qualitative Evaluation of the Impact of Cambodian Education Sector Support Project (CESSP) Activities in Schools. Phnom Penh.

នៅក្នុងផែនទីបង្ហាញផ្លូវនេះក៏មានបង្ហាញពីបញ្ហាប្រឈមនិងជោគជ័យដែលកំពុងមានក្នុងពេលបច្ចុប្បន្នរបស់អនុវិស័យអប់រំមធ្យមសិក្សាព្រមទាំងកំណត់ពីឱកាសដែលជួយឱ្យអនុវិស័យនេះសម្រេចបានលទ្ធផលកាន់តែប្រសើរនៅក្នុងទសវត្សខាងមុខ។ ផែនទីបង្ហាញផ្លូវនេះបង្ហាញសង្ខេបពីក្របខណ្ឌចំណាយរយៈពេលវែង (១០ឆ្នាំ) ដើម្បីធានាថាមានធនធានគ្រប់គ្រាន់សម្រាប់គាំទ្រការអនុវត្តកំណែទម្រង់ និងអាទិភាពនៃការអប់រំកម្រិតមធ្យមសិក្សារបស់រដ្ឋាភិបាលក្នុងរយៈពេលពីឆ្នាំ២០២១-២០៣០ (ផ្នែកទី ១១)។

គោលការណ៍គ្រឹះនៃផែនទីបង្ហាញផ្លូវ ការអប់រំកម្រិតមធ្យមសិក្សាកម្ពុជា ឆ្នាំ ២០៣០

(i) ភាពពាក់ព័ន្ធ និងគុណភាព
(ii) គណនេយ្យភាព និងភាពឆ្លើយតប
(iii) ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ
(iv) ភាពជាដៃគូ និងកិច្ចសហការ
(v) ការគោរពសមធម៌
(vi) តម្លាភាព និងភាពបត់បែន។

១-៥. គោលបំណងនៃការអប់រំកម្រិតមធ្យមសិក្សា

ប្រធានបទជាសកលចំនួន ៤ ដែលពាក់ព័ន្ធនឹងគោលបំណងនៃការអប់រំនៅកម្រិតមធ្យមសិក្សា រួមមាន៖

១ ការអភិវឌ្ឍមូលធនមនុស្ស ដើម្បីវិបុលភាពសេដ្ឋកិច្ច

២ ការត្រៀមរៀបចំខ្លួន ដើម្បីបន្តការអប់រំនៅកម្រិតឧត្តមសិក្សា

៣ ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីត្រៀមសិស្សនិស្សិតឱ្យចូលរួមនៅក្នុងទីផ្សារការងារ

៤ ការអប់រំចំណេះទូទៅដែលមានលក្ខណៈទូលំទូលាយ ដើម្បីត្រៀមរៀបចំសិស្សឱ្យបន្តការសិក្សា និង ឬធ្វើការ/ប្រកបមុខរបរ។

ការអប់រំកម្រិតមធ្យមសិក្សាជាការអប់រំផ្តល់ពុទ្ធិបំណិនសម្បទានិងចរិយាសម្បទាដើម្បីឱ្យសិស្សត្រៀមខ្លួនសម្រាប់៖ (១) ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (២) ការអប់រំឧត្តមសិក្សា និង (៣) ឱកាសការងារ និង ការងារ/មុខរបរជាមួយនឹងបំណិនសតវត្សរ៍ទី ២១ និងបំណិនបដិវត្តន៍ឧស្សាហកម្ម ៤.០។

បច្ចុប្បន្ននេះ មានទស្សនៈផ្សេងៗគ្នាចំពោះការអប់រំកម្រិតមធ្យមសិក្សា ក្នុងនោះមាន៖ ការយល់ឃើញជាទូទៅរបស់ផ្នែកអភិវឌ្ឍចំពោះការអប់រំកម្រិតមធ្យមសិក្សា គឺនាំមុខដោយកត្តាអាទិភាពសេដ្ឋកិច្ចដូចជាការខិតខំធ្វើឱ្យមានកំណើនការភ័យខ្លាចឱនភាពសេដ្ឋកិច្ច ព្រមទាំងបញ្ហាផ្សេងៗដូចជា ភាពក្រីក្រ វិសមភាព និងភាពគ្មានការងារធ្វើជាដើម។ ការអប់រំ និងការអភិវឌ្ឍជំនាញដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារជារឿយៗ គឺចាត់ទុកថាជាដំណោះស្រាយចំពោះបញ្ហាសេដ្ឋកិច្ច និងសង្គម។[3] អ្នករិះគន់អភិក្រមបែបនេះបានលើកឡើងថា នេះជាការបន្ថយមូលធនមនុស្សមកត្រឹមតែជាកម្លាំងពលកម្មប្រកបដោយផលិតភាព ខណៈពេលដែលការអប់រំត្រូវបានចាត់ទុកថា ជាធាតុចូលដើម្បីសម្រេចនូវវិបុលភាពសេដ្ឋកិច្ច។

[3] D. Balwanz. 2015. *Perspectives from South African Academic and Vocational Secondary Schools on the Purpose of Secondary Education.* University of Maryland-College Park, MD. Unpublished PhD dissertation.

ការយល់ឃើញទី២ គឺការអប់រំកម្រិតមធ្យមសិក្សា ជាការត្រៀមលក្ខណៈចូលរៀននៅសាកលវិទ្យាល័យ។ ដូចនេះ កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនរៀបចំឡើងសម្រាប់ជួយសិស្សទទួលបានជោគជ័យកម្រិតខ្ពស់ក្នុងការប្រឡង ដើម្បីឱ្យពួកគេអាចចូលរៀននៅកម្រិតឧត្តមសិក្សា។ ទោះបីសិស្សបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិជាច្រើន មិនបានបន្តការសិក្សានៅសាកលវិទ្យាល័យ (អត្រារួមនៃការសិក្សា ១៣,៧% ឆ្នាំ ២០១៨)[4] ក៏កម្មវិធីសិក្សានៅមធ្យមសិក្សាទុតិយភូមិកន្លងមកក៏ដូចជាបច្ចុប្បន្ននៅតែបន្តផ្តោតលើបណ្ដុំមុខវិជ្ជាចំនួនពីរគឺ វិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម។

ការយល់ឃើញទី៣ គឺការអប់រំមធ្យមសិក្សានៅកម្ពុជា គួរផ្តល់ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់ក្មេងជំទង់ ដើម្បីត្រៀមលក្ខណៈពួកគេសម្រាប់ចូលរួមនៅក្នុងទីផ្សារការងារ។ បច្ចុប្បន្នវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមាន១៤ នៅទូទាំងប្រទេស។ ការពង្រឹងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសដែលមានស្រាប់នាពេលបច្ចុប្បន្ន គឺមានសារៈសំខាន់ផងដែរ ព្រោះជាមូលដ្ឋានគ្រឹះសម្រាប់ពង្រីកប្រព័ន្ធអប់រំមធ្យមសិក្សាបច្ចេកទេសនាពេលអនាគត។

ការយល់ឃើញទី៤ គឺការអប់រំកម្រិតមធ្យមសិក្សា គួរផ្តល់ឱ្យយុវជននូវការអប់រំចំណេះទូទៅទូលំទូលាយ ដែលផ្តល់នូវគ្រឹះសម្រាប់បន្តការអប់រំ ឬ ការបណ្តុះបណ្តាល និង/ឬការប្រកបមុខរបរ និងការងារ។ ការយល់ឃើញបែបនេះ ចង់បាននូវការអប់រំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលជួយឱ្យយុវជនអាចធ្វើការសម្រេចចិត្តបានត្រឹមត្រូវនូវបំណងប្រាថ្នារបស់ពួកគេនាពេលអនាគត ឬ ពេលបញ្ចប់ការសិក្សានៅមធ្យមសិក្សា។ ការសិក្សាផ្តោតជាសំខាន់លើប្រាជ្ញាផ្លូវអារម្មណ៍ និងការទទួលបានចំណេះដឹងនិងជំនាញជាក់លាក់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ ទស្សនៈទី៤នេះ បានផ្តល់ឱកាសបញ្ចូលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សានូវបំណិនសតវត្សរ៍ទី ២១ ដូចជា បំណិនត្រិះរិះពិចារណា និងគិតគូរបែបច្នៃប្រឌិត ដោះស្រាយបញ្ហា ធ្វើការសម្រេចចិត្ត កសាងក្រុម សហការ និងប្រាស្រ័យទាក់ទងជាដើម។

ការយល់ឃើញខុសៗគ្នាខាងលើ គឺមិនអាចកាត់ផ្តាច់ចេញពីគ្នាបានទេ។ ការអប់រំកម្រិតមធ្យមសិក្សាគួររួមបញ្ចូលគ្នារវាងអភិក្រមចាប់ពីពីរឡើងទៅ ក្នុងចំណោមអភិក្រមខាងលើ ដើម្បីផ្តល់ឱ្យយុវជននូវការអប់រំប្រកបដោយគុណភាព និងភាពឆ្លើយតប និងត្រៀមលក្ខណៈពួកគេកាន់តែប្រសើរ ក្នុងការចាប់យកឱកាសអប់រំ និង/ឬមុខរបរ ការងារ និងអាជីព ក្រោយពេលបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សា។

[4] UNESCO. 2020. Sustainable Development Goals: Cambodia. Paris: UNESCO Institute for Statistics. http://uis.unesco.org/country/KH#slideoutsearch.

១-៦. ភាពបន្ទាន់សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា

"ការអប់រំនៅកម្ពុជា ត្រូវការកែទម្រង់ដ៏ចាំបាច់ដើម្បីស្តារឡើងវិញ នូវអត្រាត្រួតថ្នាក់ខ្ពស់ អត្រាបោះបង់ការសិក្សាខ្ពស់ និងលទ្ធផលសិក្សាទាបរបស់សិស្ស។ ជាការពិត បើទោះបីកម្ពុជាទទួលបានជោគជ័យក្នុងការបង្កើនចំនួនសិស្សចូលរៀន ពោលគឺ កុមារស្ទើរតែទាំងអស់អាចចូលរៀននៅកម្រិតបឋមសិក្សាក៏ដោយ ក៏កម្ពុជាកំពុងប្រឈមនឹងបញ្ហាសិក្សារបស់សិស្ស ដែលតម្រូវឱ្យមានដំណោះស្រាយបន្ទាន់ និងជាប្រព័ន្ធ ថែមទាំងមានចក្ខុវិស័យច្បាស់លាស់។"[5]

ពេលបច្ចុប្បន្ន ការបាត់បង់សិស្សសិក្សានៅក្នុងប្រព័ន្ធ ទាំងបឋមសិក្សា និងមធ្យមសិក្សាបានកំពុងបន្តកើតមានជារៀងរាល់ឆ្នាំ។ រូបភាពទី ២ បង្ហាញយ៉ាងច្បាស់ពីការ "បាត់បង់សិស្ស" ដែលមានចំនួនរាប់សែននាក់ចុះឈ្មោះចូលរៀននៅថ្នាក់ទី ១ ប៉ុន្តែក្រោយមក មានសិស្សក្នុងភាគរយតិចតួចប៉ុណ្ណោះក្នុងចំណោមពួកគេ ដែលបន្តការសិក្សាដល់ថ្នាក់ទី១២ ហើយមានចំនួនកាន់តែតិចទៅទៀតដែលបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា (ប្រមាណ ២០%)។ ឆ្នាំសិក្សា ២០១៩-២០២០ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានអត្រារួមនៃការសិក្សាទាបជាងគេក្នុងតំបន់សម្រាប់ថ្នាក់ទី ១០ ពោលគឺ២៨,៩% (ស្រី ៣៣,៩%) ដែលជាកត្តារួមចំណែកនាំឱ្យការបញ្ចប់ការសិក្សានៅកម្រិតទុតិយភូមិមានកម្រិតទាប (រូបភាពទី៣)[6] ។ ការថយចុះចំនួនសិស្សក្នុងឆ្នាំសិក្សា ២០១៣-១៤ គឺបណ្តាលមកពីការរឹតបន្តឹងការប្រឡងថ្នាក់ទី ១២ (សូមមើលផ្នែក ៣-៤)។ ទិន្នន័យ ក៏បង្ហាញឱ្យឃើញពីលំហូរសិស្សចេញពីការអប់រំសាធារណៈទៅសាលារៀនឯកជន កម្មវិធីអប់រំក្រៅប្រព័ន្ធ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមិនផ្លូវការ (ដែលផ្តល់ដោយវិស័យឯកជន)។[7]

រូបភាពទី ១៖ ការបន្តឡើងថ្នាក់របស់ក្រុមសិស្សក្នុងឆ្នាំសិក្សា ២០០៧-២០០៨ ដល់ឆ្នាំសិក្សា ២០១៨-២០១



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ២០០៧-២០១៩

សិស្សឆាប់បោះបង់ការសិក្សា គឺមានមូលហេតុជាច្រើន ក្នុងនោះមូលហេតុមួយចំនួនដោយសារលើសពីអ្វី ដែលពួកគេអាចគ្រប់គ្រងបាន។[8] វិធានការកាត់បន្ថយសិស្សបោះបង់ការសិក្សាត្រូវបានអនុវត្តដូចជា បង្កើនការធ្វើតេស្ត វាយតម្លៃ ដាក់ចេញនូវកម្មវិធីសិក្សា អនុវត្តរបៀបបង្រៀន និងរៀន ដែលឈានទៅកែលម្អ "គុណភាពនៃការអប់រំ"។ ក្រសួងអប់រំ យុវជន និងកីឡា បញ្ជាក់ថា បច្ចុប្បន្ន បញ្ហាសិស្សឆាប់បោះបង់ការសិក្សាកំពុងកើតមាន ហើយចាំបាច់ត្រូវឆ្លើយតបក្នុងផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សានេះ។

---

[5] Ministry of Education, Youth and Sport (MOEYS). 2018a. *Education in Cambodia: Findings from Cambodia's Experience in PISA for Development.* Phnom Penh: Education Quality Assurance Department. p. 130.
[6] MOEYS. 2019b. *Education Statistics and Indicators Preschool and General Education for Public.* Phnom Penh: RGC. p. 41.
[7] World Bank. 2010. *Providing Skills for Equity and Growth: Preparing Cambodia's youth for the labor market.* Washington, DC: World Bank.

រូបភាពទី២៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ២០០៧-២០១៩

រូបភាពទី១ និង ទី២ បង្ហាញថា ការវិនិយោគលើធនធានមនុស្ស និងការវិនិយោគហិរញ្ញវត្ថុ ក្នុងប្រព័ន្ធអប់រំសាធារណៈ រយៈពេល ១២ឆ្នាំ ការទទួលជោគជ័យនៅមានកម្រិត បើគិតពីចំនួនសិស្សបញ្ចប់ការសិក្សាធៀបនឹងចំនួនសិស្សដែលបានចូលរៀននៅថ្នាក់ទី១ ពីដំបូង។ ការសន្និដ្ឋាននេះ ផ្អែកលើភស្តុតាងបន្ថែមទៀតពីទិន្នន័យស្រាវជ្រាវថ្នាក់តំបន់ ថ្នាក់ជាតិ និងសន្ទស្សន៍មូលធនមនុស្ស ព្រមទាំងការវាយតម្លៃសិស្សក្នុងប្រទេស និងអន្តរជាតិ ដែលធ្វើឡើងក្នុងឆ្នាំ ២០១៨។ របកគំហើញទាំងនេះ រំលេចពីបញ្ហាប្រឈមដែលវិស័យអប់រំត្រូវឆ្លើយតប។

សន្ទស្សន៍មូលធនមនុស្ស

សន្ទស្សន៍មូលធនមនុស្សត្រូវបានឱ្យនិយមន័យថាជា "រង្វាស់ផលិតភាពរំពឹងទុក ដែលកុមារកើតនៅថ្ងៃនេះ នឹងមាននៅពេលដែលពួកគេអាយុ ១៨ ឆ្នាំ ដោយផ្តោតលើហានិភ័យដែលកំពុងមាននាពេលបច្ចុប្បន្នសម្រាប់ការរស់រាន សុខភាព និងការអប់រំ ដោយធៀបនឹងកុមារដែលទទួលបានការអប់រំពេញលេញ និងសុខភាពបរិបូរណ៍។[9] សន្ទស្សន៍មូលធនមនុស្សមានធាតុផ្សំចំនួនបី ៖

- *ការរស់រាន៖* តើកុមារនៅថ្ងៃនេះនឹងបន្តរស់រានរហូតដល់វ័យចូលរៀនដែរឬទេ?
- *សាលារៀន៖* តើពួកគេបានរៀនដល់កម្រិតណា/ថ្នាក់ណា និងរៀនសូត្របានច្រើនប៉ុណ្ណា?
- *សុខភាព៖* តើកុមារដែលចាកចេញពីសាលារៀននឹងមានសុខភាពកម្រិតណា? តើពួកគេនឹងត្រៀមខ្លួនរួចរាល់ដើម្បីបន្តការរៀនសូត្រ និង/ឬ ទទួលបានការងារ និងមុខរបរដែរឬទេ?

[8] ការធ្លាប់ចាកចេញពីសាលារៀន (ESL) គឺជាពាក្យដែលគួរយកមកប្រើប្រាស់ ព្រោះថា បោះបង់ការសិក្សា ជាធម្មតាបង្កប់ន័យអវិជ្ជមាន ដែលបង្ហាញថាសិស្សទទួលបរាជ័យ ហើយពាក្យនេះអាចប៉ះពាល់ដល់ការផ្តល់តម្លៃឱ្យខ្លួនឯងរបស់សិស្ស។ ការមាក់ងាយ និងការផ្តល់តម្លៃឱ្យខ្លួនឯងរបស់សិស្សគឺជាកត្តាចំនួនពីរក្នុងចំណោមកត្តាដែលអាចមានជាច្រើនក្នុងការសម្រេចចិត្តរបស់សិស្ស ឬ គ្រួសារអំពីការធ្លាប់ដកខ្លួនចេញពីសាលារៀន។ ពាក្យថា "ការបោះបង់ការសិក្សា" កាន់តែបង្កបញ្ហាដល់យុវជនដែលព្យាយាមសម្រេចនូវលទ្ធផលក្នុងបរិបទនៃការសិក្សា ដែលជារឿយៗបង្កការលំបាកដល់ពួកគេ។ សិស្សធ្លាប់ចាកចេញពីសាលារៀនដោយសារមូលហេតុជាច្រើន ដែលមិនមែនមូលហេតុទាំងអស់សុទ្ធតែពាក់ព័ន្ធជាមួយនឹងការសិក្សានោះឡើយ ហើយមូលហេតុជាច្រើនលើសពីអ្វីដែលពួកគេអាចគ្រប់គ្រងបានដោយខ្លួនឯង (ដូចជា ឥរិយាបថរបស់ឪពុកម្តាយ ការធ្លាក់ខ្លួនឈឺ និងសមាជិកគ្រួសារណាម្នាក់មានជំងឺ បន្ទុកបំណុលរបស់គ្រួសារ ចំណាយឱកាស កម្មវិធីសិក្សាមិនឆ្លើយតប គរុកោសល្យនៅខ្សោយ ចម្ងាយផ្លូវ ការគ្រប់គ្រង និងការដឹកនាំសាលារៀនទន់ខ្សោយ ភាពឆ្លើយតបចំពោះយេនឌ័រមានកម្រិតទាប ការធ្លាប់រៀបអាពាហ៍ពិពាហ៍ និងការមានផ្ទៃពោះដំបូង ដើម។ល។ ចំណុចនេះ ក៏លើកឡើងថា ប្រព័ន្ធអប់រំនៅកម្ពុជាជាកត្តាធ្វើឱ្យសិស្សទាំងនេះបោះបង់ការសិក្សា តាមរយៈការមិនផ្តល់ការអប់រំមានគុណភាពសមស្រប ដែលសិស្សានុសិស្ស និងសង្គមជាតិត្រូវការជាចាំបាច់។

[9] World Bank. 2018. *Human Capital Index – ASEAN.* Washington, DC: World Bank.

សន្ទស្សន៍មូលធនមនុស្សសរុបរបស់កម្ពុជាគឺ០,៤៩(រូបភាពទី៣)ដែលស្ថិតក្រោមអត្រាគិតជាមធ្យមរបស់អាស៊ាន០,៥៧ ហើយសន្ទស្សន៍មូលធនមនុស្ស សម្រាប់ប្រទេសសិង្ហបុរីគឺ ០,៨៨។[10]

រូបភាពទី ៣៖ សន្ទស្សន៍មូលធនមនុស្សសម្រាប់ប្រទេសនៅអាស៊ាន



ASEAN = Association of Southeast Asian Nations, Lao PDR = Lao People's Democratic Republic.
Source: World Bank. (2018). Human Capital Index – ASEAN. Washington, DC: World Bank.

រូបភាពទី៤ បង្ហាញពីការរំពឹងទុកថា កុមារកម្ពុជានឹងអាចបញ្ចប់ការសិក្សារយៈពេល ៩,៥ ឆ្នាំ ទោះបីការចាកចេញពីសាលារៀននៅកម្រិតនេះមានកម្រិតចំណេះដឹងស្មើនឹងកម្រិតនៃការរៀននៅថ្នាក់ទី ៦ (៦,៩)។ របាយការណ៍ កម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (PISA-D) សម្រាប់ប្រទេសកម្ពុជាលើកឡើងថា *"សាលារៀនគឺជាកន្លែងដ៏ពិសិដ្ឋ ប៉ុន្តែសាលារៀនមិនមែនសុទ្ធតែជាកន្លែងដែលផ្តល់នូវការរៀនសូត្រឡើយ ... ការទៅសាលារៀនដោយពុំបានរៀនសូត្រ គឺជាការខ្ជះខ្ជាយឱកាស"(ក្រសួងអ.យ.ក២០១៨, ១៣២*។[11] រូបភាពទី ៤ បង្ហាញឱ្យឃើញថា ប្រទេសភាគច្រើននៅក្នុងតំបន់អាស៊ាន កម្រិតនៃការរៀនសូត្រចេះដឹងរបស់សិស្ស មានតិចជាងចំនួនឆ្នាំដែលពួកគេបានចំណាយនសាលារៀន។

រូបភាពទី ៤៖ ចំនួនឆ្នាំដែលកុមារកើតនៅថ្ងៃនេះ រំពឹងថាទៅរៀនក្នុងសាលារៀន និងចំនួនឆ្នាំទៅរៀនក្នុងសាលារៀន ដែលត្រូវបានកែសម្រួលទៅតាមកម្រិតនៃការរៀនសូត្រ



ASEAN = Association of Southeast Asian Nations, Lao PDR = Lao People's Democratic Republic.
ប្រភព: World Bank. (2018). Human Capital Index – ASEAN. Washington, DC: World Bank.

[10] World Bank. 2018. *Human Capital Index – ASEAN.* Washington, DC: World Bank.
[11] Footnote 6, p. 132.

នៅក្នុងសន្ទស្សន៍មូលធនមនុស្ស *អនក្ខរកម្មអំណាន (learning poverty)* ត្រូវបានឱ្យនិយមន័យថាជា "ការពុំមានសមត្ថភាពអាន និងយល់អត្ថបទងាយៗ ទោះបីជាអាយុ ១០ ឆ្នាំ" និងជាសូចនាករសកល ដែលប្រមូលផ្ដុំដោយសូចនាករចូលរៀន និងសូចនាករលទ្ធផលសិក្សា។ អនក្ខរកម្មអំណាន គឺជាមធ្យមភាគដែលត្រូវបានដាក់មេគុណឱ្យនៃភាគរយប្រជាជន ដែលមានសមត្ថភាពក្រោមកម្រិតស្ទាត់ជំនាញអប្បបរមា កែសម្រួលទៅតាមចំនួនប្រជាជននៅក្រៅសាលា (តារាងទី២)។

តារាងទី២៖ អនក្ខរកម្មអំណាននៅក្នុងប្រទេសកម្ពុជា និងប្រទេសជិតខាងក្នុងតំបន់

ប្រទេស	កុមារក្រៅសាលា[13]	BMP[14] (ក្នុងសាលា)	អនក្ខរកម្មអំណាន (%)	ឆ្នាំវាយតម្លៃ	ការវាយតម្លៃ
វៀតណាម	1.0	1.0	2.0	2019	NLA
ម៉ាឡេស៊ី	1.0	12.0	13.0	2019	NLA
ថៃ	2.0	22.0	23.0	2019	TIMSS
ឥណ្ឌូនេស៊ី	2.0	34.0	35.0	2019	PIRLS
កម្ពុជា	3.0	50.0	51.0	2019	NLA

BMP = ក្រោមសមត្ថភាពអប្បបរមា, NLA = ការវាយតម្លៃអនក្ខរកម្មជាតិ, OOS =ក្រៅសាលារៀន, PIRLS =ការសិក្សាអំពីវឌ្ឍនភាពអនក្ខរកម្មអំណានអន្តរជាតិ, TIMSS = ទំនោរអន្តរជាតិលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រ

ប្រភព៖ World Bank. (2018). Human Capital Index – ASEAN. Washington, DC: World Bank។

គេត្រូវមានការប្រុងប្រយ័ត្ន ចំពោះការប្រើប្រាស់សន្ទស្សន៍មូលធនមនុស្សសម្រាប់វាស់វែងវឌ្ឍនភាពរបស់ប្រទេសមួយធៀបនឹងប្រទេសមួយទៀត ៖

> *គេត្រូវចាំថា ការគ្រាន់តែវាស់សីតុណ្ហភាពរបស់មនុស្សម្នាក់ មិនមែនជាការព្យាបាលជំងឺគ្រុនក្ដៅនោះឡើយ - ការវាស់វែងបែបនេះនឹងមិនធ្វើឱ្យការអប់រំកាន់តែមានភាពប្រសើរនោះឡើយ។ ការអប់រំប្រកបដោយគុណភាព អាចសម្រេចទៅបាននៅពេលដែលប្រព័ន្ធរបស់រដ្ឋត្រូវបានពង្រឹង តាមរយៈការដាក់ចេញនូវគោលនយោបាយ ផ្អែកតាមការស្រាវជ្រាវ ភស្តុតាង និងការពិគ្រោះយោបល់ជាមួយនឹងអ្នកប្រកបវិជ្ជាជីវៈពាក់ព័ន្ធនឹងការបង្រៀន។ សន្ទស្សន៍មូលធនមនុស្សគ្រាន់តែជាឧបករណ៍សម្រាប់វាស់វែងតែប៉ុណ្ណោះ ហើយផលជះរបស់វា គឺអាស្រ័យលើសកម្មភាពដែលអនុវត្តផ្អែកតាមលទ្ធផលនៃការវាយតម្លៃនេះ។[15]*

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី ១១ (២០១៨)

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី ១១ កាលពីឆ្នាំ ២០១៨ ផ្អែកតាមស្តង់ដាជាតិ បានបង្ហាញលទ្ធផលប្រហាក់ប្រហែលនឹងការវាយតម្លៃ PISA-D ដែរ (ធ្វើឡើងក្នុងឆ្នាំ ២០១៨ ដែរ)។ សរុបសិស្សថ្នាក់ទី ១១ មានចំនួន ៦ ៦៤១ នាក់ មកពីសាលារៀនរដ្ឋចំនួន ២០០ និងសាលារៀនឯកជនចំនួន ៣០ បានចូលរួមក្នុងការវាយតម្លៃថ្នាក់ជាតិនេះ ក្នុងនោះមានស្រី ៥៥% ដោយឡែកសិស្ស ៦៤% មកពីសាលារៀនជនបទ និង ៧២% ជាសិស្សដែលរៀនក្នុងបណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រ។ លទ្ធផលតេស្តវង្វាយតម្លៃសម្រាប់មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា ដូចបង្ហាញក្នុងតារាងខាងក្រោម (តារាងទី៣) គឺបែងចែកទៅតាមមុខវិជ្ជា និងក្រុមអាយុ ៖

[12] World Bank. 2018. *Human Capital Index – ASEAN*. Washington, DC: World Bank.
[13] OOS សំដៅលើកុមារក្រៅសាលាគិតជាភាគរយនៃកុមារដល់វ័យសិក្សានៅបឋមសិក្សា ដែលកុមារក្រៅសាលាទាំងនោះត្រូវបានចាត់ទុកថាមានភាពស្ទាត់ជំនាញក្រោមកម្រិតអប្បបរមា។
[14] BMP ដៅលើភាគរយរបស់កុមារបញ្ចប់បឋមសិក្សាដែលចេះអានក្រោមកម្រិតអប្បបរមា ដូចដែលត្រូវបានកំណត់និយមន័យដោយសម្ព័ន្ធសកល ដើម្បីពិនិត្យតាមដានការរៀនសូត្រក្នុងបរិបទនៃការពិនិត្យតាមដានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ៤.១.១។
[15] D. Edwards. 2018. "What's wrong with the World Bank's Human Capital Index?" https://www.worldsofeducation.org/en/woe_homepage/woe_detail/16022/what%E2%80%99s-wrong-with-the-world-

តារាងទី៣៖ លទ្ធផលតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី ១១ (២០១៨)

មុខវិជ្ជា	មិនទាន់ដល់វ៉ៃយសិក្សាថ្នាក់ទី ១១	ដល់វ៉ៃយសិក្សាថ្នាក់ទី ១១	លើសវ៉ៃយសិក្សាថ្នាក់ទី ១១	មធ្យមភាគជារួម
ភាសាខ្មែរ	61.5%	57.9%	55.1%	58.2%
គណិតវិទ្យា	46.6%	39.4%	34.9%	40.3%
រូបវិទ្យា	41.2%	35.6%	32.8%	36.5%

ប្រភព៖ Ministry of Education, Youth and Sport. 2018d. Results of Grade 11 Student Achievement from the National Assessment in 2018. Phnom Penh: Education Quality Assurance Department.

សិស្សដែលចូលរួមការធ្វើតេស្ត សុទ្ធតែបានរៀនបន្ថែមក្រៅម៉ោង*(រៀនគួរ)*។ សិស្សរៀនបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រនៅថ្នាក់ទី១១ រំពឹងទុកថា ទទួលបានលទ្ធផលខ្ពស់ក្នុងការវាយតម្លៃលើកម្មវិធីសិក្សាជាតិ ដែលរៀបចំនៅកម្ពុជា។ ប៉ុន្តែ លទ្ធផលជារួមបែរជាមានកម្រិតទាបទៅវិញ (៣៦,៤%)។

ការវាយតម្លៃថ្នាក់ជាតិសម្រាប់សិស្សថ្នាក់ទី ១១ បានបង្ហាញឱ្យឃើញនូវភាពមិនស្របគ្នារវាងកម្មវិធីសិក្សា និងការបង្រៀនក្នុងថ្នាក់រៀន។ សិស្សដែលត្រូវបានកត់សម្គាល់ថារៀនពូកែក្នុងសាលា មិនសុទ្ធតែអាចធ្វើតេស្តស្តង់ដារវាយតម្លៃថ្នាក់ជាតិបានល្អទេ៖

សិស្សដែលគ្រូចាត់ចំណាត់ថ្នាក់ថាជាសិស្សរៀនពូកែនៅក្នុងថ្នាក់ ពួកគេមិនអាចធ្វើតេស្តស្តង់ដារវាយតម្លៃថ្នាក់ជាតិបានល្អទេ នេះជាការឆ្លុះបញ្ចាំងពីភាពមិនស្របគ្នារវាង កម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃ (ពិន្ទុ) នៅកម្រិតសាលារៀន។ ជាពិសេស លទ្ធផលដែលរកឃើញទាំងនេះហាក់ដូចជាបង្ហាញថាការបង្រៀន និងការវាយតម្លៃ (ពិន្ទុ)នៅក្នុងថ្នាក់រៀន មិនឆ្លើយតបទៅនឹងលទ្ធផលសិក្សាដែលត្រូវបានកំណត់នៅក្នុងកម្មវិធីសិក្សា។[16]

កម្មវិធីអន្តរជាតិស្តីពី វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ឆ្នាំ២០១៨ (PISA-D)

មូលហេតុចម្បងដែលកម្ពុជាសម្រេចចិត្តចូលរួមក្នុងកម្មវិធី PISA-D គឺ ក្រសួងចង់ស្វែងយល់ពីលទ្ធផលសិក្សារបស់សិស្សនៅកម្ពុជា ធៀបនឹងចំណុចដៅជាអន្តរជាតិ ធៀបជាមួយនឹងប្រទេសផ្សេងទៀតដែលជួបប្រទះនឹងបញ្ហាប្រឈមស្រដៀងគ្នា និងដើម្បីកំណត់ពីកត្តានានាដែលមានទំនាក់ទំនងជាមួយនឹងការទទួលបានលទ្ធផលសិក្សាទាប ហើយធ្វើការលុបបំបាត់ដោយប្រសិទ្ធភាព។[17]

PISA-D គឺជាតេស្ត ធ្វើឡើងចំពោះក្រុមសិស្សមានអាយុជាក់លាក់ (តែសិស្សអាយុ ១៥ ឆ្នាំ ប៉ុណ្ណោះ) គឺសិស្សអាយុ ១៥ ឆ្នាំ ចំនួន ៥ ១៦២ នាក់ ដែលរៀននៅថ្នាក់ទី ៧ ដល់ ១២ ក្នុងនោះ ភាគច្រើនជាសិស្សរៀននៅថ្នាក់ទី ៩ និងទី ១០ (៣ ១២៤នាក់ ស្មើនឹង៦១%)។ សិស្សស្រីមាន ៥៣% និងសិស្សនៅជនបទមាន ៧៣%។ ក្នុងឆ្នាំ ២០១៧ មានក្មេងជំទង់អាយុ ១៥ ឆ្នាំ ត្រឹមតែ ២៨% ប៉ុណ្ណោះ ដែលរៀនដល់ថ្នាក់ទី ៧ ខណៈដែល ៧២% រៀននៅកម្រិតបឋមសិក្សា ឬ នៅក្រៅសាលា។ សិស្សអាយុ ១៥ឆ្នាំ ជិតពាក់កណ្តាល រៀនយឺតជាងកម្រិតថ្នាក់សមស្របទៅនឹងអាយុរបស់ពួកគេ មួយ ឬពីរឆ្នាំ ជាពិសេសសិស្សប្រុស ដោយសារតែការចុះឈ្មោះចូលរៀននៅបឋមសិក្សាគឺលើសអាយុ និង/ឬរៀនត្រួតថ្នាក់។ សិស្សប្រមាណ ១ភាគ៣ រាយការណ៍ថា ធ្លាប់រៀនត្រួតថ្នាក់នៅកម្រិតបឋមសិក្សា ឬ មធ្យមសិក្សា។[18]

bank%E2%80%99s-human-capital-index-by-david-edwards.

[16] MoEYS. (2018). *លទ្ធផលតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី១១ ឆ្នាំ២០១៨ ទំព័រ ៣៤-៣៥*

[17] Footnote 17, p. 7.

[18] Footnote 6, p. 2.

សំណួរនៅក្នុង PISA-D វាយតម្លៃពីជំនាញត្រិះរិះពិចារណាកម្រិតខ្ពស់ ដែលដកស្រង់ចេញពី Bloom's Taxonomy (ការអនុវត្តនិងការស្វែងរកហេតុផល) ដោយចៀសវាងផ្តោតតែលើចំណេះដឹង ខ្លឹមសារ ដែលដកស្រង់ចេញពីមុខវិជ្ជានៅក្នុងកម្មវិធីសិក្សា។លទ្ធផលបានបង្ហាញថាអំណាននិងវិទ្យាសាស្ត្ររបស់សិស្សកម្ពុជាមានកម្រិតទាបជាងកម្រិតមធ្យមនៃPISA-Dគួរឱ្យកត់សម្គាល់ ដោយឡែក លទ្ធផលមុខវិជ្ជាគណិតវិទ្យាមានកម្រិតប្រហាក់ប្រហែលនឹងកម្រិតមធ្យមរបស់ PISA-D៖

សិស្សទទួលបានលទ្ធផលអំណានទាបជាងស្តង់ដាមូលដ្ឋាន ដែលជាស្តង់ដាបានទទួលការឯកភាពជាអន្តរជាតិ (កម្រិតទី ២) ... ។ សិស្សប្រមាណ ៩០% ស្ថិតនៅកម្រិត ១a ឬ ក្រោមកម្រិតនេះ ក្នុងគ្រប់សមាសភាគទាំងបី។ ភាគរយនេះ គឺផ្អែកទៅតាមបទពិសោធន៍របស់ PISA និងគន្លងនៃការអភិវឌ្ឍរបស់កុមារដែលរំលេចឱ្យឃើញពីវិបត្តិនៃការរៀនសូត្រ មិនមែនត្រឹមតែថ្នាក់ទី ៧ ឡើងនោះទេ តែក៏ជាវិបត្តិនៃការសិក្សានៅកម្រិតថ្នាក់ដំបូងៗផងដែរ។[19]

លទ្ធផលសរុបរួមបង្ហាញថាសិស្សអាយុ១៥ឆ្នាំប្រមាណ៩០%(នៅកម្ពុជា)មានភាពស្ទាត់ជំនាញនៅកម្រិតទាបនិងអាចប្រើប្រាស់ជំនាញកម្រិតទាបបំផុតដែលមានក្នុង Bloom's Taxonomy (ចាំ! តែមិនយល់)។ មូលហេតុចម្បង គឺដោយសារតែការវាយតម្លៃថ្នាក់ជាតិរបស់កម្ពុជាយើងផ្តោតជាសំខាន់លើសំណួរដែលធ្វើតេស្តលើការរំឭកឡើងវិញពីចំណេះដឹងខ្លឹមសារដែលបច្ចុប្បន្នកម្មវិធីសិក្សាអន្តរជាតិជាច្រើន លែងយកចិត្តទុកដាក់ដូចមុនទៀតហើយ ពេលនេះគេបែរមកផ្តោតការយកចិត្តទុកដាក់លើជំនាញសតវត្សរ៍ទី ២១ ឬ បំណិនត្រិះរិះពិចារណាកម្រិតខ្ពស់ ដូចជា៖ ជំនាញត្រិះរិះពិចារណារិះរក ភាពច្នៃប្រឌិត ការសហការ និងការប្រាស្រ័យទាក់ទងជាដើម។ ដូចនេះ ការរៀនតាមបែបគិតក្នុងកម្រិតខ្ពស់ និងការរៀនបែបសាកសួរ រិះរក ស្ថាបនា និងសហការ និងវិធីសាស្ត្រថ្មីៗ គឺត្រូវបញ្ចូលទៅក្នុងការរៀន និងបង្រៀននៅកម្រិតមធ្យមសិក្សា និងក្នុងគ្រប់មុខវិជ្ជា។

ក្រសួងអប់រំ យុវជន និងកីឡា គ្រោងនឹងអនុវត្តឱ្យបានពេញលេញ ចំពោះលទ្ធផលនៃការរកឃើញ និងមតិយោបល់ទាំងនេះតាមរយៈការតាមដានបន្តលើអន្តរាគមន៍ដែលមានប្រសិទ្ធភាព ដូចមានកំណត់ក្នុងរបាយការណ៍ PISA-D និងរួមមាន៖

- កសាងមូលដ្ឋានគ្រឹះឱ្យបានរឹងមាំ ដើម្បីទទួលបានជោគជ័យ និងលើកកម្ពស់លទ្ធផលនៃការអប់រំ
- បែងចែកធនធានក្នុងវិស័យអប់រំឱ្យបានកាន់តែប្រសើរឡើង
- កែលម្អបរិយាកាសក្នុងសាលារៀន
- បង្កើនគុណភាពនៃការបង្រៀន
- ពង្រឹងការគាំទ្រពីគ្រួសារ និងសហគមន៍ដល់ការអប់រំ។[20]

សន្ទស្សន៍មូលធនមនុស្ស និងលទ្ធផលពីការវាយតម្លៃសិស្សនៅកម្រិតមធ្យមសិក្សា បានបង្ហាញឱ្យឃើញថា សុខមាលភាព និងលទ្ធផលសិក្សារបស់សិស្សពុំសម្រេចបានទៅតាមការគ្រោងទុកទេ។ ទោះបី កម្ពុជាទើបចូលរួម PISA-D លើកដំបូង (ឆ្នាំ២០១៨) ក៏លទ្ធផលពីការចូលរួមនេះបានរួមចំណែកឆ្លុះបញ្ចាំងពីភាពពិតនៃលទ្ធផលបានមកពីការវាយតម្លៃសិស្សថ្នាក់ទី១១ ដោយប្រើប្រាស់តេស្តស្តង់ដាថ្នាក់ជាតិ។ សរុបមក តើគេអាចភ្ជាប់ទំនាក់ទំនងរវាងលទ្ធផលខាងលើនេះជាមួយនឹងកត្តាសុខភាព សុខុមាលភាព និងការអភិវឌ្ឍកុមារនៅវ័យដំបូងៗ ទៅនឹងការអនុវត្តការបង្រៀន (ចំណេះដឹងមុខវិជ្ជា វិធីសាស្ត្របង្រៀន របៀបរៀន) និងសមត្ថភាពក្នុងការដឹកនាំការងារសាលារៀនដែរឬ?

[19] Level 2 is a particularly important threshold, as this marks the baseline level of proficiency at which students begin to demonstrate the competencies that will enable them to participate effectively and productively as continuing students, workers, and citizens, within the low-income country context. (MOEYS, 2018: 130) See pages 24-26 of the report for complete level descriptors in Reading, Mathematics, and Science.

[20] Footnote 6, p. I.

១-៧. លទ្ធផលអំពីការវិនិយោគលើវិស័យអប់រំ

បើតាមច្បាប់ថវិកាឆ្នាំ២០២០ ការចំណាយលើវិស័យអប់រំនៅកម្ពុជាគិតជាតួលេខជាក់ស្តែង កើនឡើងជិតបីដង ដោយពី ៣៤៣លានដុល្លារ ក្នុងឆ្នាំ ២០១៤ ដល់ ៨៤៨ លានដុល្លារក្នុងឆ្នាំ ២០១៩។[21] កំណើនថវិកាអប់រំមួយភាគធំ គឺការបង្កើនបៀវត្សមន្ត្រីរាជការ ដែលមានប្រមាណ ៨០% នៃចំណាយសរុប។ ក្នុងរយៈពេលដូចគ្នានេះ បៀវត្សសម្រាប់គ្រូចេញថ្មី កើនឡើងប្រមាណបីដង បៀវត្សគ្រូបឋមសិក្សាបានកើនឡើងបួនដង (ពី៨៤៨ ដុល្លារដល់ ៣ ៦០០ ដុល្លារ ក្នុងមួយឆ្នាំ) បៀវត្សគ្រូមធ្យមសិក្សាបឋមភូមិបានកើនឡើងបីដង (ពី១ ២៥៩ ដុល្លារ ដល់ ៣ ៨៧៦ ដុល្លារ ក្នុងមួយឆ្នាំ) និងបៀវត្សគ្រូមធ្យមសិក្សាទុតិយភូមិបានកើនឡើង ២,៣ ដង (ពី ១ ៨១៤ ដុល្លារ ដល់ ៤ ២២២ ដុល្លារ ក្នុងមួយឆ្នាំ)។

ជាការកត់សម្គាល់ ទោះបីជាមានការកើនឡើងនូវបៀវត្សគ្រូបង្រៀនរហូតដល់បីដង ក៏លទ្ធផលសិក្សារបស់សិស្សមធ្យមសិក្សាពីឆ្នាំ២០១៣ ដល់ ២០១៨ ពុំសូវមានការប្រែប្រួលជាដុំកំភួននៅឡើយ ដូចបានបង្ហាញតាមរយៈលទ្ធផលតេស្តស្តង់ដាខាងលើ។ ការបង្កើនបៀវត្ស គឺជាវិធានការចាំបាច់ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់គ្រូបង្រៀន ក៏មិនមែនជាលក្ខខណ្ឌតែមួយគត់សម្រាប់កែលម្អលទ្ធផលសិក្សារបស់សិស្សនោះទេ។ ក្រៅពីការបង្កើនបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ក៏ចាំបាច់ត្រូវមានយន្តការគណនេយ្យភាព និងការលើកទឹកចិត្តដទៃទៀតផងដែរ។

បញ្ហាសំខាន់បំផុតរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកែលម្អប្រព័ន្ធអប់រំ ដើម្បីបង្កើនគុណភាពអប់រំ ឱ្យបានខ្លាំងក្លាស្របគ្នានឹងការធានាឱ្យបាននូវសមធម៌ និងយុត្តិធម៌សង្គមដោយរបៀបណា។ ចំណុចនេះ គឺជាបញ្ហាដ៏លំបាក ព្រោះតែធនធាននៅមានកម្រិត។ បញ្ហាប្រឈមនេះ គឺជាជម្រើសរវាងការវិនិយោគលើសមធម៌សង្គម ដោយមិនគិតពីគុណភាពអប់រំ ឬ វិនិយោគលើគុណភាពអប់រំ ដោយមិនគិតពីសមធម៌សង្គម ជាពិសេស ដោយហេតុថា ការវិនិយោគកន្លងមក បានជំរុញឱ្យអត្រាចូលរៀននៅគ្រប់កម្រិតសិក្សាមានការកើនឡើង តែគុណភាពអប់រំនៅពុំទាន់មានប្រែប្រួលខ្លាំងនៅឡើយ។[22] ទោះជាយ៉ាងណា ពុំមែនដាច់ខាតត្រូវតែ "យកជម្រើសតែមួយគត់នោះឡើយ" ប៉ុន្តែត្រូវមានអភិក្រមដែលអាចធានាបាននូវតុល្យភាព។ យុទ្ធសាស្ត្រអភិវឌ្ឍដោយការប្រើវិធីសាស្ត្រចម្រុះរួមមានការបង្កើនការវិនិយោគលើគ្រឹះស្ថាន និងសាលារៀនមួយចំនួនតូច ដូចជាវិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យជាដើម ដើម្បីឱ្យគ្រឹះស្ថានទាំងនេះ ក្លាយជា "មជ្ឈមណ្ឌលឧត្តមភាព" និងជាសាលាមធ្យមសិក្សាដែលអនុវត្តការងារបានកាន់តែប្រសើរ ព្រមទាំងផ្នែកផ្សេងៗទៀតដែលត្រូវវិនិយោគតិចតួច តែអាចផ្តល់លទ្ធភាពឱ្យប្រព័ន្ធអប់រំឆ្លើយតបចំពោះបញ្ហាសមធម៌សង្គម និងបញ្ហាគុណភាពមួយចំនួន ដែលកំពុងកើតមាននៅតាមតំបន់នានាក្នុងប្រទេសផង។ ការវិនិយោគ កាន់តែច្រើន អាចផ្តល់នូវឧត្តមានុវត្តន៍ ដែលអាចយកទៅអនុវត្តតាមសាលាមធ្យមសិក្សា និងវិទ្យាស្ថានគរុកោសល្យដទៃទៀតនៅទូទាំងប្រទេស នៅពេលមានធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស។ អភិក្រមនេះតម្រូវឱ្យមានការវាយតម្លៃ សមត្ថភាពស្រូបយករបស់សាលារៀន ពោលគឺ ការត្រៀមខ្លួន និងការប្តេជ្ញាចិត្តក្នុងការបង្កើនការវិនិយោគ និងការរំពឹងទុកកាន់តែខ្ពស់ ដែលត្រូវបង្កើតនូវធនធានកាន់តែច្រើន និងបង្កើនប្រសិទ្ធភាពថវិកា។

[21] ចំណាយលើការអប់រំ រួមទាំងចំណាយចរន្ត និងចំណាយមូលធន។ ចំណាយមូលធនសម្រាប់វិស័យអប់រំ មានចាប់តាំងពីឆ្នាំ ២០១៥ មក។
[22] KAPE. 2016. *Achieving Greater Efficiencies in Educational development through High and Low Cost Development Strategy. Discussion paper.* Kampong Cham: Kampuchean Action to Promote Education.

១-៨. ទំនាក់ទំនងក្នុងអនុវិស័យមធ្យមសិក្សា

រូបភាពទី៥បង្ហាញពីទំនាក់ទំនងទៅវិញទៅមករវាងបទពិសោធន៍ជាមួយនឹងការរៀនសូត្ររបស់យុវជនដែលបានឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សា ហើយចុងក្រោយនឹងបន្តទៅកម្រិតក្រោយមធ្យមសិក្សា ដែលរាប់បញ្ចូលទាំងការអប់រំឧត្តមសិក្សា ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការអប់រំក្រៅប្រព័ន្ធ និង/ឬ ការប្រកបមុខរបរ/ការងារនៅក្នុងវិស័យរដ្ឋ និងឯកជន[23]។

រូបភាពទី ៥៖ ការអប់រំមធ្យមសិក្សា និងទំនាក់ទំនងរបស់វា



ខាងក្រោមនេះ គឺជាការបង្ហាញដោយសង្ខេបអំពីការអប់រំកម្រិតអនុវិស័យបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ ព្រមទាំងឧត្តមសិក្សា និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (សូមមើលផ្នែក ៣-១៥ សម្រាប់ការពិភាក្សាអំពីទីផ្សារការងារ)៖

ការអប់រំកុមារតូច

កម្ពុជាបានអនុវត្តកម្មវិធីនិងយុទ្ធសាស្ត្រជាច្រើនដើម្បីពង្រីកលទ្ធភាពចូលរៀនរបស់កុមារក្នុងការអប់រំមត្តេយ្យសិក្សា។ក្នុងឆ្នាំសិក្សា ២០១៩-២០២០ កុមារចំនួន ៣៦៣ ៦៨១ នាក់ បានចូលរៀនក្នុងការអប់រំកុមារតូច (ស្រី ១៨២ ១១៤នាក់) ដែលត្រូវនឹងអត្រារួមនៃការសិក្សា ៣៨,៤% (ស្រី ៣៩,៤%)។ សន្ទស្សន៍យុគភាពយេនឌ័រ នៅតែមានកម្រិត ១.០ ដដែល។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកចំនួនសាលាមត្តេយ្យរដ្ឋបានកើនឡើងយ៉ាងច្រើនដោយកើនពី១៦៣៤នៅឆ្នាំសិក្សា២០០៧-២០០៨ ដល់ ៤ ៤០៩ នៅឆ្នាំសិក្សា ២០១៩-២០២០។ ចំនួនគ្រូមត្តេយ្យសិក្សាក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដោយកើនពី ២ ៩៦០ នាក់នៅឆ្នាំសិក្សា២០០៧-២០០៨ ដល់ ៥ ៦៧៨ នាក់ នៅឆ្នាំសិក្សា ២០១៩-២០២០។ ទន្ទឹមនេះដែរ ស្ថានភាពសុខភាព និងអាហារូបត្ថម្ភកុមារ បរិក្ខារទឹកស្អាត និងអនាម័យ និងចំនួនសាលាមត្តេយ្យសិក្សាដែលបំពេញស្តង់ដាអប្បបរមា មានភាពប្រសើរឡើងតាំងពីឆ្នាំ ២០១៥។[24]

[23] គន្លងអប់រំ បណ្តុះបណ្តាល និងអាជីព ត្រូវបានស្នើឡើងនៅក្នុងផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០ (ផ្នែក ៤.២)
[24] MOEYS. 2020. *របាយការណ៍សន្និបាតអប់រំ ឆ្នាំ២០២០* ក្រសួងអប់រំ យុវជន និងកីឡា ទំព័រ ៣៧

ទោះបីសម្រេចបានសមិទ្ធិផលទាំងនេះ ក៏អនុវិស័យនេះនៅតែមានបញ្ហាប្រឈមធំៗផងដែរ។ កុមារនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល ជាពិសេសកុមារក្រីក្រ និងកុមារជួបការលំបាក មិនសូវបានចូលរៀននោះទេ។ អត្រាចូលរៀននៅមត្តេយ្យសិក្សាទាប បានជះឥទ្ធិពលលើសមត្ថភាពរបស់កុមារតូចភាគច្រើនក្នុងការត្រៀមខ្លួនចូលរៀនបឋមសិក្សា។ កង្វះគ្រូបង្រៀន គឺមានទាំងនៅសាលាមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍។ ការជ្រើសរើសគ្រូបង្រៀនមិនទាន់ឆ្លើយតបនឹងការចូលរៀនរបស់សិស្ស ដែលកំណើនសិស្សប្រចាំឆ្នាំ មាន១០,៣% ខណៈដែលកំណើនគ្រូបង្រៀនដែលមានគុណវុឌ្ឍិមានតែ ៥,៥% ក្នុងមួយឆ្នាំ។ កត្តានេះបានជះឥទ្ធិពលដល់ផលធៀបគ្រូ-សិស្ស ដែលកើនពី ២៦,៩ នៅឆ្នាំសិក្សា ២០០៧-២០០៨ ដល់ ៤៣,១ នៅឆ្នាំសិក្សា ២០១៩-២០២០។ ការអប់រំកុមារតូចដែលមានគុណភាព គឺជាមូលដ្ឋានគ្រឹះសម្រាប់កុមារតូចឆ្លងទៅបឋមសិក្សានិងមធ្យមសិក្សា និងកម្រិតអប់រំបន្ទាប់ទៀត។ ដូចនេះ ការអប់រំកុមារតូច ត្រូវផ្តោតយកចិត្តទុកដាក់យ៉ាងខ្លាំង ដូចបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៩-២០២៣ និងផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ឆ្នាំ ២០៣០។

ការអប់រំកម្រិតបឋមសិក្សា

ការវិភាគបង្ហាញថាលទ្ធផលសិក្សារបស់សិស្សមានការខុសៗគ្នាទៅតាមយេនឌ័រសាវតារសង្គមសេដ្ឋកិច្ចនិងទីតាំងភូមិសាស្ត្ររបស់ពួកគេ។ ចំណុចនេះ មានការបង្ហាញពីមូលហេតុជាច្រើន ដែលបណ្តាលឱ្យការសិក្សារបស់សិស្សទទួលលទ្ធផលមិនបានល្អ។ ការសិក្សាមួយនៅក្នុងឆ្នាំ ២០១៣ បានបង្ហាញថា ចំនួនម៉ោងបង្រៀនភាគច្រើននៅក្នុងសាលារៀនត្រូវបាត់បង់ដោយសារគ្រូអវត្តមាន ថ្ងៃឈប់សម្រាកបុណ្យជាតិច្រើនពេក និងការបាត់បង់ចំនួនម៉ោងបង្រៀននៅថ្ងៃបង្រៀន ដោយសារតែការដឹកនាំនិងការគ្រប់គ្រងសាលារៀននៅមានកម្រិតខ្សោយ។[25] របាយការណ៍ ថ្មីៗនេះ បង្ហាញថា សិស្សចប់កម្រិតបឋមសិក្សា (ថ្នាក់ទី៦) មានបំណិនអាន សរសេរ និងលេខនព្វន្តក្នុងកម្រិតទាប ដែលធ្វើឱ្យពួកគេពុំអាចត្រៀមខ្លួនបានល្អសម្រាប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ ដែលនេះជាហេតុធ្វើឱ្យមាតាបិតាសម្រេចចិត្តបញ្ឈប់ការសិក្សារបស់កូន ឬ ជំរុញឱ្យកូនៗ ឆាប់បោះបង់ការសិក្សា។[26] ចំណុចនេះ បណ្តាលមកពីនិយមឱ្យឡើងថ្នាក់ដោយស្វ័យប្រវត្តិដែលបានអនុវត្តនៅតាមសាលាបឋមសិក្សាទូទាំងប្រទេស។ ក្នុងការដោះស្រាយបញ្ហាសិស្សរៀនខ្សោយនៅបឋមសិក្សា ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំកម្មវិធីអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ដោយសហការជាមួយនឹងដៃគូអភិវឌ្ឍ ផ្តោតលើកម្មវិធីក្សា ការបង្រៀន និងវង្វាយតម្លៃថ្នាក់ទី១ និង ២។ លទ្ធផលរំពឹងទុកនៃកម្មវិធីនេះ គឺពង្រឹងបំណិនអាន សរសេរ និងលេខនព្វន្ត ដើម្បីឱ្យសិស្សបញ្ចប់ការសិក្សានៅបឋមសិក្សាមានសមត្ថភាពឆ្លងទៅកម្រិតមធ្យមសិក្សា ឬ អាចចាប់យកឱកាសសិក្សាផ្សេងទៀតក្រោយកម្រិតបឋមសិក្សា។

នៅឆ្នាំសិក្សា ២០១៩-២០ សាលាបឋមសិក្សាប្រមាណ ៦៥% រៀនពីរវេន ដោយសារតែចំនួនសិស្សច្រើន ធៀបនឹងបុគ្គលិកអប់រំ។ បញ្ហាមួយផ្នែក គឺមកពីថវិកាមានកម្រិត និងបញ្ហាពង្រាយគ្រូពីសាលាលើសចំនួនគ្រូ ឬសាលាខ្វះគ្រូ។ គ្រូបង្រៀនខ្លះស្ទាក់ស្ទើរមិនចង់ទៅបង្រៀននៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលឡើយ។ អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិទូទាំងប្រទេស គឺ ៨៥% ក្នុងឆ្នាំសិក្សា ២០១៩-២០ ក្នុងនោះ ៩៦,២% (តំបន់ទីប្រជុំជន) និង៨២,៨% (តំបន់ជនបទ)។ អត្រាឆ្លងភូមិសិក្សាសម្រាប់សិស្សប្រុស មាន ៨១,៥% (ថ្នាក់ជាតិ) ៩៤,២% (តំបន់ទីប្រជុំជន) និង ៧៨,៩% (តំបន់ជនបទ)។ អត្រាឆ្លងភូមិសិក្សាសម្រាប់សិស្សស្រី ៨៨,៥% (ថ្នាក់ជាតិ) ៩៨,២% (តំបន់ទីប្រជុំជន) និង ៨៦,៧% (តំបន់ជនបទ)។ ទិន្នន័យនេះបង្ហាញថា សិស្សស្រីឆ្លងភូមិសិក្សាទៅកម្រិតមធ្យមសិក្សាបឋមភូមិ ខ្ពស់ជាងសិស្សប្រុស។

---

[25] Universalia. 2019. *Summative GPE Country Program Evaluation.* Phnom Penh: UNESCO/UNICEF.
[26] ADB. 2018. Cambodia: *Upper Secondary Education Early School Leaving Field Study in Nine Provinces (USESDP 2).* Phnom Penh: Asian Development Bank.

ការអប់រំក្រៅប្រព័ន្ធ

ការអប់រំក្រៅប្រព័ន្ធបានផ្តល់ដល់មនុស្សពេញវ័យនិងយុវជននៅក្រៅសាលាដែលចង់បន្តការសិក្សានិងអាចបង្កើតកាលវិភាគសិក្សាដោយខ្លួនឯង និងមានឱកាសរៀនសូត្រពេញមួយជីវិតបន្ទាប់ពីបញ្ចប់ថ្នាក់បឋមសិក្សា។ ការអប់រំក្រៅប្រព័ន្ធនៅកម្ពុជាត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នជាច្រើន ដោយមានគោលបំណងផ្សេងៗគ្នា ឬ ត្រួតគ្នា។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដំណើរការថ្នាក់រៀនដើម្បីលើកកម្ពស់ជំនាញវិជ្ជាជីវៈនិងបំណិនជីវិតដល់សិស្សដែលធ្លាប់ចាកចេញពីសាលា (សិស្សបោះបង់ការសិក្សា) និងអនក្ខរជនពេញវ័យ។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីអក្ខរកម្ម បំណិនជីវិត និងជំនាញវិជ្ជាជីវៈ។ លើសពីនេះក៏អនុវត្តកម្មវិធីបណ្តុះបណ្តាល ដើម្បីរៀបចំយុវជនឱ្យធ្វើសមាហរណកម្មមកក្នុងសាលាចំណេះទូទៅក្នុងប្រព័ន្ធវិញផងដែរ។

បញ្ហាបោះបង់ការសិក្សានៅបន្តកើតមានដែលធ្វើឱ្យកម្មវិធីអប់រំក្រៅប្រព័ន្ធចាំបាច់ជាខ្លាំងក្នុងការចូលរួមដោះស្រាយបញ្ហា។ ដូចនេះ ត្រូវមានការសម្រួចកម្មវិធីអប់រំក្រៅប្រព័ន្ធជាលក្ខណៈយុទ្ធសាស្ត្រ ដើម្បីប្រើប្រាស់ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលមានកម្រិត ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា មានកម្មវិធីអប់រំក្រៅប្រព័ន្ធ ៥៖ (១) អក្ខរកម្មវិជ្ជាជីវៈ (២) ការចូលរៀនឡើងវិញ (៣) ការអប់រំសមមូល (៤) ការអប់រំបំពេញវិជ្ជា និង (៥) កម្មវិធីរកប្រាក់ចំណូល។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ បានកំណត់និងរៀបចំសកម្មភាពជាច្រើនសម្រាប់កម្មវិធីអប់រំក្រៅប្រព័ន្ធដូចជា គោលនយោបាយ គោលការណ៍ណែនាំ ផែនការ ប្រព័ន្ធព័ត៌មានគ្រប់គ្រង និងការគ្រប់គ្រងដែលភាគច្រើនជាមុខងាររៀបចំលិខិតបទដ្ឋាន គតិយុត្ត និងមុខងារ។ ដោយឡែក គួរផ្តល់អាទិភាពដល់តម្រូវការជាក់ស្តែងមួយចំនួនដូចជាការជ្រើសរើស និងចាត់តាំងគ្រូ ការរៀបចំ កម្មវិធីសិក្សា វិធីសាស្ត្រ បង្រៀន និងវង្វាយតម្លៃ និងតម្រូវការធនធាន។ ប្រសិនបើពុំមានកម្មវិធីអប់រំក្រៅប្រព័ន្ធប្រកបដោយគុណភាព និងឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋនោះទេ មុខងារគាំទ្រមួយនេះនឹងមិនត្រូវបានប្រើប្រាស់ឱ្យអស់លទ្ធភាពឡើយ។

ការអប់រំឧត្តមសិក្សា

សាកលវិទ្យាល័យរដ្ឋ និងឯកជន ទទួលបានការទទួលស្គាល់គុណភាពពីគណៈកម្មាធិការទទួលស្គាល់គុណភាពកម្ពុជាដែលបច្ចុប្បន្ននេះស្ថិតក្រោមក្រសួងអប់រំ យុវជន និងកីឡា។ គ្រឹះស្ថានឧត្តមសិក្សាដ៏ច្រើននៅកម្ពុជា ធ្វើឱ្យដំណើរការបញ្ជាក់ទទួលស្គាល់គុណភាពជួបការលំបាកមួយចំនួន។ អនុវិស័យអប់រំឧត្តមសិក្សា ប្រមូលផ្តុំនៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលភាគច្រើនជាសាកលវិទ្យាល័យឯកជន ឬសាកលវិទ្យាល័យដែលបង្កើតឡើងដោយក្រសួងផ្សេងៗទៀត។ នៅក្នុងឆ្នាំ ២០១៨ មានគ្រឹះស្ថានឧត្តមសិក្សាចំនួន ១២៥ នៅក្នុងរាជធានីខេត្តចំនួន ២០ ក្នុងនោះ ៤៨ ជាសាកលវិទ្យាល័យរដ្ឋ និង ៧៧ ជាសាកលវិទ្យាល័យឯកជន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង/ស្ថាប័នរាជរដ្ឋាភិបាលចំនួន ១៦។ ក្រសួងអប់រំ យុវជន និងកីឡា គ្រប់គ្រងសាកលវិទ្យាល័យរដ្ឋចំនួន ១៣ និងឯកជនចំនួន ៦៣ ខណៈពេលដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់គ្រងសាកលវិទ្យាល័យរដ្ឋចំនួន ១២ និងឯកជនចំនួន ១៤។

ការចូលរៀននៅឧត្តមសិក្សា មានការថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ទាំងក្នុងកម្មវិធីបរិញ្ញាបត្រ និងកម្មវិធីក្រោយបរិញ្ញាបត្រ។ ផ្ទុយមកវិញ ចំនួនបេក្ខជនជាស្ត្រី មានការកើនឡើងពីឆ្នាំ ២០១៥ មកដល់បច្ចុប្បន្ន។ ចំនួនអាហារូបករណ៍សម្រាប់កម្រិតឧត្តមសិក្សា ក៏មានការកើនឡើងផងដែរ ជាពិសេសសម្រាប់និស្សិតនារី។ នៅក្នុងប៉ុន្មានឆ្នាំខាងមុខ និន្នាការអប់រំនៅកម្រិតឧត្តមសិក្សានឹងមានភាពស្រដៀងគ្នាទៅនឹងការអប់រំកម្រិតមធ្យមសិក្សាផងដែរ ដោយសន្ទស្សន៍យេនឌ័រនឹងងាកទៅរកនិស្សិតនារីវិញ។ ចំនួននិស្សិតក្នុងកម្មវិធីបរិញ្ញាបត្ររងមានការថយចុះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ដោយសារតែលទ្ធផលប្រឡងថ្នាក់ទី១២មានភាពប្រសើរជាបន្តបន្ទាប់។ ការសិក្សាកម្រិតបរិញ្ញាបត្ររង គឺច្រើនតែជាកម្មវិធីស្ពានចម្លងរយៈពេល ២ឆ្នាំ សម្រាប់សិស្សមធ្យមសិក្សាដែលត្រូវការការអប់រំបន្ថែម ឬ ដែលមិនចង់ ឬ ដែលមិនត្រូវការការសិក្សាកម្រិតបរិញ្ញាបត្ររយៈពេល៤ ឆ្នាំ។

មុខជំនាញដែលបេក្ខជនចុះឈ្មោះចូលរៀនច្រើននៅឧត្តមសិក្សាគឺជំនាញពាក់ព័ន្ធនឹងធុរកិច្ចដូចជាហិរញ្ញវត្ថុគណនេយ្យ ធនាគារ និងការគ្រប់គ្រងធុរកិច្ចជាដើម បើទោះជាទីផ្សារការងារត្រូវការជំនាញផ្សេងទៀតក៏ដោយ។ និស្សិតរៀនមុខវិជ្ជាធុរកិច្ចដ៏ច្រើនលើសលុប ធ្វើឱ្យនិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យជាច្រើន មិនអាចរកការងារបានធ្វើសមស្របឡើយ ដែលជាហេតុធ្វើឱ្យពួកគេចាប់ផ្តើមងាកទៅរកការងារនៅក្នុងវិស័យដ៏ទៃទៀត ឬ ទទួលការបណ្តុះបណ្តាលជំនាញផ្សេងទៀត។ ការចូលរៀនមុខជំនាញនៅកម្រិតក្រោយបរិញ្ញាបត្រ ក៏មាននិន្នាការស្រដៀងគ្នានឹងការសិក្សានៅថ្នាក់បរិញ្ញាបត្រដែរ។ ដូចការលើកឡើងនៅក្នុងសូចនាករ និងចំណុចដៅនៃផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៩-២០២៣ នៅក្នុងឆ្នាំ ២០១៨ មាននិស្សិតសាកលវិទ្យាល័យជាង ២៥% បានចូលរៀនក្នុងមុខជំនាញ STEM ហើយរំពឹងថានឹងមានការកើនឡើងដល់ជាង ៣០% ត្រឹមឆ្នាំ ២០២៣ ដោយសារតែមានការយកចិត្តទុកដាក់ជាងមុនលើមុខវិជ្ជា STEM នៅកម្រិតមធ្យមសិក្សា។

គ្រឹះស្ថានឧត្តមសិក្សាភាគច្រើនគឺជាសាកលវិទ្យាល័យដែលផ្តោតលើការបង្រៀនហើយការស្រាវជ្រាវនិងផ្សព្វផ្សាយមានតិចតួចបំផុត។ សាស្ត្រាចារ្យពុំបានទទួលការបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់អំពីការស្រាវជ្រាវកម្រិតខ្ពស់ និងនវានុវត្តន៍ ហើយក៏ពុំសូវមានការផ្តល់ការលើកទឹកចិត្ត និងគាំទ្រទូលំទូលាយដល់សាស្ត្រាចារ្យដែលមានសមត្ថភាពបំពេញមុខងារទាំងនេះផងដែរ។ គ្រឹះស្ថានឧត្តមសិក្សាគួរមានការបញ្ចូលមុខងារស្រាវជ្រាវ និងផ្សព្វផ្សាយឱ្យបានល្អ ដើម្បីឱ្យគ្រឹះស្ថានឧត្តមសិក្សាមានគុណភាពខ្ពស់ និងឆ្លើយតបចំពោះសេដ្ឋកិច្ច និងសង្គមទាំងមូល។

ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)

កម្មវិធី TVET ផ្តោតលើក្រុមគោលដៅជាច្រើនដូចជា អ្នកធ្វើកសិកម្មនៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល និងម្ចាស់អាជីវកម្មខ្នាតតូច។ កម្មវិធី TVET មួយចំនួនគឺ ផ្តល់ជាវគ្គបណ្តុះបណ្តាលខ្លីៗដូចជា ការចិញ្ចឹមមាន់ ការដាំបន្លែ ការចិញ្ចឹមជ្រូក និងការចិញ្ចឹមសត្វដទៃទៀត ដែលសុទ្ធតែជាវគ្គបណ្តុះបណ្តាលពេញនិយមបំផុត។ វគ្គបណ្តុះបណ្តាលខ្លីៗទាំងនេះមានលក្ខណៈបែបប្រពៃណី និងធ្វើឡើងនៅតាមមណ្ឌល TVET នៅតាមសហគមន៍ និង/ឬនៅតាមសហគ្រាស (ដំណើរការអាជីវកម្មឯកជន)។ បើតាមក្របខណ្ឌគុណវុឌ្ឍិកម្ពុជា វគ្គបណ្តុះបណ្តាល TVET រយៈពេលវែង គឺមានចាប់ពីថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ (C1) ២ (C2) និង ៣ (C3) ថ្នាក់សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស (HDT/S) (២ ឆ្នាំ) និងថ្នាក់បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ (BT/S/BE) (៤ឆ្នាំ)។ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស និងថ្នាក់បណ្ឌិតបច្ចេកវិទ្យា/ឯកទេស អាចទទួលបាននៅតាមគ្រឹះស្ថានបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ (TTI)។ កម្មវិធីអភិវឌ្ឍជំនាញ (កម្មវិធីស្ពាន) ត្រូវបានបង្កើតឡើងសម្រាប់យុវជនអាយុចាប់ពី ១៥ ឆ្នាំឡើង ដែលជាអ្នកធាប់ចាកចេញពីការសិក្សាថ្នាក់ទី៧ ទី៨ និងទី៩ និងអតីតសិស្សដែលបានចាកចេញពីសាលារៀនក្នុងរយៈពេលយ៉ាងតិច ២ឆ្នាំ មានឱកាសទទួលបានការអប់រំឡើងវិញតាមរយៈការពន្លឿនការសិក្សា ហើយពួកគេអាចចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចាប់ពីថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១តទៅ។

ចំណុចនេះ មានការស្នើឱ្យកែសម្រួលរចនាសម្ព័ន្ធនៃអនុវិស័យនេះ ដើម្បីឱ្យកម្មវិធី TVET កាន់តែមានភាពពាក់ព័ន្ធឆ្លើយតប មានគុណភាពខ្ពស់ និងឱ្យពលករមានជំនាញស្របតាមស្តង់ដា TVET កម្រិតអន្តរជាតិ និងអាស៊ាន។ ចំណុចមួយទៀត រំពឹងទុកថា លទ្ធភាពចូលរៀនការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព នឹងមានការកើនឡើង ហើយអ្នកបញ្ចប់ការសិក្សាពីកម្មវិធី TVET នឹងទទួលបានជំនាញពាក់ព័ន្ធ ឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារការងារដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។ ថ្មីៗនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកំពុងដំណើរការទៅមុខនូវគម្រោងបង្កើនបុគ្គលិក - កម្មករជំនាញ សម្រាប់វិស័យផលិតកម្ម សំណង់ អគ្គិសនី និងបរិក្ខារអេឡិចត្រូនិច។ កិច្ចព្រមព្រៀងភាពជាដៃគូ នឹងត្រូវបង្កើតឡើងរវាងឧស្សាហកម្ម និងវិជ្ជាស្ថានបណ្តុះបណ្តាលបច្ចេកទេស (TTIs) ដើម្បីជំរុញកម្មវិធីសិក្សា "ផ្អែកលើការអនុវត្តការងារជាក់ស្តែងនិងពង្រីកមូលនិធិអភិវឌ្ឍន៍ជំនាញដែលជាយន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយភាពច្នៃប្រឌិតរបស់អង្គភាពបណ្តុះបណ្តាល អប់រំ និងវិជ្ជាជីវៈ។[27]

១-៩. តួនាទីរបស់វប្បធម៌នៅក្នុងការអប់រំ

> វប្បធម៌តែងបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការអប់រំនៅក្នុងប្រទេសទាំងឡាយ។ វប្បធម៌ "គឺជាបណ្តុំចិត្តគំនិតរបស់មនុស្សមួយក្រុម ដែលញែកសមាជិកមនុស្សមួយក្រុម ឬ មួយប្រភេទពីក្រុម ឬ ប្រភេទផ្សេងទៀត"។ គុណតម្លៃ ជំនឿ ឥរិយាបថ ទំនៀមទម្លាប់ និងអាកប្បកិរិយាដែលញែកសមាជិករបស់ក្រុមមួយពីក្រុមផ្សេងទៀត គឺមានឥទ្ធិពលលើដំណើរការនៃប្រព័ន្ធអប់រំ តាមបែបផែនច្រើនយ៉ាង។ វប្បធម៌ ជាកត្តាកំណត់ពីតួនាទីរបស់ការអប់រំក្នុងសង្គមកម្ពុជា ហើយមានធាតុផ្សំដូចជា សនិទានភាព កម្មវិធីសិក្សា ការបង្រៀន ការគ្រប់គ្រង និងលទ្ធផលសិក្សាជាដើម។ល។

[27] https://www.adb.org/projects/50394-002/main

ភស្តុតាងពីការនិយាយតៗគ្នាបង្ហាញថាធាតុផ្សំជាច្រើនរបស់វប្បធម៌មានឥទ្ធិពលលើវិធីសាស្ត្របង្រៀន និងបែបផែននៃការគ្រប់គ្រងក្នុងសាលារៀននៅកម្ពុជា។ ជាធម្មតា គ្រូច្រើនតែបង្រៀនទៅតាមរបៀបដែលធ្លាប់បង្រៀនកន្លងមក ដោយប្រើប្រាស់វិធីសាស្ត្រគរុកោសល្យឈរបង្ហាត់ ដែលចាត់ទុកសិស្សជាតែ្ត(ធុង)ដើម្បីបំពេញចំណេះដឹងដែលបានកំណត់ជាមុន តាមរយៈការរៀនបែបចងចាំ។ "ការបង្រៀនដើម្បីឱ្យសិស្សប្រលងជាប់" គឺជាការបង្រៀនដែលកើតមានជាទូទៅ នៅតាមសាលារៀន ជាពិសេសនៅតាមសាលាមធ្យមសិក្សា ឧទាហរណ៍ជាក់ស្តែង គ្រូបង្រៀនខ្លះឆ្ងល់ពីសារៈសំខាន់ និងចោទជាសំណួរថា ហេតុអ្វីបានជាត្រូវបង្រៀនមុខវិជ្ជា ព័ត៌មាន និងបច្ចេកវិទ្យាសារគមនាគមន៍ នៅថ្នាក់ទី១២ បើពុំមានបានបញ្ចូលមុខវិជ្ជានេះទៅក្នុងការប្រឡងផង។

នាយកសាលាក្លាយខ្លួន ជាប្រធានរដ្ឋបាល ("ជាអ្នកគ្រប់គ្រងការងារ") ហើយចាត់ទុកការគ្រប់គ្រងសម្ភាររូបវន្តក្នុងសាលារៀនជាការងារអាទិភាព ចំពោះភាពជាអ្នកដឹកនាំការរៀន និងបង្រៀន គឺបានយកចិត្តទុកដាក់តិចតួច ឬ ពុំមានសោះតែម្តង រីឯការជំរុញឱ្យមានការចូលរួមពីសហគមន៍ជុំវិញសាលារៀនក៏មានតិចតួច ឬពុំបានជំរុញ សហគមន៍ឱ្យចូលរួមទាល់តែសោះ។ គម្លាតនៃឋានានុក្រមក្នុងសង្គមបាននាំឱ្យមានផ្នត់គំនិតថា អ្នកមានឋានៈតួនាទីខ្ពស់ គឺជាមនុស្សសំខាន់ ហើយអាចនឹងមិនទទួលយកការចែករំលែកគំនិត ការអនុវត្ត និងមេរៀនពីអ្នកដទៃទៀត ក៏ដូចជាអ្នកដែលមានតួនាទីទាបជាង ឬ អ្នកក្រោមបង្គាប់។ ប្រការនេះបាននាំឱ្យអ្នកមានតួនាទីទាបជាង ឬ អ្នកក្រោមបង្គាប់ មានការស្ទាក់ស្ទើរក្នុងការបញ្ចេញមតិ/យោបល់ផ្ទុយរបស់ពួកគេ។ ចំណុចនេះ ក៏បានរួមចំណែកបង្កផលប៉ះពាល់ដល់សាលារៀន ដោយជាទូទៅនាយកសាលា និងគ្រូបង្រៀនច្រើនតែមិនហ៊ានធ្វើអ្វី ដែលប្រាសចាកពីការរំពឹងទុកមកលើពួកគេ បើទោះជារាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការក៏ដោយហើយបុគ្គលិកសាលារៀនបន្តជួបការលំបាកក្នុងការទទួលបានការផ្លាស់ប្តូរដែលចង់បាន។

ការកែលម្អសាលារៀនតាមរយៈ គោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាព ការធ្វើសេចក្តីសម្រេចនៅមូលដ្ឋាន តម្លាភាពថវិកា គោលវិធីបង្រៀនបែបថ្មី និងការជំរុញឱ្យមានការចូលរួមពីសហគមន៍ គឺជារឿងដែលពិបាកដើម្បីបញ្ជ្រាបចូលទៅតាមសាលារៀនជាច្រើន ដោយសារតែប្រពៃណី និងការរំពឹងទុកនៅក្នុងវប្បធម៌ ដូចលើកឡើងខាងលើ។ នាយកសាលា និងគ្រូបង្រៀនត្រូវបានតែងតាំងដោយអភិបាលខេត្ត ផ្អែកតាមសំណើរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ច្រើនតែបង្ហាញពីភាពស្មោះត្រង់ចំពោះអ្នកនៅថ្នាក់ក្រោមជាតិជាងចំពោះថ្នាក់ជាតិ។ បញ្ហានេះ បង្កការលំបាកដល់ក្រសួងអប់រំ យុវជន និងកីឡា នៅពេលព្យាយាមជ្រើសរើសបេក្ខជនដែលមានសមត្ថភាព និងអនុវត្តគោលនយោបាយ ក៏ដូចជានវានុវត្តន៍នៅថ្នាក់មូលដ្ឋាន។

បទពិសោធន៍កន្លងមក បង្ហាញថា ការអនុវត្តក្នុងវប្បធម៌បង្កឱ្យមានឧបសគ្គដល់ការផ្លាស់ប្តូរ ប៉ុន្តែក៏ជាឱកាសសម្រាប់ធ្វើការកែលម្អប្រព័ន្ធទាំងមូលផងដែរ។ ដូច្នេះ ក្នុងទសវត្សខាងមុខនេះ ជាការសំខាន់ណាស់ដែលគេត្រូវទទួលស្គាល់ និងយល់ពីផលប៉ះពាល់ និងឥទ្ធិពលនៃវប្បធម៌របស់កម្ពុជាមកលើប្រព័ន្ធអប់រំ និយាយជារួម និងនិយាយដោយឡែកលើដំណើរការសាលារៀន ។

[28] Hofstede, G. (2007). *Asian management in the 21st century. Asia Pacific Journal of Management,* 24, 411-420.
[29] Fan, Y. (2000). A classification of Chinese culture. *Cross Cultural Management: An International Journal,* 7(2), 3-10.

១-១០. ឧទាហរណ៍ល្អដែលមាននៅក្នុងបរិបទវប្បធម៌

ទោះបី មានការប្រឈមមួយចំនួនក្តី ក៏គួរកត់សម្គាល់ឃើញថានៅក្នុងបណ្តាឆ្នាំកន្លងមកថ្មីៗ ការអនុវត្តគំនិតផ្តួចផ្តើមថ្មី និងនវានុវត្តន៍នានាក្នុងវិស័យអប់រំនៅកម្ពុជាបានទទួលជោគជ័យ ទោះបីជាស្ថិតនៅបរិបទវប្បធម៌ ដូចបានមានបង្ហាញក្នុងផ្នែក ១-៩។ ការអនុវត្តគំនិតផ្តួចផ្តើមថ្មីៗដូចជា *ការវាយតម្លៃ អំណាន និងគណិតវិទ្យាថ្នាក់ដំបូងៗ* គឺជាកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រឹងបំណិនអាន សរសេរ និងលេខនព្វន្តសម្រាប់កម្រិតថ្នាក់បឋមសិក្សា ដើម្បីផលិតសិស្សបញ្ចប់ការអប់រំកម្រិតបឋមសិក្សានៅថ្នាក់ទី៦ ដែលកាន់តែមានឱកាសទទួលបានជោគជ័យនៅកម្រិតមធ្យមសិក្សាបឋមភូមិ។ *កម្មវិធីបង្រៀនការអប់រំពហុភាសា* នៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល បានជួយឱ្យកុមារ និងក្មេងជំទង់ ជាពិសេស កុមារ និងក្មេងជំទង់មកពីសហគមន៍ជនជាតិដើមភាគតិចឱ្យឡើងថ្នាក់ពីកម្រិតបឋមសិក្សាទៅមធ្យមសិក្សា។ គោលវិធី *សាលារៀនជំនាន់ថ្មី* ត្រូវបានអនុវត្តតាមរយៈភាពជាដៃគូរវាងរដ្ឋ និងភាគីមិនមែនរដ្ឋ និងឈរមូលដ្ឋានលើគោលការណ៍អភិបាលកិច្ចល្អ តម្លាភាព ការបំពេញការងារប្រកបដោយវិជ្ជាជីវៈ ឥរិយាបថគោរពតាមក្រមសីលធម៌ យុទ្ធសាស្ត្របង្រៀន និងដឹកនាំប្រកបដោយប្រសិទ្ធភាពព្រមទាំងមានការជំរុញឱ្យមានការចូលរួមកម្រិតខ្ពស់ពីសហគមន៍ និងកំណែទម្រង់ប្រព័ន្ធប្រឡងថ្នាក់ទី១២ កាន់តែទទួលបានការគាំទ្រពីប្រជាពលរដ្ឋយ៉ាងច្រើន និងមន្ត្រីអប់រំនៅកម្ពុជា។ *E2STEM* (ភ្នំពេញ) គឺជាសាលារៀនជំនាន់ថ្មីផ្តោតលើបច្ចេកវិទ្យាដែលកំពុងនាំមកនូវការអនុវត្តទំនើប និងល្អបំផុត ក្នុងការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ភាសាអង់គ្លេស និងការរៀនតាមប្រព័ន្ធអេឡិចត្រូនិក មកបញ្ចូលក្នុងប្រព័ន្ធអប់រំនៅកម្ពុជា។ សាលារៀននៅតាមមូលដ្ឋានក៏ចូលរួមនៅក្នុងការអនុវត្តគំនិតផ្តួចផ្តើមថ្មី និងនវានុវត្តន៍ដែលផ្តោតលើការរៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិកកម្មវិធីភាពជាអ្នកដឹកនាំរបស់សិស្ស ការអភិវឌ្ឍចំណេះដឹង អក្ខរកម្ម និងអំណាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) សម្រាប់ស្ត្រី ព្រមទាំងកម្មវិធីផ្លាស់ប្តូរនិស្សិត និងកម្មវិធីអាហារូបករណ៍ជាមួយនឹងប្រទេសជិតខាងនៅអាស៊ានផងដែរ។

ទន្ទឹមនឹងនោះធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក៏កំពុងពង្រីកជំនួយតាមរយៈគម្រោងផ្សេងៗទៀតជាច្រើនផងដែរ។ គម្រោងអភិវឌ្ឍន៍វិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិ (USESDP) បាននិងកំពុងអនុវត្តបច្ចុប្បន្ន ដោយផ្តោតជាសំខាន់លើការពង្រឹងបណ្តាញសាលាមធ្យមសិក្សា ការដឹកនាំនិងគ្រប់គ្រងសាលារៀន វិធីសាស្ត្របង្រៀននិងធនធានសម្រាប់មុខវិជ្ជា STEM គន្លងអាជីពសម្រាប់សិស្ស បណ្ណាល័យនិងការរៀនសូត្រផ្អែកតាមការស្រាវជ្រាវ និងការកសាងទំនាក់ទំនងរវាងសាលារៀននិងអាជីវកម្មក្នុងមូលដ្ឋាន(សូមមើលFootnote 27)។ គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា (SEIP) អនុវត្តក្នុងអនុវិទ្យាល័យចំនួន ១០០ ទូទាំងប្រទេស ដោយផ្តោតលើការអភិវឌ្ឍជំនាញដឹកនាំ និងគ្រប់គ្រងដល់នាយកសាលា ដែលនឹងជួយកសាងការជឿទុកចិត្តមកលើប្រព័ន្ធ និងលើកទឹកចិត្តឱ្យមានការកែលម្អដំណើរការសាលារៀន ក៏ដូចជា លទ្ធផលសិក្សារបស់សិស្ស។ គម្រោងកែលម្អការអប់រំមធ្យមសិក្សា គាំទ្រមូលនិធិដោយធនាគារពិភពលោកក៏ព្យាយាមអភិវឌ្ឍសាលារៀនប្រភេទជំនាន់ថ្មីផងដែរ។ គម្រោងកែលម្អការអប់រំមធ្យមសិក្សាគាំទ្រដោយធនាគារពិភពលោក ក៏នឹងខិតខំបង្កើនការឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សា និងអត្រាគង់វង្សនៃសិស្សមធ្យមសិក្សា តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈ និងការបង្កើនគុណវុឌ្ឍិគ្រូបង្រៀន និងនាយកសាលា ការគ្រប់គ្រងតាមសាលារៀន ការកែលម្អការបណ្តុះបណ្តាលគ្រូ ការគាំទ្រដល់ការអប់រំពិសេស ប្រព័ន្ធសិក្សាពីចម្ងាយ អគារសិក្សាថ្មី និងការកសាងសមត្ថភាពគ្រប់គ្រង។

ការបង្កើនការទទួលបានការអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ តាមរយៈការវិនិយោគរបស់ក្រសួងអប់រំយុវជន និងកីឡា និងការគាំទ្រពីដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល បានជួយឱ្យសិស្សកាន់តែច្រើនបញ្ចប់ថ្នាក់ទី ៩ ។ ដូចបង្ហាញក្នុងរូបភាពទី ៦ នៅក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ ការទទួលបានការអប់រំ មានការរីកចម្រើនយ៉ាងច្រើន។ សិស្សប្រុសបញ្ចប់ការសិក្សាយ៉ាងហោចត្រឹមថ្នាក់ទី ៩ មានការកើនឡើង ១០ ពិន្ទុ ពី ២១% (២០០៤) ដល់ ៣១% (២០១៧) ខណៈពេលដែលសិស្សស្រីកើនឡើងទ្វេដងពី ៨,៥% ទៅ ១៨% ក្នុង រយៈពេលដូចគ្នានេះ។

រូបភាពទី ៦៖ ភាគរយនៃមនុស្សអាយុចាប់ពី ២៥ឆ្នាំ ឡើងទៅ ដែលបញ្ចប់ការសិក្សា យ៉ាងហោចណាស់ត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ ឆ្នាំសិក្សា២០០៤-២០១៧



ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ២០១៧ ការអង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជា ២០១៧ ភ្នំពេញ ក្រសួងផែនការ

វិទ្យាស្ថានគរុកោសល្យពីរដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ និងខេត្តបាត់ដំបង គឺជាកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្របសម្រួលការអប់រំគ្រូកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដែលនឹងផ្តល់នូវអត្ថប្រយោជន៍នាពេលអនាគតជុំវិញគុណភាពនៃការបង្រៀននៅទាំងពីរកម្រិត។ មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) បានដាក់ឱ្យដំណើរការតាំងពីឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំតាមរយៈការផ្តល់កម្មវិធីបណ្តុះបណ្តាលរយៈពេលមួយឆ្នាំដល់គ្រូបង្រៀន ដែលត្រូវទៅបំពេញភារកិច្ចនៅតាមសាលារៀនជំនាន់ថ្មី និងសាលារៀនធម្មតា ក្នុងនាមជាគ្រូណែនាំ និងគ្រូបង្វឹក ដើម្បីជួយគាំទ្រដល់គ្រូបន្ទុកថ្នាក់ និងអ្នកគ្រប់គ្រងសាលារៀន។

១-១១. ឧបសគ្គសម្រាប់ការវិវឌ្ឍជាវិជ្ជមានក្នុងស្ថាប័ន

ផែនទីបង្ហាញផ្លូវនេះ គឺជាឯកសារដែលបង្ហាញពីចក្ខុវិស័យជាយុទ្ធសាស្ត្ររហូតដល់ឆ្នាំ២០៣០។ ដូចនេះ ទាមទារឱ្យមានការផ្លាស់ប្តូរការអនុវត្តបច្ចុប្បន្ន ដើម្បីឱ្យការអប់រំកម្រិតមធ្យមសិក្សានៅកម្ពុជាមានការវិវត្តឈានឡើងជាវិជ្ជមាន។ ដូចកត់សម្គាល់ខាងលើ ជាធម្មតាការផ្លាស់ប្តូរតែងតែបង្កើតឱ្យមាន ការតបត មិនស្របតាម មិនចូលរួមឬមិនចុះសម្រុង ដែលជារឿងត្រូវយកមកធ្វើការពិចារណា។ ជាទូទៅ ឧបសគ្គដែលរារាំង/រាំងស្ទះដល់ការផ្លាស់ប្តូរនៅក្នុងស្ថាប័នអាចលេចចេញជាច្រើនទម្រង់ មានដូចជា៖

- គេអាចមានអារម្មណ៍ថាទទួលរងការគំរាមកំហែងដោយសារអ្វីដែលថ្មី ឬ អ្វីដែលខុសប្លែកពីមុន ព្រោះថា "ជានិច្ចជាកាល/ពីមុនមក យើងធ្លាប់ធ្វើតែបែបនេះ"។
- គេអាចនឹងគិតថា សិទ្ធិគ្រប់គ្រងរបស់គេត្រូវបានកាត់បន្ថយ ឬ គ្រប់គ្រងបានតិចតួច ដែលនេះអាចជាហេតុនាំឱ្យមានអាក់អន់ក្នុងចិត្ត និងនាំឱ្យមានការជំទាស់ខ្លះៗទៅនឹងការផ្លាស់ប្តូរ។ អារម្មណ៍នៃការបាត់បង់ការគ្រប់គ្រង អាចផ្តើមចេញពីទម្លាប់ប្រើប្រាស់គោលវិធី "ពីលើមកក្រោម" របស់អ្នកគ្រប់គ្រង ដែលផាត់បុគ្គលិកចេញ មិនឱ្យពួកគេចូលរួមក្នុងការពិគ្រោះយោបល់ និងការសម្រេចនានា។
- ការពុំបានទុកពេលវេលាឱ្យបានគ្រប់គ្រាន់សម្រាប់ដំណើរការ ក៏អាចជាឧបសគ្គដល់ការផ្លាស់ប្តូរផងដែរ។
- អ្នកសម្រេចចិត្តមានរបៀបវារៈ និងកាលវិភាគការងារច្រើន ហើយពួកគេក៏ជាអ្នកដឹកនាំរៀបចំការងារ និងអនុវត្តគំនិតផ្តួចផ្តើមថ្មីៗ។ ដូចនេះ ពួកគេអាចផ្ទេរបន្ទុកការងារទាំងនោះទៅសហការី និងមន្ត្រីក្រោមឱវាទ ដែលជាការបន្ថែមការងារទៅលើតួនាទីនិងការទទួលខុសត្រូវដែលមានរួចមកហើយ។កត្តាទាំងនេះអាចនាំឱ្យមន្ត្រីក្រោមឱវាទត្រូវទទួលរងបន្ទុកការងារកាន់តែច្រើន បង្កឱ្យមានការបែកអារម្មណ៍ តានតឹង(ស្ត្រេស) និងឱ្យមានការបំពេញការងារដែលពុំមានសូវមានផលិតភាព។

ការផ្លាស់ប្តូរគួរតែជាកិច្ចការស្នូលរបស់ស្ថាប័ន ជាជាងជាបន្ទុកបន្ថែម ព្រោះថាការផ្លាស់ប្តូរទាមទារ ពេលវេលា ការយកចិត្តទុកដាក់ និងការកែសម្រួលដំណើរការការងារតាមដែលអាចធ្វើបាន។

ដើម្បីលើកទឹកចិត្តឱ្យមាន "ការផ្លាស់ប្តូរពិតប្រាកដ" ដំណោះស្រាយចំពោះភាពបន្ទាន់ខាងនយោបាយ និងការអនុវត្តឱ្យបានលឿន "គឺដំណើរការដែលមានភាពស្ងប់ស្ងាត់/ស្រុះស្រួល មានការវិវឌ្ឍទៅមុខ ដែលអនុវត្តរួមគ្នានៅក្នុងបរិបទដែលមានលក្ខណៈស្មុគស្មាញ"។[30] សមីការដើម្បីឱ្យមានការផ្លាស់ប្តូរត្រូវមាន៖ (១) ចក្ខុវិស័យ (២) ផែនការសកម្មភាព (៣) ធនធាន(៤) ជំនាញ និង (៥) ការលើកទឹកចិត្ត។ ទំនាក់ទំនងគ្នាទៅវិញទៅមករវាងកត្តាទាំងនេះ នឹងបង្កើតឱកាសឱ្យមានការផ្លាស់ប្តូរ និងការកែលម្អនៅក្នុងប្រព័ន្ធទាំងមូល ខណៈពេលដែលការខ្វះកត្តាមួយ ឬ ច្រើន អាចនឹងនាំឱ្យមានការខ្វះការកំណត់ពីទិសដៅ ការខកចិត្ត ការពុំមានប្រសិទ្ធភាព ការសម្រេចបានសមិទ្ធផលតិចតួច និងក្នុងករណីមួយចំនួន ពុំមានការផ្លាស់ប្តូរទាល់តែសោះ។

២. សាវតារនៃឯកសារផែនទីបង្ហាញផ្លូវ

ប្រទេសកម្ពុជា ទទួលបានការរីកចម្រើនយ៉ាងឆាប់រហ័សពីឆ្នាំ២០០០រហូតដល់ឆ្នាំបច្ចុប្បន្ននេះ។ក្នុងអំឡុងឆ្នាំ២០១១-២០១៩ ផលិតផលសរុបក្នុងស្រុក កើនឡើងក្នុងអត្រាជាមធ្យម ៧,០៥% ក្នុងមួយឆ្នាំ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធ បានរួមចំណែកធ្វើឱ្យប្រទេសសម្រេចបានកំណើនជាទីចាប់អារម្មណ៍ ដែលក្នុងនោះ វិស័យសេវាកម្ម រួមចំណែក ៤០% ដល់ផ.ស.ស របស់កម្ពុជា ហើយវិស័យឧស្សាហកម្មរួមចំណែក ៣១% ក្នុងឆ្នាំ ២០១៧។ កំណើនដ៏ឆាប់រហ័ស និងការធ្វើពិពិធកម្ម កើតឡើងទន្ទឹមគ្នានឹងកំណើនតម្រូវការកម្លាំងពលកម្មដែលមានជំនាញ។ ប៉ុន្តែ ប្រព័ន្ធអប់រំពុំទាន់អាចតាមទាន់ការផ្លាស់ប្តូររចនាសម្ព័ន្ធទាំងនេះឡើយ ហើយបាននាំឱ្យមានកង្វះជំនាញក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់។ ខណៈពេលដែលមានការសម្រេចបានវឌ្ឍនភាពជាច្រើនក្នុងការទទួលបានការអប់រំ និងគុណភាពនៃការអប់រំនៅកម្រិតបឋមសិក្សា ក៏នៅតែបន្តមានបញ្ហាប្រឈមនៅកម្រិតមធ្យមសិក្សា។

សេដ្ឋកិច្ចសកល និងភាពជឿនលឿននៃបច្ចេកវិទ្យាក្នុងបដិវត្តន៍ឧស្សាហកម្ម៤.០ បានជំរុញឱ្យកម្ពុជាត្រូវពង្រឹងកិច្ចខិតខំប្រឹងប្រែងកែលម្អប្រព័ន្ធអប់រំរបស់ខ្លួន ដើម្បីផលិតធនធានមនុស្សដែលមានជំនាញកាន់តែខ្ពស់ ឆ្លើយតបនឹងបញ្ហាប្រឈម។ ជាងនេះទៅទៀត គំនិតផ្តួចផ្តើមធ្វើឱ្យកាន់តែប្រសើរនូវប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាកម្ពុជា គឺជាអាទិភាពដ៏ចម្បង ដែលចាំបាច់ត្រូវអនុវត្ត ដើម្បីឈានទៅសម្រេចចក្ខុវិស័យរបស់កម្ពុជា ចង់បាននូវ "សង្គមពុទ្ធិ" និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដែលកំណត់ការអភិវឌ្ឍធនធានមនុស្សជាសសរស្តម្ភមួយ។ កន្លងមក មានការសម្រេចបាននូវវឌ្ឍនភាពក្នុងការបង្កើនការចូលរៀន និងគុណភាពនៃការអប់រំកម្រិតមធ្យមសិក្សា។ ប៉ុន្តែ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ល្បឿននៃបម្លាស់ប្តូរបច្ចេកវិទ្យា តម្រូវឱ្យមានការបង្កើន និងពន្លឿនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបង្កើតនូវប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាមួយ ដែលអាចតាមទាន់ការផ្លាស់ប្តូរនានា និងបំពេញគម្លាតកង្វះជំនាញដែលជាតម្រូវការរបស់ទីផ្សារ។ សេដ្ឋកិច្ចកម្ពុជាមានកំណើន -៣,១% នៅឆ្នាំ ២០២០ ដោយសារផលប៉ះពាល់នៃជំងឺកូវីដ ១៩។ ដូចនេះ ចាំបាច់ត្រូវគូសបញ្ជាក់ពីសារៈសំខាន់នៃគោលនយោបាយ និងកម្មវិធីអប់រំដែលកាន់តែមានភាពឆ្លើយតប និងកាន់តែរឹងមាំក្រោយវិបត្តិជំងឺកូវីដ ១៩។

[30] P. Wood. 2017. Overcoming the Problem of Embedding Change in Educational Organizations: A Perspective from Normalization Process Theory. *Management in Education.* 31 (1). pp. 33–38.

ការឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ និងការគាំទ្រដល់ការគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់ធនធានមនុស្ស ក្រសួងអប់រំ យុវជន និងកីឡាដោយមានការសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំផែនទីបង្ហាញផ្លូវការអប់រំ មធ្យមសិក្សាកម្ពុជាឆ្នាំ ២០៣០ ចាប់ផ្តើមពីឆ្នាំ ២០២០ ដល់ដើមឆ្នាំ២០២១ (រូបភាពទី៧)។ ចន្លោះពីខែមីនា ឆ្នាំ ២០២០ ដល់ ខែកុម្ភៈ ឆ្នាំ ២០២១ ក្រុមការងារជំនួយបច្ចេកទេសនិងគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានជួបពិភាក្សា ជាមួយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការទទួលបន្ទុក (គោលនយោបាយ និងផែនការ មធ្យមសិក្សា) ឯកឧត្តមអគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន នាយកសាលា គ្រូបង្រៀនកម្រិតមធ្យមសិក្សា (ការពិភាក្សាជាក្រុម) និងបុគ្គលិកអង្គការសង្គមស៊ីវិល ដើម្បីពិភាក្សាពីបញ្ហាប្រឈម និងជោគជ័យនានានៅក្នុងអនុវិស័យអប់រំមធ្យមសិក្សា។ ចន្លោះពីខែ មីនា ដល់ ខែឧសភា ឆ្នាំ២០២០ ក្រុមការងារជំនួយបច្ចេកទេស និងគោលនយោបាយ ដោយមានការគាំទ្រពីលេខាធិការដ្ឋាន និងដៃគូដទៃទៀត បានរៀបចំឯកសារសង្ខេប និងការវិភាគស្ថានភាពជាច្រើន ផ្តោតលើអនុវិស័យនៃវិស័យអប់រំ ការធ្វើចំណោលពីការចូលរៀន ការវាយតម្លៃលើភាពក្រីក្រ និងការវាយតម្លៃសង្គម យេនឌ័រ ទីផ្សារការងារ និងស្ថានភាពសេដ្ឋកិច្ច។ ក្នុងខែសីហា-តុលាឆ្នាំ ២០២០ កិច្ចប្រជុំពិគ្រោះយោបល់ ត្រូវបានរៀបចំឡើងដោយគណៈកម្មការបច្ចេកទេស និងក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ដើម្បីប្រមូលមតិយោបល់សម្រាប់ធ្វើការកែសម្រួលផែនទីបង្ហាញផ្លូវនេះ។ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ដែលមានការចូលរួមពីសាលាគរុកោសល្យ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត និងនាយកសាលាមធ្យមសិក្សា ត្រូវបានរៀបចំឡើងកាលពីចុងខែមករា ឆ្នាំ២០២១។ បន្ទាប់មក នៅខែកុម្ភៈ ឆ្នាំ ២០២១ មានការពិគ្រោះយោបល់ជាមួយមន្ត្រីជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលដឹកនាំដោយឯកឧត្តបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ សេចក្តីព្រាងចុងក្រោយ ផែនទីបង្ហាញផ្លូវ ត្រូវបានប្រជុំឆ្លង និសម្រេច ដោយគណៈកម្មាធិការដឹកនាំ កាលពីខែមេសា ឆ្នាំ ២០២១[31]។

ផែនទីបង្ហាញផ្លូវនេះកំណត់ពីអាទិភាព និងយុទ្ធសាស្ត្រគន្លឹះៗ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអប់រំកម្រិតមធ្យមសិក្សាផង និងជួយឱ្យកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ ទៀតផង។ ឯកសារផែនទីបង្ហាញផ្លូវនេះត្រូវបានរៀបចំឡើងផ្អែកតាមយុទ្ធសាស្ត្រ គោលនយោបាយ និងទិសដៅ ដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០៣០ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។[32]

---

[31] សមាសភាគនៃក្រុមជំនួយបច្ចេកទេស និងផ្តល់ប្រឹក្សាគោលនយោបាយ (PATA) របស់ ADB រួមមានទីប្រឹក្សាជាតិ និងអន្តរជាតិ មកពី Inno-Change International Consultants (ទីក្រុងម៉ានីល) និង TANCONS (ទីក្រុងភ្នំពេញ) ដោយសហការជាមួយអ្នកឯកទេសជាន់ខ្ពស់ផ្នែកអប់រំ និងសង្គមរបស់ ADB (ទីក្រុងម៉ានីល និងភ្នំពេញ)។

[32] ADB. 2019. *PATA 9178: Accelerating Policy Reforms in Secondary Education. Terms of Reference, Consulting Firm to Prepare the Long-term Roadmap and Plan for Secondary Education.* Manila.

រូបភាពទី ៧៖ រចនាសម្ព័ន្ធរៀបចំផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០



ADB : ធនាគារអភិវឌ្ឍន៍អាស៊ី

CAMSEB : ផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាកម្ពុជា ២០៣០

ប្រភព៖ ADB. 2020. CAMSEB 2030 Policy and Advisory Technical Assistance: Inception Report. Phnom Penh

៣. បញ្ហាប្រឈមនៅក្នុងអនុវិស័យមធ្យមសិក្សា

៣-១. ការយល់ឃើញរបស់សាធារណជនចំពោះវិស័យអប់រំ

ខណៈពេលដែលការផ្តល់សេវាអប់រំឯកជន នៅមានទំហំតូច បើធៀបនឹងសេវាអប់រំរដ្ឋ ក៏សង្កេតឃើញថា ប៉ុន្មានឆ្នាំកន្លងមក ចំនួនសិស្សចុះឈ្មោះនៅសាលាឯកជន និងសាលារបស់អង្គការមិនមែនរដ្ឋាភិបាលមានការកើនឡើងផងដែរ (រូបភាពទី ៨)។ ចំណុចនេះ គឺជាសញ្ញាមួយបង្ហាញថា ទំនុកចិត្តលើគុណភាពនៃសាលាមធ្យមសិក្សារបស់រដ្ឋនៅមានកម្រិតនៅឡើយ។ បន្ថែមលើនិន្នាការនេះ ក៏មានការកើនឡើងពីតម្រូវការរបស់មាតាបិតា/អាណាព្យាបាលដែលចង់ឱ្យកូនចូលរៀនក្នុងសាលារៀនជំនាន់ថ្មីផងដែរ (សាលារដ្ឋដែលមានលក្ខណៈម្ចាស់ការ) ដោយហេតុថា សិស្សរៀននៅសាលារៀនទាំងនេះទទួលបានលទ្ធផលសិក្សាខ្ពស់គួរឱ្យកត់សម្គាល់។

រូបភាពទី ៨៖ កំណើននៃការអប់រំឯកជននៅកម្ពុជា ឆ្នាំសិក្សា២០០៩-២០១៩



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ២០០៩-២០១៩

កាលពីខែកញ្ញា ២០១៩ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការសិក្សាលើវិទ្យាល័យធនធានចំនួន១០ ដែលតំណាងឱ្យវិទ្យាល័យធនធានទាំងអស់។ ការសិក្សានេះបានរកឃើញពីការយល់ឃើញខុសៗគ្នាអំពីគុណភាពនៃការអប់រំកម្រិតមធ្យមសិក្សារបស់នាយកសាលា គ្រូ និងមាតាបិតាសិស្ស។ លទ្ធផលទាំងនេះមានបង្ហាញក្នុងរូបភាពទី១២ ខាងក្រោម។

តារាងទី៤៖ ការផ្តល់អាទិភាពដល់បញ្ហាអប់រំសំខាន់ៗ

បញ្ហាសំខាន់ៗ	នាយកសាលា	គ្រូ	មាតាបិតាសិស្ស
ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ	1	2	2
សិស្សរៀនបានល្អ	1	3	1
គ្រូបង្ហាញពីសមត្ថភាពវិជ្ជាជីវៈកម្រិតខ្ពស់	2	3	1
គ្រូទទួលបានបៀវត្សគ្រប់គ្រាន់	3	1	4
មាតាបិតាពេញចិត្តចំពោះការបង្រៀនរបស់សាលា	4	4	3

ប្រភព៖ ក្រសួងអ.យ.ក ២០១៩ Rapid Assessment of Secondary Resource School Network. Second Upper Secondary Education Sector Development Project. Kampong Cham: Kampuchean Action to Promote Education.

ខណៈដែលសំណាកនេះមានចំនួនតូចមួយនៃសាលាមធ្យមសិក្សា ក៏លទ្ធផលរកឃើញបានរួមចំណែកយ៉ាងសំខាន់ដល់ការធ្វើសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នាយកសាលា និងមាតាបិតាសិស្សចាត់ទុកការរៀនសូត្ររបស់សិស្សជាអាទិភាពខ្ពស់ជាងគេ ខណៈពេលដែលគ្រូផ្តល់អាទិភាពដល់ប្រាក់បៀវត្ស និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធជាងការរៀនសូត្ររបស់សិស្ស។ លទ្ធផលនៃការស្ទាបស្ទង់ខាងលើបង្ហាញថា គ្រូចាត់ទុកថាសម្ភាររូបវន្ត និងសាលារៀនមានសារៈសំខាន់ជាងសមត្ថភាពវិជ្ជាជីវៈ(សិល្បៈក្នុងការបង្រៀន)របស់ខ្លួន និងការពេញចិត្តរបស់មាតាបិតាសិស្សលើការបង្រៀន។ គ្រូបង្រៀនចាត់ទុកថា ប្រាក់បៀវត្សជាបញ្ហាសំខាន់ជាងគេ និងចាត់ទុកការរៀនសូត្ររបស់សិស្ស និងការពេញចិត្តរបស់មាតាបិតាថាមានសារៈសំខាន់តិចជាង គឺជាចម្លើយមួយគួរឱ្យភ្ញាក់ផ្អើល។

៣-២. បញ្ហាគណនេយ្យភាពនៅកម្រិតផ្សេងៗ

ប្រព័ន្ធអប់រំបច្ចុប្បន្ន ពុំទាន់ទាមទារដាច់ខាតឱ្យបុគ្គលិកអប់រំនៅកម្រិតសាលារៀន មានគណនេយ្យភាពចំពោះគុណភាពនៃការអប់រំ ដែលផ្តល់ទៅឱ្យសិស្ស។ ប្រព័ន្ធអប់រំនៅកម្ពុជា ក៏ពុំទាន់តម្រូវឱ្យគ្រូបង្រៀនដែលមានវិជ្ជាជីវៈត្រូវមានអាជ្ញាប័ណ្ណនៅឡើយដែរ។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា ធ្វើឡើងយូរៗម្តង និងភ្លាមៗ ហើយស្តង់ដាវិជ្ជាជីវៈដែលត្រូវបានកំណត់ដោយប្រយោលក្នុងការវាយតម្លៃលើសមិទ្ធកម្ម (ស្នាដៃ) ប្រចាំឆ្នាំ ពុំត្រូវបានសាលារៀនជាច្រើនគោរព ឬអនុលោមតាម។[33]

ក្រសួងកត់សម្គាល់ឃើញថាសិស្សថ្នាក់ទី ៦ រហូតដល់ ៣០% ទូទាំងប្រទេស ពុំទាន់មានបំណិនអាន សរសេរ និងលេខនព្វន្តឱ្យដល់កម្រិតមូលដ្ឋានដែលចាំបាច់ ដើម្បីឱ្យពួកគេអាចឆ្លងភូមិសិក្សាទៅកាន់កម្រិតអប់រំមធ្យមសិក្សាបឋមភូមិប្រកបដោយជោគជ័យនៅឡើយ[34]។ ដូចនេះ ការសំខាន់ គឺសិស្សថ្នាក់ទី ៦ ទូទាំងប្រទេសត្រូវទទួលបានបំណិនអាន សរសេរ និងលេខនព្វន្ត កម្រិតមូលដ្ឋានដែលចាំបាច់សម្រាប់ឱ្យពួកគេអាចឆ្លងទៅកម្រិតមធ្យមសិក្សាបឋមភូមិ។ សាលាបឋមសិក្សាត្រូវទទួលខុសត្រូវខ្ពស់លើការធានាថា សិស្សស្ទាត់ជំនាញផ្នែកអំណាន សំណេរ និងលេខនព្វន្ត ក្រោយពីបញ្ចប់ថ្នាក់ទី ៦។ ដូច្នេះ វិស័យអប់រំត្រូវតែមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខ្ពស់ជាងមុនលើជោគជ័យរបស់សិស្សនៅគ្រប់កម្រិតភូមិសិក្សាទាំងអស់និងត្រូវផ្តួចផ្តើមកម្មវិធីបំប៉នសម្រាប់សិស្សដែលប្រឡងឡើងថ្នាក់ ដើម្បីសម្រេចបានលទ្ធផលសិក្សាដែលចង់បាន មុននឹងឱ្យសិស្សឡើងថ្នាក់។ គោលដៅចម្បងមួយក្នុងចំណោមគោលដៅនានារបស់គោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធិភាព គឺសហគមន៍ត្រូវចូលរួមផ្ទាល់ក្នុងការធានាថា សាលារៀនសម្រេចបានលទ្ធផលសិក្សាដែលចង់បាន តាមរយៈការរៀបចំផែនការកែលម្អសាលារៀន ការកៀគរធនធាន ការពិនិត្យតាមដាន និងការគាំទ្រផ្នែកបច្ចេកទេស។ ក្រៅពីនេះ សហគមន៍ត្រូវត្រៀមខ្លួនទទួលយកការទទួលខុសត្រូវលើឧបសគ្គរាំងស្ទះលទ្ធផលសិក្សារបស់សិស្ស។

[33] ដូចលើកឡើងជាអនុសាសន៍ ក្នុងរបាយការណ៍របស់ VSO "ផ្តល់ឱ្យគ្រូនូវកិច្ចសន្យាផ្លូវការ ដែលរៀបរាប់ពីកាំប្រាក់ វិធីសាស្ត្រនិងពេលដែលត្រូវបើកបៀវត្ស ដំណើរការបែងចែកប៉ុស្តិ៍ការងារ អត្ថប្រយោជន៍ និងប្រាក់ឧបត្ថម្ភ..." (2008)
[34] MoEYS. (2018). *ផែនការយុទ្ធសាស្ត្រវិស័យ ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា*

៣-៣. ការឆ្លងភូមិសិក្សាពីកម្រិតបឋមសិក្សាទៅមធ្យមសិក្សា

សិស្សហាក់បីដូចជាមានការលំបាកក្នុងការឡើងថ្នាក់ ជាពិសេសក្នុងការឆ្លងភូមិសិក្សានៅថ្នាក់ទី៦ និងថ្នាក់ទី ៩។[35]

ការធ្វើតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី១១ (២០១៨) បានបង្ហាញថា សិស្សថ្នាក់ទី៦ បញ្ចប់ការអប់រំកម្រិតបឋមសិក្សាមានបំណិនអាន សរសេរ និងលេខនព្វន្តក្នុងកម្រិតទាប។ ចំណុចនេះមានន័យថា ពួកគេពុំបានត្រៀមខ្លួនឱ្យបានល្អសម្រាប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិឡើយ និងជាហេតុដែលធ្វើឱ្យពួកគេឆាប់បោះបង់ការសិក្សា ឬត្រូវបានឪពុកម្ដាយបញ្ឈប់ពីសិក្សា។ ជាទូទៅ សាលាបឋមសិក្សានិយមប្រើប្រាស់ប្រព័ន្ធឡើងថ្នាក់ដោយស្វ័យប្រវត្តិ ដើម្បីទទួលបានអត្រាឡើងថ្នាក់កើនឡើង និងអត្រាត្រួតថ្នាក់ថយចុះ។ ការអនុវត្តបែបនេះ ធ្វើឱ្យសិស្សឡើងថ្នាក់នៅកម្រិតបឋមសិក្សាដោយពុំបានសម្រេចលទ្ធផលសិក្សាដែលចង់បាន និងបន្តការសិក្សានៅថ្នាក់មធ្យមសិក្សាដោយពុំមានចំណេះដឹង និងជំនាញមូលដ្ឋានផ្នែកលេខនព្វន្ត និងអក្សរសាស្ត្រ ដែលជាកត្តាចាំបាច់ដើម្បីឱ្យពួកគេទទួលបានជោគជ័យ។

យោងតាមទិន្នន័យពីការធ្វើវង្វាយតម្លៃថ្នាក់ជាតិសម្រាប់ថ្នាក់ទី ៣ ទី៦ និងទី ៨ ក្នុងរយៈពេលពីឆ្នាំ ២០១៥-២០១៧ ផ្ដោតលើមុខវិជ្ជាគោលពីរ គឺមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា បានបង្ហាញថា លទ្ធផលសិក្សាមានកម្រិតក្រោម ៥០% និងពុំមានសញ្ញាដែលបង្ហាញពីនិន្នាការប្រសើរឡើងនោះទេ (តារាងទី៥)។[36]

សិស្សមានមូលដ្ឋានគ្រឹះទាប គឺជាកត្តារារាំងមិនឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សានៅកម្រិតថ្នាក់ ខ្ពស់ៗ[37]។ ជាឧទាហរណ៍សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិអាចធ្លាប់ចាកចេញពីសាលារៀនជាពិសេសថ្នាក់ទី ៩ នៅពេលដែលពួកគេជួបការលំបាកខ្លាំងពេកជាមួយនឹងការសិក្សា។ បញ្ហានេះ ក៏កើតមានឡើងស្រដៀងគ្នារវាងការឆ្លងភូមិសិក្សាពីកម្រិតមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិ។

តារាងទី៥៖ លទ្ធផលកន្លងមកសម្រាប់ថ្នាក់ទី ៣ ទី៦ និងទី៨ បែងចែកតាមឆ្នាំ

មុខវិជ្ជាដែលត្រូវបានវាយតម្លៃ	ថ្នាក់ទី ៣	ថ្នាក់ទី ៦		ថ្នាក់ទី ៨	
	២០១៥	២០១៣	២០១៦	២០១៤	២០១៧
ភាសាខ្មែរ	35	46	52	56	54
គណិតវិទ្យា	41	43	48	44	47
រូបវិទ្យា	ពុំមានមុខវិជ្ជា	ពុំមានមុខវិជ្ជា	ពុំមានមុខវិជ្ជា	ពុំមានមុខវិជ្ជា	46

ប្រភព៖ លទ្ធផលវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី ១១ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៨ ភ្នំពេញ

ការសិក្សាស្រាវជ្រាវប្រតិបត្តិនៅតាមសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តចំនួនបី ក្នុងឆ្នាំ ២០១៨ បានបង្ហាញឱ្យឃើញថា ចំណេះដឹង និងជំនាញអក្សរសាស្ត្រ និងលេខនព្វន្ត មានកម្រិតទាបរបស់សិស្សថ្នាក់ទី៧ រួមចំណែកធ្វើឱ្យអត្រាធ្លាប់ចាកចេញពីសាលារៀនមានកម្រិតខ្ពស់។ បញ្ហាទាំងនេះ បញ្ជាក់ឱ្យឃើញឡើងវិញដូចបានកត់សម្គាល់ខាងលើ គឺសិស្សនៅកម្រិតបឋមសិក្សាត្រូវបានអនុញ្ញាតឱ្យឡើងថ្នាក់ ដោយពុំសូវបានគិតពីលទ្ធផលនៃការសិក្សារបស់ពួកគេ។[38] ទិន្នន័យអាស៊ានបង្ហាញថា កុមារកម្ពុជាជាមធ្យមរៀនបាន ៩,៥ ឆ្នាំ ប៉ុន្តែលទ្ធផលនៃការសិក្សារបស់ពួកគេ ជាមធ្យមសមមូលនឹងថ្នាក់ទី ៦។[39]

[35] Footnote 17, p. 31.
[36] Footnote 17, p. 4.
[37] Footnote 27.
[38] MoEYS. (2018). *របាយការណ៍ស្រាវជ្រាវ កម្មវិធីអភិវឌ្ឍវិស័យអប់រំទី៣ (ESDP III)*. ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ
[39] World Bank. 2015. *ASEAN Human Capital Index*. Washington, DC: World Bank Group.

៣-៤. គុណវិបត្តិនៃការឆាប់ចាកចេញពីសាលារៀន

ទោះបីជាមានការសម្រេចវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ក៏អត្រាបោះបង់ការសិក្សានៅតែជាកង្វល់ខ្លាំងរបស់អ្នករៀបចំគោលនយោបាយ។ យោងតាមការសិក្សាស្រាវជ្រាវកម្រិតសកលលោកបង្ហាញថា មនុស្សពេញវ័យដែលចាកចេញពីសាលារៀនដោយពុំបានទទួលគុណវុឌ្ឍិ (វិញ្ញាបនបត្រ/សញ្ញាបត្រ) ជាផ្លូវការ ណាមួយ ពួកគេប្រឈមនឹងការប្រេកបមុខរបរនិងការងារដែលមិនល្អ មានវិបត្តិសុខភាព និងអាចស្ថិតនៅក្នុងចំណោមអ្នកដែលប្រព្រឹត្តិបទល្មើស (Belfield & Levin, 2007; Lochner, 2011; Machin, Marie, & Vujić, 2011).[40]

ការឆាប់ចាកចេញពីសាលារៀន (ការបោះបង់ការសិក្សា) គឺជាបញ្ហាបន្តកើតមាន ដែលប្រព័ន្ធអប់រំកម្ពុជាត្រូវធ្វើការឆ្លើយតបខណៈបញ្ហានេះក៏កើតមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែលព្យាយាមលើកកម្ពស់ជីវភាពជាប្រជាពលរដ្ឋ និងផ្តោតសារៈសំខាន់លើការអប់រំប្រជាពលរដ្ឋ។ ដូចបង្ហាញនៅក្នុងរូបភាពទី ៩ អត្រានៃការឆាប់ចាកចេញពីសាលារៀនទូទាំងសម្រាប់ប្រទេសថ្នាក់ទី៧ (ថយពី ២១,៧ មក ១៤,១%) និងថ្នាក់ទី៨ (ថយពី ១៩,៧% មក ១៣,៨%) បានថយចុះនៅក្នុងរយៈពេលនេះ ទន្ទឹមនឹងអត្រាឆាប់ចាកចេញពីសាលារៀននៅថ្នាក់ទី៩ កើនពី ២១,៦% ក្នុងឆ្នាំ ២០១៣ ដល់ ២៦,២% ក្នុងឆ្នាំ២០១៩។[41] ការឆាប់ចាកចេញពីសាលារៀនកើនឡើងនៅថ្នាក់ទី៩ បានបណ្តាលឱ្យអត្រាឆាប់ចាកចេញពីសាលារៀននៅថ្នាក់ទី១០មានកម្រិតទាប (ថយពី ១៧,១% មក ១៤,៥%) និងថ្នាក់ទី ១១ (ថយពី ១១,៧% មក ៨,៥%) និងម្យ៉ាងទៀតដោយសារតែសិស្សរៀនពូកែបានឆ្លងភូមិសិក្សាទៅបន្តសិក្សានៅមធ្យមសិក្សាទុតិយភូមិ។

រូបភាពទី១០ បង្ហាញថា"ការរឹតបន្តឹង" ការប្រឡងថ្នាក់ទី១២ ដែលត្រូវបានផ្តួចផ្តើមកាលពីឆ្នាំ២០១៤ បាននាំឱ្យអត្រាឆាប់ចាកចេញពីសាលាថ្នាក់ទី១២ កើនឡើងយ៉ាងគំហុក (៥៥,២% ក្នុងឆ្នាំសិក្សា ២០១៣-២០១៤)។[42] ចាប់ពីពេលនោះមកអត្រាឆាប់ចាកចេញពីសាលារៀនបានថយចុះ (៣០,២% ក្នុងឆ្នាំសិក្សា ២០១៨-២០១៩) ដោយសារតែសិស្ស គ្រូបង្រៀន និងមាតាបិតាសិស្សបានសម្របខ្លួនទៅតាមគោលការណ៍ណែនាំដ៏តឹងរ៉ឹងសម្រាប់ការប្រឡងរបស់ក្រសួងអប់រំ យុវជននិងកីឡា។ ទោះជាយ៉ាងណា អត្រាទាំងនេះនៅតែមានកម្រិតខ្ពស់ ព្រោះថាក្នុងចំណោមសិស្ស ១០ មាន ៣ នាក់ដែលបានបោះបង់ការសិក្សាមុនចប់ថ្នាក់ទី១២ ឬ មិនចូលរួមនៅក្នុងការប្រឡងថ្នាក់ជាតិ (សូមមើលរូបភាពទី១)។ ចំណុចនេះបណ្តាលមកពីកត្តាផ្សេងៗ ដូចជា សាលានៅឆ្ងាយពីផ្ទះ និងកង្វះគ្រូដែលមានគុណវុឌ្ឍិ សៀវភៅសិក្សាគោល វិធីសាស្រ្តបង្រៀន និងអាហារូបករណ៍។ ការឆាប់ចាកចេញពីសាលារៀនមានអត្រាខ្ពស់នៅតំបន់ជនបទ ព្រោះសិស្សត្រូវធ្វើការរកប្រាក់ចំណូល និងជួយគ្រួសារពួកគេ។

ដូចការកត់សម្គាល់កន្លងមក អត្រាឡើងថ្នាក់នៅមធ្យមសិក្សាសម្រាប់សិស្សស្រី ច្រើនតែមានកម្រិតខ្ពស់ជាងសិស្សប្រុស គឺដោយសារសិស្សប្រុសឆាប់ចាកចេញពីសាលារៀនជាងសិស្សស្រីសម្រាប់ថ្នាក់ពីទី៧-១២។ បញ្ហានេះ ត្រូវដោះស្រាយដោយប្រើប្រព័ន្ធរលឹកជាមុន (ការពិនិត្យតាមដានការសិក្សារបស់សិស្ស ការកំណត់អត្តសញ្ញាណសិស្សដែលប្រឈមនឹងហានិភ័យ និងការផ្តល់ការគាំទ្របន្ថែម ដូចជា ថ្នាក់បំប៉ន និងអាហារូបករណ៍) និងកម្មវិធីផ្តល់ប្រឹក្សាអាជីព។

---

[40] Footnote 6, p. 17.

[41] MOEYS. 2019a. *Education Management Information System (EMIS),* 2018–2019. Phnom Penh.

[42] កាលពីឆ្នាំសិក្សា២០១៣-២០១៤ "ការរឹតបន្តឹង" មណ្ឌលប្រឡងថ្នាក់ទី ១២ ទូទាំងប្រទេស ត្រូវបានដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលុបបំបាត់ការលួចចម្លងរបស់សិស្ស និងការសមគំនិតគ្នារបស់គ្រូ គ្រួសារ និងមិត្ត ដើម្បីឱ្យសិស្សទទួលបានលទ្ធផលប្រឡងចុងក្រោយល្អបំផុត។ វិធានការត្រួតពិនិត្យតឹងរ៉ឹងដែលត្រូវបានអនុវត្តនេះ នាំឱ្យមានបេក្ខជនមិនដល់ ២០% តែប៉ុណ្ណោះ ដែលប្រឡងជាប់ ដែលនាំឱ្យមានការភ្ញាក់ផ្អើលទូទាំងប្រទេស។ ទោះបីជារាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យមានការប្រឡងលើកទី២ ប៉ុន្មានខែក្រោយក៏ដោយ អត្រាអ្នកប្រឡងជាប់ គឺនៅតែមានកម្រិតទាប (៣៤,៤%) ជាមួយនឹងអត្រាឆាប់ចាកចេញពីសាលារៀន ៥៥,២%។ ក្នុងរយៈពេលចាប់តាំងពីពេលដែលវិធានការរឹងបន្តឹងការប្រឡងថ្មីត្រូវបានដាក់ឱ្យអនុវត្តរួចមក អត្រាឡើងថ្នាក់គិតជាមធ្យមទូទាំងប្រទេសបានកើនឡើងជាបណ្តើរៗ (៦៨% ក្នុងឆ្នាំ ២០១៩) ដោយសារតែសិស្សប្រឹងរៀនជាងមុន និងចូលរួមកាន់តែសកម្មនៅក្នុងការសិក្សា។

រូបភាពទី ៩៖ អត្រានៃការឆាប់ចាកចេញពីសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ ឆ្នាំ២០១៣-២០១៩



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ២០១៣-២០១៩

រូបភាពទី ១០៖ អត្រានៃការឆាប់ចាកចេញពីសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០១៣-២០១៩



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ២០១៣-២០១៩

៣-៥. ការចូលរួមដោយគ្មានសមធម៌រវាងក្មេងប្រុស និងក្មេងស្រីនៅគ្រប់កម្រិតសិក្សា

គម្លាតយេនឌ័រនៅមធ្យមសិក្សាមានកម្រិតគួរឱ្យកត់សម្គាល់ និងកំពុងបន្តកើនឡើង រីឯលទ្ធផលសិក្សាសិស្សស្រីខ្ពស់ជាងសិស្សប្រុសនៅមធ្យមសិក្សា និងការវាយតម្លៃថ្នាក់ជាតិ។ ចំណុចនេះ គឺជានិន្នាការដែលអាចនាំឱ្យមានបញ្ហាសង្គម និងសេដ្ឋកិច្ចនៅពេលកាន់តែមានការកើនឡើងនូវចំនួនបុរសដែលមានឱកាសតិចតួចនៅក្នុងសង្គម។ សន្ទស្សន៍យុគភាពយេនឌ័របង្ហាញពីនិន្នាការលម្អៀងទៅរកសិស្សស្រីសម្រាប់ការអប់រំនៅកម្រិតមធ្យមសិក្សា។ ខណៈដែលនៅបឋមសិក្សា ដំបូងឡើយសន្ទស្សន៍យុគភាពយេនឌ័រលម្អៀងទៅរកសិស្សប្រុស និងខិតជិត ១,០ ត្រឹមថ្នាក់ទី៦ តែនៅពេលដែលសិស្សទាំងនេះបន្តការសិក្សានៅសាលាមធ្យមសិក្សា សន្ទស្សន៍នេះលម្អៀងទៅរកសិស្សស្រីវិញ។ រូបភាពទី៩ និងទី១០ បង្ហាញពីនិន្នាការនេះយ៉ាងជាក់ច្បាស់ ព្រោះថាសិស្សប្រុសច្រើនតែធាប់ចាកចេញពីសាលារៀនជាងសិស្សស្រី ខណៈពេលដែលរូបភាពទី១១ បង្ហាញពីសន្ទស្សន៍យុគភាពយេនឌ័រផ្សេងៗគ្នានៅតាមបណ្ដាខេត្តផ្សេងគ្នា។ សន្ទស្សន៍យុគភាពយេនឌ័រ មានសមធម៌កាន់តែច្រើនចំពោះសាលាមធ្យមសិក្សាក្នុងទីក្រុង ដោយមានចំនួនសិស្សស្រីចូលរៀនច្រើនខ្លាំងជាងនៅសាលាមធ្យមសិក្សាក្នុងតំបន់ជនបទ។ ប្រការគួរឱ្យចាប់អារម្មណ៍ គឺនៅរាជធានីភ្នំពេញ ការចូលរៀនរបស់សិស្សស្រីនៅមធ្យមសិក្សាទុតិយភូមិតិចជាង បើធៀបនឹងខេត្តដទៃទៀត។

[43] Footnote 17.

ជារួម នៅលើសកលលោក ជោគជ័យក្នុងការអប់រំរបស់សិស្សស្រីនៅក្នុងទសវត្សរ៍ចុងក្រោយនេះ មិនមែនកើតឡើងដោយសារសិស្សប្រុសទទួលបានជោគជ័យតិច ផ្ទុយមកវិញ ជោគជ័យរបស់សិស្សប្រុសក៏មិនមែនកើតឡើង ដោយសារតែសិស្សស្រីទទួលបានជោគជ័យតិចដែរ។ លទ្ធផលនៃការអប់រំ មិនមែនជាការបូកបញ្ចូលគ្នាស្មើសូន្យនោះទេ ពោលគឺ មិនមែនក្រុមមួយទទួលលទ្ធផល ហើយក្រុមមួយទៀតត្រូវបាត់បង់នោះទេ។ ជាក់ស្តែង លទ្ធផលសម្រេចបានដោយសិស្សស្រី និងសិស្សប្រុសមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នា។ នៅក្នុងប្រព័ន្ធអប់រំដែលគ្រប់គ្រងបានល្អ សិស្សស្រីចូលរៀនទទួលបានលទ្ធផលល្អប្រសើរ ហើយជារឿយៗសិស្សប្រុសក៏ទទួលបានលទ្ធផលល្អប្រសើរដូចគ្នាផងដែរ។[44]

រូបភាពទី ១១៖ យុគភាពយេនឌ័រនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា (បែងចែកតាមខេត្ត) ឆ្នាំសិក្សា ២០១៩-២០២០



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ២០១៩-២០២០

ការសម្រេចបាននូវយុគភាពយេនឌ័រ គឺគ្រាន់តែជាជំហានមួយប៉ុណ្ណោះ ដើម្បីសម្រេចបានសមភាពយេនឌ័រក្នុងវិស័យអប់រំទាំងមូល។ គេចាំបាច់ត្រូវចាត់ទុកថាកត្តាសមភាពយេនឌ័រក្នុងការអប់រំ គឺជាសិទ្ធិទទួលបានការអប់រំ (ចូលរៀន និងចូលរួមក្នុងការសិក្សា) ក៏ដូចជាសិទ្ធិក្នុងការអប់រំ (ការគិតគូរអំពីយេនឌ័របរិយាកាសអប់រំ ដំណើរការ និងលទ្ធផល) និងសិទ្ធិតាមរយៈការអប់រំ (លទ្ធផលនៃការអប់រំប្រកបអត្ថន័យ ដែលផ្សារភ្ជាប់សមភាពក្នុងការអប់រំជាមួយនឹងដំណើរការយុត្តិធម៌យេនឌ័រទូទៅ)[45]។ គោលដៅនេះ គួរប្រើគោលវិធីដែលមានតុល្យភាពក្នុងការសម្រេចបានការចូលរួមប្រកបដោយសមធម៌រវាងសិស្សប្រុស និងសិស្សស្រី ក្នុងការអប់រំកម្រិតមធ្យមសិក្សា។

៣-៦. ចំណុចខ្វះខាតក្នុងការអប់រំ និងបណ្តុះបណ្តាលគ្រូបង្រៀន

ការសិក្សានិងរបាយការណ៍នានារបស់ក្រសួងអប់រំយុវជននិងកីឡានិងដៃគូអភិវឌ្ឍបានបង្ហាញឱ្យឃើញបញ្ហាជាច្រើនចំពោះការអប់រំ និងបណ្តុះបណ្តាលគ្រូបង្រៀន។[46] បញ្ហាទាំងនេះ ជាអាទិ៍មាន ៖

- សិស្សបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាដោយមានលទ្ធផលសិក្សាខ្ពស់ច្រើនតែមិនចង់ចាប់យកអាជីពជាគ្រូបង្រៀនឡើយ ផ្ទុយទៅវិញពួកគេនិយមស្វែងរកអាជីពផ្សេងៗ ទៀត។

---

[44] UNESCO. (2019). *Global Education Mentoring Gender Report: Building bridges for gender equality.* Washington DC: UNESCO and United Nations Girls Education Initiative.
[45] R. Subrahmanian. 2003. Gender Equality in Education. “Paper commissioned for the EFA Global Monitoring Report 2003/4, The Leap to Equality”. Accessed from https://unesdoc.unesco.org/ark:/48223/pf0000146983, 12 May 2020.
[46] M. Walsh. 2020. *Teacher Education: An overview to inform the CAMSEB 2030.* Phnom Penh: Asian Development Bank.

- និស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យដាក់ពាក្យចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូសម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ ជាជាងកម្រិតបឋមសិក្សា ឬ មធ្យមសិក្សាបឋមភូមិ។
- ស្តង់ដានៃកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូ មានកម្រិតទាបនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំ ខ្វះលទ្ធផលនៃការរៀនសូត្រដែលមានប្រសិទ្ធភាព ។
- ការធ្វើកម្មសិក្សាពុំមានការសម្របសម្រួលឱ្យបានល្អ ហើយការចុះកម្មសិក្សាក៏ពុំបានផ្តល់នូវបទពិសោធន៍រៀនសូត្រដ៏មានតម្លៃសម្រាប់គរុសិស្សនោះដែរ។
- ចំណេះដឹង និងជំនាញវិជ្ជាជីវៈរបស់គ្រូឧទ្ទេសនៅមានកម្រិត។

គ្រឹះស្ថានអប់រំគ្រូបង្រៀន ច្រើនតែយកនិស្សិតបញ្ចប់ការសិក្សានៅក្នុងគ្រឹះស្ថានរបស់ខ្លួន ដែលមាននិទ្ទេសខ្ពស់ឱ្យបំពេញការងារក្នុងគ្រឹះស្ថាន និងបំពេញតួនាទីជាសាស្ត្រាចារ្យ(គ្រូឧទ្ទេស) បើទោះជាពួកគេពុំមានបទពិសោធន៍បង្រៀនផ្ទាល់ក្នុងថ្នាក់រៀនក្នុងរយៈពេលវែងមួយក៏ដោយ។ គ្រូឧទ្ទេសចេញថ្មី រួមទាំងគ្រូឧទ្ទេសចាស់ៗ នៅខ្វះការយល់ដឹងអំពីបរិបទនៃការអប់រំនៅកម្រិតមធ្យមសិក្សានាពេលបច្ចុប្បន្ន។ យុទ្ធសាស្ត្រជ្រើសរើសគ្រូឧទ្ទេសបែបនេះ បង្កផលប៉ះពាល់ជាអវិជ្ជមាន មិនត្រឹមតែលើគុណភាពនៃការបង្រៀននិងរៀននៅតាមគ្រឹះស្ថានអប់រំគ្រូ ថែមទាំងប៉ះពាល់ដល់សុចរិតភាព និងភាពឆ្លើយតបនៃកម្មវិធីបណ្តុះបណ្តាលគ្រូ និងក្នុងក្រសែភ្នែកអ្នកដែលប្រកបវិជ្ជាជីវៈនេះផងដែរ។

របាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានផ្សព្វផ្សាយពីឆ្នាំ ២០១៦ បង្ហាញឱ្យឃើញបញ្ហាជាច្រើនជុំវិញគ្រឹះស្ថានអប់រំគ្រូនៅសាលាគរុកោសល្យ ដែលជាកន្លែងផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ។[47] ចក្ខុវិស័យ និងគោលដៅសម្រាប់ការបណ្តុះបណ្តាលគ្រូ ដែលដាក់ចេញដោយនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ កាលពីច្រើនឆ្នាំកន្លងមក មិនសមស្របទៅតាមតម្រូវការនៃការអប់រំនាពេលបច្ចុប្បន្ន។ គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រូ ទំនងជាខ្វះគុណវុឌ្ឍិ ឬ បទពិសោធន៍ពាក់ព័ន្ធ មុនពេលដែលត្រូវបានតែងតាំង និងឱ្យបំពេញការងារក្នុងបរិបទនៃ "ការធ្វើសេចក្តីសម្រេចចិត្តពីលើមកក្រោម" និងការជួបឧបសគ្គផ្នែកថវិកា/ធនធាន។ ចំពោះគ្រូឧទ្ទេសវិញ ដូចលើកឡើងពីខាងលើ គឺនៅខ្វះបទពិសោធន៍បង្រៀនប្រកបដោយគុណភាពក្នុងថ្នាក់រៀនផ្ទាល់ និងពុំបានធ្វើបច្ចុប្បន្នកម្មការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន ហើយជារឿយៗ ត្រូវបង្រៀនមុខវិជ្ជាក្រៅពីមុខវិជ្ជាឯកទេសរបស់ខ្លួន។ កម្មវិធីបណ្តុះបណ្តាលគ្រូ ច្រើនតែផ្តោតលើការធ្វើកិច្ចតែងការបង្រៀនការគ្រប់គ្រងថ្នាក់រៀន និងវាយតម្លៃសិស្ស ដែលទាំងនេះចេញពីទស្សនៈវិស័យបែបគ្រូមជ្ឈមណ្ឌល។ បណ្ណាល័យ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ និងកន្លែងស្រាវជ្រាវ មានតិចតួចប៉ុណ្ណោះនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដែលជាហេតុធ្វើឱ្យគរុសិស្សទទួលបានបទពិសោធន៍តិចតួចបំផុតសម្រាប់ការបង្រៀនក្នុងថ្នាក់រៀនជាក់ស្តែង និងការស្រាវជ្រាវ។ អន្តេវាសិកដ្ឋាននៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ត្រូវបានវាយតម្លៃថា មានកម្រិតខ្សោយខ្លាំងសម្រាប់គរុសិស្ស ដោយសារតែបន្ទប់គេង និងបន្ទប់ទឹកត្រូវប្រើប្រាស់រួមគ្នាដោយគរុសិស្សជាច្រើននាក់ មានគ្រឿងសង្ហារឹមតិចតួច និងមានអគ្គិសនីប្រើប្រាស់មានកំណត់។ បញ្ហាហិរញ្ញវត្ថុនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កើតឡើងដោយសារការគ្រប់គ្រងបែបមជ្ឈការពីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ និងការខ្វះថវិកាឱ្យបានគ្រប់គ្រាន់។ ដំណើរការធានាគុណភាពផ្ទៃក្នុងក៏នៅខ្វះខាតតាមគ្រឹះស្ថានអប់រំគ្រូផងដែរ ដែលធ្វើឱ្យគេកាន់តែជួបការលំបាកក្នុងការធ្វើការកែលម្អនានា។

---

[47] S. Chhinh et al. 2016. *Teacher Training Center Capacity Assessment: The Case of Phnom Penh and Battambang Regional Teacher Training Centers.* Phnom Penh: Education Research Council.

ការសាងសង់ និងការដាក់ឱ្យដំណើរការវិទ្យាស្ថានគរុកោសល្យថ្មីចំនួនពីរ (រាជធានីភ្នំពេញ និងខេត្តបាត់ដំបង) ក្រោមការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) និងយូនីសេហ្វ គឺជាការឆ្លើយតបចំពោះបញ្ហាដែលត្រូវបានលើកឡើងក្នុងឯកសារផែនទីបង្ហាញផ្លូវនេះ ក៏ដូចជារបាយការណ៍ផ្សេងទៀត។[48] បច្ចុប្បន្ន វិទ្យាស្ថានគរុកោសល្យផ្តល់វគ្គបណ្តុះបណ្តាលរយៈពេល ៤ ឆ្នាំ (១២+៤) សម្រាប់ជំនាញអប់រំ ដើម្បីបំពេញបន្ថែមលើកម្មវិធីអប់រំគ្រូកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ១២+២ ដែលមានស្រាប់។ លើសពីនេះ គម្រោង STEPCam រវាងក្រសួងអប់រំ យុវជន និងកីឡា និងមូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំទី៣ (GPE3) ដោយមានការគាំទ្រពីយូណេស្កូ និងយូនីសេហ្វ ធ្វើការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវន្តនានានៅតាមមជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគចំនួន ៤ ផ្សេងទៀត។[49] GPE3 និងគម្រោងកែលម្អការអប់រំនៅឧត្តមសិក្សាទី២ ក៏កំពុងគាំទ្រដល់ការបង្កើនសមត្ថភាពរបស់គ្រូមធ្យមសិក្សា សំដៅលើកកម្ពស់គុណវុឌ្ឍិវិជ្ជាជីវៈរបស់ពួកគេផងដែរ។

កម្មវិធីបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ធ្វើឡើងនៅវិទ្យាស្ថានជាតិអប់រំសម្រាប់និស្សិត ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ។ ការសិក្សាមួយដែលធ្វើឡើងដោយវិទ្យាស្ថានជាតិអប់រំនៃប្រទេសសិង្ហបុរី សម្រាប់ក្រសួងអប់រំ យុវជន និងកីឡាកាលពីឆ្នាំ ២០១៩ បានលើកឡើងពីបញ្ហាប្រឈមជាច្រើនដែលកំពុងទទួលបានការឆ្លើយតប តាមរយៈកម្មវិធីអភិវឌ្ឍវិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិ (USESDP) ទី១ និង ទី២ របស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការសហការជាមួយនឹងសង្គមស៊ីវិល និងវិទ្យាស្ថានជាតិអប់រំនៃប្រទេសសិង្ហបូរី។ គិតត្រឹមឆ្នាំសិក្សា ២០១៧-២០១៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារនានាកំពុងស្ថិតនៅក្នុងសភាពទទួលរងការខូចខាត គ្រូឧទ្ទេសហាក់ដូចជាមានការប្តេជ្ញាចិត្តទាបក្នុងការទទួលខុសត្រូវចំពោះការបង្រៀននិងស្រាវជ្រាវរបស់ពួកគេ ហើយកម្មវិធីសិក្សា ការបង្រៀន និងវង្វាយតម្លៃពុំបានបំពេញទៅតាមស្តង់ដា ឬលក្ខខណ្ឌតម្រូវនាពេលបច្ចុប្បន្នឡើយ ដែលទាំងអស់នេះសុទ្ធតែជាបញ្ហាប្រឈមពាក់ព័ន្ធនឹងការដឹកនាំ និងគ្រប់គ្រងការងារអប់រំប្រកបដោយប្រសិទ្ធភាព។[50] អ្នកពាក់ព័ន្ធជាច្រើន ក្នុងនោះ មានទាំងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍផង បានលើកឡើងពីសារៈសំខាន់នៃការបង្កើតបរិយាកាសសិក្សាមួយ ដែលគ្រប់គ្នាអាចមានមោទកភាព ពោលគឺមជ្ឈមណ្ឌលឧត្តមភាព ដែលនឹងរួមចំណែកដ៏សំខាន់ដល់ការលើកកម្ពស់អនុវិស័យមធ្យមសិក្សានៅកម្ពុជា។

៣-៧. ការពង្រាយគ្រូ – “បញ្ហាលើស និងកង្វះគ្រូ”

របាយការណ៍ការសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡាកាលពីឆ្នាំ ២០១៨ បានគូសបញ្ជាក់ថា ការពង្រាយគ្រូ គឺជាបញ្ហាដែលបន្តកើតមាន និងជាសម្ពាធមកលើធនធានហិរញ្ញវត្ថុ។[51] ការសិក្សានេះបានពិនិត្យឃើញថា ទិន្នន័យអំពីគ្រូលើស និងខ្វះគ្រូ គឺជាទិន្នន័យពុំទាន់សុក្រឹត ដែលនាំឱ្យមានការពង្រាយបុគ្គលិកតាមសាលារៀនមានភាពមិនស្មើគ្នា។ គ្រូដែលត្រូវបានសាកសួរនៅក្នុងការសិក្សាស្រាវជ្រាវនេះមិនមានឆន្ទៈផ្ទេរទៅសាលារៀនខ្វះគ្រូឡើយ ព្រោះថាពួកគេ (១) ធ្លាប់ធ្វើការនៅក្នុងសាលានេះរាប់ទសវត្សរ៍មកហើយ ដោយមានគ្រួសារ និងមិត្តភក្តិនៅជិតគ្នា (២) មិនចង់ធ្វើការនៅតាមសាលារៀនជនបទ និងដាច់ស្រយាល ដែលមានសម្ភាររូបវន្តខ្សត់ខ្សោយ បញ្ហាសន្តិសុខ និងបញ្ហាថែទាំសុខភាព (៣) គិតថាពួកគេមិនសូវមានឱកាសបង្រៀនគួរ និង (៤) ស្រមៃឃើញថាបន្ទុកការងារធ្ងន់ធ្ងរ ជាពិសេសនៅក្នុងថ្នាក់រៀនដែលមានសិស្សច្រើនកកកុញ និងខ្វះគ្រូ។ ការសិក្សានេះ បានរកឃើញនូវការយល់ឃើញខុសៗ គ្នាគួរឱ្យចាប់អារម្មណ៍មួយចំនួនដូចជា ពុំមានឆន្ទៈផ្ទេរទៅសាលា

[48] MOEYS. 2019d. *Teacher Education Subsector Analysis Report.* Phnom Penh: Japan International Cooperation Agency.
[49] *កម្មវិធីពង្រឹងការអប់រំគ្រូ នៅកម្ពុជា* គឺជាកម្មវិធីដែលក្រសួងអប់រំ យុវជន និងកីឡា កំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ ដើម្បីលើកកម្ពស់លទ្ធផលអក្ខរកម្ម និងលេខនព្វន្តថ្នាក់ដំបូង តាមរយៈការបណ្តុះបណ្តាលគ្រូជាលក្ខណៈយុទ្ធសាស្ត្រក្រោមការគាំទ្រពីកម្មវិធីភាពភាពជាដៃគូសកលសម្រាប់ការអប់រំ និងមូលនិធិអភិវឌ្ឍន៍សមត្ថភាពសម្រាប់វិស័យអប់រំ ដែលគ្រប់គ្រងដោយយូនីសេហ្វ និងយូណេស្កូ។
[50] NIE-Singapore. 2017. *A Report of the Needs Analysis Study of the National Institute of Education (NIE) Cambodia.* Phnom Penh.
[51] F. No and S. Nguon. 2018. *Teacher Management and Redeployment: Practical Ways Forward.* Phnom Penh: MOEYS Education Research Council.

ខ្វះគ្រូឡើយ ហើយមួយចំនួនគំរាមលាលែងពីការងារ ប្រសិនបើពួកគេត្រូវបានបង្ខំឱ្យផ្ទេរទៅសាលាទាំងនោះ។ ទោះជាយ៉ាងណានាយកសាលា បុគ្គលិក ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត គិតថា បញ្ហាពង្រាយគ្រូនេះគួរដោះស្រាយតាមរយៈការប្តេជ្ញាចិត្តខ្ពស់ពីរាជរដ្ឋាភិបាល។

ជារៀងរាល់ឆ្នាំ ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗជាច្រើនលានដុល្លារត្រូវបានផ្តល់ទៅគ្រូនៅតាមសាលាលើសគ្រូ ដែលក្នុងចំណោមគ្រូទាំងនោះ មួយចំនួនគឺមកបង្រៀនតែពាក់កណ្តាលម៉ោង ឬ ធ្វើការនៅការិយាល័យ ដាក់ច្បាប់ឈឺ ឬមិនមកកន្លែងធ្វើការជាដើម។ ថវិកាទាំងនេះ គឺជាថវិកាដែលអាចប្រើប្រាស់កាន់តែមានប្រសិទ្ធភាពនៅក្នុងវិស័យអប់រំ ដើម្បីធ្វើឱ្យប្រព័ន្ធទាំងមូលកាន់តែមានភាពល្អប្រសើរ។ ស្ថានភាពបែបនេះបន្តកើតមាន ខណៈពេលដែលសាលារៀនជាច្រើននៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលកំពុងជួបការលំបាកក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាព ព្រោះមានគ្រូបង្រៀនដែលមានសមត្ថភាពតិចតួច ដែលជាកត្តាជំរុញឱ្យមានការប្រើគ្រូជាប់កិច្ចសន្យា ប្រការនេះ ពុំត្រឹមតែមិនបានជួយដោះស្រាយបញ្ហា ប៉ុន្តែបែរជាធ្វើឱ្យបញ្ហានេះរឹតតែធ្ងន់ធ្ងរទៅទៀត។[52]

របាយការណ៍ PISA-D ឆ្នាំ ២០១៨ បានបង្ហាញថា ការវិនិយោគលើវិស័យអប់រំនៅកម្ពុជាមានកម្រិតទាបបំផុតធៀបនឹងប្រទេសដែលចូលរួមក្នុងកម្មវិធី PISA-D ដូចដែលបានឆ្លុះបញ្ចាំងដាក់ស្តែងពីផលធៀបសិស្ស-គ្រូខ្ពស់ ការលំបាកក្នុងការទាក់ទាញគ្រូដែលមានសមត្ថភាពឱ្យមកបង្រៀន ហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារបរិក្ខានៅក្នុងសាលារៀនជាទូទៅនៅមានសភាពទន់ខ្សោយ និងជាពិសេស ការចំណាយទាបលើសិស្សម្នាក់ៗចាប់តាំងពីអាយុ ៦ ដល់ ១៥ ឆ្នាំ។ ការបែងចែកធនធានមនុស្សហាក់ដូចជាលម្អៀងទៅសាលារៀនស្ថិតក្នុងតំបន់ដែលមានស្ថានភាពសង្គម-សេដ្ឋកិច្ចល្អប្រសើរ និងក្នុងទីក្រុងជាដើម។ សាលារៀននៅតំបន់ជនបទ ច្រើនតែខ្វះបុគ្គលិក ខណៈពេលដែលមានការសង្កេតឃើញយ៉ាងច្បាស់ពីការលើសចំនួនគ្រូនៅក្នុងតំបន់ប្រជុំជនជាពិសេសនៅក្នុងទីក្រុងភ្នំពេញ។ បច្ចុប្បន្ននេះកំពុងមានការប្រឹងប្រែងដោះស្រាយឆ្លើយតបចំពោះបញ្ហាខ្វះគ្រូ និងលើសគ្រូនៅតាមសាលារៀននានា។ បច្ចុប្បន្ន គរុសិស្សដែលបញ្ចប់ការសិក្សាពីវិទ្យាស្ថានគរុកោសល្យ ត្រូវបានតម្រូវឱ្យជ្រើសរើសយកប៉ុស្តិ៍ការងារដែលមាននៅតាមសាលា ដែលខ្វះគ្រូ តែត្រូវមានការឯកភាពចុងក្រោយពីនាយកសាលា។ ដំណើរការបែបនេះអាចប្រើរយៈពេលវែង ព្រោះពាក់ព័ន្ធនឹងការចូលនិវត្តន៍ ការលាលែងពីមុខងារ ឬបើអាចគឺគិតគូរជាកញ្ចប់ និងផ្លាស់ប្តូរជាដំណាក់ៗទៅតាមជំនាន់។

៣-៨. ការធ្វើវិក្រឹតការគ្រូបង្រៀន និងនាយកសាលា

ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (កន្លងមកហៅថា វិក្រឹតការគ្រូ) ពុំមានការសម្របសម្រួលឱ្យបានល្អនៅឡើយ ហើយខ្វះប្រព័ន្ធសម្រាប់កត់ត្រាបទពិសោធន៍ការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់បុគ្គលិកអប់រំ ដោយសារមានការអនុវត្ត ក្នុងទម្រង់ជាកម្មវិធីតូចៗជាច្រើន និងបែកខ្ញែកដាច់ឡែកពីគ្នាទៅតាមថវិកាគាំទ្រពីក្រសួង និងការផ្តល់ធនធានពីខាងក្រៅ។ សកម្មភាពវិក្រឹតការគ្រូជាច្រើនធ្វើឡើងទៅតាមគម្រោងប្រាក់កម្ចី និងជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍។[53] ជារឿយៗ លទ្ធផល នៃសកម្មភាពវិក្រឹត្យការ មិនបានដឹង ដោយសារមានការតាមដាន ឬ វាយតម្លៃតិចតួចលើការយកចំណេះដឹង និងជំនាញថ្មីៗទាំងនេះទៅអនុវត្ត។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ច្រើនតែធ្វើឡើងក្នុងរយៈពេលខ្លី ទម្រង់ជា "ការបណ្តុះបណ្តាល"

---

[52] គ្រូជាប់កិច្ចសន្យាច្រើនតែជាគ្រូដែលមាន ឬមិនសូវមានគុណវុឌ្ឍិ ដែលត្រូវបានជួលឱ្យបង្រៀនបណ្តោះអាសន្នដោយផ្តល់អត្រាប្រាក់ឈ្នួលទាប ដើម្បីដោះស្រាយភ្លាមៗលើបញ្ហាខ្វះគ្រូក្នុងសាលារៀននៅតាមមូលដ្ឋាន។
[53] ការស្រាវជ្រាវដែលធ្វើឡើងដោយ Cameo Education (Observic software) បង្ហាញថាការផ្លាស់ប្តូរឥរិយាបថរបស់គ្រូត្រឹមតែ ១០% ប៉ុណ្ណោះ ដែលអាចកើតចេញពីសិក្ខាសាលា ខណៈពេលដែលការរៀនសូត្ររបស់គ្រូ និងការផ្លាស់ប្តូរការអនុវត្ត ៧០% កើតចេញពីបទពិសោធន៍អនុវត្តផ្ទាល់ ពេលជួបប្រទះនឹងបញ្ហាប្រឈមពាក់ព័ន្ធនឹងការងារ និងពេលទទួលបានព័ត៌មានត្រឡប់ពីគ្រូណែនាំ និងអ្នកគ្រប់គ្រងរបស់ពួកគេ។

តែម្តងចប់ដែលកម្រភ្ជាប់ទំនាក់ទំនងជាមួយនឹងគន្លងអាជីព (ការដំឡើងឋានៈ ផ្ទេរការងារ) បៀវត្ស រង្វាន់ ឬ អត្ថប្រយោជន៍វិជ្ជាជីវៈដទៃទៀត។[54] ជាទូទៅ គ្រូបន្ទុកថ្នាក់ទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលមានគុណភាព ដូចជា ការបង្វឹកនៅតាមសាលារៀន ដើម្បីជួយពួកគេក្នុងការលើកកម្ពស់លទ្ធផលដែលការរៀន និងការបង្រៀននៅតាមសាលារៀនរបស់ពួកគេ។

គ្រូម្នាក់មានប្រសាសន៍ថា៖

"ខ្ញុំមិនដឹងពីគ្រូផ្សេងទៀតនោះឡើយ ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំចង់ឱ្យគេសង្កេតមើលការបង្រៀនរបស់ខ្ញុំឱ្យបានញឹកញាប់។ ប្រសិនបើពុំមានការណែនាំ គាំទ្រ និងការបង្វឹកជាប់ជាប្រចាំរបស់ខ្ញុំនោះទេ ខ្ញុំនឹងមិនអាចកែលម្អការបង្រៀនរបស់ខ្ញុំឡើយ ហើយយូរៗទៅ ខ្ញុំប្រាកដជាបាត់បង់ទំនុកចិត្តលើខ្លួនឯងជាមិនខាន"។[55]

៣-៩. លទ្ធផលសិក្សាមុខវិជ្ជាស្នែមនៅកម្រិតមធ្យមសិក្សា

ចំនួនសិស្សដែលជ្រើសរើសយកវិទ្យាសាស្ត្រសង្គមនៅតាមសាលាមធ្យមសិក្សាទុតិយភូមិ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពី ២ ៤៩២ នាក់ ក្នុងឆ្នាំ ២០១៤ ដល់ ៤៥ ០០២ ក្នុងឆ្នាំ ២០១៨ ។ ដោយឡែក សិស្សជ្រើសយកមុខវិជ្ជាវិទ្យាសាស្ត្រពិត នៅទ្រឹង គឺប្រមាណ ៣០ ០០០ នាក់។[56] ក្នុងរយៈពេលបីឆ្នាំសិក្សាចុងក្រោយនេះ គឺឆ្នាំសិក្សា២០១៦-១៧ ដល់ឆ្នាំសិក្សា២០១៨-១៩ សិស្សដែលជ្រើសរើសបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម មានអត្រាប្រឡងជាប់ថ្នាក់ទី ១២ គិតជាមធ្យមជាង ៨០% ខណៈពេលដែលអត្រានៃសិស្សជ្រើសរើសយកមុខវិជ្ជាវិទ្យាសាស្ត្រនៅបន្តទ្រឹងជាង ៥០%។ ការវាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិ ថ្នាក់ទី ១១ កាលពីឆ្នាំ ២០១៨ (ចំនួនសិស្សចូលរួម ៦ ៦៤១ នាក់) រំលេចឱ្យឃើញពីលទ្ធផលសិក្សាទាបទាំងបណ្តុំមុខវិទ្យាវិទ្យាសាស្ត្រពិត និងបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។ លទ្ធផលគិតជាមធ្យមសម្រាប់មុខវិជ្ជាភាសាខ្មែរគឺ ៥៧,៧% (វិទ្យាសាស្ត្រពិត) និង ៥៤,៤% (វិទ្យាសាស្ត្រសង្គម) ឯលទ្ធផលសម្រាប់គណិតវិទ្យាគឺ ៤១,១% (វិទ្យាសាស្ត្រ) និង ២៩% (វិទ្យាសាស្ត្រសង្គម)។ លទ្ធផលសម្រាប់មុខវិជ្ជារូបវិទ្យាគឺ ៣៧% ភាគរយ (វិទ្យាសាស្ត្រ) និង ២៨,២% (វិទ្យាសាស្ត្រសង្គម)។

ការធ្វើផែនការ និងការរៀបចំគម្រោងអប់រំ បានពិនិត្យឃើញការពុំបានផ្សារភ្ជាប់គ្នារវាងសម្ភាររូបវន្តសម្រាប់បម្រើការអប់រំ STEM ដែលមានរួចជាស្រេច ជាមួយនឹងការបង្រៀនក្នុងថ្នាក់រៀន។ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រដែលបំពាក់នៅតាមវិទ្យាល័យធនធានចាប់តាំងពីឆ្នាំ២០១០ ជារឿយៗ គ្រូពុំអាចប្រើប្រាស់បរិក្ខារទាំងនេះក្នុងកម្រិតពេញលេញឡើយ ដោយសារតែការខ្វះការបណ្តុះបណ្តាលលើផ្នែកទ្រឹស្តី និងអនុវត្តផ្ទាល់មុខវិជ្ជាវិទ្យាសាស្ត្រ ក្នុងពេលពួកគេចូលរួមកម្មវិធីអប់រំគ្រូ ហើយមិនមានការផ្គត់ផ្គង់បន្ថែមសម្ភារបន្ទប់ពិសោធន៍ដែលប្រើប្រាស់អស់។ គេសង្កេតឃើញថា គ្រូជាច្រើនតែងលើកឡើងពីភាពចាំបាច់ឱ្យមានថ្នាក់រៀន និងបរិក្ខារវិទ្យាសាស្ត្រដែលទំនើប ប៉ុន្តែជាញឹកញាប់ ពួកគាត់មិនអាចប្រើប្រាស់បរិក្ខារទាំងនេះឱ្យមានប្រសិទ្ធភាពជាមួយនឹងសិស្សនៅកម្រិតមធ្យមសិក្សាបានឡើយ។[57] កត្តាផ្សេងទៀតដែលជះឥទ្ធិពលលើភាពជោគជ័យនៃកម្មវិធី STEM រួមមាន (១)លទ្ធផល សិក្សារបស់សិស្សក្នុងការអប់រំមូលដ្ឋាន មានកម្រិតទាប (២)កង្វះចំណេះដឹងផ្នែកគរុកោសល្យ និងយុទ្ធសាស្ត្របង្រៀនបែបនវានុវត្តន៍ និង(៣)កង្វះការយល់ដឹង និងការតម្រង់ទិសស្តីពីការណែនាំអាជីព និងបំណងប្រាថ្នាក្នុងការសិក្សាសម្រាប់សិស្ស។

---

[54] MOEYS. 2017. *Implementation Framework on Continuous Professional Development for Teachers and School Directors (draft).* Phnom Penh: Royal Government of Cambodia.
[55] MOEYS. 2018c. *Research Report: Third Education Sector Development Program (ESDP III).* Phnom Penh: Education Research Council.
[56] Footnote 44.
[57] Footnote 27.

៣-១០. ការគ្រប់គ្រងតាមសាលារៀន

បញ្ហាប្រឈមចម្បងដែលក្រសួងកំពុងជួបប្រទះ ក្នុងពេលខិតខំជំរុញការអនុវត្តគោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាព នៅតាមសាលាមធ្យមសិក្សា គឺការកសាងសមត្ថភាពនាយកសាលា និងគ្រូបង្រៀនដើម្បីអាចបំពេញមុខនាទីរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។ ការវាយតម្លៃរហ័សមួយដែលធ្វើឡើងកាលពីខែកញ្ញា ឆ្នាំ២០១៩ បានរកឃើញថា ទោះជាបានទទួលការបណ្តុះបណ្តាលអំពីគោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធិភាពរួចហើយ ក៏មាននាយកសាលាជិត ៥០% ពុំអាចកំណត់ពីគោលការណ៍ការគ្រប់គ្រងតាមសាលារៀន ឱ្យបានត្រឹមត្រូវឡើយ ចំណែកគ្រូបង្រៀនមានត្រឹមតែ ៤០% ដែលអាចលើកឡើងត្រឹមត្រូវពីគោលការណ៍ទាំងនេះ។ នាយកសាលាមុនៗ ពុំមានទម្លាប់មានគណនេយ្យភាពចំពោះលទ្ធផលការងាររបស់សាលា ហើយកាន់តែពុំសូវមានគណនេយ្យភាពចំពោះសិស្សលើលទ្ធផលសិក្សារបស់ពួកគេ និងការទាមទារពីសំណាក់មាតាបិតា/អាណាព្យាបាល ដែលប្រាថ្នាចង់បានការសិក្សាដែលមានគុណភាព និងលទ្ធផលល្អ។ ការទាមទារប្រាថ្នាចង់បានរបស់មាតាបិតា/អាណាព្យាបាល បានក្លាយជាមូលហេតុមួយទៀតដែលជំរុញនាយកសាលាមានការស្ទាក់ស្ទើរ ក្នុងការជំរុញលើកទឹកចិត្តឱ្យមាតាបិតា និងសហគមន៍ជុំវិញសាលារៀនចូលរួមនៅក្នុងគណៈកម្មការគ្រប់គ្រងសាលារៀនមានប្រសិទ្ធិភាព ហើយគណៈកម្មការនេះ ក៏ជាធាតុផ្សំមួយដ៏សំខាន់នៃអភិក្រមរបស់គោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាពទាំងមូល។ ការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ ផ្តល់គណនេយ្យភាពយ៉ាងសំខាន់ ហើយនាយកសាលាត្រូវត្រៀមខ្លួនត្រួតពិនិត្យ និងរក្សាតុល្យភាព ដែលផ្តល់ដោយគណៈកម្មការនេះ។ បញ្ហាខាងលើ បានបណ្តាលឱ្យមានការប៉ះពាល់ដល់ទំនុកចិត្តពីសំណាក់សហគមន៍មូលដ្ឋាន ។

សាលាពុំអាចក្លាយជាថ្នាលបណ្តុះបណ្តាលការសិក្សាបានទេ ខណៈដែលគ្រូ និងសិស្សអវត្តមានញឹកញាប់ និងមកសាលាយឺតយ៉ាវ ហើយគ្រូផ្តោតការយកចិត្តទុកដាក់តិចតួចលើការអភិវឌ្ឍវិជ្ជាជីវៈ និងពុំមានដំណោះស្រាយចំពោះបញ្ហាត្រួតថ្នាក់។ ប្រឈមជាមួយបញ្ហាបែបនេះ ចាំបាច់ត្រូវមានប្រព័ន្ធគណនេយ្យភាពមួយដែលរឹងមាំ។[59]

ការប្រឈមនឹងការបន្តខ្វះខាតធនធាន សាលារៀនចាំបាច់ត្រូវដឹកនាំសកម្មភាព និងបង្កើតធនធានឱ្យបានគ្រប់គ្រាន់ដោយខ្លួនឯងក្នុងការដោះស្រាយបញ្ហា។ ក្នុងន័យនេះ សហគមន៍ត្រូវផ្តល់ធនធានបន្ថែម ដើម្បីទ្រទ្រង់សាលា ដែលខ្វះមូលនិធិ។ ដើម្បីសម្រេចគោលដៅនេះ ជាចាំបាច់ត្រូវមានការដឹកនាំប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិតទាំងអស់។ ការសិក្សាមួយធ្វើឡើងដោយក្រសួងកាលពីឆ្នាំ២០១៨បានបង្ហាញថា ដើម្បីពង្រឹងការដឹកនាំតាមសាលារៀន និងដឹកនាំការងារបង្រៀននៅក្នុងសាលារៀន[60] នាយកសាលាត្រូវឆ្លងកាត់កម្មវិធីបំពាក់បំប៉នតម្រង់ទិសមួយដែលមានគុណភាព និងទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ក្នុងអំឡុងពេលបំពេញមុខងារ-អាជីពរបស់ពួកគេ កន្លងមក វិទ្យាស្ថានជាតិអប់រំបានអនុវត្តកម្មវិធីបំពាក់បំប៉ននាយកសាលា។ ប៉ុន្តែបញ្ហាប្រឈមក្នុងការរក្សានិរន្តរភាពកម្មវិធីនេះគឺ ដោយសារការតែងតាំងនាយកសាលាធ្វើឡើងដោយរដ្ឋបាលខេត្ត ដែលអាចនឹងពុំបានកត់សម្គាល់កម្មវិធីបំពាក់បំប៉នសមត្ថភាពខាងលើ ។

---

[58] KAPE. 2019. *Rapid Assessment of Secondary Resource School Network.* Second Upper Secondary Education Sector Development Project. Kampong Cham: Kampuchean Action to Promote Education.
[59] Footnote 6, p. 139.
[60] Footnote 58.

៣-១១. វិទ្យាល័យធនធាន

វិទ្យាល័យធនធានដែលមានមជ្ឈមណ្ឌលធនធាន អាចបំពេញតួនាទីជាសាលារៀនគំរូសម្រាប់សាលាបណ្ដាញ ដែលមានសាលាមធ្យមសិក្សា ៥ ជាសមាជិក ។ ដើម្បីជួយឱ្យគ្រូផ្សារភ្ជាប់ទ្រឹស្ដីជាមួយនឹងការអនុវត្តក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ ក៏ដូចជាសិស្សទទួលបានចំណេះដឹង ឌីជីថល និងលើកកម្ពស់សហគមន៍សិក្សាវិជ្ជាជីវៈក្នុងចំណោមវិទ្យាល័យធនធាន និងសាលារៀនបណ្ដាញមជ្ឈមណ្ឌលធនធានមធ្យមសិក្សានៅទូទាំងប្រទេស ត្រូវបានបង្កើតឡើង ដោយមានបំពាក់បន្ទប់ប្រជុំ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ និងបន្ទប់កុំព្យូទ័រ បណ្ណាល័យ បន្ទប់សោតទស្សន៍ និងការភ្ជាប់អគ្គិសនី និងទឹកស្អាត។ មជ្ឈមណ្ឌលធនធានដែលបានបង្កើតឡើងពុំមែនសម្រាប់តែសាលារៀនដែលមានមជ្ឈមណ្ឌលធនធានប្រើប្រាស់តែឯងនោះទេ សាលារៀនផ្សេងទៀតដែលនៅក្បែរ ឬសាលាបណ្ដាញ ក៏អាចទទួលបានប្រយោជន៍ពីការប្រើប្រាស់មជ្ឈមណ្ឌលធនធានទាំងនេះផងដែរ។

ចាប់តាំងពីឆ្នាំ ២០១០ មជ្ឈមណ្ឌលធនធានទាំង ៣៦ ត្រូវបានបង្កើតឡើងនៅក្នុងសាលាមធ្យមសិក្សា ដែលភាគច្រើនស្ថិតនៅទីរួមខេត្ត និងនៅតាមតំបន់ប្រជុំជនធំៗ ផ្សេងទៀត។ បន្ទាប់ពីឆ្លងកាត់ការលំបាករយៈពេល ១០ ឆ្នាំរួចមក បច្ចុប្បន្នទស្សនទានរបស់វិទ្យាល័យធនធាន/មជ្ឈមណ្ឌលធនធាន បានក្លាយទៅជាកន្លែងបណ្ដាញសាលាមធ្យមសិក្សាស្ថិតក្រោមការគ្រប់គ្រងពីក្រសួង មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងជួយឱ្យសាលាមធ្យមសិក្សាអាចចែករំលែកធនធាន ក្នុងបណ្ដាញរបស់ខ្លួនបានកាន់តែល្អប្រសើរ ទាំងសម្រាប់សាលាមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។

ការសិក្សាវាយតម្លៃសាលាបណ្ដាញក្នុងវិទ្យាល័យធនធានចំនួន១០ កាលពីឆ្នាំ២០១៩ បានរកឃើញនូវបញ្ហាប្រឈមធំៗមួយចំនួន ពាក់ព័ន្ធនឹងការប្រើប្រាស់មជ្ឈមណ្ឌលធនធាន ៖

- គ្រូជាច្រើនមិនដឹងពីរបៀបរបបក្នុងប្រើប្រាស់មជ្ឈមណ្ឌលធនធាន
- គ្រូដឹងពីរបៀបរបបក្នុងការប្រើប្រាស់មជ្ឈមណ្ឌលធនធាន ប៉ុន្តែពួកគេផ្ដោតការយកចិត្តទុកដាក់ប្រើប្រាស់ធនធានទាំងនោះសម្រាប់ការបង្រៀនគួរសិស្សថ្នាក់ទី ១២ ច្រើនជាង
- អ្នកគ្រប់គ្រងសាលារៀនពុំបានដឹងច្បាស់ពីរបៀបថែទាំសម្ភាររូបវន្តទាំងនោះទេ
- ពុំមានការបែងចែកពេលវេលាឱ្យល្អិតល្អន់គ្រប់គ្រាន់នៅក្នុងកាលវិភាគ ដើម្បីធ្វើយ៉ាងណាឱ្យការប្រើប្រាស់សម្ភាររូបវន្តទាំងនេះឱ្យមានប្រសិទ្ធភាព
- ពុំមានសម្ភារៈវត្ថុធាតុដើមគ្រប់គ្រាន់ ដើម្បីឱ្យការប្រើប្រាស់សម្ភាររូបវន្តទាំងនេះឱ្យមានប្រសិទ្ធភាព
- វិទ្យាល័យធនធានមានសិស្សច្រើន (ចន្លោះពី ២០០០-៤០០០ នាក់) ហើយមជ្ឈមណ្ឌលធនធានពុំអាចបំពេញតម្រូវការសិស្សទាំងនោះ ក៏ដូចជាសិស្សដែលមកពីតាមសាលាបណ្ដាញ។[61]

ការវាយតម្លៃតាមដានបន្ត ដែលធ្វើឡើងដោយនាយកដ្ឋានធានាគុណភាពអប់រំ កាលពីឆ្នាំ២០២០ លើសាលាបណ្ដាញនៃវិទ្យាល័យធនធានចំនួន១៦បានរកឃើញថា ការប្រើប្រាស់មជ្ឈមណ្ឌលធនធាននៅពុំទាន់មានប្រសិទ្ធភាពដូចការរំពឹងទុកនោះទេ ហើយគុណភាពនៃការផ្ដល់សេវាអប់រំ នៅពុំបានឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្សនោះទៀត។ ទោះបីគេសង្កេតឃើញថាមុខវិជ្ជាភាសាខ្មែររបស់សិស្សថ្នាក់ទី១១ មានការកើនឡើងនូវលទ្ធផលជារួម១០% តែការវាយតម្លៃថ្នាក់ទី៨ និងថ្នាក់ទី១១ បានរកឃើញថាលទ្ធផលនៃការសិក្សាលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា មានការប្រែប្រួលតិចតួចធៀបនឹងការវាយតម្លៃកាលពីឆ្នាំសិក្សា២០១៧-២០១៨។ ទោះជាយ៉ាងណា របាយការណ៍ខែ កុម្ភៈ ឆ្នាំ ២០២១ បង្ហាញថា ក្រុមសិស្សដែលសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រក្នុងវិទ្យាល័យធនធាន រៀនពូកែជាងសិស្សដែលនៅវិទ្យាល័យធម្មតា ហើយជារួម សិស្សថ្នាក់ទី១២

[61] MOEYS. 2019c. *Rapid Assessment of Secondary Resource School Network*. Second Upper Secondary Education Sector Development Project. Kampong Cham: Kampuchean Action to Promote Education.

ក្នុងវិទ្យាល័យធនធាន ប្រឡងជាប់ថ្នាក់ជាតិច្រើនជាងសិស្សថ្នាក់ទី១២ ធម្មតា។[62] ដើម្បីរក្សាបាននូវវឌ្ឍនភាពទាំងនេះ បណ្តាញវិទ្យាល័យធនធានត្រូវយកចិត្តទុកដាក់បន្ថែមទៀត លើការគ្រប់គ្រងធនធានមនុស្ស បរិក្ខារ និងសម្ភារសម្រាប់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ថវិកា និងធ្វើឱ្យមានសង្គតិភាពនឹងគោលនយោបាយ ស្តង់ដា និងការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។[63]

៣-១២. ការយល់ដឹងរបស់ក្មេងជំទង់អំពីយេនឌ័រ និងផ្លូវភេទ

ការពន្យល់ពីទំនាក់ទំនងផ្លូវភេទ នៅតែជាការរឹតត្បិតនៅក្នុងសង្គម-វប្បធម៌កម្ពុជា ហើយលោកគ្រូ អ្នកគ្រូតែងតែមានអារម្មណ៍លំបាក ក្នុងការពិភាក្សាអំពីបញ្ហាទំនាក់ទំនងផ្លូវភេទជាមួយនឹងកុមារ និងយុវវ័យ ជាពិសេសនៅពេលដែលគ្រូ និងសិស្សមានភេទផ្ទុយគ្នា។[64] ក្នុងបរិបទនេះ ការអប់រំអំពីទំនាក់ទំនងផ្លូវភេទអាចជាមេរៀនដែលពិបាកនឹងបង្រៀន ឬសម្របសម្រួលឱ្យមានការពិភាក្សាក្នុងលក្ខណៈជាចំហរ បើទោះជាគ្រូបង្រៀនមួយចំនួនបានទទួលការបណ្តុះបណ្តាលក៏ដោយ។ ភាសាក៏អាចជាឧបសគ្គមួយផងដែរ ជាពិសេសពាក្យបច្ចេកទេសដែលប្រើក្នុងសៀវភៅសិក្សាគោល ដែលលំបាកពន្យល់ជាភាសាខ្មែរ និង/ឬបកប្រែជាភាសាកំណើតរបស់សិស្ស។ បញ្ហានេះ ពេលខ្លះបានជំរុញឱ្យគ្រូសម្រេចចិត្តរំលងប្រធានបទផ្លូវភេទដែលពិបាក បើទោះជាប្រធានបទនោះមានសារៈសំខាន់ក៏ដោយ។ ជារឿយៗ យុវវ័យពុំសូវបានយល់ដឹងច្បាស់អំពីរឿងទំនាក់ទំនងផ្លូវភេទ ឬទទួលបានការណែនាំអំពីការទទួលខុសត្រូវក្នុងឥរិយាបថផ្លូវភេទរបស់ក្មេងជំទង់ ហើយការមានផ្ទៃពោះរបស់ក្មេងជំទង់គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើនដែលធ្វើឱ្យយុវជនធាប់ចាកចេញពីសាលារៀន។[65] ទន្ទឹមនឹងការកត់សម្គាល់ពីបញ្ហាប្រឈមទាំងនេះ ការអប់រំអំពីផ្លូវភេទ និងសុខភាពបន្តពូជ គឺជា "បំណិនជីវិត" ដែលគួរបញ្ចូលទៅក្នុងការអប់រំសម្រាប់សិស្សមធ្យមសិក្សាម្នាក់ៗ។

៣-១៣. បរិក្ខារទឹកស្អាត និងអនាម័យ និងសុខភាពសាធារណៈ

បច្ចុប្បន្នមិនមានស្តង់ដាសេវាអប្បបរមាសម្រាប់សាលាមធ្យមសិក្សាឡើយ។ ចំណុចនេះជះឥទ្ធិពលអវិជ្ជមានលើលក្ខខណ្ឌតម្រូវ នៃបរិក្ខារទឹកស្អាត និងអនាម័យគ្រប់គ្រាន់នៅគ្រប់សាលារៀន។ ក្នុងឆ្នាំសិក្សា ២០១៨-២០១៩ សាលាមធ្យមសិក្សាបឋមភូមិ ៩១,៣% និងសាលាមធ្យមសិក្សាទុតិយភូមិ ៩៨,១% មានបង្គន់អនាម័យប្រើប្រាស់ ដែលជាវឌ្ឍនភាពមួយដ៏ប្រសើរក្នុងការឆ្ពោះទៅសម្រេចតាមស្តង់ដាអនាម័យបាន១០០%។ បញ្ហាខ្វះទឹកនៅតែបន្តកើតមានឡើងនៅរដូវប្រាំង ហើយបង្គន់មិនអាចប្រើប្រាស់បានដោយសារគ្មានទឹក។ បច្ចុប្បន្ន សាលាមធ្យមសិក្សាបឋមភូមិប្រមាណ ៣៩,៥% និងសាលាមធ្យមសិក្សាទុតិយភូមិ ៤៩% មានបរិក្ខារទឹកស្អាតសម្រាប់ប្រើប្រាស់ ដែលមានន័យថាគ្រឹះស្ថានសិក្សាភាគច្រើននៅពុំទាន់មានទឹកស្អាតប្រើប្រាស់ឡើយ។ ដោយឡែក សាលាមធ្យមសិក្សាបឋមភូមិ ៤១% និងសាលាមធ្យមសិក្សាទុតិយភូមិ ៥៥% នៅពុំទាន់មានសម្ភារកន្លែងលាងដៃសម្រាប់សិស្ស ដែលបង្ហាញថា ពុំបានបំពេញតាមស្តង់ដាទឹកស្អាត និងអនាម័យឱ្យបានគ្រប់គ្រាន់សម្រាប់សិស្សជាច្រើនពាន់នាក់។[66] កង្វះទឹកស្អាត និងបង្គន់អនាម័យគ្រប់គ្រាន់ បង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ការចូលរៀនរបស់សិស្ស ជាពិសេសក្មេងស្រីជំទង់ ដែលធ្វើឱ្យពួកគេខកខានមិនបានទៅរៀនប្រមាណ ៩ ទៅ ១០សប្តាហ៍ជារៀងរាល់ឆ្នាំ (បណ្តាលពីការមករដូវ) ហើយជាមូលហេតុនាំឱ្យប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្ស។ ការគំរាមកំហែងបង្កគ្រោះថ្នាក់សុខភាពធ្ងន់ធ្ងរដោយសារការលេចចេញនូវជំងឺកូវីដ-១៩ បូករួមនឹងលទ្ធភាពនៃការចម្លងជំងឺតាមមាត់ និងរាងកាយក្នុងចំណោមសិស្ស និងបុគ្គលិកអប់រំ គួរទទួលបានដំណោះស្រាយ និងការឆ្លើយតបផងដែរ។

---

[62] ADB. 2021. *Debriefing to H.E. Dr. Hang Chuon Naron, Minister, MOEYS, on Key Findings from the Project Implementation Support Mission.* Manila (Loan 3427-CAM: Upper Secondary Education Sector Development Program [USESDP]).

[63] MOEYS. 2020a. *Inspection Report on the Effectiveness and Quality of the Secondary Resource Schools.* Phnom Penh: Education Quality Assurance Department.

[64] D. Khieu. 2019. *Promoting Gender Equality through Comprehensive Sexuality Education.* Presentation in the 1st Biennial Conference of the Comparative Education Society of Cambodia: *"Education for Shared Community and Prosperity"*. 6–7 December 2019. Siem Reap, Cambodia.

[65] ADB. 2018. *Cambodia: Upper Secondary Education Early School Leaving Field Study in Nine Provinces.* Manila.

[66] Footnote 44.

ស្តង់ដាកម្មវិធីសិក្សាថ្មីសម្រាប់មុខវិជ្ជាអប់រំសុខភាពថ្នាក់ទី១១-១២ ត្រូវបានរៀបចំរួចរាល់ ដោយឡែក ស្តង់ដាសម្រាប់ថ្នាក់ទី៨ និងទី១១ត្រូវបានផ្សព្វផ្សាយដើម្បីប្រមូលមតិយោបល់ពីអ្នកប្រើប្រាស់ស្តង់ដាទាំងនោះប៉ុន្តែការពង្រីកការអនុវត្តនៅតាមសាលារៀន ត្រូវពន្យារពេលដោយសារតែបញ្ហាថវិកា។ ក្រោមកិច្ចសហការជាមួយដៃគូអភិវឌ្ឍ សៀវភៅសិក្សាគោល និងសៀវភៅគ្រូ "ស្តីពីការអប់រំសុខភាព" កម្រិតមូលដ្ឋានសម្រាប់ថ្នាក់ទី១ ទី៤ ទី៧ និងទី១០ និងសៀវភៅមគ្គុទេសក៍សម្រាប់គ្រូ ត្រូវបានតាក់តែងឡើងនិងកំពុងរៀបចំបញ្ចប់ ហើយកម្មវិធីសិក្សាលម្អិតសម្រាប់ថ្នាក់ទី១ និងទី៤ ទើបនឹងបានសាកល្បងនៅតាមសាលាបឋមសិក្សាចំនួន ៥។ ការសាកល្បងនេះមិនទាន់បានពង្រីកវិសាលភាពបន្ថែមទៀតនៅឡើយ ដោយសារតែបញ្ហាថវិកា។

៣-១៤. ការអប់រំបច្ចេកទេសនៅមធ្យមសិក្សា

ការអប់រំបច្ចេកទេសនៅតាមសាលាមធ្យមសិក្សាទុតិយភូមិ នៅតែបន្តទទួលបានការចាប់អារម្មណ៍យកចិត្តទុកដាក់តិចតួច ព្រោះសាធារណជនយល់ថា ការអប់រំបច្ចេកទេស និងការងារបច្ចេកទេស គឺស្ថិតក្នុងលំដាប់ទី ២ ហើយយុវជនភាគច្រើនចង់បន្តការសិក្សានៅសាកលវិទ្យាល័យ ដើម្បីទទួលបានការងារ "ល្អ"។[67] ការយល់ដឹងរបស់សាធារណជនទូទៅអំពីការអប់រំបច្ចេកទេសនៅមានកម្រិតទាប ហើយឪពុកម្តាយនិងសិស្សច្រើនតែមានការយល់ឃើញអវិជ្ជមាន។ ជាទូទៅ ការបង្កើនការយល់ដឹងដល់យុវជនអំពីការរួមចំណែកដ៏សំខាន់នៃការអប់រំបច្ចេកទេស និងអាជីពការងារបច្ចេកទេស ឬពីគន្លងឆ្ពោះទៅចាប់យកការអប់រំក្រោយមធ្យមសិក្សា និងពិភពការងារនោះ គឺនៅមានកម្រិតតិចតួចនៅឡើយ។ ការអប់រំបច្ចេកទេសក៏ត្រូវបានគេ យល់ឃើញផងដែរថា ពុំមានភាពសមស្របសម្រាប់សិស្សស្រី ព្រោះថា វគ្គសិក្សាជាច្រើនផ្តោតលើជំនាញដូចជា អគ្គិសនី អេឡិចត្រូនិក មេកានិច និងវិស្វកម្មស៊ីវិល បសុព្យាបាល ក្សេត្រសាស្ត្រ និងសំណង់ ដែលសុទ្ធតែជាការងារដែលត្រូវប្រើកម្លាំងខ្លាំង និងជាការងារនៅខាងក្រៅ ដែលពេលខ្លះត្រូវធ្វើនៅក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់។ ការយល់ឃើញមិនត្រឹមត្រូវ ទាំងនេះ ព្រមទាំងការយល់ឃើញដទៃទៀត ពុំបានលើកទឹកចិត្តឱ្យយុវតីជាច្រើនពិចារណាចាប់យកការអប់រំបច្ចេកទេស និងវិជ្ជាជីវៈពាក់ព័ន្ធនោះឡើយ។

ក្រោយពីការផ្ទេរកម្មវិធី TVET ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅឆ្នាំ ២០០៥ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ដើម្បីបន្តរក្សាធាតុចូលមួយចំនួនដល់ការអប់រំបច្ចេកទេសនៅតាមសាលាមធ្យមសិក្សា ប៉ុន្តែនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈមានការលំបាកនៅក្នុងការទទួលបានថវិកាគាំទ្រឱ្យបានគ្រប់គ្រាន់ ដោយហេតុថាហេដ្ឋារចនាសម្ព័ន្ធបរិក្ខារ ការបណ្តុះបណ្តាល ការថែទាំជួសជុល ផ្លាស់ប្តូរបរិក្ខារចាស់ៗ ត្រូវការចំណាយខ្ពស់។ ក្រៅពីនេះ មិនសូវមានការសម្របសម្រួលដោយនាយកដ្ឋានដែលទទួលខុសត្រូវលើការអប់រំកម្រិត មធ្យមសិក្សា ក្នុងកិច្ចប្រឹងប្រែងអភិវឌ្ឍ និងដាក់បញ្ចូលកម្មវិធីសិក្សា គរុកោសល្យ និងធនធានដែលឆ្លើយតបនឹងតម្រូវការទីផ្សារការងារ។ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ផ្នែកមួយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ គឺផ្តោតសំខាន់លើកកម្ពស់ការរួមចំណែកកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការពង្រឹងធនធានមនុស្ស និងចាត់ទុកការអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិជាអាទិភាព។

---

[67] USEDP 2. 2018. *USE Situation Analysis.* In P. Lonn. 2015. Shaping and Scaling Up TVET in Cambodia (Source: S. Khieng et al., ed. *Cambodia Education 2015.* Phnom Penh: Cambodia Development Research Institute. p. 106.)

៣-១៥. ទំនាក់ទំនងផ្សារភ្ជាប់គ្នារវាងការអប់រំមធ្យមសិក្សា និងទីផ្សារការងារ

គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ បានបង្ហាញពីឧបសគ្គមួយដែលរារាំងដល់ការសម្រេចគោលដៅសង្គម-សេដ្ឋកិច្ចរបស់រដ្ឋាភិបាលគឺ *"ការខ្វះចំណេះដឹង និងជំនាញបច្ចេកទេសជាមូលដ្ឋានដែលមានសារៈសំខាន់ដើម្បីប្រែក្លាយកម្លាំងពលកម្ម ដែលគ្មានជំនាញទៅជាកម្លាំងពលកម្មមានជំនាញ ដែលអាចស្រូបយកជំនាញបច្ចេកទេស និងជំនាញបច្ចេកវិទ្យាថ្មីៗ ដែលមានតម្លៃខ្ពស់"*។[68]

យោងតាមរបាយការណ៍ស្តីពីភាពប្រកួតប្រជែងសកលឆ្នាំ ២០១៩ បើគិតជំនាញរបស់កម្លាំងពលកម្មនាពេលបច្ចុប្បន្ន កម្ពុជាកំពុងស្ថិតនៅក្នុងចំណាត់ថ្នាក់ក្រោមគេក្នុងបណ្តាប្រទេសនៅអាស៊ានចំនួន៩។[69]សមាសភាគរងដែលទទួលចំណាត់ថ្នាក់ក្រោមគេរួមមាន៖ ការបណ្តុះបណ្តាលបុគ្គលិក គុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ សំណុំជំនាញរបស់អ្នកបញ្ចប់ការសិក្សាជំនាញឌីជីថលក្នុងចំណោមប្រជាពលរដ្ឋសកម្ម និងភាពងាយស្រួលក្នុងការស្វែងរកនិយោជិតដែលមានជំនាញ។ ដោយឡែក កម្ពុជាក៏ទទួលបានចំណាត់ថ្នាក់ចុងក្រោយគេក្នុងចំណោមប្រទេសអាស៊ាន ក្នុងសន្ទស្សន៍ជំនាញកម្លាំងពលកម្មនាពេលអនាគតដែលមានពីរសមាសភាគ គឺ ការបង្រៀន-រៀនតាមបែប ត្រិះរិះពិចារណា និងផលធៀបសិស្ស-គ្រូនៅកម្រិតបឋមសិក្សា។ ប្រសិនបើមិនមានការកែទម្រង់ឱ្យបានច្រើនក្នុងវិស័យអប់រំកម្ពុជាហាក់ដូចជាពុំអាចឆ្លើយតបចំពោះបញ្ហាខ្វះកម្លាំងពលកម្មជំនាញឱ្យបានទាន់ពេលវេលា និងអាចពង្រឹងភាពប្រកួតប្រជែងបានឡើយ សូម្បីតែភាពប្រកួតប្រជែងជាមួយនឹងប្រទេសជិតខាង។

ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (២០១៩-២០២០) គូសបញ្ជាក់ថា កម្មករដែលមានការងារធ្វើនៅកម្ពុជា (អាយុ ១៥ ដល់ ៦៤ ឆ្នាំ)មាន ៤៤,២% (ស្រី ៤៩,២%) ទទួលបាន "ការអប់រំតិចតួច" ពោលគឺ ពួកគេពុំបានបញ្ចប់ការអប់រំផ្លូវការ ឬមិនបានបញ្ចប់បឋមសិក្សា។[70] ចំណុចនេះ ជាបញ្ហាគួរឱ្យកត់សម្គាល់ដោយហេតុថា អ្នកដែលធ្វើការងារជាអ្នកជំនាញវិជ្ជាជីវៈ អ្នកបច្ចេកទេស ជំនួយការ អ្នកវិជ្ជាជីវៈច្រើនជាងពាក់កណ្តាលនៃពួកគេ ត្រូវបានដាក់ចំណាត់ថ្នាក់ថា ទទួលបានការអប់រំទាបជាងសញ្ញាប័ត្រ។[71] ឱនភាពសេដ្ឋកិច្ចដោយសារការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ បានរំលេចឱ្យឃើញពីភាពចាំបាច់ក្នុងការបង្កើនគុណភាពនៃកម្លាំងពលកម្មរបស់កម្ពុជា។ កម្មករនិយោជិតរាប់ពាន់នាក់ដែលធ្វើការនៅតាមរោងចក្រកាត់ដេរ និងក្នុងវិស័យទេសចរណ៍បានបាត់បង់ការងារ ហើយអាចច្រើននាក់ថែមទៀតនឹងត្រូវបាត់បង់ការងារ។ ពលករចំណាកស្រុករាប់ពាន់នាក់ដែលធ្វើការងារជំនាញទាបក្នុងប្រទេសថៃបានត្រឡប់មកស្រុកកំណើតវិញ។ ទន្ទឹមនឹងនោះ ក្រោយពេលដែលវិបត្តិបច្ចុប្បន្នបញ្ចប់ ក្រុមហ៊ុនជាច្រើននឹងស្វែងរកការបំពាក់បច្ចេកវិទ្យាស្វ័យប្រវត្តិកម្ម ដើម្បីការពារខ្លួនពួកគេពីវិបត្តិស្រដៀងគ្នានេះនាពេលអនាគតទាំងនេះ នឹងជាកត្តាគំរាមកំហែងដល់កម្លាំងពលកម្ម/ការងារដែលមានជំនាញតិចតួច។ កត្តាទាំងនេះបញ្ជាក់ឱ្យឃើញពីភាពបន្ទាន់នៃការធ្វើកំណែទម្រង់វិស័យអប់រំ ដើម្បីប្រែក្លាយកម្មករ និយោជិតរបស់ប្រទេស ទៅជាកម្លាំងពលកម្មដែលមានជំនាញ ដែលមានសមត្ថភាពអាចស្រូបយកជំនាញបច្ចេកទេស និងជំនាញវិជ្ជាជីវៈថ្មីៗ ដែលមានតម្លៃខ្ពស់ ដែលចាំបាច់សម្រាប់ស្ថានភាពសេដ្ឋកិច្ចក្រោយជំងឺកូវីដ-១៩។

---

[68] Royal Government of Cambodia. 2014. *Cambodia Industrial Development Policy 2015–2025: Market Orientation and Enabling Environment for Industrial Development.* Phnom Penh.
[69] G. Ducanes and D. Mao. 2020. *Cambodia Labour Market Assessment for CAMSEB 2030.* Phnom Penh: Asian Development Bank.
[70] National Institute of Statistics. 2020. Report of the Cambodia Socio-Economic Survey 2019–2020. Phnom Penh: Ministry of Planning.
[71] M. Bruni et al. 2013. Skills Shortages and Skills Gaps in the Cambodian Labor Market: Evidence from Employer Survey. *ILO Asia-Pacific Working Paper Series.* Geneva: International Labor Organization.

ដើម្បីប្រែក្លាយបដិវត្តន៍ឧស្សាហកម្ម ៤.០ និងគោលនយោបាយស្តីអំពីពលកម្មជំនាញ ទៅជាការអនុវត្ត ដែលសម្រេចបាននូវលទ្ធផលជាវិជ្ជមាន ចាំបាច់ត្រូវមានការសម្របសម្រួលឱ្យបានស្អិតរមួតក្នុងនិងរវាងរាជរដ្ឋាភិបាល វិស័យអប់រំ ឧស្សាហកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាល។ ទំនាក់ទំនងនេះហាក់ដូចជានៅទន់ខ្សោយ ដោយសារនៅតាមស្ថាប័នក្រសួង មានការយល់ដឹងមិនដូចៗ គ្នាអំពីបដិវត្តន៍ឧស្សាហកម្ម៤.០ ដោយឡែក ការសម្របសម្រួលនៅក្នុងស្ថាប័នអប់រំ ផ្នែកជំនាញទូទៅ និងជំនាញបច្ចេកទេស គឺនៅមានកម្រិត រីឯការប្រាស្រ័យទាក់ទងគ្នារវាងឧស្សាហកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាលនៅមានកម្រិតនៅឡើយ ជាពិសេសការប្រាស្រ័យទាក់ទងលើមុខជំនាញអ្វីខ្លះ ដែលជាតម្រូវការរបស់ឧស្សាហកម្ម។[72]

៣-១៦. លទ្ធភាពរបស់អ្នកសិក្សាក្នុងការទទួលបានការអប់រំឌីជីថល

ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ នាំឱ្យមានការបិទទ្វារសាលារៀនទាំងអស់នៅទូទាំងប្រទេស ដោយបានប្តូររបៀបសិក្សាពីដោយផ្ទាល់ទៅជាការសិក្សាដោយប្រយោល តាមរយៈប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ និងទូរទស្សន៍) និងការអប់រំតាមអនឡាញ ដើម្បីកាត់បន្ថយកង្វះសេវាអប់រំទាំងសាលារដ្ឋ និងឯកជន។ ដូចប្រទេសផ្សេងទៀតដែរ វិស័យអប់រំនៅកម្ពុជាពុំបានត្រៀមខ្លួនសម្រាប់ស្ថានភាពដែលសាលារៀនទាំងអស់ត្រូវបិទទ្វារ និងតម្រូវឱ្យមានការសិក្សាពីចម្ងាយ។ កន្លងមក កម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃ ធ្លាប់អនុវត្តដោយមានគ្រូបង្រៀន និងក្នុងថ្នាក់រៀន ប៉ុន្តែបញ្ហាប្រឈមនៅពេលនេះនាំឱ្យមានការប្តូរយ៉ាងឆាប់រហ័សទៅរកការអប់រំឌីជីថលវិញ។ គ្រូបន្ទុកថ្នាក់ និងមន្ត្រីក្រសួងភាគច្រើននៅគ្រប់កម្រិតទាំងអស់មានចំណេះដឹង និងជំនាញកម្រិតមធ្យម និងតិចតួចក្នុងការ "ប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំ" ដែលធ្វើឱ្យអន្តរកាលបែបនេះ មានការលំបាក ដោយសារបញ្ហានេះកើតឡើងភ្លាមៗ។

កង្វះកុំព្យូទ័រ កម្មវិធី (software) និងឧបករណ៍ផ្សេងទៀត ក៏ដូចជាអគ្គិសនីនៅតាមសាលាជនបទ និងដាច់ស្រយាលជាច្រើន ជាកត្តារាំងស្ទះដល់ការអប់រំឌីជីថល។ ឧបសគ្គដ៏ធំមួយទៀត ក្នុងការប្រើប្រាស់សម្ភារ/ធនធានតាមអនឡាញ និងអហ្វឡាញ (Online and Offline) ឬធ្វើអ្វីមួយដែលពាក់ព័ន្ធនឹងការប្រើប្រាស់អ៊ីនធឺណេត គឺការចំណាយខ្ពស់លើថ្លៃសេវាអ៊ីនធឺណេតជាបន្ទុកអ្នកប្រើប្រាស់។ លើសពីនេះ សេវាអ៊ីនធឺណេត 3G/4G នៅតាមតំបន់ជនបទមានកម្រិតទាប និងមានល្បឿនយឺត ដែលធ្វើឱ្យការប្រើប្រាស់ការរៀនសូត្រតាមអនឡាញពុំមានប្រសិទ្ធភាព។ ចំណាយខ្ពស់ និងល្បឿនអ៊ីនធឺណេតយឺត ធ្វើឱ្យគ្រូបង្រៀន និងមាតាបិតាសិស្សមានការលំបាកក្នុងការប្រើប្រាស់អ៊ីនធឺណេតសម្រាប់ធ្វើសកម្មភាពអប់រំអនឡាញ ដែលផ្តួចផ្តើមដោយក្រសួង និងអ្នកផ្តល់សេវាអប់រំដទៃទៀត។

[72] ADB. 2021. *Reaping the Benefits of Industry 4.0 through Skills Development in Cambodia.* Manila.

៤. កត្តាសំខាន់ៗសម្រាប់ការពង្រឹងការអប់រំកម្រិតមធ្យមសិក្សា

"ការវិវត្តប្រែប្រួល គឺជារឿងដែលមិនអាចចៀសរួច ការរីកចម្រើនគឺជារឿងដែលធ្វើក៏បាន មិនធ្វើក៏បាន" ។[73]

ផ្នែកនេះផ្តោតលើអនុសាសន៍ជាច្រើន ទទួលបានពីការវិភាគគ្រប់ជ្រុងជ្រោយលើអនុវិស័យអប់រំមធ្យមសិក្សា កាលពីឆ្នាំ ២០២០ រួមទាំងការអប់រំចំណេះដឹងទូទៅ និងការអប់រំបច្ចេកទេសសម្រាប់មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ការអប់រំគ្រូបង្រៀន ភាពក្រីក្រ បញ្ហាសង្គម និងយេនឌ័រ ថវិកា និងហិរញ្ញវត្ថុសម្រាប់ការអប់រំ ការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអប់រំឧត្តមសិក្សា និងអនុវិស័យ TVET កម្មវិធី STEM និងការអប់រំឌីជីថល ការវាយតម្លៃទីផ្សារការងារ បរិបទសេដ្ឋកិច្ចជាតិ និងសន្ទស្សន៍មូលធនមនុស្ស។ ក្នុងករណីជាច្រើន ចំណុចនេះពាក់ព័ន្ធនឹងការធ្វើកំណែទម្រង់យ៉ាងជោគជ័យដោយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ ក៏ដូចជាសង្គមស៊ីវិល។[74]

ផែនទីបង្ហាញផ្លូវសម្រាប់ការអប់រំមធ្យមសិក្សា បង្ហាញអំពីខ្លឹមសារលម្អិតស្តីពីការអនុវត្តអាទិភាព និងលទ្ធផលសម្រេចបានសំខាន់ៗ (សូមពិនិត្យមើលផ្នែកទី៦ និងទី១០) ចេញពីកត្តាខាងក្រោម។

៤-១. ការធ្វើឱ្យមានការផ្លាស់ប្តូរជាប្រព័ន្ធ

ដើម្បីប្តូរឥរិយាបថ ចាំបាច់ត្រូវធ្វើឱ្យមានការប្រែប្រួលជាប្រព័ន្ធ ព្រោះជាកន្លែង ដែលឥរិយាបថទាំងនោះកើតមានឡើង។ កត្តានយោបាយ បុគ្គលិកលក្ខណៈ ទម្លាប់ជ្រើសរើសបុគ្គលិក កង្វះគុណវុឌ្ឍិ ខ្វះគោលបំណង ការប្តេជ្ញាចិត្ត និង/ឬទំនុកចិត្ត អាចជាឧបសគ្គដែលធ្វើឱ្យរាំងស្ទះដល់កំណែទម្រង់ និងការសម្រេចបានវឌ្ឍនភាពក្នុងវិស័យអប់រំ។

ដើម្បីសម្រេចបាននូវគោលដៅនេះ ការពិនិត្យ និងការវិភាគលើផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (ឆ្នាំ ២០១៩) បានផ្តល់ជាអនុសាសន៍ឱ្យមានការយកចិត្តទុកដាក់លើផ្នែកសំខាន់ៗ ចំនួន៤៖

១ បន្តផ្តោតការយកចិត្តទុកដាក់លើការអប់រំគ្រូបង្រៀន (បន្តអភិវឌ្ឍអតិក្រមវិទ្យាស្ថានគរុកោសល្យ ពង្រឹងការបណ្តុះបណ្តាលគ្រូ បង្កើនគុណវុឌ្ឍិអប់រំ និងជំនាញគរុកោសល្យ)

២ អនុវត្តក្របខណ្ឌ និងផែនការសកម្មភាពស្តីពី ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (២០១៩-២០២៣)

៣ រៀបចំយុទ្ធសាស្ត្រ អនុវត្ត និងគ្រប់គ្រងការជ្រើសរើស និងការពង្រាយគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព

៤ អភិវឌ្ឍ ផ្សព្វផ្សាយ និងគ្រប់គ្រងគោលនយោបាយគ្រូបង្រៀនដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (ចាប់ពីការជ្រើសរើស រហូតដល់ការដាក់ឱ្យចូលនិវត្តន៍)។[75]

គំនិតផ្តួចផ្តើមទាំងនេះ និងអនុសាសន៍ជាច្រើនដែលលើកឡើងក្នុងផ្នែកទី៤ មានគោលបំណងសម្រេចបានវឌ្ឍនភាពទូលំទូលាយ ក្នុងការរួមចំណែករបស់ប្រព័ន្ធអប់រំដល់ការបង្កើនលទ្ធផលសិក្សារបស់សិស្ស និងជម្រើសអាជីពរបស់សិស្ស។ គំនិតផ្តួចផ្តើមទាំងនេះនឹងបន្តរួមចំណែកដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅកម្ពុជា។

---

[73] J. Maxwell. https://www.goodreads.com/quotes/81497-change-is-inevitable-growth-is-optional
[74] The situation analyses and background papers can be made available as reference materials for the CAMSEB 2030.
[75] MOEYS. 2019e. *Teacher Policy Action Plan Review and Analysis 2019.* Phnom Penh: Teacher Training Department.

៤-២. ការអភិវឌ្ឍគន្លងអប់រំ បណ្តុះបណ្តាល និងអាជីពសម្រាប់សិស្ស



Career Pathways

បច្ចុប្បន្នមិនទាន់មាន **គន្លងអប់រំបណ្តុះបណ្តាល និងអាជីព** សម្រាប់ជាមូលដ្ឋាន និងព័ត៌មាន ជួយឱ្យសិស្ស និងក្រុមគ្រួសាររបស់ពួកគេ អាចធ្វើការសម្រេចចិត្តត្រឹមត្រូវ អំពីជម្រើសមុខវិជ្ជា ជម្រើសផ្សេងៗ និងឱកាសផ្សេងទៀត។ ការផ្តល់គន្លងអប់រំ បណ្តុះបណ្តាល និងអាជីព គឺជាការបង្ហាញយ៉ាងច្បាស់នូវ "និម្មាបនកម្ម (architecture)" នៃការអប់រំសាធារណៈ នៅកម្ពុជា ផ្អែកទៅតាម ក្របខណ្ឌគុណវុឌ្ឍិកម្ពុជា និងក្របខណ្ឌគុណវុឌ្ឍិអាស៊ាន។

គន្លងអប់រំ និងបណ្តុះបណ្តាល ក៏រួមចំណែកបង្ហាញឱ្យឃើញពីសារៈសំខាន់នៃការអប់រំនៅកម្រិតមធ្យមសិក្សា ព្រោះសិស្សនឹងមើលឃើញថា ការអប់រំនៅមធ្យមសិក្សា គឺជាការបើកទ្វារ/ច្រក ជាច្រើនសម្រាប់ពួកគេអាចបន្តចាប់យកឱកាសផ្សេងទៀតដូចជា ការអប់រំក្រោយមធ្យមសិក្សា អាជីព/ការងារផ្សេងៗ សហគ្រិនភាព ឱកាសទីផ្សារការងារ ជាដើម។ល។

ការផ្សព្វផ្សាយព័ត៌មានឱ្យបានច្បាស់លាស់អំពីគន្លងអប់រំ និងបណ្តុះបណ្តាលនានាដល់សិស្ស មាតាបិតា និងបុគ្គលិកអប់រំ នឹងលើកទឹកចិត្តឱ្យពួកគេធ្វើការសម្រេចចិត្តកាន់តែល្អអំពីជម្រើសនានាពេលអនាគត និងបំពាក់បំប៉នខ្លួនឯងបានកាន់តែប្រសើរ ដើម្បីសម្រេចគោលដៅនៃការអប់រំ និងអាជីពរបស់ខ្លួន ជាពិសេសក្នុងអំឡុងពេល និងក្រោយកម្រិតមធ្យមសិក្សាបឋមភូមិ។ ការបង្កើនតម្លាភាព និងការយល់ដឹងជាសាធារណៈអំពីប្រភេទផ្សេងៗគ្នានៃសាលារៀនមធ្យមសិក្សា បច្ចេកទេស និងឧត្តមសិក្សានៅកម្ពុជា នឹងជួយឱ្យការអប់រំអាចឆ្លើយតបចំពោះបញ្ហាតម្រូវការ-ផ្គត់ផ្គង់ផងដែរ។ គន្លងអប់រំ បណ្តុះបណ្តាល និងអាជីព គួរមានការកែតម្រូវឱ្យបានជាប្រចាំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវឌ្ឍរបស់សង្គម និងតម្រូវការទីផ្សារការងារ។

១. *គន្លងអប់រំបណ្តុះបណ្តាល និងអាជីព នឹងត្រូវរៀបចំឡើងដោយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល ក្រោមការដឹកនាំរួមរវាង ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។*

ដើម្បីធានាឱ្យមានការរៀបចំ ការផ្សព្វផ្សាយ និងអនុវត្តគន្លងអប់រំ និងបណ្តុះបណ្តាលទាំងនេះ ប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវមានការប្តេជ្ញាចិត្តកម្រិតនយោបាយ និងការដាក់ចេញនូវគោលនយោបាយ និង/ឬគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល។ ការបង្កើនទំនាក់ទំនងគ្នាឱ្យបានខ្លាំងក្លាជាងមុនរវាងស្ថាប័នក្នុងរដ្ឋាភិបាល ឧស្សាហកម្ម សហគមន៍ ទីផ្សារ និងសង្គមស៊ីវិលគឺជាយន្តការចាំបាច់មួយទៀត សម្រាប់បន្តអភិវឌ្ឍ និងធ្វើបច្ចុប្បន្នកម្មគន្លងអប់រំ និងបណ្តុះបណ្តាល ទាំងសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា ការអប់រំនិងបណ្តុះបណ្តាលក្រោយមធ្យមសិក្សា និងឱកាសការងារ។ នៅក្នុងឆ្នាំ ២០២១ ដែលជាដំណាក់កាលទី ១ គឺត្រូវបង្កើតក្រុមការងារមួយសម្រាប់រៀបចំគន្លងអប់រំ បណ្តុះបណ្តាល និងអាជីព ដោយដាក់ចេញនូវស្តង់ដា និងគោលការណ៍ណែនាំនានា ដែលមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយ។ ក្រុមការងារនេះមានសហប្រធានជាតំណាងមកពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២. ទាក់ទងនឹងគន្លងអប់រំ បណ្តុះបណ្តាល និងអាជីព គ្រឹះស្ថានអប់រំសាធារណៈត្រូវសហការគ្នា ដើម្បីឱ្យមានការទទួលស្គាល់ទៅវិញទៅមកលើគុណភាព និងវិញ្ញាបនបត្របញ្ជាក់ការសិក្សាទាំងគន្លងអប់រំ ការបណ្តុះបណ្តាល និងអាជីព ដើម្បីសម្រួលឱ្យសិស្សនិស្សិតអាចចាប់យកគន្លងសិក្សាមួយមានភាពទន់ភ្លន់ និងអាចផ្ទេរការសិក្សាទៅវិញទៅមកបាន រវាងពីគ្រឹះស្ថានអប់រំមួយ ទៅគ្រឹះស្ថានអប់រំមួយទៀត។

ជាក់ស្តែង បច្ចុប្បន្ននេះសិស្សបញ្ចប់មធ្យមសិក្សាហើយបន្តការសិក្សាថ្នាក់បរិញ្ញាបត្ររងចំនួន២ឆ្នាំ នៅក្នុងគ្រឹះស្ថានអប់រំណាមួយ ក្រោមចំណុះក្រសួងអប់រំ យុវជន និងកីឡា ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រហែលជាមិនអាចបន្តរៀនយកថ្នាក់បរិញ្ញាបត្រ នៅឆ្នាំទី៣តែម្តង នៅគ្រឹះស្ថានអប់រំមួយផ្សេងទៀត ដែលមិនស្ថិតនៅក្រោមក្រសួងដែលជាអាណាព្យាបាលរបស់គ្រឹះស្ថានអប់រំ ដែលពួកគេកំពុងរៀនក្នុងបច្ចុប្បន្ន។ រីឯសិស្សថ្នាក់ទី១០ ឬទី១១ នៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសអាចជួបការលំបាកក្នុងការផ្ទេរពីការអប់រំចំណេះទូទៅ ទៅការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ដូចនេះ ចាំបាច់ត្រូវមានការរៀបចំគន្លងអប់រំ និងបណ្តុះបណ្តាល ដើម្បីឈានទៅជានាឱ្យមានគន្លងសិក្សាមួយ ដែលមានសភាពទន់ភ្លន់ និងអាចផ្ទេរទៅវិញទៅមកបាន និងការផ្តល់ឱកាសរៀនសូត្រពេញមួយជីវិតដល់សិស្សនិស្សិត និងយុវជន។

ក្របខណ្ឌគុណវុឌ្ឍិកម្ពុជា ផ្តល់នូវក្របខណ្ឌមូលដ្ឋានសម្រាប់ការអប់រំ និងបណ្តុះបណ្តាល ៖

- ផ្តល់ការទទួលស្គាល់ ដែលមានសង្គតិភាពទូទាំងប្រទេស លើលទ្ធផលដែលសម្រេចបានតាមគុណវុឌ្ឍិនីមួយៗ សម្រាប់ការអប់រំ និងបណ្តុះបណ្តាល
- ជួយរៀបចំឱ្យចេញជាគន្លងដែលមានភាពបត់បែន ដើម្បីឱ្យគេងាយផ្លាស់ប្តូរពីការអប់រំ និងបណ្តុះបណ្តាលមួយទៅការអប់រំ និងបណ្តុះបណ្តាលមួយទៀត ព្រមទាំងរវាងការអប់រំ ជាមួយនឹងទីផ្សារការងារ តាមរយៈការផ្តល់នូវមូលដ្ឋានសម្រាប់ទទួលស្គាល់ការរៀនសូត្រកន្លងមក ដូចជា ការផ្ទេរក្រេឌីត បទពិសោធន៍ និងសមត្ថភាពនាពេលបច្ចុប្បន្នជាដើម
- ផ្តល់នូវភាពទន់ភ្លន់ ដើម្បីសម្របទៅតាមគោលបំណងផ្សេងៗ គ្នានៃការអប់រំ និងការបណ្តុះបណ្តាល
- លើកទឹកចិត្តឱ្យបុគ្គលម្នាក់ៗបន្តអភិវឌ្ឍសមត្ថភាពរបស់ខ្លួន តាមរយៈការអប់រំ និងការបណ្តុះបណ្តាល។ ទឹកចិត្តនេះកើតឡើងពីលទ្ធភាពទទួលបានគុណវុឌ្ឍិ ការកំណត់បានច្រកផ្លូវច្បាស់លាស់មួយសម្រាប់សម្រេចឱ្យបាន ហើយជាការរួមចំណែកជំរុញដល់ការសិក្សាពេញមួយជីវិត
- លើកទឹកចិត្តការផ្តល់ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានគុណភាពខ្ពស់តាមរយៈមានគុណវុឌ្ឍិអប់រំដែលបំពេញបាននូវតម្រូវការរបស់បុគ្គល តម្រូវការនៅកន្លែងធ្វើការ និងតម្រូវការវិជ្ជាជីវៈ ហើយដែលរួមចំណែកដល់ការលើកកម្ពស់សមិទ្ធកម្មសេដ្ឋកិច្ចជាតិ
- ជំរុញឱ្យមានការទទួលស្គាល់នៅថ្នាក់ជាតិ និងអន្តរជាតិដល់គុណវុឌ្ឍិ ដែលផ្តល់ក្នុងព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលការកៀរគរកម្លាំងពលកម្មជំនាញនៅថ្នាក់តំបន់។

រូបភាពទី ១២៖ បង្ហាញពីក្របខណ្ឌគុណវុឌ្ឍិកម្ពុជា



ប្រភព៖ *National Training Board. 2012. Cambodian Qualifications Framework. Phnom Penh: Royal Government of Cambodia.*

ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (ASEANQualificationsReferenceFramework) គឺជាក្របខណ្ឌយោងទូទៅមួយដែលអាចប្រៀបធៀបគុណវុឌ្ឍិអប់រំនៅទូទាំងរដ្ឋជាសមាជិកអាស៊ាន។ គោលបំណងនៃក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ានរួមបញ្ចូល៖

- គាំទ្រការទទួលស្គាល់គុណវុឌ្ឍិ
- ជំរុញការអភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិដែលអាចជួយសម្រួលដល់ការសិក្សាពេញមួយជីវិត
- ជំរុញការអភិវឌ្ឍអភិក្រមថ្នាក់ជាតិក្នុងការធ្វើសុពលកម្មការសិក្សា ដែលទទួលបានពីការអប់រំក្រៅផ្លូវការ
- លើកកម្ពស់ និងលើកទឹកចិត្តដល់ការអប់រំ និងចល័តភាពរបស់អ្នកសិក្សា

- គាំទ្រចល័តភាពរបស់កម្មករ/អ្នកធ្វើការ
- បង្កើនការយល់ដឹងអំពីប្រព័ន្ធគុណវុឌ្ឍិ
- លើកកម្ពស់ប្រព័ន្ធគុណវុឌ្ឍិដែលមានគុណភាពខ្ពស់។

៤-៣. ការបង្កើនសមិទ្ធកម្មរបស់គ្រូបង្រៀន

ការស្រាវជ្រាវអន្តរជាតិបង្ហាញយ៉ាងច្បាស់ថា នៅកម្រិតសាលារៀន គ្រូប្រចាំថ្នាក់ គឺជាអ្នកមានឥទ្ធិពលជាងគេលើលទ្ធផលសិក្សារបស់សិស្ស។[76] ដូចនេះ សមិទ្ធកម្ម/សមត្ថភាពវិជ្ជាជីវៈរបស់គ្រូមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់កិច្ចខិតខំប្រឹងប្រែងកែលម្អសាលារៀន ជាពិសេសលទ្ធផលសិក្សារបស់សិស្ស និងអត្រាលំហូររបស់សិស្ស (ការឡើងថ្នាក់ ការរៀនត្រួតថ្នាក់ និងការធ្លាប់ចាកចេញពីសាលារៀន)។ ការបណ្តុះបណ្តាលគ្រូបំពាក់បំប៉នសមត្ថភាពប្រកបដោយគុណភាព ផ្តល់ដល់គរុសិស្សមុនពេលចេញបម្រើការងារ នឹងធ្វើឱ្យអាជីពរបស់គ្រូប្រចាំថ្នាក់មានការរីកចម្រើន ជាមួយការដឹកនាំការបង្រៀនប្រកបដោយប្រសិទ្ធភាពដោយនាយកសាលា និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតាមសាលារៀន គួបផ្សំនឹងការកំណត់ច្បាស់អំពីយន្តការគណនេយ្យភាព និងតួនាទី និងការវាយតម្លៃលើសមិទ្ធកម្មប្រចាំឆ្នាំ (ការវាយតម្លៃដែលផ្តោតលើការអភិវឌ្ឍចៀសជាងការរិះគន់)។ គន្លងអាជីពដែលកំណត់បានច្បាស់លាស់ សម្រាប់បុគ្គលិកអប់រំនៅកម្ពុជា នឹងលើកទឹកចិត្តឱ្យពួកគេផ្តល់សេវាដែលល្អបំផុតដល់សហគមន៍របស់ពួកគេ។[77]

ចំណុចនេះក៏កើតមានចំពោះគ្រូឧទ្ទេសក្នុងវិទ្យាស្ថានគរុកោសល្យផងដែរដែលទាមទារឱ្យមានការបង្កើនចំណេះដឹងកម្មវិធីសិក្សា ការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ និងយុទ្ធសាស្ត្របែបនវានុវត្តន៍ និងការអនុវត្តរបៀបសិក្សាថ្មី ដើម្បីផ្តល់ការបណ្តុះបណ្តាលគ្រូប្រកបដោយគុណភាព និងជានាផលិតបាននូវគ្រូបង្រៀន ដែលមានសមត្ថភាព និងទំនុកចិត្តនាពេលអនាគត។ វិទ្យាស្ថានគរុកោសល្យដែលចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូចុះកម្មសិក្សា និងនាយកសាលានឹងត្រូវបានទទួលស្គាល់គុណភាពធៀបនឹងលក្ខណៈវិនិច្ឆ័យនានា រួមទាំងក្រុមគ្រូឧទ្ទេស ដែលមានគុណវុឌ្ឍិ។

អភិក្រមវិជ្ជាជីវៈបែបនេះនឹងជំរុញឱ្យមានការកែលម្អការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធិភាព និងជារង្វាន់លើកទឹកចិត្ត ដែលនឹងជំរុញគ្រូមានជំនាញវិជ្ជាជីវៈកាន់តែមានទឹកចិត្ត (រូបភាពទី ១៨)។ ទាំងនេះនឹងបង្កើនទំនុកចិត្តរបស់សាធារណជនលើប្រព័ន្ធអប់រំ និងអ្នកដែលសហគមន៍ផ្តល់ការទុកចិត្តឱ្យបង្រៀនកូនរបស់ពួកគេជារៀងរាល់ថ្ងៃ។

[76] K. Leithwood, S. Patten, and D. Jantzi. 2010. Testing a Conception of How School Leadership Influences Student Learning. *Educational Administration Quarterly.* 46 (5). pp. 671–706.
[77] MOEYS. 2020c. *Teacher Career Pathways Policy.* Phnom Penh: Department of Policy (DGPP).

រូបភាពទី ១៣ ៖ សមិទ្ធកម្មរបស់គ្រូបង្រៀន



ប្រភព៖ Adapted from Cambridge Education (www.LinkedIn.com).

៤-៤. ការពង្រឹងការពង្រាយគ្រូ

កិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវបានដោះស្រាយឆ្លើយតបចំពោះបញ្ហាខ្វះគ្រូ និងលើសគ្រូនៅតាមសាលារៀន។ បច្ចុប្បន្ន គរុសិស្ស ដែលបញ្ចប់ការសិក្សាពីវិទ្យាស្ថានគរុកោសល្យ ត្រូវបានតម្រូវឱ្យជ្រើសរើសយកប៉ុស្តិ៍ការងារដែលមាននៅតាមសាលាដែលខ្វះគ្រូ តែត្រូវមានការឯកភាពចុងក្រោយពីនាយកសាលា។ ដំណើរការបែបនេះអាចប្រើរយៈពេលវែង ព្រោះពាក់ព័ន្ធនឹងការចូលនិវត្តន៍ ការលាលែងពីមុខងារ ឬបើអាចគឺគិតគូរជាកញ្ចប់ និងផ្លាស់ប្តូរជាដំណាក់ៗទៅតាមជំនាន់។[78] ទោះបីមានការផ្តល់ការលើកទឹកចិត្តនានាដូចជា កន្លែងស្នាក់នៅ និងប្រាក់ឧបត្ថម្ភសម្រាប់ការបង្រៀននៅតំបន់ដាច់ស្រយាល ដើម្បីលើកទឹកចិត្តឱ្យមានការដាក់ពង្រាយគ្រូបង្រៀនឡើងវិញ ក៏សាលារៀនខ្វះគ្រូនៅតែត្រូវយកចិត្តទុកដាក់បន្ថែមទៀត។ ការសិក្សាមួយដែលធ្វើឡើងដោយក្រសួងអប់រំ យុវជន និងកីឡាកាលពីឆ្នាំ ២០១៨ បានផ្តល់អនុសាសន៍ខាងក្រោម ដើម្បីជួយសម្រាលបញ្ហានេះ ៖

- ធ្វើបច្ចុប្បន្នកម្មទិន្នន័យអំពីគ្រូលើស និងខ្វះគ្រូនៅតាមសាលារៀន
- ផ្សព្វផ្សាយទិន្នន័យនេះឱ្យបានទូលំទូលាយ ដើម្បីឱ្យគ្រូនិងនាយកសាលាអាចធ្វើការសម្រេចចិត្តកាន់តែត្រឹមត្រូវ អំពីការពង្រាយគ្រូថ្មី និងការផ្ទេរគ្រូ
- តម្រូវឱ្យនាយកសាលា និងបុគ្គលិកនៅថ្នាក់ក្រោមជាតិ លើកទឹកចិត្តឱ្យគ្រូធ្វើការផ្ទេរប៉ុស្តិ៍ការងារដោយស្ម័គ្រចិត្ត
- ដាក់ឱ្យអនុវត្តនូវកញ្ចប់ចូលនិវត្តន៍ និងកញ្ចប់លាឈប់ពីការងារមុនអាយុកំណត់ដើម្បីលើកទឹកចិត្តឱ្យគ្រូ និងនាយកសាលាដែលបង្រៀនយូរមកហើយឆាប់ចូលនិវត្តន៍
- ផ្តល់ការបណ្តុះបណ្តាលគ្រូដល់គ្រូបឋមសិក្សានៅតាមសាលារៀនដែលលើសគ្រូដើម្បីឱ្យពួកគេអាចផ្ទេរទៅសាលាមធ្យមសិក្សា ដែលមានគុណភាពខ្ពស់

[78] Footnote 79.

- ប្រែក្លាយសាលាដែលលើសគ្រូទៅជាសាលារៀនជំនាន់ថ្មី ឬ សាលារៀនប្រភេទ គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា (SEIP) ដើម្បីឆ្លើយតបចំពោះបញ្ហា "សាលារៀនដែលកំពុងបាត់បង់សិស្សជាបន្តបន្ទាប់ (dying schools)"
- ផ្តល់កម្មវិធីបង្កើនគុណវុឌ្ឍិចំគោលដៅដល់គ្រូមធ្យមសិក្សាបឋមភូមិ នៅតាមសាលារៀនលើសគ្រូ ដើម្បីឱ្យពួកគេផ្ទេរទៅកាន់សាលាមធ្យមសិក្សាទុតិយភូមិ ដែលខ្វះគ្រូ
- ជំរុញឱ្យអនុវត្តនូវវិធានការផ្ទេរប៉ុស្តិ៍ការងារ ក្រោយពីបានបំពេញការងារ ៣-៥ឆ្នាំ ជំរុញការអនុវត្តបែបនេះនៅតាមទីកន្លែងដែលបញ្ហានៅតែបន្តកើតមាន
- ដាក់ឱ្យអនុវត្តនូវការផ្តល់ប្រាក់ឈ្នួលប្រចាំម៉ោង ឬបៀវត្សទៅតាមការងារដែលធ្វើជាក់ស្តែង (pro-rated) សម្រាប់គ្រូដែលមិនធ្វើការងារពេញម៉ោង។[79]

ការដំឡើងឋានៈ ផ្ទេរ និងទទួលស្គាល់ក្របខណ្ឌ ក៏ជាចំណុចដែលពាក់ព័ន្ធនឹងការពង្រាយបុគ្គលិកផងដែរ និងតម្រូវឱ្យមានការប្រើប្រាស់រួមគ្នានូវ (i) គុណវុឌ្ឍិដែលបានពីការសិក្សា (ii) បទពិសោធន៍ការងារ (iii) ការអភិវឌ្ឍ វិជ្ជាជីវៈជាប្រចាំ និង (iv) វង្វាយតម្លៃសមិទ្ធកម្ម ដើម្បីទទួលបានការដំឡើងឋានៈនៅក្នុងអាជីព និងការទទួលស្គាល់វិជ្ជាជីវៈ។

៤-៥. ការផ្តល់អាទិភាពដល់ការដឹកនាំ និងការគ្រប់គ្រងសាលារៀន

ក្រសួងអប់រំ យុវជន និងកីឡា ផ្តោតលើការពង្រឹងគណនេយ្យភាព និងលទ្ធផលនៅគ្រប់សាលារៀនសាធារណៈទាំងអស់ត្រឹមឆ្នាំ ២០៣០ តាមរយៈគោលវិធីគ្រប់គ្រងតាមសាលារៀន។ គោលវិធីនេះ គឺជា "ការធ្វើវិមជ្ឈការសមត្ថកិច្ចពីរដ្ឋាភិបាលទៅកម្រិតសាលារៀន។ ការទទួលខុសត្រូវ និងអំណាចធ្វើសេចក្តីសម្រេចលើប្រតិបត្តិការរបស់សាលារៀនត្រូវបានផ្ទេរទៅភ្នាក់ងារតាមមូលដ្ឋាន"។[80] គោលវិធីនេះផ្តោតសំខាន់លើសារៈសំខាន់នៃការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ក្នុងដំណើរការ និងការអភិវឌ្ឍសាលារៀនតាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន និងរបៀបផ្សេងទៀតនៃការជំរុញការគាំទ្ររបស់សហគមន៍ (សូមមើលផ្នែក ៣.១០)។ គណៈកម្មការនេះមានតួនាទីជានាការទទួលខុសត្រូវរបស់នាយកសាលា និងសហគមន៍ទាំងមូលលើការបង្កើនលទ្ធផលសិក្សារបស់សិស្ស។

គោលវិធីគ្រប់គ្រងតាមសាលារៀនដែលមានការសម្របសម្រួល និងស្តង់ដា គឺជាគោលដៅរបស់ក្រសួង ដែលចង់ឱ្យកើតមាននៅតាមសាលារដ្ឋ និងរួមមាន ៖

១ គណនេយ្យភាព ៖
ថ្នាក់ដឹកនាំសាលា និងបុគ្គលិកបង្រៀនទទួលខុសត្រូវចំពោះសហគមន៍មូលដ្ឋានដោយជានាលទ្ធផលសិក្សា គួរជាទីគាប់ចិត្តសម្រាប់សិស្ស និងប្រតិបត្តិការរដ្ឋបាល និងហិរញ្ញវត្ថុ។

២ ស្វ័យភាព ៖
គណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងមូលដ្ឋាន មានកាតព្វកិច្ចកំណត់ និងផ្តោតអាទិភាព លើបញ្ហានៅកម្រិតសាលារៀន តាមរយៈផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ដែលគួសបញ្ជាក់ពី អ្នកទទួលខុសត្រូវ និងធនធានចាំបាច់។

[79] F. No and S. Nguon. 2018. *Teacher Management and Redeployment: Practical Ways Forward.* Phnom Penh: MOEYS Education Research Council.
[80] B. Bruns, D. Filmer, and H. Patrinos. 2011. *Making Schools Work: New Evidence on Accountability Reform.* Washington, DC: World Bank. p. 13.

៣ ការវាយតម្លៃ ៖

គណៈកម្មការគ្រប់គ្រងសាលារៀន មានតួនាទីពិនិត្យតាមដានសមិទ្ធកម្មរបស់សាលារៀនផ្អែកតាមលទ្ធផលសិក្សារបស់សិស្ស (ឧ. គម្លាតចំណេះដឹង បំណិន និងសមត្ថភាពសិស្សចេញពីការវាយតម្លៃលើលទ្ធផល និងការវាយតម្លៃលើដំណើរការ) វត្តមានបុគ្គលិក និងវត្តមានសិស្ស និងលំហូរផ្សេងទៀតតាមរយៈសូចនាករនានាដូចជា ៖ ការឡើងថ្នាក់ ការត្រួតថ្នាក់ និងការធ្លាប់ចាកចេញពីសាលារៀន (បោះបង់ការសិក្សា)។

ក្រសួងអប់រំ យុវជន និងកីឡានឹងធានាថា គ្រប់សាលាមធ្យមសិក្សាទាំងអស់ ទោះបីស្ថិតនៅទីកន្លែងណា និងមានកម្រិតសមិទ្ធកម្មកម្រិតណាក៏ដោយ ត្រូវតែមានក្រុមដឹកនាំដែលមានគុណភាពខ្ពស់ ដើម្បីធ្វើការដឹកនាំការបង្រៀន និងដឹកនាំសមិទ្ធកម្ម/ស្នាដៃការងាររបស់សាលារៀនទាំងមូល។

ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំបញ្ជីបេក្ខជននាយកសាលាផ្ញើជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តអាចជ្រើសរើសបេក្ខជន ដែលមានសមត្ថភាព ក្នុងចំណោមបេក្ខជនដែលបានបញ្ចប់កម្មវិធីបណ្តុះបណ្តាលអំពីការដឹកនាំ និងគ្រប់គ្រងសាលារៀន។

នាយកសាលាត្រូវបានទទួលស្គាល់ថា ជាអ្នកដែលមានតួនាទីសំខាន់ជាងគេទី២ នៅក្នុងសាលារៀន (បន្ទាប់ពីគ្រូប្រចាំថ្នាក់) ដែលមានឥទ្ធិពលលើការសិក្សារបស់សិស្ស បើទោះជាដោយប្រយោលក៏ដោយ។[81] កម្មវិធីបណ្តុះបណ្តាល វិជ្ជាជីវៈដែលមានគុណភាព និងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ នឹងជួយធានាឱ្យសាលារៀនដំណើរការល្អ ហើយសិស្សទទួលបានលទ្ធផលសិក្សាល្អប្រសើរ ដែលនាំឱ្យមានការបង្កើនការជឿទុកចិត្តរបស់សាធារណជន និងការចូលរួមរបស់សហគមន៍ នៅក្នុងប្រព័ន្ធសាលារៀន។ នីតិវិធីរដ្ឋបាល និងភាពជាអ្នកដឹកនាំការបង្រៀន នឹងធ្វើឱ្យដំណើរការសាលារៀន ការបង្រៀនក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ កាន់តែមានភាពល្អប្រសើរ។ នាយកសាលា នឹងលើកទឹកចិត្តសកម្មភាពដឹកនាំនៅមូលដ្ឋាន សកម្មភាពសម្រេចចិត្ត និងសកម្មភាពកែលម្អសាលារៀន។

មន្ត្រីអប់រំនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ខេត្ត និងរាជធានីចាំបាច់ត្រូវប្រែក្លាយជាអ្នកមានសមត្ថភាពក្នុងការគ្រប់គ្រង និងអ្នកគាំទ្រដល់សាលារៀន តាមរយៈការផ្តល់ធនធាន ការបង្វឹក ការវាយតម្លៃសមិទ្ធកម្ម និងធានាឱ្យមានគណនេយ្យភាព និងការកែលម្អប្រព័ន្ធជាប់ជាប្រចាំ។

គោលការណ៍ណែនាំស្តីពី គោលវិធីគ្រប់គ្រងតាមសាលារៀន និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងនាយកសាលា នឹងដើរតួនាទីជាត្រីវិស័យសម្រាប់មន្ត្រីការិយាល័យ និងមន្ទីរអប់រំ យុវជន និងកីឡា ក្នុងការត្រួតពិនិត្យ និងគាំទ្រដល់សាលារៀនក្នុងមូលដ្ឋាន។អគ្គនាយកដ្ឋានអប់រំ នឹងសហការជាមួយការិយាល័យ/ផ្នែកមធ្យមសិក្សានៃការិយាល័យ និងមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីធានាការអនុលោមតាម និងវាយតម្លៃការកែលម្អសាលារៀនផ្អែកតាមគោលវិធីគ្រប់គ្រងតាមសាលារៀន។

[81] K. Leithwood and D. Jantzi. 2008. Linking Leadership to Student Learning: The Contributions of Leader Efficacy. *Educational Administration Quarterly.* 44 (4). pp. 496–528.

៤-៦. ធានាឱ្យសិស្សអាចឆ្លងភូមិសិក្សា និងទទួលបានជោគជ័យ

ប្រសិនបើ សិស្សមិនអាចរៀនចេះទៅតាមរបៀបដែលយើងបង្រៀនពួកគេនោះទេ ប្រហែលជាយើងគួរបង្រៀនទៅតាមរបៀបដែលពួកគេរៀនវិញ។[82]

ការពង្រឹងគណនេយ្យភាព និងសមិទ្ធកម្មរបស់គ្រូ និងនាយកសាលានៅថ្នាក់បឋមសិក្សានឹងជួយធានាឱ្យបានកាន់តែប្រសើរឡើង ក្នុងការឱ្យសិស្សរៀនថ្នាក់ទី៦ អាចឆ្លងភូមិសិក្សាទៅកម្រិតមធ្យមសិក្សាបឋមភូមិ ដោយមានបំណិនអាន សរសេរ និងលេខនព្វន្តសមស្របដែលចាំបាច់ ដើម្បីឱ្យពួកគេកាន់តែទទួលបានជោគជ័យក្នុងការអប់រំកម្រិតមធ្យមសិក្សា។

ការវាយតម្លៃបញ្ចប់ការអប់រំកម្រិតបឋមសិក្សា ដែលផ្តោតលើបំណិនអាន សរសេរ និងលេខនព្វន្ត នឹងកំណត់បានពីការត្រៀមខ្លួនរបស់សិស្សដែលអាចបន្តការសិក្សានៅសាលាមធ្យមសិក្សា ក៏ដូចជាសិស្សអ្នកដែលពុំទាន់មានសមត្ថភាពបំពេញបានទៅតាមលទ្ធផលរំពឹងទុក និងត្រូវទទួលការសិក្សាបំពេញបន្ថែម ឬ កម្មវិធីពន្លឿនការសិក្សា (ឧ. ការសិក្សាពេលវិស្សមកាល)។ អភិក្រមបែបនេះនឹងនាំឱ្យក្មេងជំទង់កាន់តែច្រើនថែមទៀត អាចបញ្ចប់ការអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ជំនួសឱ្យការធ្លាប់ចាកចេញពីសាលារៀន ដោយសារតែមិនទាន់អាចត្រៀមខ្លួនបន្តការសិក្សាទៅកម្រិតបន្ទាប់។

៤-៧. ការបញ្ចូលជំនាញសតវត្សរ៍ទី ២១

ការឆ្លើយតបចំពោះកង្វល់របស់វិស័យឯកជន និងវិស័យសាធារណៈអំពីកម្រិតនៃភាពអាចរកការងារធ្វើបានរបស់សិស្សដែលបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សា ក្រសួងត្រូវបន្តខិតខំបញ្ចូលបំណិនសតវត្សរ៍ទី២១ ទៅក្នុងការអប់រំគ្រប់កម្រិតទាំងអស់។

បំណិនទាំងនោះរួមមាន សមត្ថភាព និងឧបនិស្ស័យរៀនសូត្រ ដែលត្រូវបានកំណត់ដោយអ្នកអប់រំ អ្នកដឹកនាំធុរកិច្ច អ្នកសិក្សាស្រាវជ្រាវ និងស្ថាប័នរដ្ឋាភិបាល ថាចាំបាច់សម្រាប់សង្គម និងជាតម្រូវការរបស់ការងារក្នុងសតវត្សរ៍ទី ២១ (រូបភាពទី ១៤)។

រូបភាពទី ១៤៖ ជំនាញសតវត្សរ៍ទី ២១

មូលដ្ឋានគ្រឹះអក្ខរកម្ម លេខនព្វន្ត	សមត្ថភាព	បុគ្គលិកលក្ខណៈ
- តើសិស្សយកបំណិនស្នូលទៅអនុវត្តសម្រាប់កិច្ចការប្រចាំថ្ងៃដោយរបៀបណា	- តើសិស្សដោះស្រាយបញ្ហាប្រឈមដែលមានលក្ខណៈស្មុគស្មាញដោយរបៀបណា	- តើសិស្សឆ្លើយតបចំពោះបរិស្ថានដែលមានការផ្លាស់ប្តូររបស់ពួកគេដោយរបៀបណា
• អក្ខរកម្ម	• ការត្រិះរិះពិចារណាល្អិតល្អន់	• ការចង់ចេះ ចង់ដឹង
• លេខនព្វន្ត	• ការដោះស្រាយបញ្ហា	• ការផ្តួចផ្តើមគំនិត
• ចំណេះដឹងអំពី វិទ្យាសាស្ត្រ	• ភាពច្នៃប្រឌិត	• ភាពអំណត់
• ចំណេះដឹង ICT	• ការប្រាស្រ័យទាក់ទង	• ភាពសម្របខ្លួន
• ចំណេះដឹងហិរញ្ញវត្ថុ	• ការសហការ	• ភាពជាអ្នកដឹកនាំ
• ចំណេះដឹងអំពីវប្បធម៌ និងពលរដ្ឋវិជ្ជា		• ការយល់ដឹងអំពីសង្គម និងវប្បធម៌

ប្រភព៖ World Economic Forum at https://widgets.weforum.org/nve-2015/chapter1.html

[82] I. Estrada. https://www.linkedin.com/pulse/child-centered-school-improvement-case-study-herman-stewart/?trackingId=fbj3rSMYzPqL8BlaUSzYXA%3D%3D.

ជំនាញសតវត្សទី២១ ជាផ្នែកមួយដែលកំពុងមានការកើនឡើងនៅក្នុងចលនាអន្តរជាតិ គឺផ្តោតលើជំនាញដែលចាំបាច់ដើម្បីឱ្យសិស្សអាចត្រៀមខ្លួនទទួលបានជោគជ័យនៅក្នុងសង្គមឌីជីថល ដែលកំពុងមានការវិវត្តផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ ជំនាញជាច្រើនក្នុងចំណោមជំនាញទាំងនេះ ក៏មានទំនាក់ទំនងជាមួយនឹងការរៀនសូត្រកាន់តែស៊ីជម្រៅផ្នែកលើការចេះស្ទាត់នូវជំនាញនានា ដូចជា ការវិភាគរកហេតុផល ការដោះស្រាយបញ្ហាដែលមានលក្ខណៈស្មុគស្មាញ និងការធ្វើការជាក្រុមជាដើម។ ជំនាញទាំងនេះខុសពីបំណិនសិក្សាដែលបានទម្លាប់អនុវត្តពីមុនមក (បែបប្រពៃណី) ព្រោះថាជំនាញទាំងនេះ មិនផ្តោតតែទៅលើចំណេះលើផ្នែកដឹងខ្លឹមសារនោះឡើយ។ ដូចនេះ ជំនាញទាំងនេះ ប្រឈមនឹងវិធីសាស្រ្តគរុកោសល្យដែលផ្តោតលើការធ្វើតេស្ត ហើយដែលកំពុងប្រើប្រាស់នៅតាមសាលាមធ្យមសិក្សានៅកម្ពុជា ចំពោះគោលដៅគឺសមស្របមួយ ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្សនៅតាមសាលារៀនក្នុងប្រទេសកម្ពុជា ហើយទន្ទឹមនឹងនោះ គឺពង្រឹងមូលធនមនុស្សរបស់ប្រទេស។

ទោះយ៉ាងណា បច្ចុប្បន្ននៅមានបញ្ហាប្រឈមជាច្រើន ដែលនាំឱ្យរាំងស្ទះដល់ការបញ្ចូលជំនាញសតវត្សរ៍ទី២១ ទៅក្នុងការអប់រំ។ ការបារម្ភចម្បងជាងគេ គឺ**ការពុំមាន**សំណុំជំនាញទាំងនេះក្នុងកម្មវិធីសិក្សា ឬ ការវាយតម្លៃដែលមានស្រាប់។ អវត្តមានសំណុំជំនាញទាំងនេះក្នុងកម្មវិធីសិក្សា ឬការវាយតម្លៃ ជាហេតុនាំឱ្យសិស្ស គ្រូ និងនាយកសាលា កន្លងមកពុំទាន់បានទទួលជំនាញទាំងនេះ។ ដូចនេះ ត្រូវចោទសួរគឺ *តើគ្រូដែលពុំទាន់ចេះ និងយល់ជំនាញទាំងនេះនៅឡើយ អាចផ្ទេរ ឬបង្រៀន ជំនាញទាំងនេះ ទៅឱ្យសិស្សនាពេលអនាគតដោយរបៀបណា? តើប្រព័ន្ធអប់រំនឹងត្រូវបញ្ចូលជំនាញទាំងនេះ ដោយរបៀបណានៅពេលដែលគ្រូនិងនាយកសាលាមួយចំនួន កន្លងមកពុំបានទទួលការលើកទឹកចិត្តពីសង្គមកម្ពុជា ចំពោះការបង្ហាញសមត្ថភាពការផ្តួចផ្តើមគំនិតផ្ទាល់ខ្លួនក្នុងមុខវិជ្ជាវិទ្យាសាស្រ្ត ចំណេះដឹងខាងព័ត៌មានវិទ្យា និងបច្ចេកវិទ្យាសារគមនាគមន៍(ICT) ជំនាញត្រិះរិះពិចារណាល្អិតល្អន់ និងជំនាញដោះស្រាយបញ្ហា? តើគេអាចបង្រៀនជំនាញសតវត្សរ៍ទី ២១ ជាទស្សនាទានដាច់ដោយឡែក ឬត្រូវបង្កប់ក្នុងបរិបទនៃមុខវិជ្ជាជាក់លាក់?* (សូមមើលផ្នែក ៦.៣ ខាងក្រោម)។ ដូចនេះ ចាំបាច់ត្រូវអភិវឌ្ឍគ្រូ និងនាយកសាលា ដែលមានសមត្ថភាពឱ្យមានចំនួនច្រើនគ្រប់គ្រាន់ ទើបអាចបញ្ចូលជំនាញសតវត្សរ៍ទី២១ ទៅក្នុងការរៀនសូត្ររបស់សិស្សប្រកបដោយជោគជ័យ ទាំងលើខ្លឹមសារ(តើជំនាញទាំងនេះ គឺជាបំណិនអ្វី) និងដំណើរការ (របៀបប្រើប្រាស់ជំនាញទាំងនេះ)។ដើម្បីសម្រេចគោលដៅនេះ គ្រូត្រូវក្លាយទៅជា "អ្នករចនា (designers)" (អ្នកផ្តល់នូវគំនិតច្នៃប្រឌិត) ជាជាងជា "អ្នកប្រើប្រាស់"(ចំណេះដឹង)។

៤-៨. ការពង្រីកអភិក្រមបែបនវានុវត្តន៍

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ នៅកម្រិតមធ្យមសិក្សា ក្រសួងអប់រំ យុវជន និងកីឡាបានផ្តួចផ្តើមឱ្យមាននូវនវានុវត្តន៍ជាច្រើន ដូចបង្ហាញជូននៅក្នុងផ្នែក ១-១០។ អន្តរាគមន៍ និងអភិក្រមទាំងនេះគួរមាននិរន្តរភាពជាបន្តទៀត យកទៅអនុវត្តនៅកន្លែងផ្សេងទៀត និងបន្តអភិវឌ្ឍសម្រាប់អនុវិស័យទាំងមូល ដើម្បីជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សបន្ថែមទៀត។

*មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី(NGPRC)*បានចាប់ផ្តើមអនុវត្តកម្មវិធីរបស់ខ្លួនកាលពីឆ្នាំ២០១៨នៅទីតាំងវិទ្យាស្ថានជាតិអប់រំ។មជ្ឈមណ្ឌលនេះផ្តល់នូវកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់រយៈពេលមួយឆ្នាំដល់គ្រូនិងនាយកសាលាដើម្បីទទួលបានជំនាញផ្តល់ការណែនាំ និងជំនាញបង្វឹក ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិសម្រាប់យកទៅប្រើប្រាស់នៅតាមសាលារដ្ឋទូទាំងប្រទេស។ ជារៀងរាល់ឆ្នាំនឹងមានអ្នកបញ្ចប់ការសិក្សាពីកម្មវិធីនេះចំនួន ២៥ នាក់ ដែលទទួលបានចំណេះដឹង និងជំនាញថ្មីៗ លើផ្នែក៖ (១) ក្រមសីលធម៌វិជ្ជាជីវៈ និងការផ្តល់ការណែនាំ (២) ការស្រាវជ្រាវលើការអប់រំជាភាសាអង់គ្លេស (៣) ការប្រើប្រាស់ព័ត៌មានសារគមនាគមន៍ និងបច្ចេកវិទ្យា(ICT) នៅក្នុងការអប់រំ និង (៤) ប្រព័ន្ធ និងគោលការណ៍វិធីសាស្រ្តទូទៅ។ នេះ គឺជាអភិក្រមថ្មីមួយសម្រាប់សាលារៀននៅកម្ពុជាដែលនឹងផ្តល់ការគាំទ្រ ភ្លាមៗក្នុងជាទម្រង់ជាការផ្តល់ការណែនាំ និងការបង្វឹកដល់នាយកសាលា និងគ្រូប្រចាំថ្នាក់។

ការសិក្សាតាមបែបដោះស្រាយបញ្ហា (PBL) និងតាមបែបរិះរក (IBL) ក៏កំពុងត្រូវបានបញ្ចូលទៅតាមថ្នាក់រៀនកម្រិតមធ្យមសិក្សាជាច្រើនផងដែរ ដោយមានការបំពេញបន្ថែមពីការអប់រំ បច្ចេកវិទ្យា និងឌីជីថលនៅក្នុងករណីដែលអាចរកបាន។ គោលវិធីបង្រៀនផ្អែកតាមដោះស្រាយបញ្ហា (PBL) និងបែបរិះរក (IBL) គឺជាវិធីសាស្ត្រផ្ទាល់ ដើម្បីនាំយកបំណិនសតវត្សរ៍ទី២១ ទៅឱ្យសិស្ស និងគ្រូក្នុងថ្នាក់រៀន។ បំណិនធ្វើការជាក្រុម និងបំណិនត្រិះរិះពិចារណាកម្រិតខ្ពស់ បានអនុវត្តតាមរយៈការសហការគ្នានិងការប្រាស្រ័យទាក់ទងជាមួយគ្នា។[83] គោលវិធីរៀនសូត្របែបពិសោធន៍ទាំងនេះ គួបផ្សំនឹងការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងថ្នាក់រៀន បានផ្តល់ឱ្យសិស្សមធ្យមសិក្សាជាច្រើននូវផលប្រយោជន៍យ៉ាងច្រើននៅក្នុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩។

បណ្ណាល័យសតវត្សរ៍ទី ២១ កំពុងត្រូវបានដំឡើង និងផ្តល់សម្រាប់ឱ្យសិស្ស និងគ្រូប្រើប្រាស់នៅតាមសាលារដ្ឋ ដោយដំបូងឡើយចាប់ផ្តើមពីសាលារៀនជំនាន់ថ្មី ហើយបច្ចុប្បន្ននេះកំពុងអនុវត្តនៅតាមសាលាមធ្យមសិក្សាតាមបណ្តាខេត្តមួយចំនួនដោយមានការសហការជាមួយនឹងដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល។ នៅពេលសាលារៀនផ្តល់ការសិក្សាដល់សិស្សគ្រប់រូប បណ្ណាល័យទាំងនេះបណ្តុះវប្បធម៌អំណាន និងការស្រាវជ្រាវរបស់គ្រូ សិស្ស និងសហគមន៍ទូទៅ។

បន្ទប់រៀនវិទ្យាសាស្ត្រ ដែលជាចំណាយមានប្រសិទ្ធិភាព កំពុងត្រូវបានសាងសង់ឡើងនៅតាមសាលារៀនជំនាន់ថ្មី និងអគារធនធាន ព្រមទាំងនៅក្នុងសាលាបណ្តុះ ដើម្បីពង្រឹងការអភិវឌ្ឍជំនាញ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) នៅតាមសាលាមធ្យមសិក្សា។ ការអប់រំ STEM បានទទួលការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ដោយចាត់ទុកថា ជាធាតុផ្សំមួយដ៏សំខាន់នៃការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា (សូមមើលផ្នែក ៤-៩)។ ការផ្តល់ប្រឹក្សាអាជីពកំពុងផ្តួចផ្តើមអនុវត្តនៅតាមសាលាមធ្យមសិក្សាទូទាំងប្រទេស តាមរយៈគម្រោងអប់រំនានា និងមានការសហការជាមួយនឹងដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល។ ផ្នែកនេះ គឺជាកិច្ចខិតខំប្រឹងប្រែងដើម្បីផ្តល់ឱ្យសិស្សនូវព័ត៌មានបន្ថែមទៀតអំពីឱកាសអប់រំ និងឱកាសអាជីព។ គន្លងអប់រំ និងបណ្តុះបណ្តាលនឹងត្រូវរៀបចំឡើង ដើម្បីឱ្យសិស្ស និងមាតាបិតាសិស្សកាន់តែយល់ពីឱកាសអប់រំ និងបណ្តុះបណ្តាលរបស់ពួកគេ។

ដើម្បីធ្វើឱ្យស្ថានភាពរៀន និងបង្រៀនកាន់តែមានភាពល្អប្រសើរ ក្រសួងបានដាក់បញ្ចូលបច្ចេកវិទ្យាក្នុងការអប់រំ ក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានអប់រំគ្រូ។[84] គំនិតផ្តួចផ្តើមនេះនឹងគាំទ្រដល់ការបង្កើនការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការអប់រំ ទាំងក្នុងថ្នាក់រៀនផ្ទាល់ ទាំងពីចម្ងាយ។ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគណៈកម្មាធិការមួយ ដើម្បីសិក្សា និងរៀបចំយុទ្ធសាស្ត្រ ស្តីពីការអប់រំឌីជីថល រួមនឹងកម្មវិធីសិក្សាសម្រាប់ *"ការរៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិក"* សម្រាប់ការរៀនតាមប្រព័ន្ធអនឡាញ។[85] ដំបូង វីដេអូមេរៀនសម្រាប់ថ្នាក់ទី៩-១២ ត្រូវបានផលិត ដើម្បីផ្តល់ការបង្រៀនដល់សិស្សមធ្យមសិក្សា និងចុងក្រោយដល់សិស្សកម្រិតបឋមសិក្សា និងសិស្សដែលរៀននៅតំបន់ជនបទ និងតំបនដាច់ស្រយាល។

---

[83] Killen បានកំណត់គោលវិធីបង្រៀន ដែលមានប្រសិទ្ធភាពចំនួន ៩ សម្រាប់ការសិក្សារបស់សិស្ស ដែលគួរបញ្ចូលទៅក្នុងកម្មវិធី PRESET, ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការរៀន និងបង្រៀននៅថ្នាក់រៀន៖ (i) ការបង្រៀនដោយផ្ទាល់, (ii) ការពិភាក្សា, (iii) ការធ្វើការជាក្រុមតូច, (iv) ការរៀនបែបសហការគ្នា, (v) ការដោះស្រាយបញ្ហា, (vi) ការស្រាវជ្រាវ, (vii) ករណីសិក្សា, (viii) ការសំដែងតួ, និង (ix) ការសរសេរដោយខ្លួនឯង។ R. Killen. 2016. *Effective teaching strategies: Lessons from research and practice.* Melbourne: Cengage Learning Australia.

[84] D. Voun. 2020. Kingdom's Teachers Receive ICT Training. *Phnom Penh Post.* 19 June. p. 3.

[85] *Phnom Penh Post.* 2020. *Ministry of Education Outlines Key Strategies in Response to COVID-19.* 1 September. https://www.phnompenhpost.com/education/ministry-education-outlines-key-strategies-response-COVID-19.

ក្នុងដំណាក់កាលទី ១ នៃផែនទីបង្ហាញផ្លូវនេះ គម្រោង USESDP1 កំពុងសាងសង់មជ្ឈមណ្ឌលធនធានមធ្យមសិក្សា ១៤ នៅទូទាំងប្រទេស ខណៈដែល USESDP2 នឹងពង្រឹងបណ្តាញវិទ្យាល័យធនធានតាមរយៈការត្រួតពិនិត្យនិងការណែនាំដោយនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ជាតុចូលពីគោលវិធីគ្រប់គ្រងតាមសាលារៀន ការចូលរួមរបស់សង្គមស៊ីវិល (បន្ទប់រៀនវិទ្យាសាស្ត្រ ការផ្តល់ប្រឹក្សាអាជីព បណ្ណាល័យ សតវត្សរ៍ទី២១ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ល។) និងភាពជាដៃគូរវាងសាលាធនធានមធ្យមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអប់រំបណ្តុះបណ្តាលនិងវិជ្ជាជីវៈ (SRS-NFE-TVET) ក្នុងមូលដ្ឋាន និងអាជីវកម្មក្នុងមូលដ្ឋាន (វាគ្មិន ការចុះតាមកន្លែងធ្វើការ បទពិសោធន៍ការងារ ការចុះកម្មសិក្សា ការរៀនពីរមុខជំនាញ)។[86]

៤-៩. ការលើកកម្ពស់ការអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

បច្ចេកវិទ្យា និងមូលធនឌីជីថលនៅកម្រិតអន្តរជាតិមានការវិវត្តយ៉ាងឆាប់រហ័សឆ្ពោះទៅការបញ្ចូលបញ្ញាសិប្បនិម្មិត (AI) ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង។ បច្ចុប្បន្នមុខវិជ្ជា STEM បានទទួលការយកចិត្តទុកដាក់ពីគ្រូបង្រៀន អ្នកតាក់តែងគោលនយោបាយ និងដៃគូនានានៅក្នុងប្រទេសកម្ពុជា។ គម្រោងអប់រំដែលមានស្រាប់ និងកំពុងស្នើឡើងជាច្រើន សម្រាប់កម្រិតបឋមសិក្សា និងមធ្យមសិក្សា បានផ្តោតជាសំខាន់លើមុខវិជ្ជា STEM សម្រាប់ការអប់រំគ្រូ ការបង្រៀនក្នុងថ្នាក់រៀន និងធនធាន។

Annual STEM in Education event held in Phnom Penh
(Photo by STEM Education for Cambodia).

អាជីពនាពេលអនាគត តម្រូវឱ្យមានការសិក្សាមុខវិជ្ជា STEM នៅតាមសាលារៀន ហើយមុខវិជ្ជានីមួយៗ ត្រូវមានការបំពាក់បរិក្ខារ សម្រាប់សិស្សសិក្សាអនុវត្តពិសោធន៍ផ្ទាល់ និងសាកល្បងតួនាទី/មុខងារ ជាឧទាហរណ៍ អ្នកជីវវិទ្យាម៉ូលេគុល ចាំបាច់ត្រូវមានចំណេះវិជ្ជាពីមុខវិជ្ជាជីវវិទ្យា គីមីវិទ្យា ការសិក្សាអំពីហ្សែន និងស្ថិតិទើបអាចទទួលបានភាពស្ទាត់ជំនាញក្នុងការបំពេញការងាររបស់ពួកគេ។ ប្រការនេះ ក៏តម្រូវឱ្យគ្រូឯកទេសមុខវិជ្ជា (ថ្នាក់ទី ៦-១២) ផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រត្រូវមានចំណេះដឹង អំពីវិទ្យាសាស្ត្រ និងគណិតវិទ្យា និងធ្វើជាបុគ្គលគំរូដើម្បីលើកទឹកចិត្តសិស្ស ដែលជ្រើសរើសសិក្សាមុខវិជ្ជា និងជួយឱ្យពួកអាចបន្តទទួលបានការអប់រំក្រោយមធ្យមសិក្សា។ បន្ថែមពីនេះ ក្នុងម៉ោងសិក្សាមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្មនិងគណិតវិទ្យា(STEM) នៅតាមសាលាមធ្យមសិក្សា សិស្សចាំបាច់ត្រូវរៀនអនុវត្តជាក់ស្តែងផ្ទាល់លើមុខវិជ្ជាវិទ្យាសាស្ត្រ ដើម្បីជួយបង្កើនជំនាញសតវត្សរ៍ទី២១ (សូមមើលផ្នែក ៤-៧) ដល់ពួកគេ ។

[86] ការរៀនពីរមុខជំនាញសំដៅលើឱកាសរបស់សិស្សមធ្យមសិក្សាក្នុងការបញ្ចប់ការសិក្សារបស់ខ្លួន ក្នុងពេលចូលរួមវគ្គខ្លី ឬកម្មវិធីវិញ្ញាបនបត្រមូលដ្ឋានក្នុងសាលា TVET តាមមូលដ្ឋាន។

សន្ទស្សន៍យុគភាពយេនឌ័ររបស់កម្ពុជា តម្រូវឱ្យយើងថ្លឹងថ្លែងយកចិត្តទុកដាក់ទាំងព្រម ព្រោះថា ការយកចិត្តទុកដាក់លើតែទៅលើការបង្កើនការចូលរួមរបស់សិស្សស្រី្ត ហើយពុំបានគិតពីការចូលរួមរបស់សិស្សប្រុសនោះអាចនាំឱ្យមានផលវិបាកផ្សេងទៀតលេចឡើង ដូចជាកំណើនសិស្សប្រុសធ្លាប់ចាកចេញពីសាលារៀន។ ទន្ទឹមនឹងនោះ ខណៈពេលដែលផ្តល់សារៈសំខាន់យ៉ាងខ្លាំង និងកំពុងមានការប្រឹងប្រែងធ្វើឱ្យកាន់តែប្រសើរនូវកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងលទ្ធផលសិក្សាសម្រាប់មុខវិជ្ជា STEM ក៏ពុំមែនមានន័យថា ត្រូវមើលរំលងមុខវិជ្ជាវិទ្យាសាស្រ្តសង្គមឡើយ បើមិនដូច្នេះទេ បញ្ហាថ្មីទៀត នឹងកើតមាននាពេលអនាគតជាក់ជាមិនខាន ឧទាហរណ៍ ការខ្វះចំនួនអ្នកវិទ្យាសាស្រ្តសង្គម ដូចជា សិល្បករ អ្នកជំនាញតែងនិពន្ធ អ្នកប្រវត្តិសាស្រ្ត អ្នកជំនាញខាងភូមិសាស្រ្ត អ្នកជំនាញខាងចិត្តវិទ្យាអ្នកជំនាញខាងសង្គមវិទ្យា អ្នកជំនាញខាងភាសា សេដ្ឋវិទូ និងអ្នកជំនាញខាងហិរញ្ញវត្ថុ។[87]

ឈរលើមូលដ្ឋាននេះ ចាំបាច់ត្រូវមានការថ្លឹងថ្លែងឱ្យមានតុល្យភាព ដើម្បីជានាបានគ្រប់វិស័យទាំងអស់ទទួលបានការគាំទ្រ "ទាំងពីរ" ចៀសជាងផ្តោតលើ "មួយណា/អត់មួយណា"។ ដើម្បីរក្សាឱ្យបានតុល្យភាពអំណះអំណាងខាងលើនេះ ក៏ត្រូវអនុវត្តនៅក្នុងការអប់រំចំណេះទូទៅ និងបច្ចេកទេសផងដែរ។

នវានុវត្តន៍ទាំងនេះខាងលើ តម្រូវឱ្យមានការផ្តល់កម្មវិធីអប់រំគ្រូ ផ្តោតលើជំនាញដូចខាងក្រោម ៖

- បង្កើនបំណិន និងចំណេះដឹងរបស់គ្រូ ដែលបង្រៀននៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា ដើម្បីបង្រៀនតាមកម្មវិធីសិក្សា ដែលត្រូវបានកែសម្រួលជាថ្មី
- របៀបបង្កើនចំណាប់អារម្មណ៍របស់សិស្ស តាមរយៈការប្រើប្រាស់គោលវិធីបង្រៀន និងរៀនថ្មីៗ និងប្រើប្រាស់កម្មវិធីសិក្សាដែលត្រូវបានកែលម្អ ដោយមានបញ្ចូលបំណិនត្រិះពិចារណាកម្រិតខ្ពស់ ដែលឆ្លើយតបចំពោះយេនឌ័រ និងតម្រូវការផ្សេងៗ គ្នារបស់អ្នកសិក្សា
- ការដាក់បញ្ចូល ICT ក្នុងមុខវិជ្ជានានា ទន្ទឹមនឹងមុខវិជ្ជាបង្រៀនផ្សេងទៀត (ឧ.ប្រវត្តិវិទ្យាក្នុងមុខវិជ្ជាវិទ្យាសាស្រ្ត គណិតវិទ្យាក្នុងមុខវិជ្ជាភូមិវិទ្យា វិទ្យាសាស្រ្តក្នុងមុខវិជ្ជាភាសាខ្មែរ)
- បង្កើនការប្រើប្រាស់ឧបករណ៍បង្រៀនបែបជាការអនុវត្ត និងខ្លឹមសារដែលពាក់ព័ន្ធជាមួយនឹងជីវិតរស់នៅប្រចាំថ្ងៃ
- កសាងការយល់ដឹងរបស់សាធារណជនទូទៅ មាតាបិតាសិស្ស និងសិស្សអំពីមុខវិជ្ជា STEM តាមរយៈយុទ្ធនាការផ្សព្វផ្សាយ និងបង្កើនការយល់ដឹងទូទាំងប្រទេស។[88]

---

[87] Several countries have integrated Art Education into STEM creating a STEAM approach, which can be effective at primary, secondary, and tertiary levels. By integrating the Arts into STEM, STEAM-focused curricula incorporate the study of the humanities, language arts, dance, drama, music, visual arts, design, new media, etc. Creative skills and knowledge of the arts, such as design, writing and history, help STEM employees solve problems in more innovative ways.

[88] The 15th Annual Cambodia STEM Festival (2019), Cambodia's first GREEN STEM festival, highlighted some of the brightest talents from public and private schools all around Cambodia. Presented by STEM Education Organization for Cambodia and STEAM Cambodia with the support from the Ministry of Education Youth and Sport, and the Ministry of Environment, the 16th Annual Festival was held online during January 2021.

៤-១០. ការបង្កើនភាពជាដៃគូនៅថ្នាក់តំបន់ក្នុងផ្នែកមុខវិជ្ជាសិក្សា

បង្កើនការផ្តួបកម្លាំងគ្នាឱ្យបានខ្លាំងក្លាសម្រាប់ការអប់រំមុខវិជ្ជា STEM តាមរយៈគំនិតផ្តួចផ្តើមរួមគ្នានៅក្នុងតំបន់អាស៊ាន ដោយប្រើប្រាស់ភាសាអង់គ្លេសជាភាសារួម។

មជ្ឈមណ្ឌលតំបន់សម្រាប់ការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យានៃអង្គការរដ្ឋមន្ត្រីអប់រំនៅអាស៊ីអាគ្នេយ៍ (SEAMEO-RECSAM) គឺជាស្ថាប័នដែលល្អបំផុតដើម្បីដឹកនាំគំនិតផ្តួចអាស៊ានក្នុងការរៀបចំម៉ូឌុល កម្មវិធីសិក្សាដែលសមស្របសម្រាប់ប្រើប្រាស់តាមរយៈមធ្យោបាយចម្រុះ។ SEAMEO-RECSAM មានតួនាទីដ៏សំខាន់សម្រាប់ជួយដល់គ្រប់បណ្តាប្រទេស SEAMEO ទាំងអស់ក្នុងការរៀបចំទាំងវិធីសាស្ត្រ ទាំងឯកសារសម្រាប់ការអប់រំមុខវិជ្ជា STEM។ គំនិតផ្តួចផ្តើមខាងលើនេះតម្រូវឱ្យរដ្ឋមន្ត្រីក្រសួងអប់រំនៅក្នុងតំបន់នេះធ្វើការងាររួមគ្នា ដើម្បីកសាងរចនាសម្ព័ន្ធសហការឱ្យបានរឹងមាំ សម្រាប់ចែករំលែកធនធាន និងឯកសារនានា ចៀសជាងជំរុញឱ្យប្រទេសនីមួយៗ ចាប់ផ្តើមស្វះស្វែងបង្កើតធនធានថ្មីឡើងវិញ (Re-inventing the wheel) សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា។ ការធ្វើឱ្យកាន់តែប្រសើរនូវការអប់រំមុខវិជ្ជា STEM នឹងផ្តល់ឱ្យសិស្សនូវជំនាញដែលចាំបាច់ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈម ក្នុងពិភពលោក ដែលកំពុងមានការប្រែប្រួល ដោយសារការវិវត្តរបស់វិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា។ ការអប់រំមុខវិជ្ជាSTEM ក៏ផ្តល់នូវមូលដ្ឋានគ្រឹះដល់សិស្សនៅតាមសាលារៀន និងដើម្បីឱ្យនិស្សិតបញ្ចប់ការសិក្សាជំនាញ STEM មានសមត្ថភាពឆ្លើយតបចំពោះបញ្ហាប្រឈមនៃបដិវត្តន៍ឧស្សាហកម្ម ៤.០។

អង្គការស្ថាប័នជាច្រើននៅក្នុងតំបន់ ដូចជា *មជ្ឈមណ្ឌលសិក្សាភាសាអង់គ្លេសថ្នាក់តំបន់របស់ SEAMEO (SEAMEO-RELC)* នៅក្នុងប្រទេសសិង្ហបុរី និង*មជ្ឈមណ្ឌលនវានុវត្តន៍ និងបច្ចេកវិទ្យា SEAMEO (SEAMEO-INNOTECH)* នៅទីក្រុងម៉ានីល ដែលក្រសួង ឬអគ្គនាយកដ្ឋានពាក់ព័ន្ធ គួរធ្វើទំនាក់ទំនងដើម្បីទទួលបានធនធានបន្ថែមសម្រាប់ការសិក្សាលើមុខវិជ្ជា STEM។ ក្រសួងអប់រំ យុវជន និងកីឡាគួរដើរតួនាទីជាអ្នកដឹកនាំដ៏សកម្ម ក្នុងគំនិតផ្តួចផ្តើមថ្នាក់តំបន់នានា ដើម្បីកសាងនូវរចនាសម្ព័ន្ធសហការឱ្យបានរឹងមាំ និងចែករំលែកធនធាន ឯកសាររវាងគ្នាទៅវិញទៅមក ជាជាងឱ្យសាលារៀន ឬ គ្រូបង្រៀនទំនាក់ទំនងគ្នាដាច់ដោយឡែកៗនោះ។ អគ្គនាយកដ្ឋាន និងនាយកដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡាត្រូវមានការចូលរួម និងបន្តធ្វើការចែករំលែក តាមរយៈមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្រុង ខណ្ឌ ដើម្បីធ្វើការផ្សព្វផ្សាយ និងវាយតម្លៃការអនុវត្តឯកសារទាំងនេះនៅក្នុងសាលារៀន។

ដូចលើកឡើងពីខាងដើម ក្នុងផ្នែកគន្លងអប់រំ និងបណ្តុះបណ្តាល (សូមមើលផ្នែក ៤.២) ក្របខណ្ឌគុណវុឌ្ឍិអាស៊ានក៏ជាឯកសារយោងមួយដ៏សំខាន់ថ្នាក់តំបន់ សម្រាប់ឯកសារផែនទីបង្ហាញផ្លូវស្តីពី ការអប់រំមធ្យមសិក្សានេះផងដែរ ព្រោះឯកសារនេះពាក់ព័ន្ធនឹងការរៀបចំ និងការផ្សព្វផ្សាយពីគន្លងអប់រំ និងបណ្តុះបណ្តាលដល់សិស្សនិស្សិត និងមាតាបិតា។

៤-១១. ការលើកកម្ពស់ការអប់រំមធ្យមសិក្សាបច្ចេកទេស

កាលពីពេលថ្មីៗនេះក្រសួងអប់រំយុវជននិងកីឡាបានគូសបញ្ជាក់សាជាថ្មីពីសារៈសំខាន់នៃការអភិវឌ្ឍការអប់រំមធ្យមសិក្សាបច្ចេកទេសនៅកម្ពុជា ដើម្បីបំពេញបន្ថែមការអប់រំមធ្យមសិក្សាចំណេះទូទៅ និងបំពាក់បំប៉នសិស្សដែលមានចំណាប់អារម្មណ៍ចង់បម្រើការងារនៅក្នុងវិស័យរដ្ឋ និងឯកជន។

ក្នុងឆ្នាំ ២០១៥ ផែនការគោលមួយត្រូវបានរៀបចំឡើង ដើម្បីបង្កើតវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស នៅក្នុងប្រព័ន្ធអប់រំ។ ចក្ខុវិស័យសម្រាប់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស គឺ "សិស្សទទួលបានចំណេះដឹង ជំនាញបច្ចេកទេស និងគុណតម្លៃ ក្រមសីលធម៌ល្អបំផុត ដើម្បីឆ្លើយតបចំពោះតម្រូវការទីផ្សារការងារ និងបន្តការសិក្សាពេញមួយជីវិត"។[89] វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស មានបេសកកម្មផ្តល់ការតម្រង់ទិស លើកកម្ពស់ និងផ្តល់សេវាអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ តាមរយៈការសហការជាមួយនឹងតួអង្គពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា។ ផែនការគោលនេះបានដាក់ចេញនូវគោលដៅដូចខាងក្រោម ៖

- បង្កើតប្រព័ន្ធអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ
- បង្កើតស្តង់ដាសម្រាប់កម្មវិធីសិក្សាបច្ចេកទេស
- បង្កើត និងពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ដែលមានស្តង់ដានៅតាមគ្រប់រាជធានី ខេត្តទាំងអស់
- បង្កើតអត្រាចូលរៀននៅក្នុងការអប់រំបច្ចេកទេស ដើម្បីឱ្យយុវជនកម្ពុជាកាន់តែច្រើននាក់អាចទទួលបានការអប់រំ និងបំប៉ននូវជំនាញដែលសមស្រប រកការងារសមរម្យបានធ្វើ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

គោលបំណងនៃផែនការគោលនេះ នឹងនាំឱ្យមានការបង្កើតវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយនៅតាមខេត្តនីមួយៗ ដែលផ្តល់នូវកម្មវិធីអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលប្រើប្រាស់កម្មវិធីសិក្សាដែលមានលក្ខណៈស្តង់ដាកម្រិតខ្ពស់ និងជំរុញបង្កើនការចូលរៀនរបស់សិស្សនៅក្នុងកម្មវិធីអប់រំបច្ចេកទេស។ បញ្ញាថវិកាមានកំណត់ ជម្រើសសម្រាប់វិនិយោគមូលធន គួរមានការសាងសង់ និងគ្រប់គ្រងអន្តេវាសិកដ្ឋានឱ្យបានល្អប្រសើរ ដើម្បីឱ្យសិស្សដែលមកពីតំបន់ឆ្ងាយៗ អាចចូលរួមនៅក្នុងការអប់រំមធ្យមសិក្សាបច្ចេកទេសបាន។ លើសពីនេះ កម្មវិធីអប់រំចំណេះទូទៅ និងបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ គួរបង្កើតគន្លងសិក្សាច្បាស់លាស់មួយដែលភ្ជាប់ពីកម្រិតមធ្យមសិក្សាបឋមភូមិនិងទៅក្រោយកម្រិតមធ្យមសិក្សា និងមជ្ឈដ្ឋានការងារ ដោយអាស្រ័យទៅតាមផែនការអប់រំ និងការងារផ្ទាល់ខ្លួនរបស់សិស្ស ។

Senior GTHS students studying electronics *(Photo by MOEYS Vocational Orientation Department).*

គោលដៅនេះ អាចសម្រេចបានតាមរយៈការរៀបចំគន្លងអប់រំ បណ្តុះបណ្តាលនិងអាជីព ដូចដែលត្រូវបានស្នើឡើង។ ការអប់រំបច្ចេកទេសតម្រូវឱ្យមានកិច្ចពិគ្រោះយោបល់ និងការសម្របសម្រួលឱ្យបានជិតស្និទ្ធជាមួយនឹងវិស័យឯកជន ដើម្បីដឹងពីតម្រូវការក្នុង វិស័យឯកជន កម្មវិធីបណ្តុះបណ្តាល កម្មវិធីសិក្សា ធនធាន ការចូលរួមរបស់សាលារៀន បទពិសោធន៍ការងារ និងកម្មវិធីហាត់ការ ព្រមទាំងការវាយតម្លៃសមិទ្ធកម្ម។ ក្រសួងអប់រំ យុវជន និងកីឡា និងសហការជាមួយនឹងសង្គមស៊ីវិល ក៏ដូចជា ដៃគូអភិវឌ្ឍនានា ដើម្បីយកការអនុវត្តល្អៗទាំងនេះទៅអនុវត្តបន្ថែមទៀត។ អង្គការស្នាមញញឹមនៃកុមារ (PSE), ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA), ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA), និងដុនបូស្កូជាអង្គការ ក្នុងចំណោមអង្គការមួយចំនួនដែលបានបង្កើតសាលា និងមជ្ឈមណ្ឌលអប់រំបច្ចេកទេសប្រកបដោយជោគជ័យ។

សិស្សបញ្ចប់ការសិក្សាពីសាលារៀនទាំងនេះបានចូលទៅក្នុងកម្លាំងពលកម្មទាំងក្នុងប្រទេសកម្ពុជា ទាំងក្រៅប្រទេស។ ការឧបត្ថម្ភធនពីរដ្ឋសម្រាប់ការបោះទុនរួមគ្នាជាមួយនឹងតួអង្គមិនមែនរដ្ឋ ដោយមានកំណត់លក្ខខណ្ឌសមិទ្ធកម្មឱ្យបានតឹងរ៉ឹង គឺជាអ្វីដែលធ្លាប់ធ្វើកន្លងមកនៅក្នុងគំរូសាលារៀនជំនាន់ថ្មី។

[89] MOEYS. 2015. *Master Plan for Technical Education at Upper Secondary Level (2015–2019).* Phnom Penh: Vocational Orientation Department. p. 8.

៤-១២. ការពង្រីកបណ្ដាញរវាងសាលារៀន និងធុរកិច្ចនៅក្នុងមូលដ្ឋាន

ក្រសួងអប់រំ យុវជន និងកីឡា នឹងបង្កើតបណ្ដាញរវាងសាលារៀន និងធុរកិច្ចក្នុងមូលដ្ឋាន ដែលស្ថិតនៅក្នុងទីរួមខេត្តជុំវិញវិទ្យាល័យធនធានចាប់ពីឆ្នាំ២០២០-២០២៤ និងបន្ទាប់ទៀត។

បណ្ដាញទាំងនេះនឹងភ្ជាប់ទំនាក់ទំនងសាលាមធ្យមសិក្សាក្នុងបណ្ដាញនីមួយៗ(វិទ្យាល័យធនធាន១និងសាលាមធ្យមសិក្សាបណ្ដាញចំនួន ៥) ជាមួយនឹងមជ្ឈមណ្ឌលសិក្សាសហគមន៍ មជ្ឈមណ្ឌលអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ មជ្ឈមណ្ឌលមុខរបរ និងធុរកិច្ចនៅក្នុងមូលដ្ឋាន។ ភាពជាដៃគូទាំងនេះនឹងនាំឱ្យមានកិច្ចពិគ្រោះយោបល់ និងការរៀបចំផែនការជាប់ជាប្រចាំ រវាងសមាជិកបណ្ដាញ ដើម្បីគាំទ្រឱ្យសិស្សអាចទទួលបានបទពិសោធន៍ការងារ និងចូលរួមក្នុងកម្មវិធីហាត់ការ ការប្រឹក្សាអាជីព ចូលរួមស្ដាប់វាគ្មិនកិត្តិយស ការចុះផ្សព្វផ្សាយពី សាកលវិទ្យាល័យ ការចុះទៅកាន់ទីតាំងធុរកិច្ច ការចុះទៅសិក្សា ស្វែងយល់ពីការផ្ដល់សេវាសាធារណៈ (ឧទាហរណ៍ នៅតាមសាកលវិទ្យាល័យ មន្ទីរពេទ្យ កន្លែងផ្ដល់សេវាសង្គ្រោះបន្ទាន់។ល។)ការបែងចែកធនធានការបណ្ដុះបណ្ដាលវិជ្ជាជីវៈ(នៅតាមសាលារៀននិងនៅកន្លែងធ្វើការ)កម្មវិធីអប់រំជាជម្រើសផ្សេងទៀតព្រមទាំងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់មន្ត្រីអប់រំ។ការសហការគ្នាទាំងនេះនឹងនាំឱ្យមានការប្រើប្រាស់ធនធាន មនុស្ស ធនធានហិរញ្ញវត្ថុ និងសម្ភារបរិក្ខារកាន់តែស័ក្តិសិទ្ធ និងកាន់តែមានប្រសិទ្ធភាព (ពោលគឺ សាលាមធ្យមសិក្សាក្លាយជាមជ្ឈមណ្ឌលសហគមន៍សម្រាប់ការអប់រំក្រៅប្រព័ន្ធនិងកម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈការប្រើប្រាស់បណ្ណាល័យ សកម្មភាពក្រៅកម្មវិធីសិក្សា និងបន្ថែមលើកម្មវិធីសិក្សា សកម្មភាពនៅក្នុងសហគមន៍។ល។)។



សិស្សមធ្យមសិក្សាដែលចាប់អារម្មណ៍ នឹងចូលរៀនវគ្គបណ្ដុះបណ្ដាលដែលផ្ដល់នៅតាមមជ្ឈមណ្ឌលTVETជាផ្នែកមួយនៃការអប់រំកម្រិតមធ្យមសិក្សារបស់ពួកគេ (ឧទា. ចូលរៀននៅមជ្ឈមណ្ឌល TVET ជារៀងរាល់សប្ដាហ៍ ដើម្បីបញ្ចប់វគ្គវិជ្ជាជីវៈ វិញ្ញាបនបត្រកម្រិតទី១) ដែលធ្វើឱ្យពួកគេអាចទទួលបានវិញ្ញាបនបត្រអប់រំចំណេះទូទៅ និងវិញ្ញាបនបត្រ TVET បន្ទាប់ពីរៀនចប់ថ្នាក់ទី១២។ សាលាមធ្យមសិក្សាក៏អាចសហការបន្ថែមទៀតជាមួយនឹងមជ្ឈមណ្ឌលការងារ ដែលមាននៅតាមមជ្ឈមណ្ឌលបណ្ដុះបណ្ដាលថ្នាក់ខេត្តដូចជាការរៀបចំទស្សនកិច្ចមកកាន់សាលារៀន និងការផ្សព្វផ្សាយព័ត៌មានអំពីការងារនៅក្នុងបណ្ណាល័យរបស់សាលាជាដើម។ លើសពីនេះ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលខេត្ត ក៏គួរប្រើប្រាស់គ្រូបង្រៀនរួមគ្នាផងដែរ ដើម្បីជួយឆ្លើយតបចំពោះបញ្ហាខ្វះគ្រូដែលមានសមត្ថភាពផ្នែកការអប់រំបច្ចេកទេស។[90]

លើសពីនេះ ក៏គួរមានការលើកទឹកចិត្តឱ្យមានការបង្កើតភាពជាដៃគូជាមួយនឹងសាលារៀនប្រភេទសាលារៀនជំនាន់ថ្មី និងសាលារៀនអន្តរជាតិដែលមានគុណភាពខ្ពស់ ដើម្បីចែករំលែកដល់សាលាមធ្យមសិក្សារដ្ឋអំពីរបៀបបង្រៀន ដឹកនាំ និងគ្រប់គ្រង។

[90] See Appendix 3: Provincial and Vocational Training and Job Centers

ការបង្រៀន និងគ្រប់គ្រងថ្នាក់រៀន នឹងទទួលបានអត្ថប្រយោជន៍ច្រើន ពីការផ្លាស់ប្តូរទស្សនកិច្ចសិក្សាទៅកាន់សាលាដៃគូ ដោយទស្សនកិច្ចសិក្សានេះផ្តោតជាពិសេស លើការដោះដូរបទពិសោធន៍របស់គ្រូលើការប្រឹក្សាគរុកោសល្យ និងការផ្តល់ការណែនាំ។ ពួកគេអាចបង្កើតសហគមន៍អ្នកសិក្សាវិជ្ជាជីវៈរវាងសាលារដ្ឋ និងសាលាអន្តរជាតិ ដែលមានការដឹកនាំសាលារៀនបានល្អ។

៤-១៣. ការឆ្លើយតបចំពោះកំណើននៃការអប់រំនៅកម្រិតមធ្យមសិក្សា

ការចូលរៀននៅមធ្យមសិក្សានាពេលអនាគតនឹងមានការកើនឡើង ដែលទាមទារឱ្យមានការវិភាគទិន្នន័យ និងការបង្កើតផែនទីឌីជីថលតាមបែបទំនើប (កម្មវិធីបង្កើតរូបភាពឌីជីថល) ដើម្បីកំណត់ពីទីតាំងនៅក្នុងប្រទេស ដែលមានតម្រូវការអគារថ្មី ការកែលម្អ និងការស្តារឡើងវិញ និងការពង្រាយគ្រូ។ ចំណុចនេះ គួរតែជាផ្នែកមួយនៃការរៀបចំផែនការយុទ្ធសាស្ត្ររៀងរាល់ឆ្នាំរបស់ក្រសួង។

សិស្សរៀននៅតាមសាលាមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ បាននិងកំពុងបន្តកើនឡើង ក្នុងទសវត្សចុងក្រោយនេះ ហើយត្រូវបានព្យាករណ៍ថា នឹងបន្តកើនឡើង ដោយហេតុថា អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សា ទៅមធ្យមសិក្សាបឋមភូមិកាន់តែខ្ពស់ និងការពង្រីកចំនួនសាលារៀន (រូបភាពទី ២០)។

រូបភាពទី ១៥៖ ការធ្វើចំណោល ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិពី ២០១៣ ដល់ ២០៣១



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ២០១៨-២០១៩

ការព្យាករណ៍រំពឹងថា ការចូលរៀននៅសាលាមធ្យមសិក្សាបឋមភូមិនឹងកើនឡើង ៣១% នៅទសវត្សបន្ទាប់ ខណៈពេលដែលការចូលរៀននៅសាលាមធ្យមសិក្សាទុតិយភូមិ នឹងកើនឡើង ៣០% (រូបភាពទី ១៦)។ ដើម្បីតាមដានការផ្លាស់ប្តូរទាំងនេះ ចាំបាច់ត្រូវមានការវិភាគទិន្នន័យឱ្យបានសុក្រឹត និងការរៀបចំផែនទីឌីជីថល (ការបង្កើតរូបភាពឌីជីថល) សម្រាប់ឱ្យអ្នកធ្វើផែនការធ្វើការសម្រេចឱ្យបានត្រឹមត្រូវសម្រាប់ទសវត្សខាងមុខនេះអំពីចំណុចដៅ ដើម្បីឱ្យកម្មវិធីហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងការអភិវឌ្ឍ និងការបែងចែកធនធានមនុស្សកាន់តែប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។ កត្តានានាដូចជា ថ្នាក់រៀនដែលមានសិស្សច្រើនពេក ផលធៀបគ្រូ-សិស្ស និងផលធៀបសិស្ស-ថ្នាក់ កាន់តែធំ បញ្ហាខ្វះ និងលើសគ្រូ និងការធ្វើចំណាកស្រុកក្នុងប្រទេស អាចកំណត់រកដោយប្រើកម្មវិធីបង្កើតរូបភាពឌីជីថល។ ព័ត៌មានទាំងនេះ នឹងគាំទ្រដល់ការវិនិយោគមូលធនជាយុទ្ធសាស្ត្រ ដោយក្រសួងអប់រំ យុវជន និងកីឡាលើសាលារៀនមានស្រាប់ និងសាលារៀនថ្មី។ ដើម្បីឱ្យមានកំណែទម្រង់នេះ អង្គភាពវិភាគស្ថិតិនឹងត្រូវបានបង្កើតឡើងនៅក្នុងអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ ដើម្បីបង្កើតមូលដ្ឋានទិន្នន័យដែលមានគុណភាពសម្រាប់ការរៀបចំផែនការដោយនាយកដ្ឋានពាក់ព័ន្ធ។

រូបភាពទី ១៦៖ ចំណោលសិស្សបញ្ចប់ការសិក្សាពីកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ២០១៣ ដល់ ២០៣១



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ២០១៨-២០១៩

ប្រការសំខាន់សម្រាប់ឆ្លើយតបចំពោះការកើនឡើងនូវចំនួនសិស្ស គឺការបង្កើនចំនួនសាលារៀន ដើម្បីផ្តល់ការអប់រំកម្រិតមធ្យមសិក្សា។ ចំនួនសាលារៀនមធ្យមសិក្សាដែលមានថ្នាក់ទី ៧-៩ មានត្រឹមតែ ១ ២១៤ ក្នុងឆ្នាំសិក្សា ២០១៨-២០១៩ ដោយឡែក ចំនួនសាលាមធ្យមសិក្សា ដែលមានពីថ្នាក់ទី ៧-១២ មាន ៤៩៣ រីឯសាលាមធ្យមសិក្សាទុតិយភូមិដែលមានថ្នាក់ទី១០-១២ មាន ៣២ (រូបភាពទី ២២) ក្នុងចំណោមសាលារៀនមធ្យមសិក្សាសរុប ១ ៧៣៩។

ការវិនិយោគមូលធនលើការអប់រំមធ្យមសិក្សា មានការប្រែប្រួលតិចតួចតែប៉ុណ្ណោះពីឆ្នាំ ២០១៤-២០២០ ដោយចំនួនសាលាមធ្យមសិក្សាបឋមភូមិកើនឡើង តិចជាង ១% ឬ មានសាលាថ្មីតែពីរប៉ុណ្ណោះ។ កន្លងមក ចំនួនបន្ទប់រៀនមធ្យមសិក្សាបឋមភូមិ មានការកើនឡើង ៥,៥% ក្នុងរយៈពេលដូចគ្នានេះ ដែលជាកំណើនថេរប្រចាំឆ្នាំ ទោះបីជាចំនួនបន្ទប់រៀនថ្មីនៅទាបក៏ដោយ។ ចំនួនសាលាមធ្យមសិក្សាទុតិយភូមិកើនឡើង ៨១ ឬ ស្មើនឹង ១៨% ក្នុងរយៈពេលដូចគ្នានេះ។

រូបភាពទី ១៧៖ សាលារៀនមធ្យមសិក្សា ២០១៤-២០១៩



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ២០១៨-២០១៩

កន្លងមកចំនួនថ្នាក់មធ្យមសិក្សាទុតិយភូមិកើនឡើង២០,៦%ក្នុងរយៈពេល៥ឆ្នាំដែលជាកំណើនថេរប្រចាំឆ្នាំ។កំណើនខ្ពស់ជាងគេ គឺនៅក្នុងឆ្នាំសិក្សា ២០១៨-២០១៩ នៅពេលដែលមានការបន្ថែមបន្ទប់រៀនថ្មីចំនួន ៨០០ បន្ថែមទៀត ជាមួយសាលាមធ្យមសិក្សាទុតិយភូមិថ្មីចំនួន ១៤ មានការគាំទ្រពីថវិការបស់ដៃគូអភិវឌ្ឍ។

៤-១៤. និម្មាបនកម្មសាលារៀនសម្រាប់សតវត្សរ៍ទី ២១

ការរចនាប្លង់ និងធ្វើបច្ចុប្បន្នកម្មប្លង់សាលារៀន ត្រូវចាប់ផ្តើមចេញពីសាលាមត្តេយ្យសិក្សាទៅ ដើម្បីនាំកុមារតូចៗឱ្យស្គាល់ពីបច្ចេកវិទ្យា និងបច្ចេកទេសថ្មីៗ និងបានរៀនសូត្រតាំងពីវ័យក្មេង ធ្វើបែបនេះ នៅពេលពួកគេឈានចូលសាលាមធ្យមសិក្សាពួកគេនឹងមានសមត្ថភាពកម្រិតខ្ពស់រួចទៅហើយ។ ស្តង់ដាសេវាអប្បបរមា នឹងត្រូវបានបង្កើតឡើងសម្រាប់សាលារៀនទាំងអស់ ដើម្បីធានាថាមានចន្លោះ និងការពង្រាយគ្រូគ្រប់គ្រាន់ធៀបនឹងចំនួនសិស្ស សម្ភារឧបទេសបង្រៀន និងរៀន គ្រឿងសង្ហារិម និងបរិក្ខារ និងទឹកស្អាត និងអនាម័យ។

Kampong Cham New Generation School
(Photo by Kampuchean Action to Promote Education).

នៅតំបន់ទីប្រជុំជន ជនបទ និងដាច់ស្រយាល សាលារៀនថ្មី នឹងមានទំហំ និងលំហរគ្រប់គ្រាន់សម្រាប់ការបង្រៀន និងរៀន បណ្ណាល័យ មន្ទីរពិសោធន៍ បន្ទប់ប្រជុំ កន្លែងធ្វើការរបស់គ្រូ និងការិយាល័យរដ្ឋបាល។ ការរចនាប្លង់នឹងផ្តល់លំហរដែលមានភាពបត់បែនទៅតាមការប្រើប្រាស់ដែលចង់បាន។ បន្ទប់រៀនបែបពហុបំណង គឺមានប្រសិទ្ធភាពជាង សម្រាប់ការសម្រួលដល់ការអនុវត្តគោលវិធីបង្រៀន និងរៀនថ្មីបែបសកម្ម ដែលក្រសួងអប់រំ យុវជន និងកីឡា និងអ្នកផ្តល់ជំនួយ ប្រឹងប្រែងលើកកម្ពស់ ខណៈពេលដែលស្ថាប័នទាំងនេះព្យាយាមបំពាក់បំប៉នយុវជនកម្ពុជាឱ្យចេះសម្របខ្លួនទៅតាមសង្គម និងសេដ្ឋកិច្ចក្នុងសតវត្សរ៍ទី ២១។

សាលាមធ្យមសិក្សាទាំងអស់នៅកម្ពុជានឹងមានសម្ភាររូបវន្តចាំបាច់សំខាន់ៗដូចជា ប្រព័ន្ធផ្គត់ផ្គង់ទឹកសមស្រប បង្គន់បែងចែកតាមយេនឌ័រ បន្ទប់សុខភាពសម្រាប់សិស្ស និងអាហារដ្ឋានដែលជាកត្តាលើកកម្ពស់សុខុមាលភាពរបស់សិស្ស និងឥរិយាបថរបស់ពួកគេចំពោះសាលារៀន។

៤-១៥. ការផ្តល់ហិរញ្ញប្បទានអប់រំ

ដូចបង្ហាញនៅក្នុងរូបភាពទី១៨រាជរដ្ឋាភិបាលបានបង្កើនចំណាយសម្រាប់វិស័យអប់រំជារៀងរាល់ឆ្នាំរហូតដល់៨២៧,៣៧លានដុល្លារ ក្នុងឆ្នាំសិក្សា ២០១៩-២០២០។ បើធៀបនឹងឆ្នាំសិក្សា ២០១៤-២០១៥ ថវិកាកើនឡើង ២,៥ដង។ ប៉ុន្តែដូចបង្ហាញដូចខាងក្រោម ជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងច្រើនមកលើនិន្នាការនេះ។

---

[91] MOEYS. 2020b. *School Architecture for a New Century: New Generation School Designs and Guidelines for Aesthetic Infrastructure Investment.* Phnom Penh.

រូបភាពទី ១៨៖ ចំណាយសាធារណៈក្នុងវិស័យអប់រំ (គិតជា លានដុល្លារអាមេរិក)



ប្រភព៖ ធនាគារពិភពលោក (២០១៩) *គម្រោងកែលម្អការអប់រំចំណេះទូទៅនៅកម្ពុជា (P174335)*៖ ឯកសារទស្សនទាន ទីក្រុងភ្នំពេញ

ការសន្មតដែលត្រូវបានប្រើប្រាស់ដើម្បីព្យាករណ៍ធនធាននិងកំណត់ពីកង្វះធនធានថវិកានៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ត្រូវបានចាត់ទុកថាមានភាពសមស្រប នៅពេលដែលឯកសារនេះត្រូវបានរៀបចំឡើង។ បញ្ហាកូវីដ-១៩ ទំនងជានឹងបង្កផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា ដែលនឹងបង្កផលប៉ះពាល់ដល់ចំណាយលើវិស័យអប់រំ ជាពិសេសនៅក្នុងឆ្នាំ ២០២១-២០២៣ ផងដែរ។

កំណើន ផសស នឹងថមថយនៅក្នុងរយៈពេលសេសសល់ឆ្នាំ ២០២០ និងឆ្នាំ ២០២១ ដោយសារតែផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើវិស័យទេសចរណ៍ និងវិស័យសេវាកម្មដទៃទៀត, ការថមថយសកម្មភាពក្នុងវិស័យសំណង់និងអចលនទ្រព្យ, ការថយចុះការផលិតសម្លៀកបំពាក់សម្រាប់ការនាំចេញ ដោយសារឱនភាពសេដ្ឋកិច្ចទូទាំងសកលលោក និងការថយចុះតម្រូវការនៅក្នុងស្រុក ដោយសារតែប្រាក់បញ្ញើរបស់ពលករចំណាកស្រុក មកកាន់ប្រទេសកម្ពុជាមានកម្រិតទាបជាងមុន។ វិស័យទេសចរណ៍ថយចុះជាង៩០% នៅខែមេសា ឆ្នាំ២០២០ ហើយចំណូលពីការលក់សំបុត្រទស្សនាប្រាសាទអង្គរវត្ត បានត្រឹមតែកន្លះភាគរយនៃចំណូលដែលធ្លាប់ទទួលបានកាលពីមុនជំងឺកូវីដ-១៩ តែប៉ុណ្ណោះ។[92]

ផ្អែកតាមរបាយការណ៍របស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា[93] គិតត្រឹមខែកក្កដា ឆ្នាំ២០២០ រោងចក្រកាត់ដេរចំនួន ៤០០ ដែលមានកម្មករប្រហែល ១៥០ ០០០ នាក់ បានបិទទ្វារ។ ក្នុងរយៈពេល ១០ ខែ ដំបូងនៃឆ្នាំ២០២០ ចំនួនភ្ញៀវទេសចរ ដែលចូលមកទស្សនាកម្ពុជាថយចុះចំនួន ៧៦% ធៀបនឹងឆ្នាំមុន។[94] ស្ថានភាពសេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងមានអត្រា -២% នៅឆ្នាំ២០២០ និងងើបឡើងវិញមកអត្រាវិជ្ជមានចំនួន ៤% នៅឆ្នាំ ២០២១។[95]

[92] https://asiatimes.com/2020/05/cambodia-poised-to-be-big-COVID-19-loser/

[93] World Bank. 2020. *Cambodia Economic Update, November 2020: Restrained Recovery.* World Bank, Phnom Penh. © World Bank. https://openknowledge.worldbank.org/handle/10986/34932.

[94] https://www.thestar.com.my/aseanplus/aseanplus-news/2020/12/05/tourist-arrivals-to-cambodia-down-76-in-10-months-due to-pandemic-covid-19-cases-rising

[95] World Bank and MoEF. 2020. *Macroeconomic and Financial Policy Framework for the preparation of the 2021 Law on Financial Management.* Phnom Penh: Ministry of Economy and Finance.

កំណើន ផសស អវិជ្ជមាននៅឆ្នាំ ២០២០ មានន័យថា មូលដ្ឋានពន្ធនៅមានកម្រិតទាបជាងការរំពឹងទុក ហើយរាជរដ្ឋាភិបាលមានធនធានហិរញ្ញវត្ថុសម្រាប់ចំណាយនៅឆ្នាំក្រោយ និងឆ្នាំបន្តបន្ទាប់ទៀត តិចជាងមុន។ នេះមានន័យថា ប្រសិនបើកម្ពុជាបន្តអនុវត្តតាមផែនការចំណាយលើវិស័យអប់រំ ដូចពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាចាំបាច់ត្រូវស្វែងរកប្រភពហិរញ្ញប្បទានបន្ថែម សម្រាប់អនុវត្តគោលដៅប្រកបដោយមហិច្ឆតានៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣។ រូបភាពទី១៩ បង្ហាញពីលក្ខណៈផ្សេងៗគ្នានៃការធ្វើចំណោលជុំវិញគម្លាតហិរញ្ញប្បទានសម្រាប់វិស័យអប់រំ ក្នុងរយៈពេលមធ្យម ២០២០- ២០២៣ ដែលធ្វើឡើងដោយរាជរដ្ឋាភិបាលនៅក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលត្រូវបានកែសម្រួលឡើងវិញរបស់ខ្លួន ធនាគារ អភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិរូបិយប័ណ្ណអន្តរជាតិ (IMF)។ ការធ្វើចំណោលទាំងនេះធ្វើឡើងផ្អែកតាមការព្យាករណ៍កំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសកម្ពុជា។[96]

រូបភាពទី ១៩៖ ការប៉ាន់ប្រមាណពីគម្លាតហិរញ្ញប្បទាន (គិតជាលានដុល្លារសហរដ្ឋអាមេរិក)



ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើប្រភពទិន្នន័យចម្រុះ (ESP 2019-2023, ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលត្រូវបានកែសម្រួលដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការព្យាករណ៍ ផសស ចុងក្រោយដោយ ADB, WB, IMF សម្រាប់កម្ពុជា)

[96] G. Ducanes. 2020. *Review of the Financing Plan, Cost Estimates, and Assumptions Used for Resource Projections in the Education Strategic Plan 2019-2023* (CAMSEB 2030). Phnom Penh: ADB.

៤-១៦. ពិភពលោក ក្រោយជំងឺកូវីដ-១៩

ដើម្បីស្វែងយល់ពីវិសាលភាព និងទិសដៅគោលនយោបាយ និងសកម្មភាពដែលចាំបាច់ សម្រាប់ប្រឈមទល់នឹងដំណាក់កាលក្រោយកូវីដ-១៩ និងពង្រឹងភាពធន់នៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល ដែលបែងចែកស្ថានភាពនេះជាបីដំណាក់កាល គឺការឆ្លើយតប ការស្តារឡើងវិញ និងការធ្វើឱ្យកាន់តែប្រសើរ ។[97]

១ ការឆ្លើយតប៖

តើប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលអាចរក្សានិរន្តរភាពនៃការបង្រៀន និងការរៀន ដោយរបៀបណា ក្នុងអំឡុងពេលបិទគ្រឹះស្ថានសិក្សា ដោយសារការផ្ទុះជំងឺកូវីដ-១៩?

២ ការស្តារឡើងវិញ៖

តើគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាល ត្រូវត្រៀមខ្លួនយ៉ាងណាសម្រាប់ដំណាក់កាលស្តារឡើងវិញនៅពេលដែលគ្រឹះស្ថានទាំងនេះបើកទ្វារទទួលសិស្សជាថ្មីម្តងទៀត ដូចជា បន្ថែមម៉ោងសិក្សា ដែលបាត់បង់ ជួយឱ្យសិស្សអាចបន្តទៅទទួលបានការអប់រំនៅកម្រិតបន្ទាប់ ឬ ចូលទៅក្នុងទីផ្សារការងារបានដោយរលូនបំផុត តាមដែលអាចធ្វើទៅបាន?

៣ ការធ្វើឱ្យកាន់តែប្រសើរ ៖

ជាការឆ្លើយតបចំពោះវិបត្តិនេះ តើគ្រឹះស្ថានសិក្សា និងបណ្តុះបណ្តាលត្រូវអនុវត្តគំនិតផ្តួចផ្តើមអ្វីខ្លះ ដើម្បីឱ្យការរៀន និងការបង្រៀនតាមរយៈការប្រើប្រាស់ឧបករណ៍ និងបច្ចេកទេសថ្មីៗ កាន់តែមានភាពល្អប្រសើរ ជាពិសេសការពង្រីកការអប់រំតាមប្រព័ន្ធអនឡាញដែលត្រូវរក្សាឱ្យបានប្រសិទ្ធភាពគរុកោសល្យ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដើម្បីបង្កើនគុណភាពនៃការសិក្សា?

ពិភពលោក ក្រោយសម័យកូវីដ-១៩ នឹងតម្រូវឱ្យអ្វីៗទាំងអស់ មានការបង្កើនប្រសិទ្ធភាពជាងមុន – ប្រព័ន្ធអប់រំក៏ចាំបាច់ត្រូវតែបង្កើនលទ្ធផលសិក្សារបស់សិស្សឱ្យដល់កម្រិតអតិបរមា ជាមួយនឹងធនធានថវិកាដែលមាន។ រាជរដ្ឋាភិបាលប៉ាន់ប្រមាណថាសេដ្ឋកិច្ចនឹងថយចុះ ១,៩% នៅក្នុងឆ្នាំ២០២០ និងងើបឡើងវិញក្នុងឆ្នាំ ២០២១ ជាមួយនឹងអត្រា ៣,៥%។ ខណៈពេលដែលថវិការដ្ឋបាលទូទៅ និងថវិកាសម្រាប់មុខងារជាច្រើនផ្សេងទៀតរបស់ក្រសួងនឹងត្រូវកាត់បន្ថយ ដោយសារតែចំណូលរដ្ឋាភិបាលមានការថយចុះ (ការព្យាករណ៍ថា ថវិកានឹងមានឱនភាព ៦,៧២% នៃផសស ក្នុងឆ្នាំ២០២១) តែការអភិវឌ្ឍធនធានមនុស្សនឹងនៅបន្តជាអាទិភាព តាមរយៈការបង្កើនគុណភាពនៃការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅគ្រប់កម្រិតទាំងអស់។ ប្រការនេះបានបង្ហាញឱ្យឃើញថា ការចំណាយលើវិស័យអប់រំត្រូវបានចាត់ជាចំណាយចាំបាច់ និងអាទិភាព ហើយផែនទីបង្ហាញផ្លូវនេះ ក៏មានគោលបំណងជំរុញឱ្យមានការផ្តល់អាទិភាពបែបនេះសម្រាប់ការអប់រំមធ្យមសិក្សា។ ការបង្កើនចំណាយលើវិស័យអប់រំកន្លងមក បានបង្កើនការចូលរៀន តែពុំសូវមានលទ្ធផលលើគុណភាពនៃលទ្ធផលសិក្សារបស់សិស្ស។ គំនិតផ្តួចផ្តើមនៅក្នុងផែនទីបង្ហាញផ្លូវនេះ ចាំបាច់ត្រូវមានការធានាតុល្យភាព ដើម្បីឱ្យមានការចំណាយលើការកសាងសមត្ថភាព ធនធានមនុស្ស ការបំពាក់សម្ភារបរិក្ខារបង្កើតសតវត្សទី២១ នៅសាលារៀន និងការផ្តល់នូវសម្ភារបរិក្ខារសមស្រប ដើម្បីធានាឱ្យសម្រេចបានជោគជ័យ។

[97] ADB. (2020). *Class of 2020-2021: Implications of COVID-19 on Education.* Manila: Education Sector Group, SDCC.

ចំណុចទាំងនេះ គឺជាសារៈសំខាន់ចាំបាច់ ជាពិសេសសម្រាប់ទ្រទ្រង់គំនិតផ្តួចផ្តើមនានា ក្រោយកូវីដ-១៩ ដែលយើងរំពឹងថា ពេលនោះ ថវិកាដ៏ច្រើនទំនងជាមានប្រភពមកពីអ្នកផ្តល់ជំនួយ ហើយអ្នករៀបចំគោលនយោបាយចាំបាច់កំណត់អំពីវិធី / របៀបគ្រប់គ្រងថវិកាទាំងនេះ ឱ្យបានល្អប្រសើរដើម្បីឱ្យសិស្សក្លាយជាអ្នកទទួលផលដោយផ្ទាល់។ ប្រការនេះ តម្រូវឱ្យមានការសហការយ៉ាងជិតស្និទ្ធ រវាងគ្រូ អ្នកសិក្សានិងមាតាបិតាសិស្សសម្រាប់ការបែងចែកធនធាននានា។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាល កំពុងរៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយឌីជីថលកម្ពុជា ដែលនឹងបង្កើតនូវបទប្បញ្ញត្តិសម្រាប់បច្ចេកវិទ្យាអភិបាលកិច្ចហេដ្ឋារចនាសម្ព័ន្ធអក្ខរកម្មឌីជីថល និងការពង្រឹងសមត្ថភាព ហើយក៏នឹងផ្តល់ទិសដៅចំបងៗជូនគ្រប់វិស័យ រួមទាំងវិស័យអប់រំផងដែរ សម្រាប់ការអភិវឌ្ឍ និងបញ្ចូលប្រព័ន្ធអេកូឌីជីថល (digital ecosystem) ។

ក្នុងស្ថានភាពសិស្សនៅតែបន្តពុំអាចរៀនដោយផ្ទាល់ជាមួយគ្រូបង្រៀន ក្នុងមួយរយៈពេលទៅមុខទៀត ចាំបាច់ត្រូវមានការប្រើប្រាស់ជម្រើសផ្សេងទៀត ដែលជាមធ្យោបាយសម្រាប់ឱ្យសិស្សអាចប្រើប្រាស់សម្ភារៈសម្រាប់បម្រើការរៀនសូត្ររបស់ពួកគេ។ ជម្រើសទាំងនោះ អាចរួមមានការផ្តល់ឯកសារថតចម្លងទៅឱ្យសិស្ស ដោយឱ្យសិស្សមកយកខ្លួនឯង ឬពាក់ព័ន្ធនឹងការប្រើប្រាស់បណ្តាញសហគមន៍ និងសាលារៀន ដើម្បីបែងចែក និងប្រមូលត្រឡប់ ឯកសារទាំងនេះដល់ដៃសិស្ស។ ការពាក់ព័ន្ធពីសំណាក់សហគមន៍មូលដ្ឋានមានភាពសមស្រប ជាពិសេសចំពោះករណីដែលសាលាពុំមានសៀវភៅសិក្សា / ធនធានគ្រប់ចំនួន សម្រាប់ឱ្យសិស្សទាំងអស់យកទៅប្រើប្រាស់។ គ្រូបង្រៀនគួរមានភាពប្រុងប្រយ័ត្នខ្ពស់នៅពេលរៀបចំឯកសារសិក្សាសម្រាប់សិស្សម្នាក់ៗ ពោលគឺមិនត្រឹមតែដាក់កិច្ចការដូចៗគ្នាឱ្យសិស្សទាំងអស់គ្នានោះឡើយ ហើយការងារនេះប្រហែលជាទាមទារឱ្យមានការចំណាយពេលជាច្រើនម៉ោង។ លើសពីនេះ គ្រូបង្រៀនក៏ត្រូវកំណត់ពីកាលបរិច្ឆេទសម្រាប់ឱ្យសិស្សផ្ញើកិច្ចការត្រឡប់មកវិញ និងគ្រូបង្រៀនផ្តល់មតិត្រឡប់ទៅឱ្យសិស្សវិញផងដែរ។ ការសហការរបស់មាតាបិតាសិស្សក៏សំខាន់ផងដែរ។

ជម្រើសផ្សេងទៀត ឬបន្ថែមលើមធ្យោបាយខាងលើ អាចរៀបចំឱ្យមានការទាញយកឯកសារសិក្សាក្នុងទម្រង់ ឌីជីថលតាមរយៈអ៊ីនធឺណិត (ប្រអប់ទី១)។ ដូច្នេះ អាចថា ថវិកាមួយភាគនឹងត្រូវចំណាយសម្រាប់ការទិញបរិក្ខារ ឌីជីថល (ស្មាតហ្វូន ឬ កុំព្យូទ័រយួរដៃដែលមានតម្លៃថោក) និងការភ្ជាប់ Wi-Fi ដែលគ្មានកំណត់។ បម្រែបម្រួលបែបនេះក៏តម្រូវឱ្យសិស្សមានចំណេះដឹងស្ទាត់ជំនាញក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថល។ ភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ ឌីជីថល គឺសំដៅលើសមត្ថភាពប្រើប្រាស់ទូរស័ព្ទឆ្លាតវៃ (ស្មាតហ្វូន) ឬ កុំព្យូទ័រ (កុំព្យូទ័រលើតុ ឬ កុំព្យូទ័រយួរដៃ) ដើម្បីចូលប្រើប្រាស់កម្មវិធី (APP) តារាងទិន្នន័យ (spread sheets) កម្មវិធី word processing ឧបករណ៍សម្រាប់ថត និងបច្ចេកវិទ្យាឌីជីថល និងយកធនធានទាំងនេះយកមកប្រើប្រាស់ក្នុងមេរៀនដែលពាក់ព័ន្ធ។ ដើម្បីទទួលបានជោគជ័យ ត្រូវមានការផ្តល់ការបណ្តុះបណ្តាលឱ្យបានល្អដល់សិស្សយ៉ាងហោចណាស់ពី ៩០%-៩៥% ដើម្បីឱ្យពួកគេស្ទាត់ជំនាញក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថល។ ដូចនេះ តួនាទីរបស់គ្រូបង្រៀនលេចឡើងយ៉ាងច្បាស់ក្នុងគោលបំណងនេះ។

[98] MEF. 2020. *Macroeconomic and Financial Policy Framework for the preparation of the 2021 Law on Financial Management.* Phnom Penh: Ministry of Economy and Finance.

[99] Supreme National Economic Council. (2019). *Digital Transformation and Policy toward Cambodia's Digital Economy.* Phnom Penh: Ministry of Economy and Finance (MEF)

ប្រអប់ទី១៖ ឱកាស និងបញ្ហាប្រឈមក្នុងការអប់រំឌីជីថល (EdTech)

ការអប់រំឌីជីថល (EdTech)

ឱកាស

- បង្កើតផ្លាតហ្វម (a simple platform) ដ៏សាមញ្ញមួយ ដែលអាចឱ្យគ្រូអាចចែករំលែកដំណោះស្រាយ អប់រំឌីជីថល (EdTech) របស់ខ្លួន។ ការបង្កើតនេះ គឺងាយ ហើយអាចចាប់ផ្តើមដំណើរការបានយ៉ាងឆាប់រហ័ស
- ការផ្សព្វផ្សាយមេរៀន តាមរយៈវិទ្យុ ឬទូរទស្សន៍ អាចជួយផ្សព្វផ្សាយដល់សិស្សនៅតំបន់ដាច់ស្រយាល ដែលពុំមានអ៊ីនធឺណិតប្រើប្រាស់
- ការឆ្លើយតបដែលមានប្រយោជន៍មួយទៀត គឺបង្កើតនូវច្រកចេញចូលតែមួយតាមប្រព័ន្ធអនឡាញសម្រាប់ផ្ទុកធនធាននានា ដែលសិស្សអាចទាញយកមកប្រើប្រាស់ដោយផ្ទាល់ ឬ ដោយមានការគាំទ្រពីឪពុកម្តាយរបស់ពួកគេ
- បង្កើតហ្គេមសម្រាប់ការអប់រំ ដោយប្រើប្រាស់បច្ចេកវិទ្យា ដើម្បីឱ្យសិស្សនៅបន្តការសិក្សា ជាពិសេសនៅពេលសាលារៀនបិទទ្វាររយៈពេលយូរ។

បញ្ហាប្រឈម

- ការងាកទៅរកការសិក្សាក្រៅសាលារៀន នឹងធ្វើឱ្យការគ្រប់គ្រងការអប់រំ និងប្រព័ន្ធទិន្នន័យដែលមានភាពទន់ខ្សោយ កាន់តែចុះខ្សោយបន្ថែមទៀត
- វឌ្ឍនភាពរបស់សិស្សធៀបនឹងកម្មវិធីសិក្សាផ្លូវការ នឹងមានការថមថយ
- សមត្ថភាពរបស់គ្រូបង្រៀនក្នុងការសម្របខ្លួន ដើម្បីផ្តល់សេវាអប់រំពីចម្ងាយ និងមានការប្រែប្រួលខុសៗគ្នា
- កុមារជាច្រើននាក់នឹងពុំអាចប្រើបច្ចេកវិទ្យា ឬ មានបរិយាកាសសិក្សាសមស្របនៅក្នុងផ្ទះឡើយ។

មួយឆ្នាំក្រោយមក

- ដើម្បីឆ្លើយតបចំពោះវិបត្តិអប់រំ នៅក្នុងអំឡុងឆ្នាំក្រោយនេះ អ្នករៀបចំគោលនយោបាយ ត្រូវការទិន្នន័យសំខាន់ចាំបាច់មួយចំនួន
- ក្នុងរយៈពេលមួយឆ្នាំទៀត ការមានបច្ចេកវិទ្យាដែលសមស្រប ដើម្បីវិភាគ និងឆ្លើយតបចំពោះកង្វះខាតនៅក្នុងការសិក្សា ដែលលេចចេញនៅក្នុងវិបត្តិនេះ នឹងនាំមកនូវការផ្លាស់ប្តូរយ៉ាងធំធេង។

ប្រភព៖ David, R., Pellini, A., Jordan, K. & Phillips, T. (2020). *Education during the COVID-19 crisis: Opportunities and constraints of using EdTech in low-income countries.* Policy Brief. Washington, DC: World Bank Group

ដើម្បីមានភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថល ចាំបាច់ត្រូវមានភាពស្ទាត់ជំនាញផ្នែកភាសាផងដែរ ដើម្បីអាចអាននិងបកស្រាយសារឌីជីថលនានាបាន។ សូម្បីតែឯកសារ ធនធានសម្រាប់បង្រៀន និងរៀន នានាដែលផលិតនៅក្នុងស្រុកក៏តម្រូវឱ្យសិស្សត្រូវចេះភាសាខ្មែរដែលជាភាសាជាតិ ឱ្យបានស្ទាត់ជំនាញទើបមានលទ្ធភាពប្រើប្រាស់បាន។ ឯកសារធនធានដ៏ទៃទៀត ដែលរកបានតាមបណ្តាញអ៊ីនធឺណិត ក៏តម្រូវឱ្យសិស្សត្រូវចេះពីរភាសា ដោយប្រើអង់គ្លេសជាភាសាទី២ និងជាភាសាទំនាក់ទំនងអន្តរជាតិ។ ចំណុចនេះ ក៏ជាភាសាចាំបាច់បំផុតផងដែរសម្រាប់ការសហការជាអន្តរជាតិក្នុងជំនាញ STEM។

៥. កត្តាខាងក្រៅដែលជះឥទ្ធិពលលើការសិក្សារបស់សិស្ស

ផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សានេះ ផ្តោតលើគោលនយោបាយទាំងឡាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលជះឥទ្ធិពលដោយផ្ទាល់លើគុណភាពនៃលទ្ធផលសិក្សារបស់សិស្ស ដែលត្រូវបានគ្រោងក្នុងផែនការ និងថវិកាសម្រាប់រយៈពេល ១០ ឆ្នាំក្រោយ។ ទោះបីជាមានផែនទីបង្ហាញផ្លូវនេះ ក៏កត្តាសំខាន់ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃប្រព័ន្ធអប់រំ និងកំណែទម្រង់អប់រំ គឺការកំណត់រកកត្តាខាងក្នុង និងកត្តាខាងក្រៅសំខាន់ៗ ដែលមានឥទ្ធិពលលើប្រសិទ្ធភាពនៃការរៀន។

កត្តាខាងក្នុង គឺសំដៅលើអ្វីដែលសិស្សពាំនាំមកជាមួយ សម្រាប់ការសិក្សារៀនសូត្រជាផ្លូវការរបស់ពួកគេ ដូចជា ៖ ឥរិយាបថ ឧបនិស្ស័យ សម្បទា ការយល់ឃើញ ការលើកទឹកចិត្ត និងហ្វឹកហ្វឺនដែលបង្កើតឡើង។ កត្តាខាងក្រៅ ទូទៅ គឺពុំមែនជាឥទ្ធិពល ឬ អ្វីដែលកើតចេញពីព្រឹត្តិការណ៍កើតមាននៅក្នុងសាលាឡើយ ហើយកត្តាខាងក្រៅមានដូចជា៖ សង្គម សេដ្ឋកិច្ច វប្បធម៌ នយោបាយ និងភូមិសាស្ត្រ។ ប៉ុន្តែកត្តាខាងក្រៅ ក៏ជាដើមហេតុ ដែលអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើគុណភាពនៃការអប់រំនៅកម្រិតមធ្យមសិក្សា ហើយកត្តាទាំងនេះអាចបង្កការរំខានដល់ការធ្វើផែនការ ទាំងរយៈពេលខ្លី ទាំងរយៈពេលវែង ជាពិសេស ប្រសិនបើកត្តាទាំងនេះកើតឡើងដោយពុំមានការរំពឹងទុកជាមុន ឬ ដោយពុំមានដឹងជាមុននោះ។

៥-១. ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩

ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ គឺជាឧទាហរណ៍ដ៏ជាក់ច្បាស់ដែលបង្ហាញពីកត្តាខាងក្រៅ ដែលលេចឡើងដោយពុំមានការព្រមានឱ្យដឹងជាមុន ហើយបានបង្កការរំខានដល់សហគមន៍ និងបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ការអប់រំ ព្រោះតែមានការតម្រូវឱ្យបិទទ្វារសាលារៀន និងគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា។ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមទំនងជាមានកម្រិតធ្ងន់ធ្ងរនៅទូទាំងប្រទេស រួមនឹងការខាតបង់ដទៃទៀតដូចជា ការបាត់បង់ឱកាសសិក្សារៀនសូត្រ ដោយសារតែការផ្អាកការអប់រំនៅក្នុងប្រព័ន្ធ។ ចំណាយលើវិស័យអប់រំក្នុងអំឡុងពេលនៃការស្តារឡើងវិញពីការរាតត្បាតជាសកលអាចថយចុះរហូតដល់ ១០% នៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ព្រោះថារដ្ឋាភិបាល នឹងបង្វែរអាទិភាពថវិកាទៅរកវិស័យសុខាភិបាលវិញ។[100] ភស្តុតាងបញ្ជាក់ថា ប្រទេសមួយចំនួនកំពុងកាត់ថវិកាសម្រាប់វិស័យអប់រំ ដើម្បីយកថវិកាទៅចំណាយលើវិស័យសុខភាពនិងសេវាគាំពារសង្គម។[101] ដោយឡែក រាជរដ្ឋាភិបាលកម្ពុជា បានផ្តើមកាត់បន្ថយចំណាយរហូតដល់ ៥០% ដើម្បីផ្តល់មូលនិធិទ្រទ្រង់វិស័យសំខាន់ៗដូចជា វិស័យអប់រំ និងសុខាភិបាល។ ជំនួយសម្រាប់វិស័យអប់រំដែលបានពីដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលក៏ទំនងជាមានការថយចុះផងដែរ ដែលនេះមានន័យថា សេវាចាំបាច់សំខាន់ៗមួយចំនួននឹងរងផលប៉ះពាល់អវិជ្ជមាន ក្នុងករណីដែលរដ្ឋាភិបាល ពុំអាចរ៉ាប់រងកង្វះថវិកានេះបាន។ ការថយចុះនូវចំណូលរបស់គ្រួសារនឹងធ្វើឱ្យប្រជាពលរដ្ឋជាច្រើនគ្រួសារជួបការលំបាក ក្នុងការរ៉ាប់រងចំណាយលើសេវាអប់រំ។ ចំណាយទាំងនេះស្រូបយកថវិកាគ្រួសារនៅក្នុងប្រទេសដែលមានចំណូលទាបក្នុងភាគរយមួយខ្ពស់ជាងអ្នកដែលរស់នៅក្នុងប្រទេសដែលមានចំណូលខ្ពស់។[102] ដូច្នេះ គ្រួសារនៅកម្ពុជាងាយរងគ្រោះខ្លាំង នៅពេលដែលមានការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចតែបន្តិច។ នេះក៏អាចធ្វើឱ្យគ្រួសារមួយចំនួនត្រូវវិលទៅរកសាលារដ្ឋវិញ ដោយសារតែចំណាយលើសេវាអប់រំឯកជនកើនឡើងខ្ពស់ជាងមុន បើធៀបនឹងកំណើនអ្នកអត់ការងារធ្វើ ឬ អ្នកដែលពុំមានការងារធ្វើគ្រប់គ្រាន់ ដែលជាការដាក់បន្ទុកបន្ថែមទៀតលើប្រព័ន្ធសាលារៀនរបស់រដ្ឋ។ ទោះបីជាអាចមានលទ្ធភាពដែលសិស្សត្រឡប់ទៅចូលរៀនសាលារដ្ឋវិញក្តី ប៉ុន្តែទិន្នន័យដែលប្រមូលដោយក្រសួងអប់រំ យុវជន និងកីឡានៅដើមឆ្នាំ២០២១

[100] World Bank. 2020. http://documents.worldbank.org/curated/en/479041589318526060/pdf/The-Impact-of-the-COVID-19-Pandemic-on-Education-Financing.pdf.
[101] World Bank. 2020. http://documents.worldbank.org/curated/en/479041589318526060/pdf/The-Impact-of-the-COVID-19-Pandemic-on-Education-Financing.pdf.
[102] Global Partnership for Education. 2020. https://www.globalpartnership.org/blog/financing-our-future-3-ways-protect-education-spending-impacts-COVID-19.

បង្ហាញថា ការចុះឈ្មោះចូលរៀនសាលារៀនរដ្ឋគ្រប់កម្រិត មានការថយចុះជាងឆ្នាំមុន មួយភាគធំដោយសារការបាត់បង់ប្រាក់ចំណូលក្នុងគ្រួសារដែលធ្លាប់តែឱ្យកូនរៀនសាលារដ្ឋ។ បច្ចុប្បន្ន គ្រួសារទាំងនោះមិនអាចរ៉ាប់រងថ្លៃសិក្សារបស់កូន (ដូចជា ឯកសណ្ឋានសិស្ស សម្ភារសិក្សា មធ្យោបាយធ្វើដំណើរ អាហារ។ល។)។

គម្លាតក្នុងការសិក្សានឹងរីកកាន់តែធំនៅទូទាំងប្រទេសកម្ពុជា ដោយសារតែការបិទទ្វារសាលារៀន ហើយសិស្សមួយចំនួនពុំអាចរៀនតាមប្រព័ន្ធអនឡាញ ដែលពួកគេនឹងធ្លាក់ចូលទៅក្នុងស្ថានភាពខ្សត់ខ្សោយ ការរៀនសូត្រ ឬ អាចនឹងធាប់ចាកចេញពីសាលារៀន/ការសិក្សា។ ផ្នែកមួយនៃដំណោះស្រាយសម្រាប់ក្រសួងអប់រំ យុវជន និងកីឡាត្រូវកំណត់ថាតើ ការវិនិយោគក្រោយកូវីដ-១៩ គួរផ្តោតឡើងវិញលើការផ្តល់សេវាជាមូលដ្ឋាន (ដូចជា សៀវភៅសិក្សាគោល និងសម្ភារៈសម្រាប់សរសេរ) ឬ ថាតើគួរមានការពិនិត្យឡើងវិញលើតម្រូវការចំណាយលើហេដ្ឋារចនាសម្ព័ន្ធបរិក្ខារទឹកស្អាត និងអនាម័យដូចជា ការផ្តល់នូវបង្គន់បែងចែកតាមភេទ និងការផ្គត់ផ្គង់ទឹកស្អាតសម្រាប់សាលារៀនទាំងអស់ក្រោយការរាតត្បាតជាសកល។ នេះគឺជាឧទាហរណ៍ដែលបង្ហាញពីការចំណាយលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់សំខាន់ៗ ដែលមានឥទ្ធិពលផ្ទាល់លើការសិក្សារបស់សិស្ស ព្រោះថាជួយឱ្យសិស្សទាំងអស់ (ជាពិសេសក្មេងស្រីជំទង់) អាចបន្តការសិក្សារបស់ពួកគេ។ ការផ្តល់លទ្ធភាពឱ្យមានការប្រើប្រាស់បច្ចេកវិទ្យា សម្រាប់ការសិក្សាពីចម្ងាយ ក៏អាចនឹងត្រូវកំណត់ថាជាអាទិភាពក្នុងការបែងចែកប្រើប្រាស់ថវិកានាពេលអនាគតរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការសម្រេចចិត្តរបស់ក្រសួង នឹងមានយន្តការគ្រប់គ្រងរក្សាការពារ ដើម្បីធានាថា រាល់ថវិកានឹងត្រូវចំណាយប្រកបដោយ ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព លើការកែលម្អការបង្រៀន និងរៀន។

៥-២. កត្តាសង្គម-សេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុ

សង្គមកម្ពុជា គឺជាសង្គមដែលប្រជាពលរដ្ឋភាគច្រើនរស់នៅតាមតំបន់ជនបទ ហើយក៏មានប្រជាជនរស់នៅប្រមូលផ្តុំនៅតាមតំបន់ប្រជុំជន/ទីក្រុងធំៗជាច្រើន (ដូចជា ភ្នំពេញ សៀមរាប បាត់ដំបង ព្រះសីហនុ។ល។)។ វិស័យកសិកម្មរួមចំណែកប្រមាណ ២៣% នៃផលសរបស់ប្រទេស ហើយសកម្មភាពកសិកម្មភាគច្រើនរបស់កម្ពុជាពឹងអាស្រ័យលើប្រព័ន្ធទន្លេមេគង្គ ប្រព័ន្ធទន្លេសាប និងប្រព័ន្ធទន្លេផ្សេងទៀតដែលពឹងអាស្រ័យលើកត្តាអាកាសធាតុ។ ជាធម្មតាកម្ពស់ទឹកទន្លេឡើងចុះទៅតាមរដូវមូសុង តែការសាងសង់ទំនប់នៅខ្សែទឹកខាងលើក្នុងប្រទេសជិតខាង បង្កការគំរាមកំហែងរំខានដល់ភាពអាចព្យាករណ៍ដឹងជាមុនពីរំហូរទឹកមកពីប៉ែកខាងជើង។ លំហូរទឹកក្នុងទន្លេសាបកើនឡើងខ្លាំងនៅរដូវមូសុង ព្រោះតែទន្លេមេគង្គធ្វើឱ្យទឹកហូរបញ្ច្រាស់ទិស ដែលធ្វើឱ្យទឹកហូរឡើងត្រឡប់ទៅខ្សែទឹកខាងលើ និងចូលទៅក្នុងបឹងទន្លេសាប ដែលធ្វើឱ្យបឹងនេះរីកមាឌក្លាយជាទឹកជំនន់ និងផ្តល់ទឹកបំពេញបន្ថែមដល់តំបន់ស្រែចម្ការ ដែលនៅស្ថិតជុំវិញបឹងនេះ។ នៅពេលដែលរដូវប្រាំងមកដល់បឹងនេះត្រូវរាំងស្ងួត ហើយបឹងទន្លេសាបបញ្ចេញទឹកអស់ឆ្ពោះទៅទីក្រុងភ្នំពេញវិញ។ ជាមួយនឹងការចាប់ផ្តើមមានការប្រែប្រួលអាកាសធាតុ សីតុណ្ហភាពមានការកើនឡើង គេកាន់តែមិនអាចព្យាករណ៍ដឹងជាមុនពីពេលដែលរដូវមូសុងមកដល់។ កត្តាអាកាសធាតុធ្ងន់ធ្ងរបានបង្កការរំខានដល់សន្តិសុខស្បៀងរបស់ជាតិ ព្រោះតែទឹកជំនន់ និងគ្រោះរាំងស្ងួតកើតឡើងកាន់តែញឹកញាប់ និងកាន់តែធ្ងន់ធ្ងរ ហើយកសិករមិនអាចពឹងអាស្រ័យលើចំណេះដឹងបែបប្រពៃណីរបស់ពួកគេ ដើម្បីធ្វើការកំណត់ដឹងពីវដ្តរដូវសម្រាប់បរនេសាទ ដាំដុះ និងប្រមូលផលរបស់ពួកគេបាន។

ក្រុមអ្នកនេសាទ និងក្រុមអ្នកអភិរក្សធនធានជលផលមានការព្រួយបារម្ភពីកម្ពស់ទឹកទាបក្នុងទន្លេមេគង្គ ដែលជាកត្តារាំងមិនឱ្យទឹកក្នុងទន្លេសាប ហូរបញ្រ្ចាស់ទិសដូចដែលធ្លាប់កើតមានជារៀងរាល់ឆ្នាំ ដែលនេះជាបាតុភូតមួយដ៏សំខាន់ ដើម្បីនាំទឹក និងត្រីចូលមកក្នុងបឹងទន្លេសាប។ ផ្នែកមួយចំនួននៃបឹងនេះរីងស្ងួតនៅរដូវវស្សា ជាអ្វីដែលមិនធ្លាប់កើតមានកន្លងមក។[103]

វដ្តទឹកទន្លេនៅកម្ពុជា កំពុងទទួលរងការរំខាន។ ផលប៉ះពាល់ជារួមមកលើស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារនៅតំបន់ជនបទ មានកម្រិតធ្ងន់ធ្ងរ នៅពេលដែលការប្រែប្រួលអាកាសធាតុ បំផ្លាញ ឬកាត់បន្ថយទិន្នផលដំណាំ និងប្រាក់ចំណូលរបស់គ្រួសារ ធ្វើឱ្យពួកគេមួយចំនួនត្រូវផុងជាប់បំណុល និងធ្លាក់ចូលទៅក្នុងភាពក្រីក្រដែលមិនអាចដោះស្រាយបាន។ កត្តាទាំងនេះបន្តបង្កផលប៉ះពាល់ដល់ការចូលរៀនរបស់កុមារនៅគ្រប់កម្រិតទាំងអស់។

៥-៣. កត្តាសង្គមវប្បធម៌

តាមធម្មតា ការសម្រេចចិត្តធ្វើឡើងពីថ្នាក់កណ្តាល ដែលបណ្តាលឱ្យគ្មានភាពបត់បែនក្នុងប្រព័ន្ធអប់រំ។ ដូច្នេះ ប្រព័ន្ធអប់រំមានការលំបាកក្នុងការឆ្លើយតបទៅនឹងតម្រូវការនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ជាពិសេសនៅកម្រិតសាលារៀន។ ដូចសង្គមផ្សេងទៀតដែរ វប្បធម៌បែបនេះបានបង្កផលប៉ះពាល់លើការអប់រំរបស់កុមារ និងប្រព័ន្ធអប់រំតាមរូបភាពជាច្រើន។

កត្តាសំខាន់ៗដែលរារាំងមិនឱ្យមានការផ្លាស់ប្តូរធំៗនៅក្នុងប្រព័ន្ធអប់រំ គឺការថយចុះនៃការយល់ដឹងនូវកម្រិតគណនេយ្យភាព ខ្វះការផ្តល់តម្លៃដល់គុណសម្បត្តិការងារ និងការខ្វះទស្សនវិស័យវែងឆ្ងាយ។ ជារឿយៗ សង្កេតឃើញថាបុគ្គលម្នាក់ៗ តែងទទួលយកស្ថានភាពជីវិតរបស់ពួកគេក្នុងពេលបច្ចុប្បន្ន ទៅតាមប្រព័ន្ធដែលកំពុងកើតមាន និងពុំមានអារម្មណ៍បន្ទាន់ថា ត្រូវព្យាយាមធ្វើការកែលម្អប្រព័ន្ធនេះ ឬទទួលខុសត្រូវអនុវត្តគំនិតផ្តួចផ្តើមថ្មី ឬគំនិតផ្តួចផ្តើមណាដែលពុំធ្លាប់សាកល្បងកន្លងមកឡើយ។ នេះមានន័យថា ការទទួលខុសចំពោះការផ្លាស់ប្តូរកម្រជាការទទួលខុសត្រូវរបស់បុគ្គលណាម្នាក់ណាស់ ប៉ុន្តែត្រូវតែបែងចែកនៅក្នុងក្រុមធំមួយ ដើម្បីឱ្យពួកគេទាំងនោះអាចបន្តអនុវត្តការផ្លាស់ប្តូរនេះទៅមុខទៀត។ ប្រការនេះធ្វើឱ្យក្រសួងអប់រំ យុវជន និងកីឡា មានការលំបាកក្នុងការអនុវត្តប្រព័ន្ធវាយតម្លៃសមិទ្ធកម្មរបស់បុគ្គលិកប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិតទាំងអស់ទៅតាមសមិទ្ធកម្មរបស់គ្រូបង្រៀនម្នាក់ៗ និងអ្នកគ្រប់គ្រងសាលារៀន។

[103] N. Chheng. 2020. Tonle Sap Yet to Reverse. *Phnom Penh Post.* 22 July 2020.

៦. អាទិភាពនៃអនុវិស័យអប់រំមធ្យមសិក្សា

សិស្ស គ្រូបង្រៀន អ្នកគ្រប់គ្រងសាលារៀន គ្រួសារ និងសហគមន៍ គឺជាផ្នែកមួយនៃចក្ខុវិស័យរួម សម្រាប់លើកកម្ពស់កម្រិត នៃការសិក្សានៅក្នុងសាលារៀន។ គុណភាពនៃការបង្រៀន និងការគ្រប់គ្រង សម្ភារបរិក្ខារ និងធនធានសម្រាប់ការសិក្សា គឺជាធាតុផ្សំដ៏សំខាន់សម្រាប់ផ្ដល់ការគាំទ្រដល់កម្រិតនៃការសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡា នឹងបង្កើនគុណភាពនៃធាតុផ្សំនីមួយៗក្នុងចំណោមធាតុផ្សំទាំងនេះ តាមរយៈការយកចិត្តទុកដាក់ជាបន្ទាន់ចំពោះអាទិភាពចំនួន៨ ដែលកំណត់ដោយផែនទីបង្ហាញផ្លូវនេះ និងត្រូវបានបង្ហាញលម្អិតដូចខាងក្រោម៖

៦-១. បង្កើនការចូលរៀន និងគុណភាពអប់រំមធ្យមសិក្សាចំណេះទូទៅ (រួមទាំងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស)

ក) រៀបចំ និងផ្សព្វផ្សាយ **គន្លងអប់រំ បណ្ដុះបណ្ដាល និងអាជីព**[104] ដើម្បីឱ្យ ៖
   ១) ឱកាសនៃការអប់រំ និងបណ្ដុះបណ្ដាលត្រូវបានបង្ហាញយ៉ាងច្បាស់ដល់សិស្ស មាតាបិតាសិស្ស និងបុគ្គលិកអប់រំ
   ២) បង្កើតយន្តការទទួលស្គាល់គុណភាព និងផ្ដល់វិញ្ញាបនបត្របញ្ជាក់ដែលមានការទទួលស្គាល់ទៅវិញទៅមក ដើម្បីឱ្យសិស្សអាចទទួលបានក្រេឌីតនៅដំណាក់កាលផ្សេងៗ ក្រោយបញ្ចប់ការសិក្សា
   ៣) គន្លងអប់រំ បណ្ដុះបណ្ដាល និងអាជីព មានលក្ខណៈមិនលម្អៀង មានយុត្តិធម៌យេនឌ័រ និងបរិយាបន្នសង្គម។

ខ) រំពឹងថាសិស្សថ្នាក់ទី៦នឹងបន្តរៀននៅសាលារៀនមធ្យមសិក្សាដោយមានសមត្ថភាពអំណានសរសេរនិងលេខនព្វន្តដែលអាចជួយឱ្យពួកគេកាន់តែទទួលបានជោគជ័យនៅកម្រិតមធ្យមសិក្សា។ ដោយឡែក សិស្សដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ត្រូវបានពង្រឹងសមត្ថភាពតាមរយៈការផ្ដល់ថ្នាក់បំប៉ន។

គ) ប្រើប្រាស់ទិន្នន័យបែងចែកតាមប្រភេទសិស្ស ដែលទទួលបានពីការវាយតម្លៃស្តង់ដា សម្រាប់ការអប់រំថ្នាក់មូលដ្ឋាន ដូចជា នៅថ្នាក់ទី៣ ទី៦ និងទី៨ ដើម្បីវិភាគពីឧបសគ្គក្នុងការសិក្សា និងផ្ដល់មតិត្រឡប់ ដើម្បីកែលម្អការបង្រៀនក្នុងថ្នាក់រៀន។

ឃ) ផ្ដល់ការលើកទឹកចិត្ត(តាមរយៈការផ្ដល់អាហារូបករណ៍ឱ្យចំសិស្សដែលមានតម្រូវការ)ដើម្បីបង្កើនការចូលរៀនរបស់សិស្សទាំងអស់ (ទាំងពីរភេទ) ដើម្បីឱ្យពួកគេអាចរៀនចប់កម្រិតអប់រំមធ្យមសិក្សា។

ង) ផ្ដល់អាហារូបករណ៍បន្ថែម ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើនពីកុមារមានពិការភាព ជនជាតិដើមភាគតិច កុមារមកពីគ្រួសារក្រីក្រ និងក្រុមដែលជួបការលំបាកផ្សេងទៀត។

ច) ជួយដល់សិស្សដែលធ្លាប់បោះបង់ការសិក្សាចេញពីសាលាមធ្យមសិក្សាឱ្យត្រឡប់មកចូលរៀនវិញ និងទទួលបានគុណវុឌ្ឍិដែលបង្កើនឱកាសទទួលបានការងារល្អ ដោយបង្កើនការគាំទ្រដល់ការអនុវត្តកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន។

ឆ) ផ្ដល់ជម្រើសជំនាញវិជ្ជាជីវៈ សម្រាប់ការអប់រំ និងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈជាជម្រើសនៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

ជ) ប្រើប្រាស់ការបង្កើតរូបភាពឌីជីថល (ការវិភាគទិន្នន័យ និងផែនទីឌីជីថល) ដើម្បីកំណត់ពីតម្រូវការសាងសង់ ជួសជុល កែលម្អ និងស្តារសម្ភារបរិក្ខារជាយុទ្ធសាស្ត្រនៅក្នុងសាលារៀន និងការពង្រាយគ្រូប្រកបដោយប្រសិទ្ធភាព។ បង្កើតអង្គភាពវិភាគស្ថិតិតូចមួយនៅក្នុងអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ ដើម្បីបង្កើតមូលដ្ឋានទិន្នន័យចម្រុះដែលស៊ីសង្វាក់គ្នា នឹងកម្មវិធីបង្កើតរូបភាពឌីជីថល (compatible with digital visualization software) និងផ្ដល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ក្នុងក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការរៀបចំផែនការ។ ប្រការនេះតម្រូវឱ្យមានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំត្រឹមត្រូវ និងទូលំទូលាយដែលគួរឱ្យទុកចិត្ត ដើម្បីគាំទ្រដល់ការវិភាគទិន្នន័យ និងមុខងារផែនការ។

[104] See section 4-2.

ឈ) ណែនាំប្រើប្រាស់ស្តង់ដាសេវាអប្បបរមា សម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងកែលម្អប្លង់បន្ទប់រៀន ដែលគាំទ្រដល់ការអនុវត្តគរុកោសល្យបែបថ្មី។[105]

ញ) បង្កើតកន្លែងធ្វើការសម្រាប់គ្រូ ដើម្បីឱ្យពួកគេរៀបចំ និងសហការគ្នាប្រកបដោយវិជ្ជាជីវៈ។

ដ) ធានាថាគ្រប់សាលាមធ្យមសិក្សាទាំងអស់ មានបង្គន់ដែលអាចប្រើប្រាស់បាន បែងចែកតាមភេទ និងមានទឹកប្រើប្រាស់ពេញមួយឆ្នាំ, មានបន្ទប់ថែទាំសុខភាព, មានអាហារដ្ឋានដែលផ្តល់នូវអាហារប្រកបដោយ អាហារូបត្ថម្ភ និងនាំមកនូវសុខភាពមាំមួន, មានកម្មវិធីសិក្សាដែលផ្តោតលើប្រធានបទសុខភាពរបស់ក្មេងជំទង់ ដូចជា សុខភាពផ្លូវភេទ និងបន្តពូជ អំពើហិង្សាផ្អែកលើយេនឌ័រ ការអប់រំអំពីជំងឺអេដស៍/មេរោគអេដស៍ និងថ្នាំញៀន។

ឋ) តម្រូវឱ្យមានការពិនិត្យសុខភាពជាប្រចាំ សម្រាប់សិស្ស និងបុគ្គលិកសាលារៀនទាំងអស់ ដោយមណ្ឌលសុខភាពក្នុងមូលដ្ឋាន (វិស័យអប់រំ និងវិស័យសុខាភិបាល អាចពិចារណាបង្កើតទីតាំង ដែលមានសាលាសហគមន៍ និងមណ្ឌលសុខភាពនៅជាមួយគ្នា ដើម្បីពង្រឹងការផ្តល់សេវាក្នុងមូលដ្ឋាន)។

ឌ) ធានាថា សាលាមានការគាំទ្រ ក្នុងការកាត់បន្ថយការរើសអើងសិស្សក្រីក្រ និងសិស្សជួបការលំបាកទាំងពីរភេទ។

ឍ) ពង្រឹងការអប់រំកាយ និងកីឡានៅតាមសាលាមធ្យមសិក្សា ដើម្បីបង្កើនសុខភាពរាងកាយរបស់សិស្ស អភិវឌ្ឍសមត្ថភាពរបស់ពួកគេក្នុងការចូលរួមក្នុងសកម្មភាពអប់រំកាយ និងបំពាក់បំប៉នវិន័យផ្ទាល់ខ្លួន។

៦-២. បន្តផ្តោតការយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ការដឹកនាំ និងគ្រប់គ្រងសាលារៀនមធ្យមសិក្សា

ក) កំណត់ការជ្រើសរើស និងតែងតាំងអ្នកដឹកនាំសាលារៀន ផ្អែកតាមគុណសម្បត្តិការងារ និងស្តង់ដា ដែលបានកំណត់សម្រាប់នាយកសាលា។

ខ) បង្កើតកម្មវិធីត្រៀមខ្លួនដឹកនាំ និងគ្រប់គ្រងសាលារៀន សម្រាប់នាយកសាលាដែលទើបចេញបម្រើការងារថ្មី និងអ្នកដែលមានបំណងធ្វើជានាយកសាលា និងផ្តល់ការបណ្តុះបណ្តាលអភិវឌ្ឍន៍វិជ្ជាជីវៈ ជាប្រចាំឱ្យបានទៀងទាត់ ក្នុងអំឡុងពេលនៃការបំពេញអាជីពរបស់ពួកគេ។

គ) ដាក់បញ្ចូលភាពជាអ្នកដឹកនាំ ក្នុងការណែនាំ ក្នុងកម្មវិធីត្រៀមខ្លួន និងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ ជាប្រចាំសម្រាប់នាយកសាលា ដើម្បីពង្រឹងការបង្រៀន និងរៀនសូត្រ។

ឃ) ផ្តល់បរិយាកាស ដែលកាន់តែមានលក្ខណៈអំណោយផល សម្រាប់នាយកសាលាទាំងនេះ ដោយប្រើប្រាស់គោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធិភាព រួមមាន៖

  ១) នៅក្នុងឯកសារពិពណ៌នាអំពីការងារ ត្រូវមានការរៀបរាប់កំណត់ឱ្យបានច្បាស់លាស់ពីតួនាទី (សិទ្ធិ) និងការទទួលខុសត្រូវ

  ២) ផ្តល់អំណាចឱ្យពួកគេគ្រប់គ្រងបុគ្គលិកក្នុងសាលារៀន ដោយពុំមានការរើសអើង ដូចជា ត្រូវដាក់ចេញនូវគោលនយោបាយសម្រាប់ជួលបុគ្គលិក បញ្ឈប់ការងារបុគ្គលិក ដែលធ្វើការងារពុំបានល្អ និងអនុវត្តការវាយតម្លៃសមិទ្ធកម្មរបស់គ្រូ ទៅតាមការចាំបាច់។

ង) ក្នុងករណីដែលសាលារៀនមានសមត្ថភាពស្រូបយកការងារបន្ថែម ត្រូវបញ្ចូលគំរូសាលារៀនជំនាន់ថ្មី ជាយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស តាមរយៈការលើកកម្ពស់អភិបាលកិច្ចល្អ ក្រមសីលធម៌វិជ្ជាជីវៈ កែលម្អវិធីសាស្ត្របង្រៀន ផ្តល់ប្រាក់លាភការផ្អែកតាមសមិទ្ធកម្មការងារដល់គ្រូ ការអភិវឌ្ឍវិជ្ជាជីវៈផ្តោតលើការសិក្សាផ្អែកតាមបញ្ហា ជំនាញ STEM ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងការអប់រំ និងការធ្វើឱ្យកាន់តែប្រសើរនូវសេវាសម្រាប់សិស្ស ដូចជាផ្តល់ការណែនាំ និងការប្រឹក្សាអាជីព ការសិក្សាទៅតាមស្ថានភាពខុសៗ គ្នារបស់សិស្ស ការសិក្សាពីចម្ងាយ និងការអប់រំបំណិនជីវិត ជាដើម។

[105] MOEYS. 2020d. *21st century School Architecture.* Phnom Penh.

ច) បន្តអភិវឌ្ឍការចូលរួមរបស់មាតាបិតា-អាណាព្យាបាល និងសហគមន៍ ក្នុងការគ្រប់គ្រងសាលារៀន មានប្រសិទ្ធភាព តាមរយៈគណកម្មការគ្រប់គ្រងសាលា និងវិធីដ៏ទៃទៀតដែលនាំឱ្យមានការចូលរួមពីសំណាក់សហគមន៍ (ឧ. ការបើកបវេសនកាល ការស្វែងរកថវិកា អញ្ជើញឪពុក-ម្តាយ ឬ ធុរជនមកធ្វើវាគ្មិន)។ នាយកសាលាត្រូវទទួលខុសត្រូវចំពោះគណៈកម្មការគ្រប់គ្រងសាលា ដែលមានតួនាទីរដ្ឋបាល ក្នុងការគ្រប់គ្រងកិច្ចការសាលារៀន។

ឆ) ធានានូវប្រព័ន្ធអប់រំដែលឆ្លើយតបនឹងយេនឌ័រ និងមានបរិយាបន្នសង្គម តាមរយៈការរៀបចំឡើងជាថ្មី និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធជនបង្គោលយេនឌ័រ សម្រាប់ការណែនាំ និងពិនិត្យតាមដាន។ គ្រូបង្រៀនទាំងពីរភេទនៅកម្រិតផ្សេងៗ តាមសាលានីមួយៗ នឹងចូលរួមក្នុងវគ្គបណ្តុះបណ្តាលកម្រិតខ្ពស់ស្តីពី យេនឌ័រ និងដើរតួនាទីជាក្រុមគ្រូបង្គោល ដើម្បីផ្តល់ការតម្រង់ទិសមូលដ្ឋានស្តីពីយេនឌ័រដល់គ្រូបង្រៀន និងគាំទ្របុគ្គលិកគ្រប់រូប។

៦-៣. រៀបចំកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃឱ្យស្របតាមការអប់រំប្រកបដោយគុណភាពសម្រាប់សតវត្សរ៍ទី២១

ក) ធានាថា កម្មវិធីសិក្សាកម្រិតមធ្យមសិក្សា៖
- ១) ផ្អែកតាមទស្សនាទាន (ប្រសិនបើអាច)
- ២) បានត្រៀមយុវជនឱ្យឆ្លើយតបចំពោះបញ្ហាប្រឈមនានា ដែលកើតមាននាពេលអនាគត
- ៣) ផ្តល់តម្លៃដល់ចំណេះដឹង និងផលិតចំណេះដឹង និងការយល់ដឹងសម្រាប់សិស្សគ្រប់រូប
- ៤) អភិវឌ្ឍភាពច្នៃប្រឌិត ការសហការ និងការយល់ដឹងកម្រិតខ្ពស់អំពីវប្បធម៌ខ្មែរ
- ៥) លើកកម្ពស់សមធម៌ និងទទួលយកភាពចម្រុះ
- ៦) ផ្តល់អាទិភាពដល់សុខភាព និងសុខុមាលភាពសង្គម និងផ្លូវចិត្ត
- ៧) ផ្តល់ឱកាសឱ្យបុគ្គលគ្រប់រូបក្លាយជាមនុស្សល្អមានចំណេះដឹងធ្មើម។

ខ) បញ្ចូលជំនាញសតវត្សរ៍ទី ២១ ដូចជា ជំនាញសហការ ការត្រិះរិះពិចារណាល្អិតល្អន់ ការគិតបែបច្នៃប្រឌិត និងការងារក្រុមចូលទៅក្នុងគ្រប់មុខវិជ្ជាទាំងអស់ ជាពិសេស មុខវិជ្ជា STEM នៅកម្រិតមធ្យមសិក្សា ដោយផ្តោតទាំងលើខ្លឹមសារ និងដំណើរការ (សូមមើលរូបភាពទី ១៤)។

គ) បញ្ចូលការអប់រំសិល្បៈ ទៅក្នុងមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម គណិតវិទ្យា ដើម្បីលើកកម្ពស់ការគិតប្រកបដោយភាពច្នៃប្រឌិត និងបង្កើតដំណោះស្រាយ។

ឃ) បង្កើតគណៈកម្មាធិការតាមមុខវិជ្ជា ដើម្បីរៀបរៀងឡើងវិញនូវកម្មវិធីសិក្សាលម្អិត ដោយមានការពិពណ៌នាជាក់លាក់អំពីការសិក្សារបស់សិស្សជាពាក្យពេចន៍ដែលអាចវាស់វែងបាន។

ង) បញ្ចូលប្រធានបទបន្ថែមទៀតដែលទទួលបានចំណាប់អារម្មណ៍នាពេលបច្ចុប្បន្នដោយភ្ជាប់ជាមួយនឹងបរិបទរបស់សិស្សផ្ទាល់ (ជាពិសេសនៅសាលាជនបទ –កសិកម្ម ការចិញ្ចឹមសត្វ បច្ចេកវិទ្យា។ល។

ច) ពង្រឹងការសិក្សាផ្តោតលើការធ្វើសកម្មភាពជាក់ស្តែង តាមរយៈគម្រោង និងគោលវិធីផ្អែកតាមការរិះរក និងការស្រាវជ្រាវមេរៀនដែលផ្សារភ្ជាប់ជាមួយនឹងការអនុវត្តផ្ទាល់ បំណិនជីវិត និងកម្មវិធីបច្ចេកទេស។

ឆ) ពិចារណាអភិវឌ្ឍឯកសារអំណាន រូបភាព និងឌីជីថលបន្ថែមដើម្បីបំពេញឱ្យសៀវភៅសិក្សា។

ជ) ធានាថា សារសំខាន់ៗ ក្នុងកម្មវិធីសិក្សា និងធនធានបង្រៀន គ្មានការរើសអើង ក៏ដូចជាលើកកម្ពស់សិទ្ធិមនុស្ស សមភាពយេនឌ័រ និងបរិយាបន្នសង្គម។

ឈ) ដាក់បញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាក្នុងកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន។

ញ) កែទម្រង់ការប្រឡងថ្នាក់ទី ១២៖

១) ធានាថា ការប្រឡងនេះធ្វើតេស្តលើជំនាញគិតពិចារណាកម្រិតខ្ពស់ ក៏ដូចជា ការរំឭកឡើងវិញពីខ្លឹមសារមុខវិជ្ជា

២) ផលិតចេញពីកម្រងតេស្តស្តង់ដា

៣) បូកពិន្ទុវាយតម្លៃតាមសាលារៀន (ដែលអាចបញ្ចូលទាំងកម្រងស្នាដៃសិស្ស) របស់សិស្សថ្នាក់ទី១២ ម្នាក់ៗ ដើម្បីយកមកបញ្ចូលគ្នាជាមួយនឹងការដាក់ពិន្ទុប្រឡង ដែលមានការត្រួតពិនិត្យពីខាងក្រៅ ទើបផ្តល់ជាពិន្ទុសរុបដល់សិស្សម្នាក់ៗ។

៦-៤. បញ្ចូលការអប់រំឌីជីថលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សា

ក) បញ្ចូលបច្ចេកវិទ្យាឌីជីថលក្នុង "បន្ទប់រៀនវៃឆ្លាត" ដែលអនុញ្ញាតឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាកាន់តែច្រើនក្នុងការបង្រៀន និងរៀនក្នុងគ្រប់បណ្ណាញវិទ្យាល័យធនធាន និងសាលារៀនជំនាន់ថ្មី (រួមទាំងទូរទស្សន៍ និងវិទ្យុ)[106]។ ពង្រីកការដាក់បញ្ចូលបច្ចេកវិទ្យា ក្នុងការបង្រៀន និងរៀននៅគ្រប់សាលាមធ្យមសិក្សាទៅតាមធនធាន និងបុគ្គលិកដែលមាន។

ខ) បង្កើតភាពជាដៃគូដ៏រឹងមាំជាមួយ អ្នកផ្តល់សេវាអ៊ីនធឺណិត ដើម្បីអភិវឌ្ឍ និងទ្រទ្រង់ដល់ដំណើរការប្រព័ន្ធអប់រំឌីជីថលនៅមធ្យមសិក្សា។

គ) ដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធ ICT ដែលមានលក្ខណៈទូលំទូលាយសម្រាប់គាំទ្រការសិក្សាតាមប្រព័ន្ធអនឡាញរបស់សិស្ស ៖

១) ជំរុញឱ្យមានការប្រើប្រាស់ការសិក្សាបែបចម្រុះ (ក្នុងថ្នាក់ និងអនឡាញ) ជាគំរូថ្មីសម្រាប់ការប្រាស្រ័យទាក់ទងគ្នារវាងគ្រូ និងសិស្ស

២) រៀបចំកញ្ចប់សិក្សាឱ្យស្របតាមកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សា តាមរយៈនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងមជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយ ជាមជ្ឈមណ្ឌលថ្មីដែលត្រូវផ្សព្វផ្សាយធនធានទាំងនេះឱ្យបានទូលំទូលាយ

៣) ទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ម៉ូឌុលសិក្សា ដែលផលិតទូទាំងសកលលោក បន្ទាប់ពីការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ឧទាហរណ៍ ដូចជា ម៉ូឌុលដែលផលិតដោយភាពជាដៃគូ សកលសម្រាប់ការអប់រំ និងមជ្ឈមណ្ឌល SEAMEO ជាពិសេសម៉ូឌុលដែលពាក់ព័ន្ធនឹងតំបន់អាស៊ាន។

ឃ) ដាក់បញ្ចូលការយល់ដឹងពី "ការរករឿងរំខានតាមប្រព័ន្ធអ៊ីនធឺណិត" និងកំណត់ ក៏ដូចជាពង្រឹង ការធានាការពារពីការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណេត និងសន្តិសុខក្នុងការអប់រំឌីជីថល។[107]

[106] C. Redmond. 2020. *Armed with a radio, Cambodian girl climbs tree to access education.* Phnom Penh: Southeast Asia Globe. https://southeastasiaglobe.com/accessing-education-in-remote-cambodia/?utm_source=newsletterandutm_medium=emailandutm_campaign=Vol.%2067andutm_term=2020-10-02

[107] https://gen-pol.org/2018/11/digital-gender-based-violence-can-education-stop-abuse-genpol-at-the-european-parliament/

៦-៥. អនុវត្តគោលនយោបាយគ្រូបង្រៀន ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងអនុវិស័យអប់រំមធ្យមសិក្សា[108]

ក) រៀបចំគោលនយោបាយគ្រូបង្រៀនគ្រប់ជ្រុងជ្រោយ ដែលត្រូវបានអនុម័ត និងផ្សព្វផ្សាយសម្រាប់គ្រូដែលទើបចូលបង្រៀន និងគ្រូទាំងអស់ដែលកំពុងបង្រៀនក្នុងសាលារៀន។ គោលនយោបាយនេះរួមមាន ៖

- ១) ស្តង់ដាជ្រើសរើសគរុសិស្ស ដើម្បីទទួលបានការបណ្តុះបណ្តាល និងការពន្យារពេលទទួលយកអ្នកជំនាញផ្សេងទៀត
- ២) ពិពណ៌នាការងារនៅគ្រប់កម្រិតទាំងអស់ ដែលផ្តល់ការគាំទ្រដល់ការងារបង្រៀន ក្នុងនាមជាអាជីពមួយ
- ៣) កិច្ចសន្យាការងារ (អាជ្ញាប័ណ្ណសម្រាប់គ្រូបង្រៀន លក្ខខណ្ឌការងារ បៀវត្ស និងអត្ថប្រយោជន៍នានា)
- ៤) ស្តង់ដាសម្រាប់ការតែងតាំង និងពង្រាយគ្រូ
- ៥) ក្របខណ្ឌស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (ក្រមសីលធម៌)
- ៦) ក្របខណ្ឌស្តង់ដាវិជ្ជាជីវៈនាយកសាលា (ក្រមសីលធម៌)
- ៧) ការអនុវត្តគំរូការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ-គន្លងអាជីពគ្រូបង្រៀនដូចជាគុណវុឌ្ឍិដែលបានពីការសិក្សាបទពិសោធន៍ការងារ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការវាយតម្លៃសមិទ្ធកម្មដើម្បីទទួលបានការដំឡើងឋានៈនៅក្នុងការបំពេញការងារ ការផ្ទេរប៉ុស្តិ៍ការងារ និងការទទួលស្គាល់
- ៨) ការបង្កើតសមាគមវិជ្ជាជីវៈ ព្រមទាំងក្រុមបច្ចេកទេសសម្រាប់គ្រប់មុខវិជ្ជាទាំងអស់
- ៩) ការរៀបចំជាកម្រងស្នាដៃវិជ្ជាជីវៈរបស់គ្រូ និងនាយកសាលា
- ១០) ការលើកកម្ពស់ និងសម្របសម្រួលការផ្តល់សេវាអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ ដល់គ្រូ និងនាយកសាលា
- ១១) ការត្រួតពិនិត្យការបង្រៀនរបស់គ្រូទាំងអស់ ផ្តល់ការណែនាំ និងការបង្វឹក ដើម្បីកែលម្អសមិទ្ធកម្មរបស់ពួកគេ
- ១២) ការវាយតម្លៃសមិទ្ធកម្ម ដើម្បីកំណត់រកចំណុចខ្លាំង និងចំណុចខ្សោយ និងដាក់ចេញនូវដំណើរការសម្រាប់ធ្វើការកែលម្អ
- ១៣) ការកំណត់គន្លងអាជីពច្បាស់លាស់សម្រាប់ការដំឡើងឋានៈ ប្រាក់លាភការសម្រាប់ការផ្ទេរ
- ១៤) លក្ខខណ្ឌតម្រូវសម្រាប់ការព្យួរការងារ និងការបញ្ឈប់ពីការងារ
- ១៥) ដំណើរការសម្រាប់ការលាលែង និងការចូលនិវត្តន៍។

ខ) ធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពី ការជ្រើសរើសបុគ្គលិក ដើម្បីទាក់ទាញបេក្ខជន ដែលមានសមត្ថភាពបង្រៀនខ្ពស់ (គុណវុឌ្ឍិដែលបានពីការសិក្សា និងឧបនិស្ស័យ)។

គ) រៀបរាប់ពីតួនាទី និងការទទួលខុសត្រូវរបស់គ្រូក្នុងពិពណ៌នាការងារ និងកិច្ចសន្យា (បញ្ចូលជម្រើសអាចនឹងត្រូវពង្រាយឡើងវិញ ក្នុងករណី ដែលលើសបុគ្គលិក)។

ឃ) ធានាឱ្យមានការអនុវត្តយុទ្ធសាស្ត្រជ្រើសរើសបុគ្គល ដែលធានាបាននូវតុល្យភាពរវាងគ្រូបង្រៀនជាស្ត្រី និងគ្រូបង្រៀនជាបុរស

ង) បង្កើនប្រាក់លាភការសម្រាប់គ្រូបង្រៀន ដែលទទួលយកប៉ុស្តិ៍ការងារនៅតំបន់ខ្វះគ្រូ។

ច) អនុវត្តកញ្ចប់លើកទឹកចិត្តសម្រាប់ការកាត់ចំនួនគ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលារៀន ដើម្បីកាត់បន្ថយបញ្ហាលើសគ្រូនៅតាមសាលាមធ្យមសិក្សា (ត្រូវចំណាយដំបូងជាមុនសិន ដើម្បីទទួលបានប្រយោជន៍រយៈពេលវែង)។

[108] Adapted from the *UNESCO Teacher Policy Development Guide (2015)*, https://unesdoc.unesco.org/ark:/48223/pf0000235272

៦-៦. បន្តផ្តោតការយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ការអប់រំគ្រូមធ្យមសិក្សា

ក) ពង្រីកគំរូវិទ្យាស្ថានគរុកោសល្យទៅតំបន់ផ្សេងទៀតនិងបញ្ចូលគំរូវិទ្យាគរុកោសល្យទៅក្នុងគ្រប់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំ។

ខ) កែសម្រួលកម្មវិធីសិក្សា និងវិធីសាស្ត្រដែលប្រើប្រាស់សម្រាប់បណ្តុះបណ្តាលគ្រូ ដើម្បីយកគំរូតាមវិធីសាស្ត្ររៀន និងបង្រៀន ផ្អែកតាមសកម្មភាព និងផ្អែកតាមលទ្ធផល ព្រមទាំងយុទ្ធសាស្ត្រវាយតម្លៃបន្តបន្ទាប់។

គ) ជានាការចូលរួមប្រកបដោយសមធម៌រវាងបេក្ខជនទាំងពីរភេទក្នុងការអប់រំគ្រូមធ្យមសិក្សា។

ឃ) លើកកម្ពស់គុណវុឌ្ឍិរបស់គ្រូឧទ្ទេស ដែលបានមកពីការសិក្សាបន្ថែម និងការកើនឡើងនូវចំណេះដឹង និងជំនាញគរុកោសល្យរបស់ពួកគេ។ ពង្រឹងគន្លងអាជីពគ្រូឧទ្ទេស (អត្ថប្រយោជន៍ លក្ខខណ្ឌការងារ ការជ្រើសរើសផ្អែកតាមគុណសម្បត្តិការងារ ការអភិវឌ្ឍវិជ្ជាជីវជាប្រចាំ និងការវាយតម្លៃ)។

ង) ជានាថា គ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលាទទួលបានការបណ្តុះបណ្តាលស្តីពី ការយល់ដឹងពីយេនឌ័រ និងបរិយាបន្នសង្គម។

ច) ពង្រីកកម្មសិក្សា ការបណ្តុះបណ្តាលគ្រូ ដើម្បីផ្តល់បទពិសោធន៍ពិតប្រាកដដល់គរុសិស្ស។

ឆ) ផ្តល់ការណែនាំការងារដំបូង ដល់គ្រូបង្រៀន និងនាយកសាលាទាំងអស់ ដែលទើបចេញបម្រើការងារ ក្នុងនោះរួមទាំងការណែនាំអំពីការប្រើប្រាស់បច្ចេកទេសគរុកោសល្យ ដែលឆ្លើយតបចំពោះយេនឌ័រ និងជំនាញប្រើប្រាស់គោលវិធីរៀនសូត្របែបចម្រុះផងដែរ។

ជ) អនុវត្តស្វ័យសិក្សា ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ នៅតាមសាលារៀន និងកម្រងសមាគមវិជ្ជាជីវៈគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយមានការគាំទ្រពីគ្រឹះស្ថានអប់រំគ្រូ។

ឈ) ដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធ ICT ដែលមានមូលដ្ឋានទូលំទូលាយ ដើម្បីផ្តល់សេវាអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដល់គ្រូ ទាំងតំបន់ប្រជុំជន និងជនបទនៅកម្ពុជា រួមទាំងថ្នាល ដែលមានសុវត្ថិភាពសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃការចូលរួមរបស់គ្រូ និងអ្នកដឹកនាំសាលារៀន។

ញ) រៀបចំឱ្យមានការណែនាំ និងការផ្តល់ប្រឹក្សាគរុកោសល្យ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន និងការដឹកនាំ និងគ្រប់គ្រងសាលារៀន ដែលជាផ្នែកមួយដ៏សំខាន់ នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយយកគំរូតាមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីទៅតាមការសមស្រប។

ដ) ជានាថា អ្នកផ្តល់ប្រឹក្សាគ្រប់រូប (ទាំងពីរភេទ) ទទួលបានការបណ្តុះបណ្តាលស្តីពី ការពិគ្រោះយោបល់ដែលឆ្លើយតបនឹងយេនឌ័រក្នុងការពិភាក្សាជាមួយក្មេងស្រី និងក្មេងប្រុសតាមរបៀបខុសគ្នា និងយុត្តិធម៌។

៦-៧. ធ្វើពិពិធកម្ម និងពង្រឹងលទ្ធផលនៃការអប់រំមធ្យមសិក្សាបច្ចេកទេសដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និងទីផ្សារការងារក្នុងមូលដ្ឋាន

ក) ពង្រឹងបណ្តាញវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ដែលមានស្រាប់ រួមនឹងការផ្តល់អន្តេវាសិកដ្ឋានដល់សិស្ស ដែលត្រូវរស់នៅឆ្ងាយពីផ្ទះ សម្រាប់ជាយុទ្ធសាស្ត្រក្នុងការពង្រីកបណ្តាញនេះ។

ខ) បំពាក់បំប៉នគ្រូបច្ចេកទេសឱ្យក្លាយជាអ្នកបង្រៀនមានសមត្ថភាព និងគុណវុឌ្ឍិ ដែលឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងកម្មវិធីសិក្សា និងស្របតាមតម្រូវការទីផ្សារការងារ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់អាស៊ាន ដោយផ្តោតលើសមត្ថភាព ឬជំនាញជាក់លាក់។

គ) ពង្រឹងសមត្ថភាពបុគ្គលិកសម្រាប់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស តាមរយៈការចូលរួមចែករំលែក/កិច្ចសហការជាមួយគ្រូបង្រៀនមកពី មជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិជ្ជាជីវៈខេត្ត។

ឃ) ផ្តល់ថ្នាក់រៀនគ្រប់គ្រាន់ បន្ទប់ពិសោធន៍ រោងជាង និងអគាររដ្ឋបាល ដើម្បីអនុវត្តកម្មវិធីបច្ចេកទេសប្រកបដោយជោគជ័យ។

ង) ជួយដល់ការឆ្លងភូមិសិក្សារបស់សិស្សមធ្យមសិក្សាបឋមភូមិទៅកាន់កម្មវិធីអប់រំបច្ចេកទេសនៅកម្រិតទុតិយភូមិតាមរយៈការកែសម្រួលកម្មវិធីសិក្សា ការផ្តល់ការណែនាំ និងការប្រឹក្សា និងការផ្តល់ដំបូន្មានអំពីការអប់រំ។

៦-៨. បង្កើនការសហការសម្រាប់ការអប់រំនៅកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សា

ក) បង្កើតបណ្តាញវិទ្យាល័យធនធានក្នុងមូលដ្ឋានជាមួយគ្រឹះស្ថានឧត្តមសិក្សា មជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធ មជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ និងសហគ្រាសក្នុងមូលដ្ឋានដើម្បីពង្រឹងការសហការផ្តោតលើ៖[109]

  ១) សកម្មភាពប្រឹក្សាអាជីព ដើម្បីបង្ហាញគន្លងពីសាលាមធ្យមសិក្សាទៅគ្រឹះស្ថានឧត្តមសិក្សា (ឧ. វិស័យសិក្សាធិការ និងការអប់រំបច្ចេកទេស)

  ២) អញ្ជើញម្ចាស់សហគ្រាស ឱ្យធ្វើជាវាគ្មិនកិត្តិយស ចុះទស្សនកិច្ចដល់កន្លែងធ្វើការ បទពិសោធន៍ការងារកម្មវិធីហាត់ការ

  ៣) កម្មវិធីរៀនពីរមុខជំនាញសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ ដើម្បីឱ្យពួកគេបញ្ចប់ការសិក្សាចំណេះទូទៅ ហើយក្នុងពេលជាមួយគ្នាមានឱកាសចូលរៀនក្នុងវគ្គបណ្តុះបណ្តាល TVET ដែលផ្តល់នៅតាមមូលដ្ឋាន

  ៤) ឱកាសស្ម័គ្រចិត្តសម្រាប់សិស្សនៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ (សម្រាប់ការអប់រំក្រៅប្រព័ន្ធ) ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីអក្ខរកម្ម។

ខ) សហការជាមួយនឹងក្រុមហ៊ុនឯកជន ដើម្បីភ្ជាប់ទំនាក់ទំនងការបណ្តុះបណ្តាលបច្ចេកទេស ដែលផ្តល់នៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ជាមួយនឹងទីផ្សារការងារ តាមរយៈកម្មវិធីទទួលបទពិសោធន៍នៅកន្លែងធ្វើការ កម្មវិធីហាត់ការ និងកម្មវិធីហ្វឹកហាត់កូនជាង។

គ) តម្រូវឱ្យមានវិញ្ញាបនបត្រ និងលទ្ធភាពនៃការផ្លាស់ប្តូរ (transferability) រវាងអ្នកផ្តល់សេវាអប់រំក្រោយមធ្យមសិក្សា (រដ្ឋ និងឯកជន) រួចដាក់បញ្ចូលក្នុងគន្លងអប់រំ បណ្តុះបណ្តាល និងអាជីព (សូមមើលផ្នែកទី ៦-១)។

ឃ) រៀបចំឱ្យមានការផ្លាស់ប្តូរបទពិសោធន៍រវាងគ្រូ និងបង្កើតសហគមន៍អ្នកសិក្សាវិជ្ជាជីវៈ រវាងសាលាមធ្យមសិក្សា និងសាលាអន្តរជាតិដែលមានគុណភាពខ្ពស់។

[109] Footnote 27.

៧. ការផ្លាស់ប្ដូរនៃអនុវិស័យការអប់រំមធ្យមសិក្សាឆ្ពោះទៅឆ្នាំ ២០៣០

ការអនុវត្តផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាត្រូវបានរៀបចំ ដើម្បីឱ្យមានការអនុវត្តជាដំណាក់កាលៗ ទៅតាមធនធានថវិកា ដែលមានការសម្របសម្រួល និងធនធាន ដែលផ្ដល់ដោយដៃគូគាំទ្រ (ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឧស្សាហកម្ម) និងតាមកម្រិតជោគជ័យនៃអន្តរាគមន៍នីមួយៗ។ ការបន្តពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត គឺអាស្រ័យទៅតាមការពិនិត្យតាមដានជាទៀងទាត់លើអន្តរាគមន៍នានា ដើម្បីផ្ដល់មតិត្រឡប់អំពីវឌ្ឍនភាព ដែលសម្រេចបាន។ ដំណាក់កាលទី ១ មានសកម្មភាពជាច្រើនរបស់គម្រោង ដែលកំពុងអនុវត្តរួចទៅហើយ ឬដែលត្រូវបានលើកស្នើឡើងសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៩-២០២៣ និងឆ្នាំបន្តបន្ទាប់ទៅមុខទៀត(សូមមើលប្រអប់ទី២)។

ប្រអប់ទី២៖ ដំណាក់កាលនិមួយៗ នៃផែនទីបង្ហាញផ្លូវ អប់រំមធ្យមសិក្សាកម្ពុជា ២០៣០

ដំណាក់កាលទី ១ (២០២១-២០២៣)
ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣

- រៀបចំ និងផ្សព្វផ្សាយគន្លងអប់រំ បណ្ដុះបណ្ដាល និងអាជីពសម្រាប់សិស្សនិស្សិត និងគ្រួសាររបស់ពួកគេ
- បង្កើតស្តង់ដាសេវាអប្បបរមាសម្រាប់សាលាមធ្យមសិក្សាទាំងអស់
- រៀបចំគោលនយោបាយគ្រូបង្រៀនដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងផ្សព្វផ្សាយក្នុងអនុវិស័យអប់រំមធ្យមសិក្សាទាំងមូល
- បង្កើតអង្គភាពវិភាគស្ថិតិ (DGPP) ដើម្បីប្រើប្រាស់សុសវែរបង្កើតរូបភាពឌីជីថល
- សាងសង់អគារធនធានមធ្យមសិក្សាថ្មី ១៤ កន្លែងទៀត
- កែទម្រង់ដំណើរការ និងខ្លឹមសារនៃការប្រលងថ្នាក់ទី ១២
- ផ្ដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូដែលបង្រៀនគ្រប់មុខវិជ្ជាស្នូលទាំងអស់(ដែលបញ្ចូលទៅក្នុងការប្រលង)
- ដំណើរការវិទ្យាស្ថានគរុកោសល្យថ្មីទាំងពីរ ដើម្បីទទួលក្រុមគរុសិស្សដំបូងៗ
- អនុវត្តផែនការសកម្មភាពស្ដីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលាគោលដៅ
- បង្កើតបន្ទប់រៀនវិទ្យាសាស្ត្រ បណ្ណាល័យសតវត្សរ៍ទី ២១ និងបន្ទប់រៀនពហុបំណងនៅក្នុងបណ្ដាញវិទ្យាល័យធនធាន
- អនុវត្តការណែនាំ និងការប្រឹក្សាអាជីពសម្រាប់សិស្សមធ្យមសិក្សាក្នុងបណ្ដាញវិទ្យាល័យធនធាន
- អនុវត្តគោលវិធីគ្រប់គ្រងតាមសាលារៀន នៅតាមសាលាគោលដៅ (កម្មវិធីកែលម្អសាលារៀន)
- រៀបចំសេចក្ដីពិពណ៌នាអំពីកម្មវិធីសិក្សា ផ្អែកតាមលទ្ធផលសិក្សា
- បង្កើតមជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយ (CDDE)
- ផ្ដួចផ្ដើមអនុវត្តយុទ្ធសាស្ត្រពង្រាយគ្រូប្រកបដោយប្រសិទ្ធភាពក្នុងគ្រប់សាលាមធ្យមសិក្សាទាំងអស់
- កែលម្អបរិក្ខារទឹកស្អាត និងអនាម័យនៅក្នុងគ្រប់វិទ្យាល័យធនធានទាំងអស់ (អនុវត្តជាដំណាក់កាល)
- ធ្វើការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយលើគ្រប់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសទាំងអស់។

ដំណាក់កាលទី ២ (២០២៤-២០២៨)
ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨

- ដាក់បញ្ចូលស្តង់ដាសេវាអប្បបរមាក្នុងអគារសិក្សាថ្មីទាំងអស់
- កែលម្អ វិទ្យាស្ថានជាតិអប់រំទៅជា "មជ្ឈមណ្ឌលឧត្ដមភាព"
- ពង្រីកតួវិទ្យាស្ថានគរុកោសល្យទៅកាន់មជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងក្រឹត្យការភូមិភាគទាំងបួន
- បង្កើតសាលារៀនជំនាន់ថ្មីឱ្យបានយ៉ាងតិច ៩
- ពង្រីកគោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធិភាព ទៅគ្រប់បណ្ដាញវិទ្យាល័យធនធាន
- ពង្រីកប្រព័ន្ធអប់រំឌីជីថល តាមរយៈបណ្ដាញវិទ្យាល័យធនធាន
- ពង្រីកផែនការសកម្មភាពស្ដីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំទៅកាន់បណ្ដាញវិទ្យាល័យធនធាន
- ពង្រីកការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផ្ដោតលើមុខវិជ្ជា STEM/ICT ដល់គ្រូមធ្យមសិក្សា
- កែលម្អបរិក្ខារទឹកស្អាត និងអនាម័យសម្រាប់គ្រប់សាលាមធ្យមសិក្សាទាំងអស់ (អនុវត្តជាដំណាក់កាល)
- ពង្រីកកម្មវិធីអាហារូបករណ៍ និងកម្មវិធីគាំទ្រផ្សេងទៀតសម្រាប់សិស្ស
ប្រឈមនឹងហានិភ័យ និងក្រុមដែលជួបការលំបាក
- បង្កើតបណ្ដាញសាលារៀន និងសហគ្រាសក្នុងមូលដ្ឋាន តាមរយៈប្រព័ន្ធវិទ្យាល័យធនធាន
- ពង្រឹងវិទ្យាចំណេះទូទៅ និងបច្ចេកទេស ដែលមានស្រាប់ (១៤ កន្លែង)។

ដំណាក់កាលទី ៣ (២០២៩-២០៣៣)
ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៩-២០៣៣

- ដាក់បញ្ចូលស្តង់ដាសេវាអប្បបរមាក្នុងសាលាមធ្យមសិក្សាទាំងអស់
- រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំសម្រាប់កម្រិតមធ្យមសិក្សា (ឯកសារគោល) សម្រាប់ឆ្នាំ ២០៤០ - ផ្អែកតាមការពិនិត្យឡើងវិញចុងក្រោយ
- ពង្រីកគោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធិភាព ទៅគ្រប់សាលាមធ្យមសិក្សា
- បង្កើតសាលារៀនជំនាន់ថ្មីឱ្យបានយ៉ាងតិច ៥ សាលា
- សាងសង់អគារធនធានមធ្យមសិក្សា ១០ កន្លែងថ្មីទៀត
- ពង្រីកប្រព័ន្ធអប់រំឌីជីថល តាមរយៈប្រព័ន្ធអប់រំមធ្យមសិក្សា
- បង្កើតថ្នាក់រៀនវិទ្យាសាស្ត្រ បណ្ណាល័យសតវត្សរ៍ទី ២១ និងថ្នាក់រៀនពហុគោលបំណងនៅតាមអនុវិទ្យាល័យ
- ពង្រីកសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំទៅកាន់គ្រប់សាលាមធ្យមសិក្សាទាំងអស់
- កែលម្អបរិក្ខារទឹកស្អាត និងអនាម័យសម្រាប់គ្រប់សាលាមធ្យមសិក្សាទាំងអស់ (អនុវត្តជាដំណាក់កាល)
- បន្តផ្ដល់កម្មវិធីអាហារូបករណ៍ និងកម្មវិធីគាំទ្រផ្សេងទៀតសម្រាប់សិស្សដែលប្រឈមនឹងហានិភ័យ និងក្រុមជួបការលំបាក
- ធ្វើការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយលើគ្រប់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសទាំងអស់ ដើម្បីពិនិត្យមើលលទ្ធភាពពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។

ប្រភព៖ រចនាដោយក្រុមអ្នកនិពន្ធ

៨. ផលជះរយៈពេលវែងនៃការផ្លាស់ប្តូរ អនុវិស័យការអប់រំមធ្យមសិក្សា

ដើម្បីឱ្យផ្លាស់ប្តូរប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាកម្ពុជាមានប្រសិទ្ធភាព និងធានាបាននូវនិរន្តរភាព អ្នកចូលរួមម្នាក់ៗ ត្រូវយល់ពីតួនាទីដ៏សំខាន់ និងអត្ថប្រយោជន៍របស់ពួកគេ។ ការរំពឹងទុកចំពោះកម្មវិធីដែលត្រូវបានដាក់ចេញនៅក្នុងផែនទីបង្ហាញផ្លូវនេះនឹងនាំឱ្យមានការសម្រេចបានរួមគ្នា នូវអត្ថប្រយោជន៍ សិទ្ធិ និងការទទួលខុសត្រូវដែលគេចង់បានសម្រាប់ក្រុមនីមួយៗ(ប្រអប់ទី៣)។

ប្រអប់ទី៣៖ តួនាទី និងទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធការអប់រំ

សិស្ស	គ្រូបង្រៀន	អ្នកដឹកនាំសាលារៀន	មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា	មាតាបិតាសិស្ស
សិស្សនឹងទទួលបានការអភិវឌ្ឍយ៉ាងច្រើនដោយមិនគិតពីសាវតាររបស់ពួកគេ។ សិស្សនឹងសិក្សានៅក្នុងបរិយាកាសរៀនសូត្រដែលមានលក្ខណៈអំណោយផល និងមានអារម្មណ៍ថា ទទួលបានការរីកចម្រើន និងការទំនុកបម្រុងតាមរយៈបទពិសោធន៍របស់ពួកគេនៅក្នុងសាលារៀន។ នៅពេលដែលពួកគេចាកចេញពីសាលារៀន សិស្សនឹងទទួលបានចំណេះដឹង និងជំនាញកម្រិតខ្ពស់ មានគុណតម្លៃសីលធម៌រឹងមាំ និងមានសមត្ថភាពប្រកួតប្រជែងជាមួយនឹងប្រជាពលរដ្ឋនៅក្នុងប្រទេសផ្សេងទៀត។	គ្រូបង្រៀននឹងអភិវឌ្ឍសមត្ថភាពលំដាប់ថ្នាក់ពិភពលោកដែលចាំបាច់ ដើម្បីសម្របសម្រួលឱ្យសិស្សទទួលបានលទ្ធផលសិក្សា ដែលចង់បាន ព្រមទាំងរីករាយនិងពេញចិត្ត ជាមួយនឹងការងាររបស់ពួកគេ។ ជាមួយនឹង កញ្ចប់អាជីពសម្រាប់គ្រូដែលទើបជ្រើសរើសថ្មី ពួកគេនឹងទទួលបានឱកាសអភិវឌ្ឍវិជ្ជាជីវៈដែលធ្វើឱ្យពួកគេកាន់តែពេញចិត្ត គន្លងអាជីពដែលធ្វើឱ្យកាន់តែប្រសើរជាងមុន ព្រមទាំងដំណើរការវាយតម្លៃដែលយុត្តិធម៌ និងតម្លាភាព និងភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងសមត្ថភាព និងសមិទ្ធកម្មដែលពាក់ព័ន្ធ។	អ្នកដឹកនាំសាលារៀននឹងក្លាយជាអ្នកដឹកនាំការងារបង្រៀនដ៏ល្អ និងបំពេញតួនាទីជាភ្នាក់ងារដែលនាំមកនូវការផ្លាស់ប្តូរ។ ពួកគេនឹងទទួលបានការគាំទ្រកាន់តែជិតដិត និងសេវាកាន់តែប្រសើរពីមន្ត្រីអប់រំនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក។ ពួកគេនឹងទទួលបានវគ្គបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំលំដាប់ថ្នាក់ពិភពលោក ក៏ដូចជា ឧត្តមានុវត្តន៍ពីសហការីរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។	មន្ត្រីរបស់ក្រសួងនឹងអភិវឌ្ឍសមត្ថភាពជាអ្នកដឹកនាំការផ្លាស់ប្តូរជាមួយនឹងជំនាញ និងលក្ខណៈសម្បត្តិដែលចាំបាច់សម្រាប់ជួយគាំទ្រដល់សាលារៀន។ ពួកគេនឹងក្លាយជាអ្នកគ្រប់គ្រងគ្រូបង្វឹក និងអ្នកគាំទ្រកាន់តែប្រសើរ ដើម្បីជួយឱ្យសាលារៀនសម្រេចបានលទ្ធផលការងារល្អបំផុត។ ពួកគេនឹងត្រូវបានឱ្យតម្លៃសម្រាប់គុណសម្បត្តិការងារ របស់ពួកគេ ទទួលបានការបង្កើនភាពអង់អាចតាមរយៈការផ្តល់នូវការទទួលខុសត្រូវច្រើនជាងមុន និងការងាកចេញពីឋានុក្រម និងការត្រួតត្រា។	មាតាបិតាសិស្សនឹងមើលឃើញភាពល្អប្រសើរដែលស្តែងចេញយ៉ាងច្បាស់ និងបន្តនៅគង់វង្ស ជុំវិញបទពិសោធន៍ទទួលបានការអប់រំរបស់កូនៗរបស់ពួកគេ។ ចំណុចនេះ នឹងមានការបង្កើនតម្លាភាពជុំវិញសមិទ្ធកម្ម និងការកំណត់អាទិភាពរបស់សាលារៀន ហើយមាតាបិតាសិស្សនឹងទទួលបានព័ត៌មានជាប់ជាប្រចាំអំពីការសិក្សារបស់កូនរបស់ពួកគេទាំងលទ្ធផលសិក្សាទាំងផ្នែកដែលត្រូវអភិវឌ្ឍបន្ថែម។ មាតាបិតានឹងមានអារម្មណ៍ថាពួកគេជាដៃគូពិតប្រាកដជាមួយនឹងសាលារៀនក្នុងការសម្របសម្រួលការរៀនសូត្ររបស់កូនពួកគេ។
• សិស្សនឹងរៀនសូត្រក្នុងបរិយាកាសដែលមានជំនឿជាមូលដ្ឋានថា សិស្សទាំងអស់សុទ្ធតែអាចរៀនចេះ និងសិស្សទាំងអស់សុទ្ធតែអាចទទួលបានជោគជ័យ។ គ្រូនឹងមានការរំពឹងទុកខ្ពស់ពីសិស្ស ដោយមិនប្រកាន់ពីសាវតារ ឬសមិទ្ធផលដែលពួកគេសម្រេចបានកន្លងមក ព្រមទាំងផ្តល់ឱ្យពួកគេនូវការគាំទ្រដែលចាំបាច់ ដើម្បីបំពេញការរំពឹងទុកទាំងនោះ។ • សិស្សនឹងទទួលបានបទពិសោធន៍ក្នុងសាលារៀនកាន់តែសម្បូរបែបទាំង បទពិសោធន៍ពាក់ព័ន្ធនឹងការ	• គ្រូបង្រៀននឹងទទួលបានការគាំទ្រដែលពួកគេត្រូវការ ដើម្បីទទួលបានជោគជ័យ។ ពួកគេនឹងទទួលបានឱកាសអភិវឌ្ឍវិជ្ជាជីវៈនៅតាមសាលារៀនបន្ថែមទៀត។ ពួកគេនឹងចូលរួមក្នុងកិច្ចពិភាក្សា និងកិច្ចពិគ្រោះយោបល់ ដើម្បីទទួលបានមតិត្រឡប់ប្រកបដោយលក្ខណៈស្ថាបនា ដែលមិនផ្តោតលើការបន្ទោស និងការដាក់ទោសទណ្ឌនោះឡើយ ប៉ុន្តែផ្តោតលើការរៀនសូត្រ និងការអភិវឌ្ឍ ដើម្បីឱ្យចំណុចដែលត្រូវកែលម្អក្លាយទៅជាចំណុចខ្លាំង។	• អ្នកដឹកនាំសាលានឹងទទួលបានការគាំទ្រ ក៏ដូចជា ធនធានដែលពួកគេត្រូវការ ដើម្បី តម្រង់ទិសសាលារៀនរបស់ពួកគេឱ្យមានប្រសិទ្ធភាព។ ពួកគេនឹងទទួលបានការបណ្តុះបណ្តាលត្រៀមការណែនាំការងារ និងការបណ្តុះបណ្តាលបន្តកាន់តែប្រសើរ ដើម្បីជួយឱ្យពួកគេអភិវឌ្ឍជំនាញដឹកនាំរបស់ពួកគេ។ ពួកគេនឹងទទួលបានការឆ្លើយតបកាន់តែប្រសើរពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំពោះបញ្ហាដែលពួកគេជួបប្រទះ ចាប់ពីការពង្រាយទីប្រឹក្សា	• មន្ត្រីក្រសួងនឹងទទួលបានការគាំទ្រការបណ្តុះបណ្តាល និងធនធានចំគោលដៅដែលពួកគេត្រូវការ ដើម្បីបំពេញតួនាទី និងការទទួលខុសត្រូវថ្មីរបស់ពួកគេ។ ពួកគេនឹងមានតួនាទីថ្មីដែលផ្តោតលើការគាំទ្រសាលារៀន និងទទួលបាន ឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈបន្ថែមទៀត។ ពួកគេនឹងចូលរួមនៅក្នុងការពិភាក្សាផ្តល់មតិត្រឡប់បែបស្ថាបនា ដែលមិនផ្តោតលើការបន្ទោស និងការដាក់ទោសទណ្ឌឡើយ ប៉ុន្តែផ្តោតលើការរៀនសូត្រ និងការអភិវឌ្ឍ។	• មាតាបិតាសិស្សនឹងយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍរបស់កូនៗរបស់ពួកគេ និងរបៀបដែលពួកគេអាចជួយឱ្យកូនរបស់ពួកគេកាន់តែប្រសើរជាងមុន។ ពួកគេនឹងអាចទំនាក់ទំនងជាប្រចាំជាមួយនឹងគ្រូមិនមែនត្រឹមតែពេលដែលមានបញ្ហាកើតមានឡើងនោះឡើយ។ ពួកគេនឹងមើលឃើញច្បាស់ ក៏ដូចជាទទួលបានព័ត៌មានពេញលេញអំពីលទ្ធផលសិក្សារបស់កូនពួកគេក្នុងការប្រឡងថ្នាក់ជាតិ និងការវាយតម្លៃតាមសាលារៀន។ ពួកគេនឹងទទួល

សិក្សា និងបទពិសោធន៍ដែលមិនពាក់ព័ន្ធនឹងការសិក្សា ដើម្បីឱ្យពួកគេអាច
រីកចម្រើននៅក្នុងជីវិត។ ចំណុចនេះនឹងមានការងារជាគម្រោង និងការងារក្រុមកាន់តែច្រើន ដើម្បីអភិវឌ្ឍជំនាញត្រិះរិះពិចារណាកម្រិតខ្ពស់របស់សិស្ស និងសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើការដោយម្ចាស់ការដោយខ្លួនឯង និងសហការជាក្រុម។ លើសពីនេះ ក៏នឹងមានគម្រោងតាមសហគមន៍ និងសកម្មភាពឆ្លងសាលារៀន ដើម្បីបណ្ដុះជំនាញទំនាក់ទំនងជាមួយនឹងមនុស្សដែលមកពីគ្រប់ស្រទាប់វណ្ណៈ។ នេះនឹងមានឱកាសកាន់តែច្រើន ដើម្បីឱ្យសិស្សរៀនសូត្រទៅតាមល្បឿនផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីចាប់យកជំនាញដែលពួកគេចាប់អារម្មណ៍ដូចជា ផ្នែកសិក្សា ផ្នែកវិជ្ជាជីវៈ ឬផ្នែកបច្ចេកទេស ជាដើម។

- គ្រូបង្រៀននឹងទទួលបានលក្ខខណ្ឌការងារកាន់តែប្រសើរ ការផ្ដល់រង្វាន់ផ្អែកតាមសមិទ្ធកម្ម និងគន្លងអាជីពដែលកាន់តែប្រសើរជាងមុន។ ពួកគេនឹងធ្វើការក្នុងសាលារៀនដែលមានសម្ភារបរិក្ខារគ្រប់គ្រាន់និងលក្ខខណ្ឌការងារសមស្រប។ ពួកគេនឹងទទួលបន្ទុកការងាររដ្ឋបាលតិចជាងមុន ដើម្បីឱ្យពួកគេអាចចយកថាមពលរបស់ពួកគេទៅផ្ដោតលើសកម្មភាពរៀន និងបង្រៀនស្នូល។ ពួកគេនឹងទទួលបានរង្វាន់ ផ្អែកតាមសមិទ្ធកម្មដូចជាការរីក-ចម្រើន ក្នុងអាជីពលឿនជាងមុន ព្រមទាំងអាចអភិវឌ្ឍជំនាញដែលពួកគេចង់អភិវឌ្ឍក្នុងគន្លងអាជីពពិសេស ដូចជា ការដឹកនាំការបង្រៀន និងឯកទេស មុខវិជ្ជា ជាដើម។
- គ្រូបង្រៀននឹងចូលប្រលូកក្នុងវប្បធម៌សហការ និងឧត្តមភាពវិជ្ជាជីវៈ។ ពួកគេនឹងសហការជាមួយគ្នាទៅវិញទៅមក ដើម្បីដោះស្រាយបញ្ហា ព្រមទាំងចែករំលែកឧត្តមានុវត្តន៍នានា។ ពួកគេនឹងមានភាពទទួលខុសត្រូវផ្អែកគរុកោសល្យជាងមុននៅក្នុងថ្នាក់រៀន ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាឱ្យសិស្សគ្រប់រូបសុទ្ធតែអាច រៀនបាន។

គរុកោសល្យរហូតដល់ការផ្ដល់ធនធានបន្ថែម ប្រសិនបើសាលារៀនត្រូវការធនធានទាំងនោះ។

- អ្នកដឹកនាំសាលារៀននឹងទទួលបានលក្ខខណ្ឌការងារកាន់តែប្រសើរ និងរង្វាន់ផ្អែកតាមសមិទ្ធកម្ម។ នាយកនាយករង ក៏ដូចជា ប្រធានក្រុមបច្ចេកទេសមុខវិជ្ជា និងប្រធានដេប៉ាតឺម៉ង់ នឹងធ្វើបំពេញការងារតាមសាលារៀន ជាមួយនឹងសម្ភាររូបវន្តគ្រប់គ្រាន់ ព្រមទាំងទទួលបន្ទុកការងាររដ្ឋបាលតិចជាងមុន ដើម្បីឱ្យពួកគេអាចយកថាមពលទៅផ្ដោតលើការដឹកនាំការងារបង្រៀន។
- ពួកគេនឹងទទួលបានរង្វាន់ផ្អែកតាមសមិទ្ធកម្ម ដូចជា ការរីកចម្រើនក្នុងអាជីពលឿនជាងមុន ព្រមទាំងប្រាក់ឧបត្ថម្ភបន្ថែម សម្រាប់ការបំពេញការងារប្រកបដោយជោគជ័យនៅតាមសាលាជនបទ ដែលសម្រេចបានលទ្ធផលការងារកម្រិតទាបនៅឡើយ។
- អ្នកដឹកនាំសាលារៀននឹងទទួលបានភាពអង់អាចតាមរយៈការបង្កើនការគ្រប់គ្រងតាមសាលារៀន។ ពួកគេនឹងទទួលបានភាពបត់បែនក្នុងការដំណើរការសាលារៀន ស្របតាមសមិទ្ធកម្មសាលារៀន សម្រាប់បញ្ហានានា ដូចជា ការរៀបចំកាលវិភាគសម្រាប់អនុវត្តន៍កម្មវិធីសិក្សា និងការវិភាជថវិកាជាដើម។ ពួកគេនឹងកសាងភាពជាដៃគូកម្រិតវិជ្ជាជីវៈជាមួយនឹងមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តរបស់ពួកគេ តាមរយៈជាតុចូលក្នុងផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំរបស់សាលារៀនរបស់ពួកគេ ព្រមទាំង

- មន្ត្រីក្រសួងនឹងបំពេញការងារនៅក្នុងបរិយាកាសប្រកបដោយការសហការ និងតម្លាភាព។ ការធ្វើការងារដាច់ដោយឡែកពីគ្នារវាងផ្នែកមួយនឹងផ្នែកមួយទៀត នឹងលែងមាន ហើយតួនាទី និងការទទួលខុសត្រូវនឹងត្រូវបានសម្រួល ដើម្បីលុបបំបាត់ការបំពេញមុខងារ និងការធ្វើសកម្មភាពត្រួតគ្នា។ ចំណុចនេះនឹងមានការចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធភាព ដើម្បីផ្ដល់លទ្ធភាពឱ្យមានការធ្វើការសម្រេចចិត្តផ្អែកតាមភស្តុតាង។ នេះនឹងមានការបង្កើតភាពច្បាស់លាស់ជុំវិញរបៀបធ្វើការសម្រេចចិត្ត។
- មន្ត្រីក្រសួងនឹងទទួលបានភាពបត់បែនក្នុងប្រតិបត្តិការការងារនិងគណនេយ្យភាពខ្ពស់ជាងមុន។ មន្ត្រីទាំងនេះនឹងអាចផ្ដល់មតិយោបល់ច្រើនជាងមុន ក្នុងការកំណត់ពីចំណុចដែលត្រូវធ្វើការកែលម្អសម្រាប់ រាជធានីខេត្ត ស្រុក ក្រុង ខណ្ឌ និងសាលារៀនរបស់ពួកគេ ក៏ដូចជា រៀបចំដំណោះស្រាយឱ្យស្របតាមបរិបទ ជាក់លាក់។

បានការណែនាំ ដំបូន្មានអំពីរបៀបចិញ្ចឹមបីបាច់កូននៅក្នុងថ្នាក់អប់រំមនុស្សពេញវ័យ របៀបផ្ដល់ការគាំទ្រ ដើម្បីឱ្យកូនរបស់ពួកគេទទួលបានការសិក្សា និងការអភិវឌ្ឍល្អបំផុត។

- មាតាបិតាសិស្សនឹងកាន់តែមានឱកាស ដើម្បីផ្ដល់ធាតុចូលទៅក្នុងយុទ្ធសាស្ត្រកែលម្អសាលារៀន។ ពួកគេនឹងមានសិទ្ធិទទួលបានព័ត៌មានពេញលេញអំពីបេសកកម្ម សមិទ្ធកម្មបច្ចុប្បន្ន និង កម្មវិធីកែលម្អប្រចាំឆ្នាំរបស់សាលារៀន តាមរយៈគោលវិធីអនុវត្តន៍ការគ្រប់គ្រងតាមសាលារៀនរបស់ពួកគេ ពួកគេនឹងអាចផ្ដល់ធាតុចូលលើបញ្ហានានា ដូចជា បញ្ហាគ្រូ និងគុណភាពនៃកម្មវិធីសិក្សា ជាដើម។ ពួកគេនឹងទទួលបានអារម្មណ៍កក់ក្ដៅ និងត្រូវបានគេឱ្យតម្លៃចំពោះការប្ដេជ្ញាចិត្តរបស់ពួកគេចំពោះកូនៗ និងចំពោះសាលារៀន។

		ទទួលបានតម្លាភាពកាន់តែខ្ពស់ជាងមុន ពាក់ព័ន្ធនឹងការសម្រេចចិត្តនានាដែលប៉ះពាល់ដល់សាលារៀនរបស់ពួកគេ។		
• ជាថ្នូរត្រឡប់មកវិញ ជានិច្ចកាលនឹងមានការស្នើឱ្យសិស្សព្យាយាមឱ្យអស់ពីលទ្ធភាព និងធ្វើការសហការជាមួយនឹងគ្រូបង្រៀនរបស់ពួកគេ ដើម្បីកាត់បន្ថយឥរិយាបថដែលបង្ករាំងខានក្នុងថ្នាក់រៀន។ សិស្សទាំងអស់នឹងទទួលខុសត្រូវរួមគ្នា ដើម្បីជួយធ្វើឱ្យសាលារៀនរបស់ពួកគេមានសុវត្ថិភាព និងជាកន្លែងដែលមានលក្ខណៈអំណោយផលសម្រាប់ការរៀនសូត្រ។	• ជាថ្នូរត្រឡប់មកវិញ គ្រូបង្រៀននឹងត្រូវស្នើឱ្យបើកចំហទទួលយកការរៀនសូត្រ និងរបៀបធ្វើការថ្មីៗ ជំរុញឱ្យមានការចូលរួមពីឪពុកម្ដាយ និងសិស្សនៅក្នុងដំណើរការរៀន និងធ្វើជាបុគ្គលគំរូដែលបង្ហាញពីផ្នត់គំនិត គុណតម្លៃ និងឥរិយាបថដែលពួកគេរំពឹងចង់បានពីសិស្ស។	• ជាថ្នូរត្រឡប់មកវិញ អ្នកដឹកនាំសាលានឹងត្រូវស្នើឱ្យបំពេញការងារស្របតាមការរំពឹងទុកកម្រិតខ្ពស់ដែលត្រូវបានដាក់ចេញ និងដែលត្រូវបានឯកភាពសម្រាប់សាលារៀនរបស់ពួកគេ។ ពួកគេចាំបាច់ត្រូវបើកចំហទទួលយករបៀបធ្វើការថ្មី ជំរុញឱ្យមានការចូលរួមពីសហគមន៍នៅក្នុងការកែលម្អសាលារៀន និងបំពេញតួនាទីជាគ្រូបង្វឹក និងគ្រូបណ្ដុះ-បណ្ដាល ដើម្បីកសាងសមត្ថភាពបុគ្គលិករបស់ពួកគេ ក៏ដូចជា បុគ្គលិកមកពីសាលារៀនដទៃទៀត។	• ជាថ្នូរត្រឡប់មកវិញ មន្ត្រីក្រសួងនឹងត្រូវបានស្នើឱ្យបើកចំហទទួលយកមតិត្រឡប់ពីសាលារៀន និងពីសហគមន៍។ ពួកគេនឹងដឹកនាំការផ្លាស់ប្ដូរនៅក្នុងប្រព័ន្ធដែលនឹងត្រូវអនុវត្តនាពេល ឆាប់ៗនេះ។ពួកគេចាំបាច់ត្រូវឆ្លើយតបក្នុងកម្រិតខ្ពស់ ដើម្បីផ្ដល់ឱ្យសាលារៀននូវការគាំទ្រ និងធនធាននានាដែលសាលារៀនទាំងនោះត្រូវការ ក៏ដូចជាបន្តផ្ដល់ព័ត៌មានដល់អ្នកពាក់ព័ន្ធទាំងក្នុងក្រសួង ទាំងក្រៅក្រសួង។	• ជាថ្នូរត្រឡប់មកវិញ មាតាបិតានឹងត្រូវស្នើឱ្យជួយដល់កូនរបស់ពួកគេអាចសម្រេចសក្ដានុពលនៃការរៀនសូត្រ (ឧទាហរណ៍ ជួយឱ្យកូនធ្វើកិច្ចការផ្ទះ និងមករៀនឱ្យបានទាន់ពេលវេលា) និងបង្ហាញជាគំរូអំពីការប្ដេជ្ញាចិត្ត ការចូលរួម និងការបើកចំហសម្រាប់កូនៗរបស់ពួកគេ។ មាតាបិតាសិស្សចាំបាច់ត្រូវបង្ហាញពីជាតុចូល និងការព្រួយបារម្ភទៅកាន់សាលារៀនក្នុងលក្ខណៈស្ថាបនា និងត្រូវចូលរួមឱ្យបានសកម្មក្នុងសកម្មភាពនានានៅក្នុងសាលារៀន។

ប្រភព៖ ដកស្រង់ចេញពី*ឯកសារគោលស្ថិតិវិស័យអប់រំរបស់ប្រទេសម៉ាឡេស៊ី ២០១៣-២០២៥៖ ពីកម្រិតមត្តេយ្យសិក្សាដល់កម្រិតអប់រំក្រោយមធ្យមសិក្សា* ទីក្រុងគូឡាឡាំពួ ក្រសួងអប់រំប្រទេសម៉ាឡេស៊ី ឆ្នាំ ២០១៣។

៩. អាទិភាព និងលទ្ធផលសំខាន់ៗនៅក្នុងផែនទីបង្ហាញផ្លូវ

ផែនទីបង្ហាញផ្លូវនេះមានគោលបំណងសម្រេចឱ្យបាននូវវត្ថុបំណងដូចខាងក្រោម ស្របតាមគោលដៅដែលបានដាក់ចេញនៅក្នុងផែនទីបង្ហាញផ្លូវស្តីពីការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤ - ការអប់រំកម្ពុជាឆ្នាំ ២០៣០ និងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣។

(១) សិស្សកម្ពុជាគ្រប់រូបបញ្ចប់ការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ដោយឥតបង់ថ្លៃ ប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងទទួលបានបំណិនអាន សរសេរ លេខនព្វន្ត ចំណេះដឹងលើមុខវិជ្ជាផ្សេងៗ បំណិនក្នុងការគិត និងភាពប៉ិនប្រសប់ក្នុងការងារដែលផ្តល់លទ្ធភាពឱ្យពួកគេអភិវឌ្ឍសក្តានុពលបានយ៉ាងពេញលេញ។

(២) សិស្សគ្រប់រូបមានលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលផ្តល់ជម្រើសក្នុងការអប់រំបច្ចេកទេសវិជ្ជាជីវៈ ដែលមានតម្លៃសមរម្យ និងប្រកបដោយគុណភាព ឬ ការត្រៀមខ្លួនសម្រាប់ឧត្តមសិក្សា។ ពោលគឺ ពួកគេមានសមត្ថភាពឆ្លងទៅដំណាក់កាលទាំងពីរនេះ។

(៣) សម្រេចបានស្តង់ដានៃការបង្រៀន និងការរៀនសូត្រ ដែលមានគុណភាពខ្ពស់តាមរយៈការបង្កើនការអប់រំគ្រូបង្រៀននៅកម្រិតបណ្តុះបណ្តាលគ្រូ និងវិក្រឹតការគ្រូ។

(៤) ស្តង់ដានៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងល្អឯកនៅគ្រប់កម្រិត ដែលលើកកម្ពស់ការបង្រៀន និងការរៀនសូត្រកម្រិតខ្ពស់ លេចឡើងនៅគ្រប់សាលាមធ្យមសិក្សាទាំងអស់ទូទាំងប្រទេសកម្ពុជា។

(៥) យុវជនកាន់តែច្រើនមានលទ្ធភាពកាន់តែប្រសើរ ក្នុងការទទួលបានកម្មវិធីបច្ចេកទេសវិជ្ជាជីវៈ ដែលមានគុណភាព និងពាក់ព័ន្ធ ដែលឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច និងតម្រូវការឧស្សាហកម្មក្នុងមូលដ្ឋាន។

ដើម្បីសម្រេចលទ្ធផលទាំងនេះ អាទិភាពសំខាន់ៗ ៨ ដែលត្រូវបានកំណត់នៅក្នុងជំពូកទី ៦ រួមមាន៖

(១) បង្កើនការចូលរួមរបស់សិស្សក្នុងការអប់រំមធ្យមសិក្សាចំណេះទូទៅ (រួមទាំងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស)

(២) កែសម្រួលកម្មវិធីសិក្សា សៀវភៅសិក្សា ការបង្រៀន និងការវាយតម្លៃ ឱ្យស្របតាមការអប់រំប្រកបដោយគុណភាពសម្រាប់សតវត្សរ៍ទី ២១

(៣) បញ្ចូលការអប់រំឌីជីថល ទៅក្នុងការអប់រំកម្រិតមធ្យមសិក្សា

(៤) អនុវត្តគោលនយោបាយគ្រូបង្រៀន ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនៅកម្រិតមធ្យមសិក្សា

(៥) បន្តផ្តោតការយកចិត្តទុកដាក់ជាប្រព័ន្ធលើការអប់រំគ្រូមធ្យមសិក្សា

(៦) បន្តផ្តោតការយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ការដឹកនាំ និងការគ្រប់គ្រងសាលាមធ្យមសិក្សា

(៧) ធ្វើពិពិធកម្ម និងពង្រឹងលទ្ធផលនៃការអប់រំមធ្យមសិក្សាបច្ចេកទេសឱ្យបំពេញតម្រូវការសេដ្ឋកិច្ច និងតម្រូវការទីផ្សារការងារក្នុងមូលដ្ឋាន

(៨) បង្កើនការផ្សារភ្ជាប់ និងការចូលរួមក្នុងការអប់រំកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សា។

ក្នុងអាទិភាពនីមួយៗ មានការកំណត់លទ្ធផលរំពឹងទុកសំខាន់ៗ មួយចំនួន ដែលត្រូវអនុវត្ត ដើម្បីសម្រេចបានគោលបំណងនៃការអប់រំមធ្យមសិក្សាដែលចង់បានសម្រាប់យុវជនកម្ពុជា(តារាងទី៦)។

តារាងទី៦៖លទ្ធផលរំពឹងទុករបស់អាទិភាពគន្លឹះទាំង៨

អាទិភាពគន្លឹះ		លទ្ធផលសំខាន់ៗ	លទ្ធផលសំខាន់ៗ
១. បង្កើនការចូលរៀន និងគុណភាពការអប់រំមធ្យមសិក្សាចំណេះទូទៅ (រួមទាំងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស)	១.១	មានគន្លងអប់រំមធ្យមសិក្សា ដែលបង្ហាញយ៉ាងច្បាស់ដល់សិស្ស មាតាបិតា និងគ្រូបង្រៀន ពីជម្រើសអប់រំ និងបណ្តុះ-បណ្តាលដែលមាន ហើយនឹងស្តង់ដានៃការទទួលស្គាល់គុណភាព និងវិញ្ញាបនបត្រដែលមានការទទួលស្គាល់ទៅវិញទៅមកនៅដំណាក់កាលនីមួយៗ។	MOEYS, MLVT
	១.២	សិស្សដែលប្រឈមនឹងការបោះបង់ពីសាលារៀនត្រូវបានកំណត់អត្តសញ្ញាណ និងពិនិត្យតាមដានដោយអ្នក/គ្រូប្រឹក្សាយោបល់ ដើម្បីកាត់បន្ថយការបោះបង់ពីសាលា និងផ្តល់ការលើកទឹកចិត្ត (ឧ. អាហារូបករណ៍ ថ្នាក់បំប៉ន បទពិសោធន៍ការងារ) ដើម្បីបន្តការសិក្សា។	DGSE
	១.៣	មានការផ្តល់អាហារូបករណ៍បន្ថែមដល់សិស្សមធ្យមសិក្សាដែលមានពិការភាព ជនជាតិដើមភាគតិច យុវជន កុមារក្រីក្រ និងក្រុមជួបការលំបាក។	DGSE
	១.៤	កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន (BEEP) សម្រាប់សិស្សដែលធ្លាប់បោះបង់ពីសាលារៀន ត្រូវបានកែសម្រួលដោយបញ្ចូលបង្ហាញពីគន្លងអប់រំដាក់លាក់ ដើម្បីឈានទៅទទួលបានការបញ្ជាក់ទទួលស្គាល់ពីក្របខណ្ឌគុណវុឌ្ឍិកម្ពុជា។	DNFE
	១.៥	បង្កើតមូលដ្ឋានទិន្នន័យដែលមានគុណភាពសម្រាប់កម្មវិធីបង្កើតរូបភាពឌីជីថល សម្រាប់ឱ្យនាយកដ្ឋាន ក្រសួង អ.យ.ក ប្រើប្រាស់ក្នុងការរៀបចំផែនការជាប្រចាំជាពិសេសការរៀបចំផែនការ ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងតម្រូវការពង្រាយគ្រូបង្រៀន។	DGPP
	១.៦	ផ្អែកតាមស្តង់ដាសេវាអប្បបរមារបស់ក្រសួង អ.យ.ក ធ្វើការកែលម្អបរិក្ខារអប់រំមធ្យមសិក្សាដោយប្រើប្រាស់ការរចនាប្លង់ស្ថាបត្យកម្មសតវត្សទី ២១ ដើម្បីសម្រួលនិងគាំទ្រដល់ការអនុវត្តគោលវិធីរៀន និងបង្រៀនបែបនវានុវត្តន៍ និងបែបស្ថាបនាក្នុងសាលាមធ្យមសិក្សា។	DGE, DGPP, DGAF
	១.៧	សាលាមធ្យមសិក្សាទាំងអស់ មានកន្លែង/ការិយាល័យសម្រាប់គ្រូម្នាក់ៗបំពេញការងារ និងសាលប្រជុំដើម្បីសម្រួលដល់កិច្ចសហការប្រកបដោយវិជ្ជាជីវៈរបស់គ្រូបង្រៀន។	DoC
	១.៨	គ្រប់សាលាមធ្យមសិក្សាទាំងអស់ មានបង្គន់ដែលអាចប្រើប្រាស់បាន និងបែងចែកទៅតាមសិស្សប្រុស សិស្សស្រី ដោយមានបរិក្ខារអនាម័យ និងទឹកប្រើប្រាស់គ្រប់ពេល/វេរ ។	DoC
	១.៩	ប្រធានបទស្តីពីសុខភាព និងសុខុមាលភាព ត្រូវបានបញ្ចូលក្នុងមុខវិជ្ជាពាក់ព័ន្ធ ដោយផ្តោតជាសំខាន់បន្ថែមទៀតលើសកម្មភាពអប់រំកាយ និងកីឡា។	SHD
	១.១០	សិស្សមធ្យមសិក្សា និងបុគ្គលិកកម្រិតមធ្យមសិក្សាទាំងអស់ បានទទួលការពិនិត្យសុខភាពពេញលេញ (រួមទាំងតេស្ត ភ្នែក ធ្មេញ និងការស្តាប់) រៀងរាល់ ២ ឆ្នាំម្តងពីមណ្ឌលសុខភាព។	DGSE, MoH
២. បន្តផ្តោតការយកចិត្តទុកដាក់ ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ការដឹកនាំ និងការគ្រប់គ្រងសាលាមធ្យមសិក្សា	២.១	គ្រប់សាលាមធ្យមសិក្សាទាំងអស់ ទោះស្ថិតនៅកន្លែងណាក៏ដោយ មានក្រុមដឹកនាំសាលារៀន (នាយក និងនាយករង) ដែលមានសមិទ្ធកម្ម/ស្នាដៃការងារល្អ និងត្រូវបានជ្រើសតាំងទៅតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពីការតែងតាំងនាយកសាលា ហើយក៏ជាអ្នកដឹកនាំការបង្រៀន និងជំរុញសមិទ្ធកម្ម/ស្នាដៃការងាររួមរបស់សាលារៀន។	DGSE, DoP
	២.២	កម្មវិធីអភិវឌ្ឍន៍ការដឹកនាំ និងគ្រប់គ្រងសាលារៀន ជាកាតព្វកិច្ចសម្រាប់នាយក និងនាយករងដែលទើបតែងតាំងថ្មី ទាំងអស់ និងអ្នកដែលមានបំណងចង់ក្លាយខ្លួនជានាយក និងនាយករង តាមរយៈកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ ដើម្បីធានាស្តង់ដាខ្ពស់។	TTD, NIE
	២.៣	គោលវិធីគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព រួមទាំងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដោយមានការទទួលខុសត្រូវលើការជួយដល់នាយកសាលាក្នុងបញ្ហារដ្ឋបាល ត្រូវបានអនុវត្តនៅគ្រប់សាលាមធ្យមសិក្សាទាំងអស់ និងត្រូវបានកំណត់ថាជាស្តង់ដាអប្បបរមា។	DGSE
	២.៤	ប្រព័ន្ធបណ្តាញវិទ្យាល័យធនធាន ត្រូវបានបង្កើតឡើងពេញលេញ និងស្ថិតនៅក្រោមនាយកដ្ឋានអប់រំមធ្យមសិក្សាចំណេះទូទៅ សម្រាប់ឱ្យការគ្រប់គ្រងទូទាំងប្រព័ន្ធកាន់តែមានភាពល្អប្រសើរ ។	DGSE
	២.៥	គោលនយោបាយគ្រប់គ្រង និងការអនុវត្តរបស់សាលាជំនាន់ថ្មី ហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីសិក្សា ត្រូវបានរួមបញ្ចូលទៅក្នុងប្រព័ន្ធអប់រំនៅមធ្យមសិក្សា។	DGSE
	២.៦	សាលាមធ្យមសិក្សាផ្សេងទៀត ដែលប្រាថ្នាក្លាយជាសាលាជំនាន់ថ្មី ត្រូវអនុវត្តទៅតាមគោលនីតិវិធីបានត្រឹមត្រូវ ។	DGSE, EQAD

អាទិភាពគន្លឹះ		លទ្ធផលសំខាន់ៗ	លទ្ធផលសំខាន់ៗ
៣. រៀបចំកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃ ឱ្យស្របតាមការអប់រំប្រកបដោយគុណភាពសម្រាប់សតវត្សទី ២១	៣.១	ស្តង់ដាកម្មវិធីសិក្សាលម្អិតសម្រាប់កម្រិតមធ្យមសិក្សាគ្រប់មុខវិជ្ជា ត្រូវបានរៀបចំឡើងផ្អែកតាមលទ្ធផលសិក្សា របស់សិស្ស។	DCD
	៣.២	កម្មវិធីសិក្សាត្រូវបានកែសម្រួល និងបញ្ចូលជំនាញសិក្សាសម្រាប់សតវត្សទី ២១ សមាសភាគ STEM និងភាសាបរទេសយ៉ាងតិចចំនួន ៣ (សម្រាប់សិស្សជ្រើសរើសសិក្សា)។	DCD
	៣.៣	យុទ្ធសាស្ត្ររៀន និងបង្រៀនផ្អែកតាមបញ្ហា និងបែបរិះរក ត្រូវបានអនុវត្តក្នុងថ្នាក់រៀនមធ្យមសិក្សា ដោយប្រើការរៀនសូត្រចម្រុះ (បច្ចេកវិទ្យាក្នុងមុខវិជ្ជាសិក្សា)។	DGSE, TTD
	៣.៤	កែទម្រង់លទ្ធផលប្រឡងបញ្ចប់ការសិក្សារបស់សិស្សថ្នាក់ទី១២ ដោយការបូកបញ្ចូលពិន្ទុដែលបានមកពីការប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិ និងពិន្ទុដែលសិស្សទទួលបាននៅក្នុងថ្នាក់ ។	DExA
៤. បញ្ចូលការអប់រំឌីជីថលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សា	៤.១	គ្រូមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន និងរៀន ។	TTD, NIE, DIT
	៤.២	មានប្រព័ន្ធ ICT ទូលំទូលាយ សម្រាប់បម្រើដល់ការរៀនសូត្ររបស់សិស្សតាមប្រព័ន្ធអនឡាញ និងការរៀនសូត្រចម្រុះ បានដាក់ឱ្យអនុវត្ត និងងាយស្រួលចូលប្រើដោយគ្រូ និងសិស្សមធ្យមសិក្សាទាំងអស់ ។	DIT, CDE
	៤.៣	បរិក្ខារ ឧបករណ៍ និងសម្ភារអប់រំឌីជីថលទាំងអស់ ត្រូវបានដាក់បញ្ចូលក្នុងការបង្រៀន និងរៀននៅគ្រប់បណ្ដាញវិទ្យាល័យធនធានទាំងអស់ (រួមទាំងទូរទស្សន៍ និងវិទ្យុ-បើអាច)។	DGSE, DoC, DIT
៥. អនុវត្តគោលនយោបាយគ្រូបង្រៀនដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុង អនុវិស័យមធ្យមសិក្សា	៥.១	គោលនយោបាយគ្រូបង្រៀនថ្មី និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ត្រូវបានផ្សព្វផ្សាយ និងអនុវត្តនៅតាមសាលាមធ្យមសិក្សា។	DoPo
	៥.២	គោលនយោបាយស្តីពីការជ្រើសរើសគ្រូបង្រៀនចេញថ្មី ត្រូវបានធ្វើបច្ចុប្បន្នកម្ម ដើម្បីទាក់ទាញបេក្ខជនឆ្នើមឱ្យចាប់យកអាជីពបង្រៀន (ផ្តោតលើសមត្ថភាពសិក្សា និងឧបនិស្ស័យ)។	DoPo, DoP
	៥.៣	មានការពិពណ៌នាច្បាស់លាស់អំពីការងារ តួនាទី ការទទួលខុសត្រូវ រួមទាំងការតម្រូវឱ្យអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជារៀងរាល់ឆ្នាំទៅតាមសេចក្ដីត្រូវការដែលបានកត់សម្គាល់ឃើញ ត្រូវបានបញ្ចូលទៅក្នុងកិច្ចសន្យាការងារ រយៈពេល ៥ ឆ្នាំរបស់គ្រូបង្រៀន។	DoP
	៥.៤	គន្លងអាជីពសម្រាប់បុគ្គលិកសិក្សាត្រូវបានបង្កើត ដើម្បីបង្ហាញ និងទាក់ទាញបុគ្គលដែលមានសមត្ថភាពខ្ពស់ (ការបង្ហាញពីអត្ថប្រយោជន៍ លក្ខខណ្ឌការងារ ការជ្រើសរើសផ្អែកតាមគុណសម្បត្តិការងារ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការវាយតម្លៃ)។	DoP
	៥.៥	របាយ/ការបែងចែកគ្រូកាន់តែមានសមធម៌រវាងសាលាដែលខ្វះគ្រូ និងសាលាលើសគ្រូ និងរវាងគ្រឹះស្ថានអប់រំនានា។	DoP, DGSE
	៥.៦	ស្តង់ដាវិជ្ជាជីវៈ(ក្រមសីលធម៌)សម្រាប់គ្រូ និងនាយកសាលាបានកែសម្រួលធ្វើបច្ចុប្បន្នកម្ម បោះពុម្ព និងបានផ្សព្វផ្សាយអនុវត្ត។	DoP
	៥.៧	ក្របខ័ណ្ឌសមិទ្ធកម្ម និងអភិវឌ្ឍន៍គ្រូ ត្រូវបានរៀបចំ អនុវត្តសាកល្បង ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្ត។ លទ្ធផលនៃរង្វាយតម្លៃ គឺជាព័ត៌មានសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ។	DoP, TTD, NIE
	៥.៨	ក្របខ័ណ្ឌសមិទ្ធកម្ម និងអភិវឌ្ឍន៍នាយកសាលាត្រូវបានរៀបចំ អនុវត្តសាកល្បង ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្ត។	DoP, TTD, NIE
៦. បន្តយកចិត្តទុកដាក់ជាប្រព័ន្ធលើការលើកកម្ពស់ អប់រំគ្រូកម្រិតមធ្យមសិក្សា	៦.១	គំរូវិទ្យាស្ថានគរុកោសល្យ ត្រូវបានពង្រីកទៅកាន់គ្រប់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។	TTD
	៦.២	គោលវិធីបណ្ដុះបណ្ដាលគ្រូមុនពេលចេញបម្រើការងារ(គរុសិស្ស/និសិត្ស) កម្មវិធីសិក្សា និងសម្ភារបវត្ត ត្រូវបានធ្វើបច្ចុប្បន្នកម្មឱ្យស្របតាមរបៀបរៀន និងបង្រៀនតាមបែបទំនើប។	TTD, DCD
	៦.៣	កម្មសិក្សាត្រូវបានពង្រីក និងធ្វើបច្ចុប្បន្នកម្ម ដើម្បីផ្តល់នូវបទពិសោធន៍ពិតប្រាកដដល់គរុសិស្សបន្ថែមទៀត ។	TTD, DGSE

អាទិភាពគន្លឹះ		លទ្ធផលសំខាន់ៗ	លទ្ធផលសំខាន់ៗ
	៦.៤	គន្លងអាជីពសម្រាប់គ្រូឧទ្ទេស (អត្ថប្រយោជន៍ លក្ខខណ្ឌការងារ ការជ្រើសរើសផ្អែកតាមគុណសម្បត្តិការងារ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការវាយតម្លៃ) ត្រូវបានអនុវត្ត ដើម្បីទាក់ទាញបុគ្គលដែលមានសមត្ថភាពខ្ពស់។	DoP, DoF
	៦.៥	លិខិតបទដ្ឋានគតិយុត្តនានា ត្រូវបានពង្រឹង ដើម្បីតម្រូវឱ្យគ្រូឧទ្ទេស មានគុណវុឌ្ឍិ សមត្ថភាពសមស្រប និងមានកម្រិតបទពិសោធនបង្រៀនទៅតាមការតម្រូវ ។	TTD, NIE
	៦.៦	គ្រឹះស្ថានអប់រំគ្រូ ធ្វើការវាយតម្លៃតាមដានបន្តលើគ្រូដែលចេញបង្ហាត់/បង្រៀននៅឆ្នាំទី១ ដើម្បីវាយតម្លៃលើភាពឆ្លើយតបនៃការបណ្តុះបណ្តាលគ្រូចំពោះការបង្រៀននៅសាលាមធ្យមសិក្សា។	TTD, NIE
	៦.៧	ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំត្រូវបានអនុវត្តពេញលេញនៅតាមសាលាមធ្យមសិក្សា។	DoP, TTD
	៦.៨	កម្មវិធីផ្តល់ការណែនាំការងារដំបូង ការបង្វឹក និងការណែនាំ បានរៀបចំឡើងជាសមាសភាគមួយដ៏សំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់គ្រូបង្រៀនដែលទើបចេញថ្មី និងគ្រូបង្រៀនបច្ចុប្បន្ន។	DoP, NGPRC
	៦.៩	ប្រព័ន្ធ ICT ដ៏ទូលំទូលាយមួយត្រូវបានអនុវត្ត និងមានអ្នកបណ្តុះបណ្តាល ដែលអាចផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ តាមប្រព័ន្ធអនឡាញដល់គ្រូ នាយកសាលា និងគ្រូឧទ្ទេស (សាស្ត្រាចារ្យ) ទាំងមកពីតំបន់ប្រជុំជន និងតំបន់ជនបទ។	DIT, CDE
	៦.១០	មានការបង្កើតភាពជាដៃគូក្នុងចំណោមសាលាមធ្យមសិក្សាជាមួយសាលាជំនាន់ថ្មី និងសាលាអន្តរជាតិដែលមានគុណភាពខ្ពស់ ដើម្បីបង្កើនការបង្រៀនក្នុងថ្នាក់ និងការដឹកនាំសាលារៀន។	DGSE, TTD, NIE
៧. ធ្វើពិពិធកម្ម និងពង្រឹង លទ្ធផលនៃការអប់រំមធ្យមសិក្សាបច្ចេកទេស ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និងទីផ្សារការងារក្នុងមូលដ្ឋាន	៧.១	សិស្សដែលបានបញ្ចប់ការសិក្សាពីសាលាចំណេះទូទៅ និងបច្ចេកទេស មានចំណេះដឹង និងជំនាញបច្ចេកទេសកម្រិតខ្ពស់ អាចរកការងារបានធ្វើក្នុងវិស័យជាក់លាក់។	VOD, DGSE
	៧.២	មុខវិជ្ជា និងសម្ភារៈសិក្សាផ្អែកតាមម៉ូឌុល (Module -based subjects)មានសង្គតិភាព ហើយឆ្លើយតបទៅនឹងកំណើនរបស់ប្រទេសនិងតម្រូវការទីផ្សារការងារត្រូវបានណែនាំ និងអនុវត្តនៅក្នុងកម្មវិធីសិក្សាមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស ។	VOD, DCD
	៧.៣	គ្រូមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស មានសមត្ថភាពគ្រប់គ្រាន់ និងគុណភាពក្នុងការបង្រៀន អនុវត្តបង្ហាញ និងធ្វើការវាយតម្លៃ ។	DoP, VOD
	៧.៤	បណ្តាញរបស់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសដែលមានស្រាប់ត្រូវបានពង្រឹងលើការគ្រប់គ្រង បំពាក់សម្ភារកាន់ប្រសើរឡើង និងមានអន្តេវាសិកដ្ឋានសម្រាប់សិស្សដែលស្នាក់នៅឆ្ងាយពីផ្ទះ។	VOD, DoC
	៧.៥	កិច្ចសហការគ្នារវាងសាលាមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស ជាមួយនឹងវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានពង្រឹង ដើម្បីសម្របសម្រួលឱ្យមានគន្លងអាជីពមួយដែលអាចបត់បែននិងប្រទាក់គ្នា រវាងការអប់រំមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេស និងវិញ្ញាបនប័ត្រឬកំរិតសញ្ញាប័ត្រ ដែលស្ថិតនៅក្រោមប្រព័ន្ធវាយតម្លៃនិងវិញ្ញាបនប័ត្រក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជា។	VOD, MLVT
	៧.៦	វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមានបរិក្ខារបច្ចេកទេសសំខាន់ៗគ្រប់គ្រាន់ និងក្រោមកិច្ចសហការជាមួយវិទ្យាស្ថានពហុបច្ចេកទេស វិទ្យាស្ថានបច្ចេកទេសកម្រិតឧត្តម និងសហគ្រាសសាធារណៈ ឯកជន ផ្នែកឧស្សាហកម្មពង្រឹងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសឱ្យមានគុណភាព។	VOD, MLVT
	៧.៧	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដៃគូឧស្សាហកម្ម និងគ្រឹះស្ថានអប់រំឧត្តមសិក្សា នឹងអនុវត្តកម្មវិធីសហការជាមួយសាលាមធ្យមសិក្សា ដើម្បីផ្តល់ការតម្រង់ទិសអំពីអាជីពសម្រាប់សិស្សដែលចង់ជ្រើសរើសផ្នែកបច្ចេកទេស ឬការសិក្សានៅឧត្តមសិក្សា។	VOD, DHE, MLVT
	៧.៨	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដៃគូឧស្សាហកម្ម នឹងអនុវត្តកម្មវិធីសហការជាមួយសាលាមធ្យមសិក្សាដើម្បីផ្តល់លទ្ធភាពឱ្យមានកម្មវិធីសិក្សាទៅវិញទៅមករវាងសាលារៀន និងឧស្សាហកម្ម ដែលអាចរួមបញ្ចូលបទពិសោធន៍បណ្តុះបណ្តាលក្នុងពេលបំពេញការងារ។	DGSE, VOD, MLVT

អាទិភាពគន្លឹះ		លទ្ធផលសំខាន់ៗ	លទ្ធផលសំខាន់ៗ
៨. បង្កើនការសហការសម្រាប់ ការអប់រំកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សា	៨.១	សិស្សមធ្យមសិក្សាទទួលបានព័ត៌មានអំពីកម្មវិធីអប់រំនានា ដែលមានតាមរយៈកម្មវិធីអប់រំក្រៅប្រព័ន្ធ (ការចូលរៀនឡើងវិញ កម្មវិធីសិក្សាបំពេញបន្ថែម កម្មវិធីអក្ខរកម្ម)	DGSE, VOD, DNFE
	៨.២	សាលាមធ្យមសិក្សា នឹងសហការ/ផ្សារភ្ជាប់ជាមួយនឹងសហគ្រាសក្នុងមូលដ្ឋាន ដើម្បីបង្កើតឱកាសអប់រំ និងឱ្យសិស្សយល់ដឹងអំពីឱកាសការងារ (*ការបង្ហាញអំពីអាជីព/វិជ្ជាជីវៈ បទពិសោធន៍ការងារ ការចុះទស្សនៈកិច្ចដល់ទីតាំងធ្វើការងារ ការអញ្ជើញវាគ្មិនកិត្តិយសចែករំលែកបទពិសោធន៍ និងហ្វឹកហាត់ការងារ ។ល។*)	DGSE, VOD
	៨.៣	គ្រឹះស្ថានឧត្តមសិក្សា និងសាលាមធ្យមសិក្សា សហការគ្នារៀងរាល់ឆ្នាំដើម្បីធានាការចែករំលែកកម្មវិធីពាក់ព័ន្ធ មានការជាប់ទាក់ទិនជាមួយគ្នា និងការបន្តគ្នារវាងកម្មវិធីនានា និងមានការយល់ច្បាស់ពីការផ្ទេរការសិក្សាពីមធ្យមសិក្សាទៅការអប់រំក្រោយមធ្យមសិក្សា និងការបណ្តុះបណ្តាល។	DGSE, VOD, DHE

CDE : Center for Digital Education;
CPD : Continuous Professional Development;
CQF : Cambodian Qualifications Framework;
DCD : Department of Curriculum Development;
DGSE : Department of General Secondary Education;
DHE : Department of Higher Education;
DIT : Department of Information Technology;
DNFE : Department of NonFormal Education
DOC : Department of Construction;
DOP : Department of Personnel;
EQAD : Education Quality Assurance Department;
GTHS : General and Technical High Schools;
HEI : Higher Education Institution;
ICT : information and communication technology;
MLVT : Ministry of Labour and Vocational Training;
NGPRC : New Generation Pedagogical Research Center;
NGS : New Generation School;
NIE : National Institute of Education;
TEC : Teacher Education College;
TTD : Teacher Training Department;
RTTC : Regional Teacher Training Center;
VOD : Vocational Orientation Department.

ប្រភព៖ Author generated from desk reviews, situation analyses, interviews and focus group discussions, and government and development partner consultation sessions.

១០. ផែនការសកម្មភាពសម្រាប់អនុវត្តផែនទីបង្ហាញផ្លូវ

ផ្នែកមុននេះបង្ហាញអាទិភាពគន្លឹះ និងលទ្ធផលសំខាន់ដែលចាំបាច់ត្រូវឆ្លើយតបជាបន្ទាន់ ដើម្បីបន្តលើកកម្ពស់គុណភាពនៃការអប់រំនៅកម្ពុជា។ ផែនការសកម្មភាពបែងចែងទៅជាតារាងទី៧ដល់ទី១៤ ដើម្បីបង្ហាញលទ្ធផលសំខាន់ៗរួមនឹងលទ្ធផលរំពឹងទុកក្រោមអាទិភាពនីមួយៗ និងលើកស្នើឱ្យមានការប្រើប្រាស់អភិក្រមបែងចែកជាដំណាក់កាល ដើម្បីសម្រេចលទ្ធផលនេះឱ្យបានត្រឹមឆ្នាំ ២០៣០។

តារាងទី៧៖ អាទិភាពទី ១ "បង្កើនការចូលរៀន និងគុណភាពអប់រំមធ្យមសិក្សាចំណេះទូទៅ (រួមទាំងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស)"

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
១.១	គន្លងអប់រំមធ្យមសិក្សា ដែលបង្ហាញពីជម្រើសអប់រំ និងបណ្តុះបណ្តាលត្រូវបានបង្ហាញច្បាស់ដល់សិស្ស មាតាបិតា និងគ្រូបង្រៀន បូករួមនឹងស្តង់ដានៃការទទួលស្គាល់គុណភាព និងវិញ្ញាបនបត្រ ដែលមានការទទួលស្គាល់ទៅវិញទៅមកនៅដំណាក់កាលនីមួយៗ	• គន្លងអប់រំ បណ្តុះបណ្តាល និងអាជីពផ្អែកតាមក្របខណ្ឌគុណវុឌ្ឍិកម្ពុជា ត្រូវបានផ្សព្វផ្សាយ និងអាចរកបានសម្រាប់ ប្រើប្រាស់ជាឯកសារយោងនៅក្នុងសាលាមធ្យមសិក្សាទាំងអស់	• មិនទាន់បានបង្កើតឡើង	• គន្លងអប់រំ បណ្តុះបណ្តាល និងអាជីពតាមរយៈការអប់រំមធ្យមសិក្សាត្រូវបានបោះពុម្ព និងផ្សព្វផ្សាយ ទៅគ្រប់គ្រឹះស្ថានអប់រំគ្រូ និងសាលាមធ្យមសិក្សាទាំងអស់	• គន្លងអប់រំ បណ្តុះបណ្តាល និងអាជីព ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីផ្តល់ប្រឹក្សាមធ្យមសិក្សា។	• ការវាយតម្លៃផលប៉ះពាល់នៃគន្លងអប់រំ បណ្តុះបណ្តាល និងអាជីព លើការអប់រំក្រោយមធ្យមសិក្សា និងការងារ
១.២	សិស្សដែលប្រឈមនឹងការបោះបង់ការសិក្សា ... សិស្សដែលប្រឈមនឹងការចាកចេញពីសាលារៀនត្រូវបានកំណត់អត្តសញ្ញាណ និងពិនិត្យតាមដានដោយអ្នកប្រឹក្សាយោបល់ ដើម្បីកាត់បន្ថយមូលហេតុជំរុញឱ្យមានការចាកចេញពីសាលា និងផ្តល់គ្រឿងលើកទឹកចិត្ត (ឧ. អាហារូបករណ៍ ថ្នាក់បំប៉ន បទពិសោធន៍ការងារ) ដើម្បីបន្តការសិក្សា	• លក្ខណៈវិនិច្ឆ័យដែលមានភាពច្បាស់លាស់ ដើម្បីកំណត់សិស្សដែលប្រឈមនឹងការចាកចេញពីសាលា • ការកំណត់អត្តសញ្ញាណអ្នកទទួលអាហារូបករណ៍ដែលប្រឈមនឹងហានិភ័យនៃការចាកចេញពីសាលា និងការបង្កើតលក្ខណៈសម្បត្តិ	• ការកំណត់លក្ខណៈ • វិនិច្ឆ័យបន្ថែមសម្រាប់សិស្សដែលប្រឈមនឹងការចាកចេញពីសាលា	• ចំនួនសិស្សទាំងពីរភេទដែលបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាកើនឡើង ២០%	• ចំនួនសិស្សទាំងពីរភេទដែលបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាកើនឡើង ២០%	• សិស្សប្រុស និងសិស្សស្រីដែលបញ្ចប់ការសិក្សាមធ្យមសិក្សា មានចំនួនប្រហាក់ប្រហែលគ្នា
១.៣	មានការផ្តល់អាហារូបករណ៍បន្ថែមដល់សិស្សមធ្យមសិក្សាដែលមានពិការភាព ជនជាតិដើមភាគតិច យុវជន កុមារក្រីក្រ និងក្រុមជួបការលំបាកដែលមិនត្រូវបានដាក់បញ្ចូលក្នុងចំណុច ១.២	• អ្នកដែលទទួលបានអាហារូបករណ៍ត្រូវបានកំណត់ ដោយប្រើប្រាស់លក្ខណៈ វិនិច្ឆ័យដែលមានភាពច្បាស់លាស់ ដើម្បីកំណត់ពីលក្ខណៈសម្បត្តិសមស្រប ដើម្បីទទួលបានអាហារូបករណ៍នេះ	• ចំនួនអ្នកដែលបានទទួលអាហារូបករណ៍រួចទៅហើយនៅឆ្នាំ២០២០ ទាំងនៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ	• ចំនួនសិស្សពីដើមគ្រាកើនឡើងថែម ១០% ទៀត	• ចំនួនសិស្សចុះឈ្មោះចូលរៀនពីឆ្នាំមុនកើនឡើងថែម ១០% ទៀត	• ចំនួនសិស្សចុះឈ្មោះចូលរៀនពីឆ្នាំមុនកើនឡើងថែម ១០% ទៀត

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក			
			ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
១.៤	កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន (BEEP) សម្រាប់សិស្សដែលធ្លាប់ចាកចេញពីសាលារៀន ត្រូវបានកែសម្រួលដោយបញ្ចូលបង្ហាញពីគន្លងអប់រំជាក់លាក់ ដើម្បីឈានទៅទទួលបានការបញ្ជាក់ទទួលស្គាល់ពីក្របខណ្ឌគុណវុឌ្ឍិកម្ពុជា	• សិស្សដែលចាកចេញពីសាលារៀនបានវិលត្រឡប់មកសិក្សាវិញ ដើម្បីទទួលបានគុណវុឌ្ឍិកម្រិតមូលដ្ឋាន • ចំនួនសិស្សបញ្ចប់កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន ដែលត្រូវបានទទួលឱ្យចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ និងកម្មវិធី TVET។	• ចំនួនសិស្សដែលគ្មានគុណវុឌ្ឍិការអប់រំកម្រិតមូលដ្ឋាន • ចំនួនសិស្សក្នុងកម្មវិធី BEEP នៅឆ្នាំ ២០២០	• សិស្សដែលចុះឈ្មោះចូលរៀនក្នុងកម្មវិធី BEEP កើនឡើង ២០% ធៀបនឹងនៅដើមគ្រានាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និង នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ រៀបចំ និង វាយតម្លៃ កម្មវិធីអប់រំជាជម្រើសសាកល្បងសម្រាប់ យុវជននៅក្រៅសាលា ក្រោមកម្មវិធី BEEP	• សិស្សដែលចុះឈ្មោះចូលរៀនក្នុងកម្មវិធី BEEP កើនឡើង ២០% ទៀតធៀបនឹងចំនួនចុះឈ្មោះចូលរៀនឆ្នាំមុន • កម្មវិធីអប់រំជាជម្រើសសម្រាប់យុវជននៅក្រៅសាលា ត្រូវបានអនុវត្តក្រោមកម្មវិធី BEEP	• សិស្សដែលចុះឈ្មោះចូលរៀនក្នុងកម្មវិធី BEEP កើនឡើង ២០% ទៀតធៀបនឹងចំនួនចុះឈ្មោះចូលរៀនឆ្នាំមុន • ការអនុវត្តកម្មវិធីអប់រំជាជម្រើសបន្ថែមទៀត
១.៥	បង្កើតមូលដ្ឋានទិន្នន័យដែលមានគុណភាពសម្រាប់កម្មវិធីបង្កើតរូបភាពឌីជីថលសម្រាប់ឱ្យនាយកដ្ឋានរបស់ក្រសួងអ.យ.កប្រើប្រាស់ក្នុងការរៀបចំផែនការជាប្រចាំ ជាពិសេសការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងតម្រូវការពង្រាយគ្រូបង្រៀន	• ការរៀបចំអង្គភាពវិភាគស្ថិតិ (អ្នកបង្កើត) និងការកំណត់អត្តសញ្ញាណនាយកដ្ឋាន (អ្នកប្រើប្រាស់) • ការវិនិយោគជាយុទ្ធសាស្ត្រ និងមានប្រសិទ្ធភាពចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងការពង្រាយគ្រូ	• មិនទាន់មានការប្រើប្រាស់ ការវិភាគឌីជីថល និងការគូសផែនទីសម្រាប់ការរៀបចំផែនការ	• បង្កើតអង្គភាពវិភាគស្ថិតិ ដោយមានការបណ្តុះ-បណ្តាលស្តីពីកម្មវិធីកម្រិតខ្ពស់ក្រោម "អាជ្ញាប័ណ្ណអ្នកបង្កើត" • ផ្តល់ការបណ្តុះបណ្តាលស្តីពី "អាជ្ញាប័ណ្ណអ្នកប្រើប្រាស់" សម្រាប់នាយកដ្ឋានពាក់ព័ន្ធ	• កម្មវិធីបង្កើតរូបភាពឌីជីថលត្រូវបានប្រើប្រាស់ជាឧបករណ៍រៀបចំផែនការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការវិនិយោគលើការជ្រើសរើសបុគ្គលិក	• កម្មវិធីបង្កើតរូបភាពឌីជីថលដំណើរការពេញលេញជាឧបករណ៍រៀបចំផែនការដែលមានប្រសិទ្ធភាពចំណាយ
១.៦	ផ្អែកតាមស្តង់ដាសេវាអប្បបរមារបស់ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការកែលម្អបរិក្ខារអប់រំមធ្យមសិក្សាដោយប្រើប្រាស់ការរចនាប្លង់ស្ថាបត្យកម្មសតវត្សទី ២១ ដើម្បីសម្រួល និងគាំទ្រដល់ការអនុវត្តគោលវិធីរៀន និងបង្រៀនបែបនវានុវត្តន៍ និងបែបស្ថាបនាក្នុងសាលាមធ្យមសិក្សា	• បញ្ចប់ និងដំណើរការឯកសារស្តង់ដាសេវាអប្បបរមា	• គ្មានស្តង់ដាសេវាអប្បបរមា • រៀបចំរចនាប្លង់សម្រាប់អគារសិក្សាទំនើបដោយមានចន្លោះរៀនសូត្រ និងគ្រឿងសង្ហារិមដែលផ្តល់ភាពបត់បែនដើម្បីបន្សីនឹងគោលវិធីបង្រៀន និងរៀនថ្មី	• ការអភិវឌ្ឍស្តង់ដាសេវាអប្បបរមា • សាលាមធ្យមសិក្សាចំនួន ២០% បានកែលម្អអគារសិក្សា និងគ្រឿងសង្ហារិមដែលមានភាពបត់បែនដើម្បីគាំទ្រការរៀនសូត្រយ៉ាងសកម្ម និងបែបសហការ ដូចមានកំណត់ក្នុងស្តង់ដាសេវាអប្បបរមា	• អនុវត្តស្តង់ដាសេវាអប្បបរមាក្នុងអគារសិក្សាថ្មីទាំងអស់ • សាលាមធ្យមសិក្សា ៥០% បានកែលម្អអគារសិក្សា និងគ្រឿងសង្ហារិមដែលមានភាពបត់បែនដើម្បីគាំទ្រការរៀនសូត្រយ៉ាងសកម្ម និងបែបសហការ	• ការអនុវត្តស្តង់ដាសេវាអប្បបរមានៅតាមសាលាមធ្យមសិក្សាទាំងអស់

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក			
			ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
១.៧	សាលាមធ្យមសិក្សាទាំងអស់ មានកន្លែង/ការិយាល័យសម្រាប់គ្រូម្នាក់ៗបំពេញការងារ និងសាលប្រជុំដើម្បីសម្រួលដល់កិច្ចសហការប្រកបដោយវិជ្ជាជីវៈរបស់គ្រូបង្រៀន	• ទឹកចិត្ត សុខុមាលភាព និងការពេញចិត្តវិជ្ជាជីវៈរបស់គ្រូបង្រៀន មានការកើនឡើង • ចំនួនកន្លែងការងារដែលបានរៀបចំសម្រាប់គ្រូ	• ការរចនាកន្លែងការងារសម្រាប់គ្រូ និងកន្លែងជួបប្រជុំសម្រាប់ការរៀបចំផែនការជាក្រុម និងការចែករំលែក ត្រូវបានរៀបចំទៅតាម ស្តង់ដាសេវាអប្បបរមា	• សាលាមធ្យមសិក្សា ៤០% បានកែសម្រួលកន្លែងធ្វើការសម្រាប់គ្រូដោយបំពាក់នូវគ្រឿងសង្ហារិមទំនើប	• សាលាមធ្យមសិក្សា ៦០% បានកែសម្រួលកន្លែងធ្វើការសម្រាប់គ្រូដោយបំពាក់នូវគ្រឿងសង្ហារិមទំនើប	• សាលាមធ្យមសិក្សា ១០០% បានកែសម្រួលកន្លែងធ្វើការសម្រាប់គ្រូដោយបំពាក់នូវគ្រឿងសង្ហារិមទំនើប
១.៨	គ្រប់សាលាមធ្យមសិក្សាទាំងអស់ មានបង្គន់ដែលអាចប្រើប្រាស់បាន និងបែងចែកទៅតាមសិស្សប្រុស សិស្សស្រី ដោយមានទឹក និងបរិក្ខារអនាម័យប្រើប្រាស់គ្រប់ពេល/រដូវ	• ចំនួនបង្គន់អនាម័យដែលអាចប្រើប្រាស់បានបែងចែកតាមភេទ ដែលមានកន្លែងលាងសម្អាតដៃ មានសម្រាប់ការចុះពិនិត្យនៅក្នុងគ្រប់សាលាមធ្យមសិក្សាទាំងអស់	• អនុវិទ្យាល័យ និងវិទ្យាល័យ ៤០% មានបង្គន់អនាម័យ និងកន្លែងលាងសម្អាតដៃលអាចប្រើប្រាស់ និងបែងចែកតាមភេទ • ការផ្តល់ទឹកពិសាពេញមួយឆ្នាំ	• អនុវិទ្យាល័យ និងវិទ្យាល័យ ៦០% មានបង្គន់ដែលអាចប្រើប្រាស់បាន និងបែងចែកតាមភេទ (១ សម្រាប់សិស្ស ៣០-៤០ នាក់) • ការផ្តល់ទឹកពិសាពេញមួយឆ្នាំ	• អនុវិទ្យាល័យ និងវិទ្យាល័យ ៨០% មានបង្គន់ដែលអាចប្រើប្រាស់បាន និងបែងចែកតាមភេទ (១ សម្រាប់សិស្ស ៣០-៤០ នាក់) • ការផ្តល់ទឹកពិសាពេញមួយឆ្នាំ	• អនុវិទ្យាល័យ និងវិទ្យាល័យ១០០% មានបង្គន់ដែលអាចប្រើប្រាស់បាន និងបែងចែកតាមភេទ (១ សម្រាប់សិស្ស ៣០-៤០ នាក់) • ការផ្តល់ទឹកពិសាពេញមួយឆ្នាំ
១.៩	ប្រធានបទស្តីពីសុខភាព និងសុខុមាលភាព ត្រូវបានបញ្ចូលក្នុងមុខវិជ្ជាពាក់ព័ន្ធ ដោយផ្តោតជាសំខាន់បន្ថែមទៀតលើសកម្មភាពអប់រំកាយ និងកីឡា	• ប្រធានបទស្តីពីសុខភាព និងការអប់រំកាយសមស្របតាមអាយុត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា • ត្រូវមានសកម្មភាពកាយសិក្សារយៈពេលយ៉ាងតិច ១ ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ក្រុមសិស្សនៅកម្រិតថ្នាក់នីមួយៗនៅកម្រិតមធ្យមសិក្សា	• ប្រធានបទស្តីពីសុខភាព និងសកម្មភាពអប់រំកាយ ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាសម្រាប់សិស្សថ្នាក់ទី ១០ ទី១១ & ទី១២ • សកម្មភាពកាយសិក្សារយៈពេលយ៉ាងតិច ១ ម៉ោងក្នុងមួយសប្តាហ៍ ត្រូវបានរៀបចំឡើង និងអនុវត្តសាកល្បងនៅតាមសាលាមួយចំនួន	• ប្រធានបទស្តីពីសុខភាព និងសកម្មភាពអប់រំកាយ ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាសម្រាប់សិស្សថ្នាក់ទី ៧-១២ និងសាលារៀនមធ្យមសិក្សាចំនួន ៤០%។ • សកម្មភាពកាយសិក្សារយៈពេលយ៉ាងតិច ១ ម៉ោងក្នុងមួយសប្តាហ៍ ត្រូវបានរៀបចំឡើងនៅតាមសាលាមធ្យមសិក្សាចំនួន ៤០%	• សាលាមធ្យមសិក្សា ៦០% មានប្រធានបទស្តីពីសុខភាពនិងសកម្មភាពកាយសិក្សា ដែលត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាសម្រាប់សិស្សថ្នាក់ទី ៧-១២ • សកម្មភាពកាយសិក្សារយៈពេលយ៉ាងតិច ១ ម៉ោងក្នុងមួយសប្តាហ៍ ត្រូវបានរៀបចំឡើងសម្រាប់ថ្នាក់គ្រប់កម្រិត	• សាលាទាំងអស់មានប្រធានបទស្តីពីសុខភាព និងសកម្មភាពកាយសិក្សា ដែលត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាសម្រាប់សិស្សថ្នាក់ទី ៧-១២ • សកម្មភាពកាយសិក្សារយៈពេលយ៉ាងតិច ១ ម៉ោងក្នុងមួយសប្តាហ៍ ត្រូវបានរៀបចំឡើងសម្រាប់ថ្នាក់គ្រប់កម្រិត

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក			
			ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
១.១០	សិស្សមធ្យមសិក្សា និងបុគ្គលិកកម្រិតមធ្យមសិក្សាទាំងអស់ បានទទួលការពិនិត្យសុខភាពពេញលេញ (រួមទាំងតេស្តគំហើញ និងការស្តាប់) រៀងរាល់ ២ ឆ្នាំម្តងពីមណ្ឌលសុខភាព	• ចំនួនសិស្ស និងបុគ្គលិកសាលារៀនដែលបានទទួលការពិនិត្យសុខភាពជាមូលដ្ឋានរៀងរាល់ ២ ឆ្នាំម្តង ស្របតាមរបាយការណ៍ពិនិត្យសុខភាព	• មិនទាន់មាន	• សាលាមធ្យមសិក្សា ៥០% ផ្តល់ការពិនិត្យសុខភាពដល់សិស្ស និងបុគ្គលិក	• សាលាមធ្យមសិក្សា ៧៥% ផ្តល់ការពិនិត្យសុខភាពដល់សិស្ស និងបុគ្គលិក	• សាលាមធ្យមសិក្សា ១០០% ផ្តល់ការពិនិត្យសុខភាពដល់សិស្ស និងបុគ្គលិក

BEEP : Basic Education Equivalency Program;	**ETCP** : Education, Training, and Career Pathway;	**NFE** vNonFormal Education;
CQF : Cambodian Qualifications Framework;	**LSS** : lower secondary school;	**OOSY** : out-of-school youth;
DGPP : Directorate-General of Policy and Planning;	**MOEYS** : Ministry of Education, Youth and Sport;	**TEI** : teacher education institution;
DGSE : Department of General Secondary Education;	**MSS** : minimum service standards;	**USS** : upper secondary school.

ប្រភព៖ Author generated from desk reviews, situation analyses, interviews and focus group discussions, and government and development partner consultation sessions.

តារាងទី ៨៖ អាទិភាពទី ២ "បន្តផ្តោតការយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលការលើកកម្ពស់ ការដឹកនាំ និងគ្រប់គ្រងសាលាមធ្យមសិក្សា"

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក			
			ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
២.១	គ្រប់សាលាមធ្យមសិក្សាទាំងអស់ ទោះស្ថិតនៅកន្លែងណាក៏ដោយ មានក្រុមដឹកនាំសាលារៀន (នាយក និងនាយករង) ដែលមានសមិទ្ធកម្ម/ស្នាដៃការងារល្អ និងត្រូវបានជ្រើសតាំងទៅតាមបទដ្ឋានរបស់ក្រសួង អ.យ.ក ស្តីពីការតែងតាំងនាយកសាលា ហើយក៏ជាអ្នកដឹកនាំការបង្រៀន និងជំរុញសមិទ្ធកម្ម/ស្នាដៃការងាររួមរបស់សាលារៀន	• នាយកសាលាត្រូវបានចាត់តាំងទៅតាម • ស្តង់ដាជាតិសម្រាប់នាយកសាលា • ផែនការកែលម្អសាលារៀន ដែលបំពេញស្តង់ដាតម្រូវដោយ អរយក ត្រូវបានដាក់ជារៀងរាល់ឆ្នាំ • លទ្ធផលនៃការបំពេញការងាររបស់សាលារៀននីមួយៗ ត្រូវបានប្រៀបធៀបពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីបង្ហាញចំណុចកែលម្អ	សាលាមធ្យមសិក្សា៥០%៖ • ធ្វើផែនការកែលម្អសាលារៀនដែលបំពេញស្តង់ដាតម្រូវដោយ អរយក ជារៀងរាល់ឆ្នាំ • ធ្វើព័ត៌មានអំពីលទ្ធផលនៃការបំពេញការងាររបស់សាលារៀនពីឆ្នាំមុន	សាលាមធ្យមសិក្សា៧៥%៖ • ធ្វើផែនការកែលម្អសាលារៀនដែលបំពេញស្តង់ដាតម្រូវដោយ អរយក ជារៀងរាល់ឆ្នាំ • ធ្វើព័ត៌មានអំពីលទ្ធផលនៃការបំពេញការងាររបស់សាលារៀនពីឆ្នាំមុន	សាលាមធ្យមសិក្សា ១០០%៖ • ធ្វើផែនការកែលម្អសាលារៀនដែលបំពេញស្តង់ដាតម្រូវដោយ អរយក ជារៀងរាល់ឆ្នាំ • ធ្វើព័ត៌មានអំពីលទ្ធផលនៃការបំពេញការងាររបស់សាលារៀនពីឆ្នាំមុន	សាលាមធ្យមសិក្សា១០០%៖ • ធ្វើផែនការកែលម្អសាលារៀនដែលបំពេញស្តង់ដាតម្រូវដោយ អរយក ជារៀងរាល់ឆ្នាំ • ធ្វើព័ត៌មានអំពីលទ្ធផលនៃការបំពេញការងាររបស់សាលារៀនពីឆ្នាំមុន
២.២	កម្មវិធីអភិវឌ្ឍន៍ការដឹកនាំ និងគ្រប់គ្រងសាលារៀន ជាកាតព្វកិច្ចសម្រាប់នាយក និងនាយរងដែលទើបតែងតាំងថ្មីទាំងអស់ និងអ្នកដែលមានបំណងចង់ក្លាយខ្លួនជានាយក និងនាយករង តាមរយៈកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដើម្បីធានាស្តង់ដាខ្ពស់	• កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំត្រូវបានរៀបចំសម្រាប់នាយកសាលាដោយវិទ្យាស្ថានជាតិអប់រំ និងដៃគូ • ចំនួន និងឈ្មោះអ្នកដែលបានចូលរៀនក្នុងកម្មវិធីនេះ ត្រូវបានកត់ត្រាជារៀងរាល់ឆ្នាំ	• កម្មវិធី SBM របស់ក្រសួងអ.យ.ក កំពុងត្រូវបានអនុវត្តតាមសាលារៀនក្នុងគម្រោង • វិទ្យាស្ថានជាតិអប់រំ រៀបចំការបណ្តុះបណ្តាលស្តីពី SBM សម្រាប់នាយកសាលាវិទ្យាល័យធនធានរួមទាំងការគ្រប់គ្រងការផ្លាស់ប្តូរ	• កម្មវិធីរៀបចំអ្នកដឹកនាំសាលារៀនប្រកបដោយគុណភាព ត្រូវបានរៀបចំនៅវិទ្យាស្ថានជាតិអប់រំសម្រាប់នាយក និងនាយករងថ្មី និងអ្នកដែលមានបំណងចង់ធ្វើជានាយក និងនាយករង	• កម្មវិធីរៀបចំអ្នកដឹកនាំសាលារៀនសម្រាប់នាយកសាលាថ្មី និងអ្នកដែលមានបំណងចង់ធ្វើជានាយកសាលាត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំដើម្បីគ្រប់គ្រងនិន្នាការប្រែប្រួល និងសម្រាប់ជាចំណុចផ្តោតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកសាលា	• កម្មវិធីរៀបចំអ្នកដឹកនាំសាលារៀនសម្រាប់នាយកសាលាថ្មី និងអ្នកដែលមានបំណងចង់ធ្វើជានាយកសាលាត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំដើម្បីគ្រប់គ្រងនិន្នាការប្រែប្រួល និងសម្រាប់ជាចំណុចផ្តោតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកសាលា

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក			
			ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
២.៣	គោលវិធីគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព រួមទាំងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដោយមានការទទួលខុសត្រូវលើការជួយដល់នាយកសាលាក្នុងបញ្ហារដ្ឋបាល ត្រូវបានអនុវត្តនៅគ្រប់សាលាមធ្យមសិក្សាទាំងអស់ និងត្រូវបានកំណត់ថាជាស្តង់ដាអប្បបរមា	• ផែនការកែលម្អសាលារៀន ដែលបំពេញស្តង់ដាតម្រូវដោយ អរយក ត្រូវបានបញ្ចូលទៅក្នុងសំណុំឯកសារ • មានប័ណ្ណរបាយការណ៍សាលារៀន ដែលត្រូវបញ្ចូលទៅក្នុងសំណុំឯកសារ (ការវាយតម្លៃចុងឆ្នាំ)	• ផែនការកែលម្អសាលារៀន ត្រូវបានរៀបចំនៅក្នុងសាលាមធ្យមសិក្សា ៥០% (សូមមើល២.១) • ប័ណ្ណរបាយការណ៍សាលារៀនត្រូវបានរៀបចំនៅក្នុងសាលាមធ្យមសិក្សា ៥០%	• ផែនការកែលម្អសាលារៀន និងប័ណ្ណរបាយការណ៍សាលារៀនត្រូវបានរៀបចំនៅក្នុងសាលាមធ្យមសិក្សា ៦០% • ការឆ្លុះបញ្ចាំងប្រចាំឆ្នាំរបស់គណៈកម្មការគ្រប់គ្រងសាលារៀន (SMC) លើចំណុចដៅដែលត្រូវបានកំណត់ក្នុងផែនការកែលម្អសាលារៀន	• ផែនការកែលម្អសាលារៀន និងប័ណ្ណរបាយការណ៍សាលារៀន ត្រូវបានរៀបចំនៅក្នុងសាលាមធ្យមសិក្សា ៨០% • ការឆ្លុះបញ្ចាំងប្រចាំឆ្នាំរបស់ SMC លើចំណុចដៅដែលត្រូវបានកំណត់ក្នុងផែនការកែលម្អសាលារៀន	• ផែនការកែលម្អសាលារៀន និងប័ណ្ណរបាយការណ៍សាលារៀន ត្រូវបានរៀបចំនៅក្នុងសាលាមធ្យមសិក្សា ១០០% • ការឆ្លុះបញ្ចាំងប្រចាំឆ្នាំរបស់ SMC លើចំណុចដៅដែលត្រូវបានកំណត់ក្នុងផែនការកែលម្អសាលារៀន
២.៤	ប្រព័ន្ធបណ្តាញវិទ្យាល័យធនធាន ត្រូវបានបង្កើតឡើងពេញលេញ និងស្ថិតនៅក្រោមនាយកដ្ឋានអប់រំមធ្យមសិក្សាចំណេះទូទៅ សម្រាប់ឱ្យការគ្រប់គ្រងទូទាំងប្រព័ន្ធកាន់តែមានភាពល្អប្រសើរ	• ប្រព័ន្ធបណ្តាញវិជ្ជាល័យធនធានត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានអប់រំមធ្យមសិក្សាចំណេះទូទៅ (បណ្តាញនីមួយៗមានវិទ្យាល័យធនធាន និងសាលាបណ្តាញចំនួន ៥) • ដាក់បញ្ចូលរបាយការណ៍វាយតម្លៃប្រចាំឆ្នាំក្នុងឯកសារ	• វិទ្យាល័យធននធានចំនួន ៣៦ដោយវិទ្យាល័យធនធាននីមួយៗ មានសាលាបណ្តាញចំនួន ៥ (សុរប = ២១៦ សាលា)	• បណ្តាញវិទ្យាល័យធនធាន ១៤ ទៀត ត្រូវបានបង្កើតឡើង (សុរប =៣០០)		• បណ្តាញវិទ្យាល័យធនធាន ១០ ទៀត ត្រូវបានបង្កើតឡើង (សុរប =៣០០)

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក			
			ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
២.៥	គោលនយោបាយគ្រប់គ្រង និងការអនុវត្តរបស់សាលាជំនាន់ថ្មី ហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីសិក្សា ត្រូវបានពង្រីកទៅសាលាមធ្យមសិក្សាផ្សេងទៀត	• សាលាដែលត្រូវបានជ្រើសរើសដើម្បីក្លាយជាសាលារៀនជំនាន់ថ្មីបានទទួលការឧបត្ថម្ភមគ្គាពីស្ថាប័នមិនមែនរដ្ឋ ដែលប្តេជ្ញាផ្តល់ប្រាក់ឧបត្ថម្ភយ៉ាងហោចណាស់ ១០ ០០០ ដុល្លារក្នុងមួយឆ្នាំ ដើម្បីរ៉ាប់រងចំណាយនានា យ៉ាងតិចណាស់ ៣ ឆ្នាំ • កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់របស់សាលារៀន ដើម្បីទទួលយកសេចក្តីណែនាំស្តីពីដំណើរការសាលារៀនជំនាន់ថ្មី	• សាលារៀនជំនាន់ថ្មីដែលមានស្រាប់ចំនួន ១១ មានដំណើរការ	• សេចក្តីណែនាំស្តីពីដំណើរការសាលារៀនជំនាន់ថ្មី ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដើម្បីទាក់ទាញស្ថាប័នមិនមែនរដ្ឋ ដែលមានសក្តានុពលឱ្យផ្តល់ការឧបត្ថម្ភដល់សាលារៀនជំនាន់ថ្មីដែលបង្កើតថ្មី	• សាលារៀនជំនាន់ថ្មីយ៉ាងតិច ២០ បន្ថែមទៀត កំពុងដំណើរការ	• សាលារៀនជំនាន់ថ្មីយ៉ាងតិច ២៥ បន្ថែមទៀត កំពុងដំណើរការ
២.៦	សាលាមធ្យមសិក្សាផ្សេងទៀត ដែលប្រាថ្នាក្លាយជាសាលាជំនាន់ថ្មី ត្រូវអនុវត្តទៅតាមគោលនីតិវិធីបានត្រឹមត្រូវ ។	• ដំណើរការទទួលស្គាល់គុណភាពត្រូវបានចងក្រងជាឯកសារដោយអរយក សម្រាប់សាលារៀនជំនាន់ថ្មីទាំងអស់	• សាលារៀនជំនាន់ថ្មីដែលមានការទទួលស្គាល់គុណភាពចំនួន ១១ កំពុងដំណើរការ	• សាលារៀនជំនាន់ថ្មីយ៉ាងតិច ៤បន្ថែមទៀតត្រូវបានទទួលស្គាល់គុណភាព	• សាលារៀនជំនាន់ថ្មីយ៉ាងតិច ៨បន្ថែមទៀតត្រូវបានទទួលស្គាល់គុណភាព	• សាលារៀនជំនាន់ថ្មីយ៉ាងតិច ២បន្ថែមទៀតត្រូវបានទទួលស្គាល់គុណភាព

CPD : Continuous Professional Development;
DGSE : Department of General Secondary Education;
MOEYS : Ministry of Education, Youth and Sport;
NGS : New Generation School;
NIE : National Institute of Education;
SBM : school-based management;
SIP : school improvement plan;
SMC : school management committee;
SRC : school report card;
SRS : Secondary Resource School.

ប្រភព៖ Author generated from desk reviews, situation analyses, interviews and focus group discussions, and government and development partner consultation sessions.

តារាងទី៩៖ អាទិភាពទី ៣ “រៀបចំកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃ ឱ្យស្របតាមការអប់រំប្រកបដោយគុណភាពសម្រាប់សតវត្សរ៍ទី ២១”

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក			
			ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
៣.១	ស្តង់ដាកម្មវិធីសិក្សាលម្អិតសម្រាប់កម្រិតមធ្យមសិក្សាគ្រប់មុខវិជ្ជា ត្រូវបានរៀបចំឡើងផ្អែកតាមលទ្ធផលសិក្សារបស់សិស្ស	• បញ្ជីឈ្មោះសមាជិកគណៈកម្មាធិការតាម មុខវិជ្ជាដែលមានភារកិច្ចកែសម្រួលកម្មវិធីសិក្សាលម្អិតទាំងអស់ទៅជាសេចក្តីពិពណ៌នាអំពីលទ្ធផលសិក្សារបស់សិស្ស • ភាគរយនៃកម្មវិធីសិក្សាលម្អិតដែលត្រូវបានសរសេរឡើងវិញ	• គណៈកម្មាធិការតាមមុខវិជ្ជាសម្រាប់គ្រប់ មុខវិជ្ជាទាំងអស់នៅកម្រិតមធ្យមសិក្សាត្រូវបានតែងតាំង (នាយកដ្ឋានអភិវឌ្ឍ កម្មវិធីសិក្សា)	• កម្មវិធីសិក្សាលម្អិតសម្រាប់គ្រប់មុខវិជ្ជានៅថ្នាក់ទី ៧ ត្រូវបានសរសេរឡើងវិញ • កម្មវិធីសិក្សាលម្អិតសម្រាប់មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រថ្នាក់ទី ៨ និងទី ៩ ត្រូវបានសរសេរឡើងវិញ	• កម្មវិធីសិក្សាលម្អិតសម្រាប់គ្រប់មុខវិជ្ជានៅថ្នាក់ទី ៨ និងទី ៩ ត្រូវបានសរសេរឡើងវិញ • កម្មវិធីសិក្សាលម្អិតសម្រាប់មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រថ្នាក់ទី ១០ ១១ និងទី ១២ ត្រូវបានសរសេរឡើងវិញ	• កម្មវិធីសិក្សាលម្អិតសម្រាប់គ្រប់មុខវិជ្ជានៅថ្នាក់ទី ១០ ទី ១១ និងទី ១២ ត្រូវបានសរសេរឡើងវិញ
៣.២	កម្មវិធីសិក្សាត្រូវបានកែសម្រួល និងបញ្ចូលជំនាញសិក្សាសម្រាប់សតវត្សរ៍ទី ២១ សមាសភាគ STEM និងភាសាបរទេសយ៉ាងតិចចំនួន ៣ (សម្រាប់សិស្សជ្រើសរើសសិក្សា)	• ការកែសម្រួលខ្លឹមសារកម្មវិធីសិក្សាត្រូវបានបញ្ចូលទៅក្នុងសំណុំឯកសារសម្រាប់គ្រប់មុខវិជ្ជាទាំងអស់ • ការបញ្ចូលបំណិនសិក្សាសតវត្សរ៍ទី ២១និងសមាសភាគ STEM ត្រូវបានដាក់បញ្ចូលក្នុងមុខវិជ្ជាពាក់ព័ន្ធ • មានការផ្តល់ការសិក្សាភាសាបរទេសយ៉ាងហោចណាស់ចំនួន ៣ នៅតាមសាលារៀននីមួយៗ (តាមដែលអាចធ្វើទៅបាន)	• មាតិកានៃជំនាញសិក្សាសម្រាប់សតវត្សទី ២១ • មាតិកាសម្រាប់សមាសភាគ STEM ដែលចង់បានសម្រាប់កម្រិតថ្នាក់ និងមុខវិជ្ជានីមួយៗ • ភាសាបរទេសចំនួន ៣ ត្រូវបានកំណត់	• កម្មវិធីសិក្សាលម្អិតសម្រាប់ថ្នាក់ទី ១០ ទី១១ និងទី១២ ត្រូវបានរៀបរៀងឡើងវិញឱ្យរួមបញ្ចូលបំណិនសិក្សាសតវត្សរ៍ទី ២១ • កម្មវិធីសិក្សាលម្អិតសម្រាប់ថ្នាក់ទី ១០ ទី១១ និងទី ១២ ត្រូវបានរៀបរៀងឡើងវិញឱ្យរួមបញ្ចូលសមាសភាគ STEM • សាលារៀនចំនួន ៥០% មានគ្រូភាសាបរទេសដែលមានសមត្ថភាពយ៉ាងហោចណាស់មួយភាសា (អង់គ្លេស បារាំង ឬចិន)	• កម្មវិធីសិក្សាលម្អិតសម្រាប់ថ្នាក់ទី ៧ ទី ៨ និង ទី៩ ត្រូវបានរៀបរៀងឡើងវិញ ឱ្យរួមបញ្ចូលបំណិនសិក្សា សតវត្សរ៍ទី ២១ • កម្មវិធីសិក្សាលម្អិតសម្រាប់ថ្នាក់ទី ៧ ទី៨ និងទី៩ ត្រូវបានរៀបរៀងឡើងវិញឱ្យរួមបញ្ចូលសមាសភាគ STEM • សាលារៀនចំនួន ៥០% មានគ្រូភាសាបរទេសដែលមានសមត្ថភាពយ៉ាងហោចណាស់ពីរភាសា (អង់គ្លេស បារាំង ឬចិន)	• កម្មវិធីសិក្សាលម្អិតទាំងអស់ ត្រូវបានរៀបរៀងឡើងវិញឱ្យរួមបញ្ចូលបំណិនសិក្សាសតវត្សរ៍ទី ២១ • កម្មវិធីសិក្សាលម្អិតទាំងអស់ត្រូវបានរៀបរៀងឡើងវិញឱ្យរួមបញ្ចូលសមាសភាគ STEM • សាលារៀនចំនួន ៥០% មានគ្រូភាសាបរទេសដែលមានសមត្ថភាពផ្នែកភាសានីមួយៗ (អង់គ្លេស បារាំង ឬចិន)

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក			
			ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
៣.៣	យុទ្ធសាស្ត្ររៀន និងបង្រៀនផ្អែកតាមបញ្ហា និងបែបរិះរក ត្រូវបានអនុវត្តក្នុងថ្នាក់រៀនមធ្យមសិក្សា ដោយប្រើការរៀនសូត្រចម្រុះ (បច្ចេកវិទ្យាក្នុងមុខវិជ្ជាសិក្សា)	• នាយកសាលាតាមដានការអនុវត្តគោលវិធីរៀន និងបង្រៀនតាមបែបទំនើបនៅក្នុងថ្នាក់រៀនកម្រិតមធ្យមសិក្សា • កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ ត្រូវបានផ្តល់ ដើម្បីជួយឱ្យគ្រូអាចអនុវត្តគោលវិធីថ្មីៗទាំងនេះ	• គ្រូបង្រៀន STEM បានទទួលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់មុខវិជ្ជាស្នូលថ្នាក់ទី ១២	• ថ្នាក់រៀននៅអនុវិទ្យាល័យ និងវិទ្យាល័យចំនួន ២៥% អនុវត្តការរៀន និងបង្រៀនបែបរិះរក និងផ្អែកតាមបញ្ហា?	• ថ្នាក់រៀននៅអនុវិទ្យាល័យ និងវិទ្យាល័យចំនួន ៦០% អនុវត្តការរៀន និងបង្រៀនបែបរិះរក និងផ្អែកតាមបញ្ហា?	• ថ្នាក់រៀននៅអនុវិទ្យាល័យ និងវិទ្យាល័យចំនួន ១០០% អនុវត្តការរៀន និងបង្រៀនបែបរិះរក និងផ្អែកតាមបញ្ហា?
៣.៤	កែទម្រង់លទ្ធផលប្រឡងបញ្ចប់ការសិក្សារបស់សិស្សថ្នាក់ទី១២ ដោយការបូកបញ្ចូលពិន្ទុដែលបានមកពីការប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិ និងពិន្ទុដែលសិស្សទទួលបាននៅក្នុងថ្នាក់	• មានតារាងរ៉ូប្រិក (Rubrics) និងត្រូវបានបញ្ចូលក្នុងសំណុំឯកសារសម្រាប់មុខវិជ្ជានីមួយៗ ដើម្បីណែនាំដល់សាលាមធ្យមសិក្សាអំពីការវាយតម្លៃស្តង់ដាផលធៀបតាមសាលារៀន និងដើម្បីជួយឱ្យសាលារៀនមានស្តង់ដាប្រហាក់ប្រហែលគ្នា	• តារាងរ៉ូប្រិកដែលត្រូវបានរៀបចំសម្រាប់មុខវិជ្ជានីមួយៗនៅថ្នាក់ទី ១២ ត្រូវបានសាកល្បងនៅតាមសាលាមធ្យមសិក្សាមួយចំនួន	• ពិន្ទុជារួម ២០% សម្រាប់ថ្នាក់ទី ១២ បានពីការវាយតម្លៃតាមសាលារៀន • ៨០% ទៀតបានពីការប្រឡងដែលរៀបចំពីខាងក្រៅ	• ពិន្ទុជារួម ៤០% សម្រាប់ថ្នាក់ទី ១២បានពីការវាយតម្លៃតាមសាលារៀន • ៦០% ទៀត បានពីការប្រឡងដែលរៀបចំពីខាងក្រៅ	• ពិន្ទុជារួម ៤០% សម្រាប់ថ្នាក់ទី ១២ បានពីការវាយតម្លៃតាមសាលារៀន • ៦០% ទៀតបានពីការប្រឡងដែលរៀបចំពីខាងក្រៅ

CPD : Continuous Professional Development; **LSS** : lower secondary school; **USS** : upper secondary school.
DCD : Department of Curriculum Development; **STEM** : Science, Technology, Engineering and Mathematics;

ប្រភព៖ Author generated from desk reviews, situation analyses, interviews and focus group discussions, and government and development partner consultation sessions.

តារាងទី៩៖ អាទិភាពទី ៣ "រៀបចំកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃ ឱ្យស្របតាមការអប់រំប្រែកបដោយគុណភាពសម្រាប់សតវត្សរ៍ទី ២១"

	លទ្ធផលចុងក្រោយ	សូចនាករ	លទ្ធផលរំពឹងទុក			
			ទិន្នន័យដើមគ្រា (២០២០)	ដំណាក់កាលទី ១ (២០២១-២០២៣)	ដំណាក់កាលទី ២ (២០២៤-២០២៨)	ដំណាក់កាលទី ៣ (២០២៩-២០៣០)
៤.១	គ្រូមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន និងរៀន	• គ្រូប្រើប្រាស់កម្មវិធីបច្ចេកវិទ្យាមួយចំនួននៅក្នុងការបង្រៀនប្រចាំថ្ងៃសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ និងមុខវិជ្ជាទាំងអស់	• គ្រូ ២៥% (វិទ្យាល័យ និងអនុវិទ្យាល័យ) ប្រើប្រាស់បច្ចេកវិទ្យាមួយចំនួន ក្នុងការបង្រៀនប្រចាំថ្ងៃរបស់ពួកគេនៅគ្រប់កម្រិត និងក្នុងគ្រប់មុខវិជ្ជា	• គ្រូ ៥០% (វិទ្យាល័យ និងអនុវិទ្យាល័យ) ប្រើប្រាស់ បច្ចេកវិទ្យាមួយចំនួន ក្នុងការបង្រៀនប្រចាំថ្ងៃរបស់ពួកគេនៅគ្រប់កម្រិត និងក្នុងគ្រប់មុខវិជ្ជា	• គ្រូ ៧៥% (វិទ្យាល័យ និងអនុវិទ្យាល័យ) ប្រើប្រាស់បច្ចេកវិទ្យាមួយចំនួន ក្នុងការបង្រៀនប្រចាំថ្ងៃរបស់ពួកគេនៅគ្រប់កម្រិត និងក្នុងគ្រប់មុខវិជ្ជា	• គ្រូ ១០០% (វិទ្យាល័យ និងអនុវិទ្យាល័យ) ប្រើប្រាស់បច្ចេកវិទ្យាមួយចំនួន ក្នុងការបង្រៀនប្រចាំថ្ងៃរបស់ពួកគេនៅគ្រប់កម្រិត និងក្នុងគ្រប់មុខវិជ្ជា
៤.២	ប្រព័ន្ធ ICT ទូលំទូលាយសម្រាប់បម្រើដល់ការរៀនសូត្ររបស់សិស្សតាមប្រព័ន្ធអនឡាញ ត្រូវបានដាក់ឱ្យអនុវត្ត និងងាយស្រួលចូលប្រើប្រាស់ដោយគ្រូ និងសិស្សមធ្យមសិក្សាទាំងអស់	• ចំនួនសាលាមធ្យមសិក្សាដែលមានកម្មវិធី និងសមត្ថភាពអនុវត្តសកម្មភាពសិក្សាចម្រុះ	• នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន មានដំណើរការ, គោលនយោបាយស្តីពីបច្ចេកវិទ្យាព័ត៌មាន ត្រូវបានដាក់ឱ្យអនុវត្ត • មជ្ឈមណ្ឌលអប់រំឌីជីថល និងអប់រំពីចម្ងាយ ត្រូវបានបង្កើត	• សកម្មភាពសិក្សាដោយប្រើប្រាស់គោលវិធីចម្រុះ ត្រូវបានរៀបចំឡើងក្នុងវិទ្យាល័យ និងអនុវិទ្យាល័យ ២០% រាប់បញ្ចូលទាំងសាលារៀនជំនាន់ថ្មីផងដែរ	• សកម្មភាពសិក្សាដោយប្រើប្រាស់គោលវិធីចម្រុះ ត្រូវបានរៀបចំឡើងក្នុងវិទ្យាល័យ និងអនុវិទ្យា ល័យ ៥០% រាប់បញ្ចូលទាំងសាលារៀនជំនាន់ថ្មីផងដែរ	• សកម្មភាពសិក្សាដោយប្រើប្រាស់គោលវិធីចម្រុះ ត្រូវបានរៀបចំឡើងក្នុងវិទ្យាល័យ និងអនុវិទ្យា ល័យទាំងអស់ រាប់បញ្ចូលទាំងសាលារៀនជំនាន់ថ្មីផងដែរ
